# សកម្មភាពការងាររដ្ឋាធរទន្លេសាប

**ទស្សនាវដ្តី លេខ ១៧** | **ប្រចាំឆ្នាំ២០២៣**








រៀបចំដោយ៖ អាជ្ញាធរទន្លេសាប

# មាតិកា

ទំព័រ

**លិខិតថ្វាយព្រះពរ**.....07

**អារម្ភកថា**.....09

I

**សកម្មភាពសំខាន់ៗថ្នាក់ដឹកនាំ**.....11

II

**សកម្មភាពការសិក្សាស្រាវជ្រាវ**.....23

ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានវិទ្យា.....25

សិក្សាស្រាវជ្រាវស្តីពីសក្តានុពលទេសចរណ៍ និងខ្សែសង្វាក់សេវាកម្មទេសចរណ៍ធម្មជាតិនៅតំបន់ទន្លេសាប.....25

សិក្សាស្រាវជ្រាវស្តីពី កាកសំណល់ឧបករណ៍នេសាទនៅតំបន់ទន្លេសាប.....25

សិក្សា និងវាយតម្លៃការប្រើប្រាស់ជីគីមី និងថ្នាំគីមីនៅក្នុងតំបន់ ២ ដែលបាននិងកំពុងប៉ះពាល់ប្រព័ន្ធអេកូឡូស៊ីបឹង-ទន្លេសាប.....26

សិក្សាស្រាវជ្រាវពីផលប៉ះពាល់ និងការប្រើប្រាស់ធនធានរ៉ែខ្សាច់នៅតាមអាងស្តឹងពោធិសាត់ និង . ស្ទឹងសែន.....28

សិក្សាស្រាវជ្រាវ ពីបច្ចុប្បន្នភាពធនធានជលផល (ត្រី និងក្រៅពីត្រី)តាមការប្រែប្រួលរបបជលសាស្ត្រ និងវាយតម្លៃ-គុណភាពទឹក បឹងទន្លេសាប.....29

បច្ចុប្បន្នភាពប្រព័ន្ធធារាសាស្ត្រ និងតាមដានបម្រែបម្រួលគុណភាពទឹក លក្ខណៈរូប-គីមី (physic-chemical- parameters) ក្នុងតំបន់បឹងទន្លេសាប.....30

សិក្សាជីវចម្រុះ និងបរិមាណប្លង់តុង (Plankton) ក្នុងតំបន់នៃបឹងទន្លេសាបដែលមានទំនាក់ទំនងទៅនឹងការលូតលាស់-របស់ប្រភេទត្រីស.....33

សិក្សាស្រាវជ្រាវតាមដានការវិវត្តន៍គុណភាពដី លើដំណាំស្រូវនៅតំបន់ប្រព័ន្ធធារាសាស្ត្រអង្គគោក្នុងភ្លៀងអាងស្ទឹងសែន.....34

សិក្សាស្រាវជ្រាវ និងវាយតម្លៃដែនព្រៃលិចទឹកតំបន់ ៣ នៅជុំវិញបឹងទន្លេសាប.....36

ការគ្រប់គ្រង ការធ្វើអាជីវកម្ម និងវារីវប្បកម្មលើធនធានជលផល.....43

សិក្សាស្រាវជ្រាវវាយតម្លៃផលចាប់នៃធនធានត្រីខេត្តកំពង់ឆ្នាំង.....43

សិក្សាតាមដានលើបទល្មើសនេសាទ និងធ្វើបច្ចុប្បន្នភាពបញ្ជីសារពើរភ័ណ្ឌឧបករណ៍នេសាទនៅខេត្តទាំង ០៦ ជុំវិញបឹង-ទន្លេសាប ........................................................................................46
សិក្សាកែច្នៃធនធានជលផល និងចរន្តអាជីវកម្មនៅខេត្តជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ .......47
សិក្សាវាយតម្លៃធនធានជលផលលើអាជីវកម្មធនធានធម្មជាតិ វារីវប្បកម្ម និងចរន្តទីផ្សារតាមច្រកចេញចូលត្រីនៅខេត្ត-ទាំង ៦ ជុំវិញបឹងទន្លេសាប ......................................................................49
សិក្សាពីបម្រែបម្រួលបរិស្ថាន និងធនធានជលផលក្នុងតំបន់រ៉ាមសារស្ទឹងសែនខេត្តកំពង់ធំ ........... 50
សិក្សាពីសក្តានុពលនិងការគ្រប់គ្រងតំបន់តំបន់អភិរក្សជលផល(អតីតឡូត៍លេខ៤)ខេត្តសៀមរាប . 51
សកម្មភាពការងារពិសោធន៍........................................................................................54
ផែនការយុទ្ធសាស្ត្រ គោលនយោបាយ និងសេដ្ឋកិច្ចសង្គម ...............................................55
សិក្សាវាយតម្លៃ និងផលចំណេញសេដ្ឋកិច្ចក្នុងផលិតកម្មស្រូវចំការនៅវាលទំនាបបឹងទន្លេសាប .... ខេត្តកំពង់ធំ............................................................................................................55
សិក្សាប្រជាសាស្ត្រនិងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាសហគមន៍នេសាទ នៅជុំវិញបឹងទន្លេសាប ជំហាន ១- ............................................................................................................57
បច្ចុប្បន្នភាពគម្រោងថ្នាក់ក្រោមជាតិនៅតំបន់ទន្លេសាប ......................................................58
រៀបចំគម្រោងវិនិយោគសាធារណៈ PIP សម្រាប់ (Public Investment Program) ...................61
សម្របសម្រួលនិងសហការជាមួយក្រសួងស្ថាប័នជំនាញ ខេត្តជុំវិញបឹងទន្លេសាប ដើម្បីប្រមូលចងក្រងបទដ្ឋានគតិយុត្ត/ច្បាប់នានាពាក់ព័ន្ធ និងការងារ គ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍បរិស្ថានធនធាន .. ធម្មជាតិ និងគោល នយោបាយ-បទបញ្ញត្តិពាក់ព័ន្ធការគ្រប់គ្រងធនធានទឹក ..............................66
ពង្រឹងបណ្តាញទំនាក់ទំនងការងារជាមួយស្ថាប័ននិងសហគមន៍មូលដ្ឋានក្នុងការ តាមដានផលប៉ះពាល់ទៅលើធនធាន-ធម្មជាតិ និង បរិស្ថានក្នុងតំបន់ជុំវិញបឹងទន្លេសាប..........................................69
ពិគ្រោះយោបល់ប្រាស្រ័យទាក់ទង និងចែករំលែកការយល់ដឹងជាមួយ Environmental Think Tanks និងសម្រប-សម្រួលទំនាក់ទំនងបណ្តាញការងារ Think Tanks និរន្តរភាពសហគមន៍ជុំវិញបឹងទន្លេសាប ជាមួយនិងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព...........................................................72
សម្របសម្រួល និងសហការជាមួយស្ថាប័នជំនាញផ្សព្វផ្សាយបង្កើនការយល់ ដឹងពីបទបញ្ញត្តិ....... ការគ្រប់គ្រង អភិរក្ស-ធនធានធម្មជាតិដល់ សហគមន៍មូលដ្ឋាន ..........................................74
ពង្រឹងទំនាក់ទំនងបណ្តាញការងារទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ និងម្ចាស់ជំនួយ ....................75
សិក្សាពីប្រសិទ្ធភាពលើការអនុវត្ត និងយន្តការគន្លឹះក្នុងការកសាងផែនការ គ្រប់គ្រងសហគមន៍..... ប្រកបដោយ និរន្តរភាព- នៅតំបន់បឹងទន្លេសាបជំហាន ២ ឆ្នាំ ២០២៣.....................................76
ពង្រឹង និងពង្រីកការកសាងសមត្ថភាពជូនមន្ត្រីក្រោមឱវាទអាជ្ញាធរទន្លេសាប.............................77
លើកកម្ពស់ប្រសិទ្ធភាពយេនឌ័រ ក្នុងការគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិ ស្ថិតនៅក្នុងខេត្តជុំវិញបឹងទន្លេសាប.......................................................................................................77

# III


សកម្មភាពការងារកិច្ចសហប្រតិបត្តិការ....................79

ការអនុវត្តគម្រោងសហប្រតិបត្តិការដៃគូរអភិវឌ្ឍន៍....................81

គម្រោងការគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន (Stung Sen IWRM)....................81

គម្រោងសិក្សាគំរូបច្ចេកវិទ្យា សង្កេត និងបញ្ជូនទិន្នន័យជលសាស្រ្តសម្រាប់អាងទន្លេសាប....................86

សកម្មភាពកិច្ចប្រជុំ និងសិក្ខាសាលា....................93

ការផ្សព្វផ្សាយ....................106

សកម្មភាពរៀបចំ និងបច្ចុប្បន្នភាពប្រព័ន្ធអេឡិចត្រូនិច (server) អាជ្ញាធរទន្លេសាប....................106

សកម្មភាពផលិតវីដេអូផ្សព្វផ្សាយពីសក្ដានុពល ផលប៉ះពាល់បឹងទន្លេសាប....................107

# លិខិតថ្វាយព្រះពរ និងជូនពរ

## ទូលបង្គំយើងខ្ញុំជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រោមឱវាទ នៃអាជ្ញាធរទន្លេសាប

ក្រាបបង្គំទូលថ្វាយ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ទូលបង្គំជាខ្ញុំ តាងនាមថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃអាជ្ញាធរទន្លេសាប សូមបរមរាជានុញ្ញាតលំឱនកាយវាចាចិត្ត សូមក្រាបបង្គំទូលថ្វាយនូវមនោសញ្ចេតនាប្រកបដោយកត្តញ្ញូ កត្តវេទីតាធម៌យ៉ាងស្មោះស្ម័គ្របំផុត និងសូមបរមរាជានុញ្ញាតថ្វាយនូវព្រះរាជសព្ទសាធុការពរជ័យ បវរសួស្តី សិរីវឌ្ឍនា វិបុលសុខ មហាប្រសើរគ្រប់ប្រការ ។

ឆ្លៀតក្នុងឱកាសដ៏មហាមង្គលាភិរម្យថ្ងៃថ្លានេះ ទូលបង្គំយើងខ្ញុំទាំងអស់គ្នា សូមបរមរាជានុញ្ញាតសូមលើកហត្ថប្រណម្យបួងសួងដល់គុណបុណ្យព្រះរតនៈត្រ័យកែវទាំងបី ឫទ្ធិបារមី ខ្លាំងក្លា ទេវតាថែរក្សាទឹកដី នៃព្រះរាជាណាចក្រកម្ពុជា វត្ថុស័ក្តិសិទ្ធិទាំងឡាយក្នុងលោក ទេវតា ថែរក្សាព្រះមហាស្វេតច្ឆត្រ បុណ្យបារមីនៃដួងព្រះវិញ្ញាណក្ខន្ធអតីតព្រះមហាក្សត្រ ព្រះមហាក្សត្រីយានីខ្មែរគ្រប់ព្រះអង្គ ពិសេសបុណ្យបារមីព្រះករុណាព្រះមហាវីរៈក្សត្រ ព្រះវររាជបិតា ព្រះបរមរតនកោដ្ឋ និងទេវតាថែរក្សាឆ្នាំថ្មី ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ព្រះនាម កិមិរាទេវី សូមព្រះអង្គយាងតាមជួយថែរក្សាអភិបាល ប្រោះព្រំនូវសព្ទសាធុការពរជ័យគ្រប់ប្រការ និងសូមព្រះករុណាជាអង្គម្ចាស់ជីវិតតម្កល់លើត្បូង ព្រះអង្គទ្រង់ប្រកបដោយព្រះរាជសុខភាពបរិបូណ៌ ព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ដើម្បីគង់ប្រថាប់ក្នុងព្រះសិរីរាជសម្បត្តិ ជាម្លប់ត្រជាក់ត្រជុំដល់ប្រជានុរាស្ត្រខ្មែរជុកកោនទូទាំងព្រះរាជាណាចក្រកម្ពុជា និងសូមព្រះអង្គទ្រង់ប្រកបនូវព្រះពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ ជាតិយោ្យភាពតរៀងទៅ ។

## សូមថ្វាយព្រះពរ និងជូនពរ

សម្តេច ព្រះអង្គម្ចាស់ ម្ចាស់ក្សត្រិយ៍ ឯកឧត្តម ឧកញ៉ា លោកជំទាវ លោក លោកស្រី ក្នុងឱកាស ឆ្នាំថ្មី ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ គ.ស ២០២៣ សូមមានសុខភាពល្អបរិបូណ៌ កម្លាំងខ្លាំងក្លាប្រាជ្ញាវាងវៃ និងសូមជួបតែវិបុលសុខ សុភមង្គល និងទទួលបានជោគជ័យគ្រប់ភារកិច្ច ។

**ឯកឧត្តម ថោ ជេដ្ឋា**
រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម
និងជា ប្រធានអាជ្ញាធរទន្លេសាប ព្រមទាំងមន្ត្រីរាជការក្រោមឱវាទទាំងអស់

# អារម្ភកថា

បឹងទន្លេសាប ជាបឹងទឹកសាបដែលធំជាងគេបំផុតក្នុងភូមិភាគអាស៊ីអាគ្នេយ៍ និងជាបេះដូងនៃព្រះរាជាណាចក្រកម្ពុជា ដែលមានតម្លៃមិនអាចកាត់ថ្លៃបាន ។ ទន្លេសាប និងបឹងទន្លេសាប ជាប្រព័ន្ធផ្លូវទឹកទំនាក់ទំនងយ៉ាងសំខាន់បំផុត ហើយដែលទទួលរងនូវឥទ្ធិពលរបបទឹកពីទន្លេមេគង្គ ។ បឹងទន្លេសាបស្រូបទឹកពីទន្លេមេគង្គនៅរដូវវស្សា និងបញ្ចេញទឹកទៅទន្លេមេគង្គវិញនៅរដូវប្រាំង បង្កើតបានជាបាតុភូតជលសាស្ត្រធម្មជាតិមួយកម្រមាននៅលើពិភពលោក និងបាននាំមកនូវដីល្បាប់ដ៏មានជីជាតិទៅចាក់បំពេញវាលទំនាបលិចទឹក នៃតំបន់ព្រៃលិចទឹកដ៏ធំល្វឹងល្វើយ ដែលជាជម្រក និងបង្កបានជាចំណីសម្រាប់ជីវចម្រុះយ៉ាងសម្បូរបែបដូចជា ពពួកមច្ឆជាតិ បក្សី ល្មូន ថនិកសត្វ និងរុក្ខជាតិគ្រប់ប្រភេទ ។ ក្រៅពីតួនាទីជាបឹងទទួលយកទឹក និងជួយកាត់បន្ថយគ្រោះទឹកជំនន់ពីទន្លេមេគង្គ វាក៏ជាប្រភពសន្តិសុខស្បៀងសម្រាប់ជួយទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា និងជួយទ្រទ្រង់ដល់វិស័យសេដ្ឋកិច្ចសង្គម វប្បធម៌ បរិស្ថាន ប្រទេសជាតិទាំងមូល ។

បច្ចុប្បន្ន វិសាលភាពដ៏ធំធេងនៃការប្រកួតប្រជែងការអភិវឌ្ឍ និងសន្ទុះកំណើនប្រជាពលរដ្ឋបានធ្វើឲ្យមានហានិភ័យដល់បឹងទន្លេសាប បាននិងកំពុងទទួលរងនូវការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរទៅដល់សុខុមាលភាពបឹង បរិស្ថាន ជីវចម្រុះ និងធនធានធម្មជាតិនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ដូចជាការកើនឡើងបម្រែបម្រួលអាកាសធាតុ ការសាងសង់ទំនប់វារីអគ្គិសនីផ្នែកខាងលើ ការប្រើប្រាស់បច្ចេកវិទ្យាខុសបទដ្ឋានបច្ចេកទេស និងការកាប់បំផ្លាញរុករានទន្ទ្រានយកដីព្រៃលិចទឹក ការធ្វើអាជីវកម្មហួសកម្រិតលើធនធានធម្មជាតិ រួមមានព្រៃលិចទឹក និងធនធានជលផល ជាដើម ។

ដោយមើលឃើញពីសារៈសំខាន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដែលមាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** ជានាយករដ្ឋមន្ត្រី បានសម្រេចបង្កើតស្ថាប័ន **អាជ្ញាធរទន្លេសាប** តាមព្រះរាជក្រឹត្យលេខ នស/រកត/០៦០៩/៧០៥ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ ២០០៩ ជាសេនាធិការផ្ទាល់ជួយដល់រាជរដ្ឋាភិបាល ដើម្បីសម្របសម្រួលក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍តំបន់ទន្លេសាបប្រកបដោយនិរន្តរភាព សម្រាប់រក្សាទុកជាកេរមរតកដ៏ប្រពៃរបស់មនុស្សជាតិបានយូរអង្វែង ។

ដើម្បីបន្តពង្រឹងតួនាទី ភារកិច្ចស្នូល និងក្នុងស្មារតីទទួលខុសត្រូវរបស់**អាជ្ញាធរទន្លេសាប** ក្នុងការលើកកម្ពស់ការអនុវត្តគោលនយោបាយ ផែនការយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលពីកិច្ចការការពារធនធានធម្មជាតិ និងការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ អាជ្ញាធរទន្លេសាប បានអនុវត្តន៍ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពការងារសិក្សាស្រាវជ្រាវ ប្រមូលចងក្រងរាល់ទិន្នន័យ ព័ត៌មានពាក់ព័ន្ធទៅនឹងសក្តានុពលសេដ្ឋកិច្ច សង្គម បរិស្ថាន ការធ្វើអធិការកិច្ចតាមដាន និង វាយតម្លៃពីភាពអនាធិបតេយ្យ និងបទល្មើស ធនធានធម្មជាតិនៅតំបន់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ ហើយសម្រេចបាននូវសមិទ្ធផលធំៗជាប្រវត្តិសាស្ត្រមួយចំនួនជូនរាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជា ប្រធានអាជ្ញាធរទន្លេសាប ។

ទស្សនាវដ្តីលេខ ១៦ ស្តីពី សកម្មភាពការងាររបស់អាជ្ញាធរទន្លេសាប បង្ហាញពីលទ្ធផលការអនុវត្តសកម្មភាពការងាររបស់ថ្នាក់ដឹកនាំ និងមន្ត្រីក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ស្របតាមផែនការសកម្មភាពការងារ ឆ្នាំ ២០២២ នៃផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប (២០២១-២០២៥) ក្រោមការដឹកនាំ និងទទួលខុសត្រូវផ្ទាល់របស់ឯកឧត្តម **ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជា ប្រធានអាជ្ញាធរទន្លេសាប ។ ទស្សនាវដ្តីនេះ នឹងផ្តល់ការយល់ដឹងដល់អ្នកអាន អ្នកសិក្សាស្រាវជ្រាវ បានស្វែងយល់ពីសកម្មភាពការងារអាជ្ញាធរទន្លេសាប អត្ថប្រយោជន៍បឹងទន្លេសាបជាពិសេស ដើម្បីចូលរួមចំណែកក្នុងការជួយលើកកម្ពស់ការគ្រប់គ្រង អភិរក្ស និងការអភិវឌ្ឍធនធានធម្មជាតិនៅតំបន់ជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធប្រកបដោយចីរភាព ៕

# I

# សកម្មភាពសំខាន់ៗថ្នាក់ដឹកនាំ



**ឯកឧត្តម ថោ ជេដ្ឋា រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជា ប្រធានអាជ្ញាធរទន្លេសាប**
អញ្ជើញជាអធិបតីភាព ដឹកនាំកិច្ចប្រជុំពិភាក្សាពីវឌ្ឍនភាពការងារអាជ្ញាធរទន្លេសាប ឆ្នាំ ២០២៣







ពិធីសំណេះសំណាល **ឯកឧត្តមកិត្តិបណ្ឌិត លឹម គានហោ និង ឯកឧត្តម ថោ ជេដ្ឋា** ជាមួយថ្នាក់ដឹកនាំក្រសួងធនធានទឹក និងឧតុនិយម គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងអាជ្ញាធរទន្លេសាប






**ឯកឧត្តម ថោ ជេដ្ឋា រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជា ប្រធានអាជ្ញាធរទន្លេសាប**
អញ្ជើញជាអធិបតីភាព សំណេះសំណាលជាមួយមន្ត្រីរាជការ



**ឯកឧត្តម ថោ ជេដ្ឋា** រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប ចុះស្វែងយល់ការប្រមូលផលត្រីនៅដាយត្រីស្រុកពញាឮ ខេត្តកណ្ដាល

















**ឯកឧត្តម ប៊ុន ហ៊ាន រដ្ឋលេខាធិការ ក្រសួងធនធានទឹក និងឧតុនិយម** អញ្ជើញជាអធិបតីភាពដឹកនាំកិច្ចប្រជុំពិនិត្យលើវឌ្ឍនភាពអនុវត្តគម្រោងសហប្រតិបត្តិការ ចំនួន ៣ កំពុងអនុវត្តដោយអាជ្ញាធរទន្លេសាប







**ឯកឧត្តម ហ៊ើល តូនី** អនុប្រធានក្ដាប់រួម អញ្ជើញដឹកនាំកិច្ចប្រជុំពិនិត្យពិភាក្សាលើសេចក្ដីព្រាងផែនការយុទ្ធសាស្ត្រសម្រាប់អាជ្ញាធរទន្លេសាប ២០២៤-២០២៨ និងដំណើរការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ២០២៤ របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប





**ឯកឧត្តម ម៉ៅ ហាក់** អនុប្រធាន អញ្ជើញដឹកនាំកិច្ចប្រជុំត្រួតពិនិត្យ តាមដានលទ្ធផលនៃការអនុវត្តផែនការសកម្មភាពការងារឆមាសទី ១ និងលើកទិសដៅការងារឆមាសទី ២ ឆ្នាំ ២០២៣







**ឯកឧត្តម លឹម ពុយ** ជួបពិភាក្សាការងារជាមួយអ្នកជំនាញខាងសិក្សាស្រាវជ្រាវលើប្លង់តុងទឹកសាបនៃប្រទេសបារាំង







**ឯកឧត្ដម ហ៊ែល តូនី**
អនុប្រធានក្លាប់រួម ដឹកនាំកិច្ចប្រជុំពិភាក្សាក្រុមការងារចុះពិនិត្យតាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹក នៅតាមបណ្ដាខេត្តជុំវិញបឹងទន្លេសាប









**ឯកឧត្តម ហៀល តូនី** អនុប្រធានក្តាប់រួម **និងឯកឧត្តម សាន់ យូ** អភិបាលរងនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង បានអញ្ជើញដឹកនាំកិច្ចប្រជុំក្រុមការងារពិនិត្យតាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹក ខេត្តកំពង់ឆ្នាំង







**ឯកឧត្តម ហ៊ែល តូនី** អនុប្រធានក្ដាប់រួម **និងឯកឧត្តម ទូច សុខា** អភិបាលរង នៃគណៈអភិបាលខេត្តកំពង់ធំ បានអញ្ជើញដឹកនាំកិច្ចប្រជុំក្រុមការងារពិនិត្យតាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹក ខេត្តកំពង់ធំ











**ឯកឧត្តម ហ៊ែល តូនី** អនុប្រធានក្ដាប់រួម អញ្ជើញដឹកនាំកិច្ចប្រជុំក្រុមករងារតាមដានត្រួតពិនិត្យ និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹកការកាត់ឆ្មៀលតំបន់២ តំបន់៣ នៅសង្កាត់ស្រយ៉ូវ  ក្រុងស្ទឹងសែន ខេត្តកំពង់ធំ



**ឯកឧត្តម ហ៊ែល តូនី** អនុប្រធានក្ដាប់រួម អាជ្ញាធរទន្លេសាប **និងឯកឧត្តម ឡាយ ទិសិដ្ឋ** អភិបាលរង នៃគណៈអភិបាល ខេត្តពោធិ៍សាត់ បានអញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំក្រុម ការងារពិនិត្យតាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹក ខេត្តពោធិ៍សាត់











**ឯកឧត្តម ហ៊ែល តូនី** អនុប្រធានក្ដាប់រួម អញ្ជើញដឹកនាំកិច្ចប្រជុំក្រុមករងារតាមដានត្រួតពិនិត្យ និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹកការកាត់ឆ្វៀលតំបន់២ តំបន់៣  នៅឃុំស្នាអន្សា ស្រុកក្រគរ ខេត្តពោធិ៍សាត់ )



**ឯកឧត្តម ហ៊ើល តូនី** អនុប្រធានក្តាប់រួម អញ្ជើញដឹកនាំក្រុមការងារមន្ត្រីបច្ចេកទេសចុះធ្វើ អធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹក នៅតំបន់ស្រុកក្រគរ និងស្រុកកណ្តៀង ខេត្តពោធិ៍សាត់







**ឯកឧត្តម ហ៊ើល តូនី** អនុប្រធានក្តាប់រួម អញ្ជើញដឹកនាំក្រុមការងារមន្ត្រីបច្ចេកទេសចុះធ្វើ អធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹក ស្រុកកំពង់លែង ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ





# II

# សកម្មភាពការសិក្សាស្រាវជ្រាវ

# សិក្សាស្រាវជ្រាវស្តីពីសក្តានុពលទេសចរណ៍ និងខ្សែសង្វាក់សេវាកម្មទេសចរណ៍ធម្មជាតិនៅតំបន់ទន្លេសាប



នៅថ្ងៃសុក្រ ១៥កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារបច្ចេកទេស នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប បានបន្តចុះសិក្សាស្រាវជ្រាវលើ ខ្សែសង្វាក់សេវាកម្មទេសចរណ៍នៅក្នុងភូមិបណ្តែតទឹកកំពង់លួង ឃុំកំពង់លួង ស្រុកក្រគរ ខេត្តពោធិ៍សាត់ ។

ការចុះសិក្សានេះ ក្រុមការងារស្រាវជ្រាវបានធ្វើការលើ៖

១-ជួបជាមួយនឹងតំណាងអ្នកសម្របសម្រួលទេសចរណ៍នៅក្នុងឃុំកំពង់លួង ពិភាក្សា និងស្វែងយល់ពីស្ថានភាពទូទៅនៃទេសចរណ៍ដែលមាននៅក្នុងឃុំកំពង់លួង រួមបញ្ចូលទាំង ចំនួនភ្ញៀវទេសចរណ៍មកទស្សនា។

២- ការរៀបចំបែងចែកវេនសម្រាប់ប្រជាជនដែលបើកទូកដឹកភ្ញៀវទេសចរណ៍ ចំនួនប្រជាពលរដ្ឋដែលបម្រើសេវាកម្មទេសចរណ៍ (ចំនួនអ្នកបើកទូក/កាណូត ចំនួនផ្ទះស្នាក់) ដែលមានសរុបនៅក្នុងឃុំកំពង់លួង។

៣- ជួបជាមួយអាជ្ញាធរដែនដី ថ្នាក់ឃុំ អំពីផែនការដែលឃុំចូលរួមក្នុងការជួយដល់ផ្នែកទេសចរណ៍ក្នុងឃុំ និងដៃគូសហការនានាពាក់ព័ន្ធនឹងវិស័យទេសចរណ៍ដែលជួយដល់ឃុំកំពង់លួង។

៤- ជួបជាមួយនឹងប្រជាជនដែលបម្រើសេវាកម្មទេសចរណ៍ (បើកទូកកាណូត)។

ជាមួយនឹងសកម្មភាពក្រុមការងារចុះសិក្សានៅតំបន់ពាក់ព័ន្ធខាងលេ ីនេះជាលទ្ធផលមានដូចជា៖

១. ចំនួនទូក/កាណូតដែលបម្រើដល់ភ្ញៀវទេសចរណ៍មានចំនួនសរុប ១៩ទូក ដែលទំហំ មធ្យមផ្ទុកមនុស្ស (១-៣០) ដែលតម្លៃអាស្រ័យទៅតាមទំហំទូក/កាណូត។

២. ចំនួនប្រជាពលរដ្ឋដែលបម្រើសេវាកម្មផ្នែកបើកទូកកាណូតដឹកភ្ញៀវទេសចរណ៍បច្ចុប្បន្នមានចំនួន ១៩នាក់ ដែលក្នុងនោះមានស្ត្រីបានចូលរួមចំណែកក្នុងវិស័យនេះផងដែរ ។

៣. ចំនួនផ្ទះស្នាក់ដែលមាននៅក្នុងឃុំកំពង់លួងមានចំនួន០២ ប៉ុន្តែ ត្រូវបានផ្អាកដំណើរការកាលពីឆ្នាំ២០២០ រហូតដល់បច្ចុប្បន្ន។

៤. ភ្ញៀវទស្សនានៅក្នុងតំបន់កំពង់លួង មានភ្ញៀវជាតិ ( ទស្សនានៅក្នុងរដូវបុណ្យទាននានា ភ្ជុំ ចូលឆ្នាំ ) ភ្ញៀវអន្តរជាតិ ( ទស្សនានៅក្នុងចន្លោះខែ០៩ ដល់ខែ០១ ) បច្ចុប្បន្នចំនួនភ្ញៀវអន្តរជាតិមានចំនួនតិចតួចប៉ុណ្ណោះមកទស្សនាក្នុងឃុំកំពង់លួង។ ភ្ញៀវបរទេសភាគច្រេ ីនមកទស្សនាក្នុងឃុំកំពង់លួង គឺក្រោយទស្សនានៅក្នុងខេត្តបាត់ដំបង បន្តមកទស្សនាក្នុងតំបន់កំពង់លួង។

សូមជម្រាបជូនថា៖ សកម្មភាពនេះមានគោលបំណង សិក្សាពីខ្សែសង្វាក់សេវាកម្មទេសចរណ៍នៅក្នុងតំបន់ទេសចរណ៍គោលដៅ និងសិក្សាពីផលប៉ះពាល់ដល់ប្រជាពលរដ្ឋដែលបម្រើសេវាកម្មទេសចរណ៍ក្រោយពេលដែល មានបញ្ហាការរីករាលដាលនៃជំងឺកូវីដ-១៩។





ថ្ងៃចន្ទ ១១រោច ដល់ថ្ងៃព្រហស្បតិ៍ ១៤រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី ១៥ ដល់ ថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ២០២៣ មន្ត្រីនៃក្រុមការងារបច្ចេកទេស អាជ្ញាធរ ទន្លេសាប បានចុះធ្វើការសិក្សា ស្រាវជ្រាវ ស្ដីអំពី ខ្សែសង្វាក់សេវាកម្មទេសចរណ៍ និងសក្ដានុពលទេសចរណ៍ធម្មជាតិបឹងទន្លេសាប ស្ថិតក្នុងភូមិសាស្ត្រភូមិបណ្ដែតទឹក ព្រែកទាល់ ឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។ ស្ថានភាពទេសចរណ៍ នៅក្នុងឃុំកោះជីវាំង ក្រោយពីផ្អាកដំណើរការជាបណ្ដោះ អាសន្នមួយរយៈ នៅក្នុង អំឡុងពេលមានវិបត្តិនៃការរីករាលដាលជំងឺកូវីដ១៩ កន្លងមក ហើយបច្ចុប្បន្ននេះ ប្រជាពលរដ្ឋដែលរស់នៅតំបន់ទាំងនោះបានចាប់ផ្ដើមមានសកម្មភាពក្នុងការផ្ដល់សេវាកម្មទេសចរណ៍ មួយចំនួនឡើងវិញជាបន្តបន្ទាប់ ដូចជា អាហារដ្ឋាន ផ្ទះស្នាក់ ទូកអុំ សម្រាប់ជិះកំសាន្តជូនភ្ញៀវទេសចរទស្សនាភូមិបណ្ដែតទឹក ផែចិញ្ចឹមក្រពើ និងស្ថានភាពជីវភាពរស់នៅរបស់ប្រជាជន លើភូមិបណ្ដែតទឹក ព្រមទាំងសិប្បកម្មកែច្នៃកំប្លោកជាវត្ថុអនុស្សាវរីយ៍ កាបូប និងសម្ភារៈប្រើប្រាស់ផ្សេងទៀតសម្រាប់លក់ជូនភ្ញៀវទេសចរ និងនាំចេញទៅក្រៅប្រទេស ផងដែរ ។ ជាងនេះទៀត គឺសក្ដានុពលដែលមានភាពទាក់ទាញភ្ញៀវគឺ បន្ទាយសត្វស្លាប។



## សិក្សាស្រាវជ្រាវស្ដីពី កាកសំណល់ឧបករណ៍នេសាទនៅតំបន់ទន្លេសាប



សៀមរាប៖ ថ្ងៃចន្ទ ៤រោច ដល់ថ្ងៃសុក្រ ៨រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស. ឆ្នាំ២៥៦៧ ត្រូវនឹង ថ្ងៃទី០៤-០៨ ខែកញ្ញា ឆ្នាំ២០២៣ មន្ត្រីនៃក្រុមការងារអាជ្ញាធរទន្លេសាប បានបន្តចុះសិក្សាស្រាវជ្រាវ ស្ដីពី ប្រភេទនៃកាកសំណល់ឧបករណ៍នេសាទ ដែលមានទីតាំងស្ថិតនៅភូមិបណ្ដែតទឹកមេជ្រៃ ឃុំកែវពណ៌ ស្រុកពួក ខេត្តសៀមរាប។ ការសិក្សាបានផ្ដោតសំខាន់ទៅលើប្រភេទនៃឧបករណ៍នេសាទនីមួយៗដែលបានប្រើប្រាស់ជាលក្ខណៈគ្រួសារ ការប្រើប្រាស់តាមរដូវកាល សិក្សាអំពីអាយុកាលនៃការប្រើប្រាស់ និងការបោះបង់ចោល។ ក្រុមការងារក៏បានសិក្សាផងដែរអំពីចរន្តទីផ្សារការនាំចូលនៃឧបករណ៍នេសាទ។ ប្រភេទកាកសំណល់ឧបករណ៍នេសាទដែលប្រើប្រាស់រួមមាន មង សន្ទូច សៃយ៉ឺន លប លាន់ និងអ៊ួនជាដើម...។

ប្រជាជនដែលរស់នៅលើភូមិបណ្ដែតទឹកមេជ្រៃស្ទើរតែ100ភាគរយ បានចោលកាកសំណល់ទាំងនោះទៅក្នុងទឹកទន្លេដោយផ្ទាល់តែម្ដង ដោយសារពុំមានទីតាំងស្តុកទុកត្រឹមត្រូវ និងសេវាកម្មប្រមូលសម្រាម។ល។





ថ្ងៃអង្គារ ៩កើត ដល់ថ្ងៃសុក្រ ១២កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស . ឆ្នាំ២៥៦៦ត្រូវនឹងត្រូវថ្ងៃទី ២៨ ខែកុម្ភៈ ដល់ថ្ងៃទី ០៣ខែមីនា ឆ្នាំ២០២៣ មន្ត្រីបច្ចេកទេសនៃក្រុមការងាររបស់អាជ្ញាធរទន្លេសាប បានចុះសិក្សាស្រាវជ្រាវស្ដីពី ប្រភេទនៃកាកសំណល់ឧបករណ៍នេសាទ ដែលមានទីតាំងស្ថិតនៅភូមិបណ្ដែតទឹកព្រែកទាល់ ឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។ ការសិក្សាស្រាវជ្រាវបានផ្ដោតសំខាន់ទៅលើប្រភេទនៃឧបករណ៍នេសាទនីមួយៗដែលបានប្រើប្រាស់ជាលក្ខណៈគ្រួសារ សិក្សាអំពីអាយុកាលនៃការប្រើប្រាស់ប្រភេទឧបករណ៍នេសាទ និងការបោះបង់ចោល ការទុកដាក់កាកសំណល់ រួមទាំងសិក្សាពីចរន្តទីផ្សារ ការនាំចូលនៃឧបករណ៍នេសាទផងដែរ។ អាយុកាលនៃការប្រើប្រាស់ប្រភេទឧបករណ៍នេសាទតាមរដូវកាល និងប្រភេទឧបករណ៍ដែលមានអាយុកាលប្រើប្រាស់បានយូរឆ្នាំលើសពី5ឆ្នាំជាដើម។ ប្រជាជនដែលរស់នៅលើភូមិបណ្ដែតទឹកភាគច្រើនបានចោលកាកសំណល់ទាំងនោះទៅក្នុងទឹក ទន្លេដោយផ្ទាល់តែម្ដង។

## សិក្សានិងវាយតម្លៃការប្រើប្រាស់ជីគីមី និងថ្នាំគីមីនៅក្នុងតំបន់ ២ ដែលបាននិងកំពុងប៉ះពាល់ប្រព័ន្ធអេកូឡូស៊ីបឹង-ទន្លេសាប



ថ្ងៃព្រហស្បតិ៍ ៩រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០២៣ ក្រុមការងារមន្ត្រីបច្ចេកទេសអាជ្ញាធរទន្លេសាប ដឹកនាំដោយឯកឧត្ដម សរ គឹមសាន្ត អគ្គលេខាធិការរងអាជ្ញាធរទន្លេសាប បានបន្តចុះសិក្សាស្រាវជ្រាវពីការប្រើប្រាស់ជីគីមី និងថ្នាំកសិកម្ម ដែលប្រជាកសិករប្រើប្រាស់សម្រាប់ដំណាំស្រូវ ស្ថិតក្នុងភូមិសាស្ត្រ ឃុំសំព្រោជ ស្រុកស្ទោង ខេត្តកំពង់ធំ។ ការសិក្សានេះ គឺដើម្បីចងក្រងប្រភេទជីគីមី និងថ្នាំកសិកម្ម ដែលកំពុងប្រើប្រាស់ក្នុងតំបន់សិក្សា ដើម្បីវាយតម្លៃកម្រិត និងបរិមាណប្រើប្រាស់សារធាតុគីមី របស់ប្រជាកសិករ និងសិក្សាបន្ទុកនៃសារធាតុគីមីដែលចេញពីការធ្វើស្រែចំការ ដែលសល់នៅក្នុងដី ទឹក និងទឹកក្រោមដី។ ក្រុមការងារបានចុះធ្វើការសំភាសន៍ដោយផ្ទាល់ជាមួយប្រជាកសិករ អាជ្ញាធរដែនដី និងអាជីវករប្រកបរបរលក់ជីគីមី និងថ្នាំគីមីនៅក្នុងទីតាំងសិក្សា និងបានប្រមូលសំណាក់ដី និងទឹកមកធ្វើការវិភាគ នៅមន្ទីរពិសោធន៍ផងដែរ។







ថ្ងៃពុធ ១៦ កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០២៣ ក្រុមការងារមន្ត្រីបច្ចេកទេស អាជ្ញាធរទន្លេសាប បានបន្តចុះសិក្សាស្រាវជ្រាវពីការប្រើប្រាស់ជីគីមី និងថ្នាំពុលកសិកម្ម ដែលប្រជាកសិករប្រើប្រាស់សម្រាប់ដំណាំស្រូវ ស្ថិតក្នុងភូមិសាស្ត្រ ឃុំប្រឡាយ ស្រុកស្ទោង ខេត្តកំពង់ធំ។ ការចុះសិក្សានេះក្រុមការងារៈ បានជួបជាមួយអាជ្ញាធរដែនដី អាជីវករលក់ជីគីមី និងថ្នាំពុលកសិកម្ម និងប្រជាកសិករ។



ការសិក្សានេះ គឺដើម្បីចងក្រងប្រភេទជីគីមីនិងថ្នាំពុលកសិកម្មដែលបាននិងកំពុងប្រើប្រាស់ក្នុងតំបន់សិក្សា វាយតម្លៃកម្រិត និងបរិមាណប្រើប្រាស់សារធាតុគីមីរបស់ប្រជាកសិករ និងសិក្សាបន្ទុកបំពុលនៃសារធាតុគីមីដែលចេញពីការធ្វើស្រែចំការ ដែលសល់នៅក្នុងដី ទឹក និងទឹកក្រោមដី។ ក្នុងការសិក្សានេះដែរក្រុមការងារបានចុះធ្វើការសម្ភាសន៍ផ្ទាល់ជាមួយប្រជាកសិករ អាជ្ញាធរ និងអាជីវករប្រកបរបរលក់ជីគីមី និងថ្នាំគីមីនៅក្នុងទីតាំងសិក្សា និងបានប្រមូលសំណាកដី និងទឹកមកធ្វើការវិភាគនៅមន្ទីរពិសោធន៍ផងដែរ។

ជាមួយនឹងសកម្មភាពនេះដែរក្រុមការងារចុះសិក្សានៅតំបន់ខាងលើ ជាលទ្ធផលបឋមរកឃើញថា:

១. ក្នុងតំបន់២ ឃុំប្រឡាយ ប្រជាកសិករធ្វើស្រែប្រាំងបាន ១ដង/ឆ្នាំ ទទួលបានផលបាន ៥តោន/ហ.ត និងប្រើពូជស្រូវ OM៥៤៥១

២. ផ្ទៃដីតំបន់២នៃ ឃុំប្រឡាយ មានជាង៥០០០ហិកតា គឺបានប្រើជីគីមីគ្រាប់ចំនួន ១៥០០តោន/ឆ្នាំ ដែលមានប្រភេទជីគីមីគ្រាប់ដូចជាៈ អ៊ុយរ៉េ ដេអាប៉េ និងអិនប៉េកា សរុបចំនួន ៣០០គក្រ/ហត និងជីទឹកបំប៉ន ៣លីត្រ/ហ.ត។ រួមទាំងថ្នាំកំចាត់ស្មៅ ថ្នាំសម្លាប់សត្វល្អិត និងថ្នាំជំងឺស្រូវ ជាច្រើនទៀត។

៣. ប្រជាកសិករខ្វះចំណេះដឹង និងបច្ចេកទេសក្នុងការប្រើប្រាស់ជីគីមីតាមតម្រូវការរបស់ដំណាំ។ ពួកគាត់ប្រើតាមការតាមគ្នា និងតាមការផ្សព្វផ្សាយ របស់ក្រុមហ៊ុនជីគីមីប៉ុណ្ណោះ។ ការប្រើថ្នាំ និងជីគីមីមិនតាមបច្ចេកទេស របស់ការដាំស្រូវ ធ្វើឲ្យខាតបង់លុយ ខូចគុណភាពដី និងបរិស្ថាន។

៤. កសិករ ចង់បានព័ត៌មានពីគុណភាពដីតើដីរបស់គាត់ត្រូវដាក់ជីប្រភេទអ្វីខ្លះដើម្បីឲ្យត្រូវនឹងតម្រូវការលូតលាស់ របស់ស្រូវ។

សូមជម្រាបជូនថាៈ សកម្មភាពសិក្សាស្រាវជ្រាវពីការប្រើប្រាស់ជីគីមី និងថ្នាំពុលកសិកម្ម ដែលប្រជាកសិករប្រើប្រាស់សម្រាប់ដំណាំស្រូវដែលអនុវត្តនៅភូមិសាស្ត្រ ស្រុកកំពង់ស្វាយ ស្រុកស្ទោង មានគោលបំណងៈ

-សិក្សាស្រាវជ្រាវប្រភេទថ្នាំសម្លាប់សត្វល្អិត និងជីគីមី ដែលបាន និងកំពុងប្រើប្រាស់ក្នុងតំបន់សិក្សា

- វាយតម្លៃកម្រិត និងបរិមាណប្រើប្រាស់សារធាតុគីមី របស់ប្រជាកសិករ

- វិភាគលើសារធាតុគីមី និងថ្នាំសម្លាប់សត្វល្អិតមាននៅក្នុងដីស្រែ និងទឹកស្រោចស្រព

- រៀបចំឯកសារសំយោគប្រៀបធៀបការប្រើប្រាស់ជីគីមីនិងថ្នាំសម្លាប់សត្វល្អិត ទៅនឹងស្តង់ដារសុវត្ថិភាព

- រៀបចំជាកាតាឡុកប្រភេទជីគីមី និងថ្នាំសម្លាប់សត្វល្អិតដែលមានប្រើប្រាស់ក្នុងតំបន់សិក្សា។





ថ្ងៃពុធ ៧កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០២៣ ក្រុមការងារមន្ត្រីបច្ចេកទេសអាជ្ញាធរទន្លេសាប ដឹកនាំដោយឯកឧត្តម សរ គឹមសាន្ត អគ្គលេខាធិការរងអាជ្ញាធរទន្លេសាប បានចុះសិក្សាស្រាវជ្រាវពីការប្រើប្រាស់ជីគីមី និងថ្នាំពុលកសិកម្ម ដែលប្រជាកសិករប្រើប្រាស់សម្រាប់ដំណាំស្រូវ ស្ថិតក្នុងភូមិសាស្ត្រ ឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ។ ការសិក្សានេះ គឺដើម្បីចងក្រងប្រភេទជីគីមី និងថ្នាំពុលកសិកម្ម ដែលបាន និងកំពុងប្រើប្រាស់ក្នុងតំបន់សិក្សា វាយតម្លៃកំរិត និងបរិមាណប្រើប្រាស់សារធាតុគីមីរបស់ប្រជាកសិករ និងសិក្សាបន្ទុកបំពុលនៃសារធាតុគីមីដែលចេញពីការធ្វើស្រែចំការ ដែលសល់នៅក្នុងដី ទឹក និងទឹកក្រោមដី។ ក្នុងការសិក្សានេះដែរ ក្រុមការងារបានចុះធ្វើការសំភាសន៍ផ្ទាល់ជាមួយប្រជាកសិករ អាជ្ញាធរ និងអាជីវករប្រកបរបរលក់ជីគីមី និងថ្នាំគីមីនៅក្នុងទីតាំងសិក្សា និងបានប្រមូលសំណាក់ដី និងទឹកមកធ្វើការវិភាគ នៅមន្ទីរពិសោធន៍ផងដែរ។




## សិក្សាស្រាវជ្រាវពីផលប៉ះពាល់ និងការប្រើប្រាស់ធនធានរ៉ែខ្សាច់នៅតាមអាងស្ទឹងពោធិសាត់ និងស្ទឹងសែន

# សិក្សាស្រាវជ្រាវ ពីបច្ចុប្បន្នភាពធនធានជលផល (ត្រី និងក្រៅពីត្រី) តាមការប្រែប្រួលរបបជលសាស្ត្រនិងវាយតម្លៃ-គុណភាពទឹក បឹងទន្លេសាប



នាថ្ងៃចន្ទ ១០រោច ខែភទ្របទ ដល់ ថ្ងៃសុក្រ ១៤រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ៩ ដល់ ១៣ ខែ តុលា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីនាយកដ្ឋានធនធានធម្មជាតិ ដឹកនាំដោយលោក ប៉ុន វុឌ្ឍី អនុប្រធាននាយកដ្ឋាន បានបន្តចុះធ្វើបច្ចុប្បន្នភាពធនធានជលផលតាមការប្រែប្រួលរបបជលសាស្ត្រ និងវាយតម្លៃគុណភាពទឹកបឹងទន្លេសាបនៅក្នុងភូមិសាស្ត្រ តំបន់កំពង់ឃ្លាំង និងតំបន់ចុងឃ្នៀស ខេត្តសៀមរាប និងតំបន់ព្រែកទាល់ ខេត្តបាត់ដំបង។

ការចុះសិក្សានេះ ក្រុមការងារបានធ្វើលើ ៖

ទី១. សម្ភាសន៍ប្រជានេសាទ ដើម្បីប្រមូលទិន្នន័យ-ព័ត៌មានពីការប្រើប្រាស់ប្រភេទឧបករណ៍នេសាទនៅតំបន់សិក្សា ។

ទី២. ប្រមូលសំណាកត្រី និងធនធានក្រៅពីត្រី, ទីតាំងនេសាទ (X,Y), វាស់ជម្រៅទឹកក្នុងតំបន់នេសាទនីមួយៗ, វាស់គុណភាពទឹកបឋម និងពិនិត្យលើលំនៅដ្ឋានធនធានត្រីនៅរដូវវស្សា ។

ជាមួយនឹងសកម្មភាពសិក្សានៅតំបន់ខាងលើ និងតំបន់ពាក់ព័ន្ធ ជាលទ្ធផលបឋមបង្ហាញឃើញថា ៖

១. បានរកឃើញប្រភេទត្រីចំនួន ៣០ ប្រភេទ ដោយប្រើប្រាស់នូវឧបករណ៍ការនេសាទ ៣ ប្រភេទ គឺឧបករណ៍ មងរាយ បរ និងសន្ទូច ។

២. បានវាស់ ថ្លឹង និងកត់ត្រាលើប្រភេទវារីសត្វ/សិប្បីសត្វសរុបមានចំនួន ០៤ ពួកធំៗ ដោយចែកចេញជា ០៤ ថ្នាក់ ស្មើនឹង ០៥ លំដាប់ និង ០៨ អម្បូរ មាន ១៧ ប្រភេទ។ ក្នុងនោះវារីសត្វដូចជា (កំពឹស ពស់ទឹក) មានចំនួន ០៣ អម្បូរ ស្មើនឹង ០៦ ប្រភេទ និងសិប្បីសត្វដូចជា (លៀស ខ្យង ខ្ចៅ គ្រុំ) មានចំនួន ០២ អម្បូរ ស្មើនឹង  ១១ ប្រភេទ។

៣.  គុណភាពទឹកបឹងទន្លេសាបនារដូវវស្សា នាពាក់កណ្តាលខែតុលា គឺជាទឹកដែលមានគុណភាពល្អសម្រាប់ធនធានជលផលគ្រប់ប្រភេទរស់នៅ លាក់ខ្លួន និងលូតលាស់ធំធាត់ ដោយទឹកមានភាពថ្លាចាប់ពី ១៥ ស.ម ទៅ ២០ ស.ម ស៊ីតុណ្ហភាពទឹកមានចន្លោះពី ៣០ ទៅ ៣១ អង្សារoC ចំណែកអុកស៊ីសែនរលាយក្នុងទឹកមានគ្រប់គ្រាន់លើសពី ៣ mgO2/L ។

សូមជម្រាបជូនថា៖ សកម្មភាពចុះធ្វើបច្ចុប្បន្នភាពធនធានជលផលតាមការប្រែប្រួលរបបជលសាស្ត្រ និងវាយតម្លៃគុណភាពទឹកបឹងទន្លេសាបនៅភូមិសាស្ត្រ ក្នុងខេត្តសៀមរាប និងខេត្តបាត់ដំបង គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តឱ្យអនុវត្តន៍នៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ២០២៣ របស់នាយកដ្ឋានធនធានធម្មជាតិនៃអាជ្ញាធរទន្លេសាប ។

សកម្មភាពខាងលើនេះ មានគោលបំណងដើម្បី៖

- តាមដាន និងវាយតម្លៃប្រភេទធនធានជលផលទៅតាមប្រភេទឧបករណ៍
- តាមដាន និងវាយតម្លៃគុណភាពទឹកបឹងទន្លេសាបទៅតាមទីតាំងសិក្សា។
- តាមដានលើលក្ខណៈជីវសាស្ត្ររបស់ត្រី លៀស និងគ្រុំ លើការរស់នៅ ការបន្តពូជ និងការលូតលាស់ (រដូវប្រាំង/រដូវវស្សា)។





នៅថ្ងៃចន្ទ ១១រោច ខែស្រាពណ៍ ដល់ ថ្ងៃសុក្រ ១កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី១១ ដល់ ១៥ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីនាយកដ្ឋានធនធានធម្មជាតិ ដឹកនាំដោយ លោក ម៉ម សុធា ប្រធានការិយាល័យជីវចម្រុះ បានចុះធ្វើបច្ចុប្បន្នភាពធនធានជលផលតាមការប្រែប្រួលរបបជលសាស្ត្រ និងវាយតម្លៃគុណភាពទឹកបឹងទន្លេសាបនៅក្នុងភូមិសាស្ត្រតំបន់បឹងទន្លេសាបក្នុងខេត្តសៀមរាប និងខេត្តបាត់ដំបង។



ការចុះសិក្សានេះ ក្រុមការងារបានធ្វើលើ ៖

ទី ១. សម្ភាសន៍អ្នកនេសាទនៅតាមតំបន់សិក្សា ដើម្បីយកព័ត៌មានពីឧបករណ៍នេសាទ។

ទី២. ប្រមូលសំណាករួមមាន: ត្រី និងធនធានក្រៅពីត្រី, យកចំណុចកូអរដោនេ(X/Y), វាស់ជម្រៅទឹក, វាស់គុណភាពទឹក និងពិនិត្យលើលំនៅដ្ឋានត្រីនារដូវវស្សា។

ជាមួយនឹងសកម្មភាពក្រុមការងារចុះសិក្សានៅតំបន់ពាក់ព័ន្ធខាងលើ ជាលទ្ធផលឃើញថា ៖

ទី១. រកឃើញត្រីចំនួន ៦ លំដាប់ ស្មើនឹង ២៣ ប្រភេទ ពីការនេសាទដោយឧបករណ៍ចំនួន ៤ ប្រភេទរួមមាន : មងរាយ មងបណ្តែត បរ និងសន្ទូច។ ក្នុងនោះត្រីកំពុងពងមាន ៣ ប្រភេទ គឺ កញ្ចុះឆ្នូត កញ្ចុះបាយ និងឆ្លាំង។

ទី២. ធនធានក្រៅពីត្រីមានចំនួន ៦ អម្បូរ ស្មើនឹង ៧ ប្រភេទ។

ទី៣. កំរិតភាពថ្លានៃទឹកមានចាប់ពី ១-៥សម និងអុកស៊ីសែនរលាយក្នុងទឹក(DO)មានពី ២៣,៥-២៧,៥mg/l ទៅតាមតំបន់សិក្សា។

ទី៤. ប្រភេទព្រៃលិចទឹក ដែលជាលំនៅដ្ឋានត្រីនារដូវវស្សានេះ រួមមាន : រាំង ផ្តៅល គ្រោះ ច្រកែង ទៀនព្រៃ រញា បន្លាយួន វល្លិ៍តាអើក ផ្កាស្នោ សារាយ ...។ល។

សូមជម្រាបជូនថា: សកម្មភាពចុះធ្វើបច្ចុប្បន្នភាពធនធានជលផលតាមការប្រែប្រួលរបបជលសាស្ត្រ និងវាយតម្លៃគុណភាពទឹកបឹងទន្លេសាបនៅក្នុងភូមិសាស្ត្រតំបន់បឹងទន្លេសាបក្នុងខេត្តសៀមរាប និងខេត្តបាត់ដំបង គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តដាក់ឱ្យអនុវត្ត នៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ២០២៣ របស់អាជ្ញាធរទន្លេសាប។

សកម្មភាពខាងលើនេះ មានគោលបំណង៖

- សិក្សាតាមដាន និងវាយតម្លៃប្រភេទធនធានជលផលទៅតាមប្រភេទឧបករណ៍
- សិក្សាតាមដាន និងវាយតម្លៃគុណភាពទឹកបឹងទន្លេសាបទៅតាមទីតាំងសិក្សា។
- សិក្សាតាមដានលើលក្ខណៈជីវសាស្ត្ររបស់លៀស និងគ្រុំ លើការរស់នៅ ការបន្តពូជ និងការលូតលាស់ (រដូវប្រាំង/រដូវវស្សា)។






នាថ្ងៃចន្ទ ១១កើត ខែភទ្របទ ដល់ ថ្ងៃសុក្រ ១៥កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ២៥ ដល់ ២៩ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីនាយកដ្ឋានធនធានធម្មជាតិ ដឹកនាំដោយ លោក ម៉ម សុធា ប្រធានការិយាល័យជីវចម្រុះ បានបន្តចុះធ្វើបច្ចុប្បន្នភាពធនធានជលផលតាមការប្រែប្រួលរបបជលសាស្ត្រ និងវាយតម្លៃគុណភាពទឹកបឹងទន្លេសាបនៅក្នុងភូមិសាស្ត្រ តំបន់ផ្អកទ្រ ខេត្តកំពង់ឆ្នាំង, តំបន់កំពង់ល្អួង ខេត្តពោធិ៍សាត់ និងតំបន់ផាត់សណ្ដាយ ខេត្តកំពង់ធំ ។

ការចុះសិក្សានេះ ក្រុមការងារបានធ្វើលើ ៖

ទី១. សម្ភាសន៍ប្រជានេសាទ ដើម្បីប្រមូលទិន្នន័យ-ព័ត៌មានពីការប្រើប្រាស់ប្រភេទឧបករណ៍នេសាទនៅតំបន់សិក្សា ។

ទី២. ប្រមូលសំណាកត្រី និងធនធានក្រៅពីត្រី, ទីតាំងនេសាទ (X,Y), វាស់ជម្រៅទឹកក្នុងតំបន់នេសាទនីមួយៗ, វាស់គុណភាពទឹកបឋម និងពិនិត្យលើលំនៅដ្ឋានធនធានត្រីនៅរដូវវស្សា ។

ជាមួយនឹងសកម្មភាពក្រុមការងារចុះសិក្សានៅតំបន់ខាងលើ និងតំបន់ពាក់ព័ន្ធ ជាលទ្ធផលបឋមបង្ហាញថា ៖

១. រកឃើញប្រភេទត្រីចំនួន ៣៦ ប្រភេទ តាមរយៈការនេសាទ ដោយប្រើប្រាស់នូវឧបករណ៍ចំនួន ៣ ប្រភេទ គឺឧបករណ៍ មង វាយ បរ និងសន្ទូច ។

២. ធនធានក្រៅពីត្រីមានចំនួន ៦ ប្រភេទ ដូចជាកំពឹស កំពឹសអង្កាម លៀស គ្រុំចំពុះទា ខ្យងបឹង និងខ្យងគូចទាល និងការប្រើប្រាស់ធនធានត្រីសម្រាប់វារីវប្បកម្មនៅក្នុងតំបន់សិក្សា ។

៣. កម្រិតភាពថ្លានៃទឹកមានចាប់ពី ៥-១៥សម និងអុកស៊ីសែនរលាយក្នុងទឹក(DO)មានពី ១,២-១,៧mg/L ទៅតាមតំបន់សិក្សានីមួយៗ និងកម្រិតកម្ពស់ទឹកមានជម្រៅពី ៤.២ ដល់ ៩.០០ ម ។

សូមជម្រាបជូនថា៖ សកម្មភាពចុះធ្វើបច្ចុប្បន្នភាពធនធានជលផលតាមការប្រែប្រួលរបបជលសាស្ត្រ និងវាយតម្លៃគុណភាពទឹកបឹងទន្លេសាបនៅភូមិសាស្ត្រ ក្នុងខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ និងខេត្តកំពង់ធំ គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តឱ្យអនុវត្តន៍នៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ២០២៣ របស់នាយកដ្ឋានធនធានធម្មជាតិ នៃអាជ្ញាធរទន្លេសាប ។

សកម្មភាពខាងលើនេះ មានគោលបំណងដើម្បី៖

- សិក្សាតាមដាន និងវាយតម្លៃប្រភេទធនធានជលផលទៅតាមប្រភេទឧបករណ៍



- សិក្សាតាមដាន និងវាយតម្លៃគុណភាពទឹកបឹងទន្លេសាបទៅតាមទីតាំងសិក្សា។
- សិក្សាតាមដានលើលក្ខណៈជីវសាស្ត្ររបស់ត្រី លៀស និងគ្រុំ លើការរស់នៅ ការបន្តពូជ និងការលូតលាស់ (រដូវប្រាំង/រដូវវស្សា)។



# បច្ចុប្បន្នភាពប្រព័ន្ធធារាសាស្ត្រ និងតាមដានបម្រែបម្រួលគុណភាពទឹក លក្ខណៈរូប-គីមី ( physic-chemical- parameters ) ក្នុងតំបន់បឹងទន្លេសាប



នាថ្ងៃសុក្រ ៥រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីបច្ចេកទេសនៃនាយកដ្ឋានធនធានធម្មជាតិ ដឹកនាំដោយ លោក វិន ប៊ុនពៅ ប្រធាននាយកដ្ឋាន បានបន្តចុះសិក្សាស្តីពីបច្ចុប្បន្នភាពប្រព័ន្ធធារាសាស្ត្រ ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំប៉ោយចារ ស្រុកភ្នំស្រុក និងឃុំគយម៉ែង ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ ។ ក្នុងសកម្មភាពនេះ ក្រុមការងារបានជួបពិភាក្សា និងសាកសួរព័ត៌មានជាមួយអាជ្ញាធរដែនដី ប្រជាពលរដ្ឋ និងការចុះដល់ទីតាំងសិក្សា ដើម្បីពិនិត្យស្ថានភាពការប្រើប្រាស់ទឹកពីប្រព័ន្ធស្រោចស្រពខាងលើ និងស្ថានភាពបង្កបង្កើនផលទូទៅរបស់ប្រជាពលរដ្ឋ ។

ជាមួយនឹងសកម្មភាពនេះ ការចុះសិក្សាស្រាវជ្រាវខាងលើទទួលបានលទ្ធផលដូចខាងក្រោម ៖

ទី១. ប្រព័ន្ធធារាសាស្ត្រទំនប់អាងត្រពាំងថ្ម ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ដែលបច្ចុប្បន្នអាងអាចស្តុកទឹកបានប្រមាណពី ៣០០-៥០០ លានម៉ែត្រគូប និងមានលទ្ធភាពស្រោចស្រពលើផ្ទៃដីស្រែស្រូវវស្សា និងស្រូវប្រាំងប្រមាណ ១០ ម៉ឺនហិកតា រួមមានប្រឡាយមេ ប្រឡាយរង ប្រឡាយស្រោចស្រព និងប្រឡាយនាំទឹកមានសរុប ១៥ ខ្សែ ប្រវែងសរុប ២០-៣០ គម និងទំនប់បង្វៀរ ទំនប់សណ្តរ និងសំណង់ទ្វារទឹកស្វ័យប្រវត្តិ ។

ទី២. សំណង់ទំនប់ស្ទាក់ទឹកសិរីមង្គល ស្រុកបង្គលបុរី ខេត្តបន្ទាយមានជ័យ ដែលអាចរក្សាទឹកបានប្រមាណ ៥០ លានម៉ែត្រគូប និងមានលទ្ធភាពស្រោចស្រព ចំនួន ១០.០០០ ហិកតា ។



ទី៣. ទ្វារទឹកនៃអាងត្រពាំងថ្ម គឺត្រូវបានបើក ដើម្បីបង្ហូរទឹកចេញពីអាងមួយចំនួនតូច សម្រាប់បម្រើអោយប្រជាកសិករនៅផ្នែកខាងលើទំនប់ប្រមូលផលស្រូវវស្សា និងបន្តធ្វើស្រែប្រាំង ឬស្រូវដើមរដូវ និងសំណង់ស្ទាក់ទឹកសិរីមង្គលត្រូវបានលិច ។ បច្ចុប្បន្នក្នុងសិក្សានៅមិនទាន់ចាប់ផ្តើមការងារបង្កបង្កើនផលទេ ព្រោះដីស្រែនៅបន្តមានជំនន់ទឹកលិចពី ៣០ ទៅ ៨០ សម ។

ទី៤. អាងត្រពាំងថ្ម ចាប់ផ្តើមសាងសង់ដំបូង នៅឆ្នាំ១៩៧៧ ដោយកម្លាំងមនុស្សរាប់ពាន់នាក់ នារបបខ្មែរក្រហម ដែលអាចមានលទ្ធភាពស្តុកទឹកបានប្រមាណតែ ៥០ លានម៉ែត្រគូប ។ អាងទឹកនេះត្រូវបានចាប់ផ្តើមស្តារឡើងវិញនៅខែសីហា ឆ្នាំ២០០៤ ក្រោមមូលនិធិបដិភាគនៃគម្រោងរបស់រដ្ឋាភិបាលជប៉ុន សហការជាមួយក្រសួងធនធានទឹក និងឧតុនិយម និងសំណង់ស្ទាក់ទឹកស្ទឹងមង្គលបុរីចាប់ផ្តើមសាងសង់នាឆ្នាំ២០១៨។

សូមជម្រាបជូនថា ៖ សកម្មភាពចុះសិក្សា ស្តីពីបច្ចុប្បន្នភាពប្រព័ន្ធធារាសាស្ត្រ ក្នុងខេត្តបន្ទាយមានជ័យ នៃខេត្តទាំង ៦ ជុំវិញតំបន់ទន្លេសាប គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តដាក់ឲ្យអនុវត្តនៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ២០២៣ របស់ការិយាល័យធនធានទឹកនៃនាយកដ្ឋានធនធានធម្មជាតិ របស់អាជ្ញាធរទន្លេសាប ។

សកម្មភាពខាងលើនេះ មានគោលបំណងដើម្បី ៖

- ប្រមូលព័ត៌មាន ទិន្នន័យ និងបច្ចុប្បន្នភាពស្តីពីប្រព័ន្ធធារាសាស្ត្រ ក្នុងខេត្តទាំង ៦ ជុំវិញតំបន់ទន្លេសាប។
- ពិនិត្យវាយតម្លៃលើការប្រើប្រាស់ទឹក និងគ្រប់គ្រងធនធានទឹកក្នុងខេត្តទាំង ៦ ជុំវិញតំបន់ទន្លេសាប ។



នៅថ្ងៃព្រហស្បតិ៍ ៦រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីបច្ចេកទេសនៃនាយកដ្ឋានធនធានធម្មជាតិ ដឹកនាំដោយលោក វិន ប៊ុនពៅ បានបន្តចុះសិក្សា ស្តីពីបច្ចុប្បន្នភាពប្រព័ន្ធធារាសាស្ត្រ ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំព្រៃ ស្រុកមោងឫស្សី និងឃុំព្រែកនរិន្ទ ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។

ការចុះសិក្សានេះ ក្រុមការងារបានជួបពិភាក្សា និងសាកសួរព័ត៌មានជាមួយអាជ្ញាធរដែនដី ប្រជាពលរដ្ឋ និងការចុះដល់ទីតាំងសិក្សា ដើម្បីពិនិត្យស្ថានភាពការប្រើប្រាស់ប្រព័ន្ធស្រោចស្រព និងស្ថានភាពបង្កបង្កើនផលរបស់ប្រជាពលរដ្ឋទូទៅ ។

ជាមួយនឹងសកម្មភាពនេះ ការចុះសិក្សាស្រាវជ្រាវខាងលើ ទទួលបានលទ្ធផលដូចខាងក្រោម ៖

ទី១. មានប្រព័ន្ធធារាសាស្ត្រ សរុប ៧ខ្សែ (ប្រឡាយមេ ៥ខ្សែ, ប្រឡាយរង ២ខ្សែ និងផ្លូវជណ្តើរត្រី ២) ប្រវែងសរុប ១៥,០០០ម៉ែត្រ និងមានសំណង់ស្ទាក់ទឹក ១០កន្លែង ។ មានលទ្ធភាពស្រោចស្រពបាន ១២,៤០០ហិកតា ។

ទី២. ប្រព័ន្ធធារាសាស្ត្ររាមគន់ ទឹកមានកម្ពស់ ១៤.៥ម៉ែត្រ និងប្រព័ន្ធធារាសាស្ត្រទំនប់សាលាតាអន ទឹកមានកម្ពស់ ១១.៣ម៉ែត្រ ។

ទី៣. ទ្វាទឹក របស់ប្រព័ន្ធធារាស្ត្រ ទាំង ២ គឺត្រូវបានបើក ១០០% ពីព្រោះក្នុងពេលចុះសិក្សាស្ថានភាពទឹកនៅផ្នែកខាងលើ មានភ្លៀងធ្លាក់ខ្លាំង និងបង្កមានទឹកជំនន់នៅតាមតំបន់មួយចំនួន ជាពិសេសតំបន់វាលទំនាប និងដីស្រែ ។

ទី៤. ប្រព័ន្ធធារាសាស្ត្ររាមគន់ ចាប់ផ្តើមសាងសង់ នៅឆ្នាំ២០១៦ ហើយបញ្ចប់ការសាងសង់ នៅឆ្នាំ ២០២១ និងប្រព័ន្ធធារាសាស្ត្រសាលាតាអន ចាប់ផ្តើមសាងសង់ នៅឆ្នាំ២០១៨ ហើយបញ្ចប់ការសាងសង់ នៅឆ្នាំ ២០២១ ។

សូមជម្រាបជូនថា ៖ សកម្មភាពចុះសិក្សា ស្តីពីបច្ចុប្បន្នភាពប្រព័ន្ធធារាសាស្ត្រ ក្នុងខេត្តបាត់ដំបង នៃខេត្តទាំង ៦ ជុំវិញតំបន់ទន្លេសាប គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តដាក់ឲ្យអនុវត្តនៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ២០២៣ របស់ការិយាល័យធនធានទឹក នៃនាយកដ្ឋានធនធានធម្មជាតិរបស់អាជ្ញាធរ ទន្លេសាប ។

សកម្មភាពខាងលើនេះ មានគោលបំណងដើម្បី ៖

- ប្រមូលព័ត៌មាន-ទិន្នន័យ និងបច្ចុប្បន្នភាពស្តីពីប្រព័ន្ធធារាសាស្ត្រ ក្នុងខេត្តទាំង ៦ ជុំវិញតំបន់ទន្លេសាប។
- ពិនិត្យវាយតម្លៃលើការប្រើប្រាស់ទឹក និងគ្រប់គ្រងធនធានទឹកក្នុងខេត្តទាំង ៦ ជុំវិញតំបន់ទន្លេសាប ។





ថ្ងៃពុធ ៧កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី ២៦ ខែមេសា ឆ្នាំ ២០២៣ លោក ខ្វាន់ ភក្ត្រា អនុប្រធាននាយកដ្ឋានធនធានធម្មជាតិ និងក្រុមការងារបច្ចេកទេស បានបន្តចុះតាមដានគុណភាពទឹក(លក្ខណៈរូប-គីមី) នៅភូមិបណ្ដែតទឹកបឹងទន្លេសាប ស្ថិតក្នុងភូមិសាស្ត្រឃុំកំពង់លួង ខេត្តពោធិ៍សាត់ ឃុំឆ្នុកទ្រូ ខេត្តកំពង់ឆ្នាំង និងឃុំផាត់សណ្ដាយ ខេត្តកំពង់ធំ។

ក្នុងការសិក្សាតាមដាននេះ ក្រុមការងារបានធ្វើការជ្រើសរើសទីតាំងចំនួន 12 ទីតាំងដែលមាន ប៉ារ៉ាម៉ែត្រ pH, ORP, CT, DO, TDS, Turbidity, Transparency, chlorophyl, Cyanobacteria និងបានយកសំណាកទឹកមកធ្វើការវិភាគលើ TSS, NO3, NH4, TN, TP នៅមន្ទីរពិសោធន៍ ដើម្បីតាមដាន និងស្វែងយល់ពីការប្រែប្រួលគុណភាពទឹកបឹងទន្លេសាបតាមរដូវកាលនីមួយៗ។


Live Data

| | | | | |
|---|---|---|---|---|
| 0.69 | 2.65 | 0.2 | 0.136 | 0.2 |
| 91.2 | 91.2 | 6.99 | 199.5 | 0.193 |
| 0.00 | 0.2 | 2.40 | 2.42 | 0 |
| 8.07 | 0 | 0.831 | 6.92 | -11.8 |
| 29.203 | 0.123 | 5.45 | 0.0 | |



ថ្ងៃចន្ទ ០៧រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី ១៣ ខែមីនា ឆ្នាំ ២០២៣ លោក វិន ប៊ុនពៅ ប្រធាននាយកដ្ឋាន បានដឹកនាំក្រុមការងារមន្ត្រីបច្ចេកទេស នាយកដ្ឋានធនធានធម្មជាតិ នៃអាជ្ញាធរទន្លេសាប ចុះសិក្សាប្រព័ន្ធជលសាស្ត្រក្នុងអាងស្ទឹងជីនិត ស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ធំ ។ ការសិក្សានេះផ្ដោតលើប្រព័ន្ធធារាសាស្ត្រ ការប្រើប្រាស់ទឹក និងការគ្រប់គ្រងធនធានទឹក ព្រមទាំងវាយតម្លៃលើការប្រែប្រួលគម្របដីក្នុងអាងស្ទឹងជីនិត ។

# សិក្សាជីវចម្រុះ និងបរិមាណប្លង់តុង ( Plankton ) ក្នុងតំបន់នៃបឹងទន្លេសាបដែលមានទំនាក់ទំនងទៅនឹងការលូតលាស់-របស់ប្រភេទត្រីស



នៅថ្ងៃចន្ទ ៤កើត ខែភទ្របទ ដល់ ថ្ងៃសុក្រ ៨កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ដល់ ២២ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីនាយកដ្ឋានធនធានធម្មជាតិ ដឹកនាំដោយលោក ប៉ុន វុឌ្ឍី អនុប្រធាននាយកដ្ឋានធនធានធម្មជាតិ ធ្វើការចុះសិក្សាស្រាវជ្រាវអំពីជីវៈចម្រុះ និងបរិមាណប្លង់តុង (Plankton) នៅតំបន់បឹងទន្លេសាប ដែលមានទំនាក់ទំនងទៅនឹងការលូតលាស់របស់ប្រភេទត្រីស នៅភូមិសាស្ត្រតំបន់បឹងទន្លេសាប និងដងស្ទឹងសែន ស្ថិតក្នុងឃុំផាត់សណ្ដាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។

ការចុះសិក្សានេះ ក្រុមការងារស្រាវជ្រាវបានធ្វើការលើ ៖

ទី១. តាមដានលើគុណភាពទឹកបឹងទន្លេសាបដូចជា កម្រិតថ្លា, ជម្រៅទឹក, សីតុណ្ហភាព, ភាពចម្លងចរន្ត, អុកស៊ីសែនរលាយក្នុងទឹក និងសារធាតុ Chlorophyll។

ទី២. ការយកសំណាកទឹកមកពិនិត្យ/វិភាគលើសារធាតុប្លង់តុងសត្វ និងរុក្ខជាតិ។

ទី៣. សិក្សាតាមដាន និងវាយតម្លៃលើការលូតលាស់របស់ប្រភេទត្រីស និងពិនិត្យវាយតម្លៃពីចំនួនប្រភេទត្រី ទៅតាមលក្ខណៈប្រភេទលំនៅដ្ឋានត្រីតាមរយៈប្រភេទឧបករណ៍នេសាទ លបមងរាយ/បណ្ដែត ដែលនេសាទក្នុងតំបន់សិក្សា។

ជាមួយនឹងសកម្មភាពក្រុមការងារមន្ត្រីចុះសិក្សានៅតំបន់ពាក់ព័ន្ធខាងលើ ជាលទ្ធផលឃើញថា ៖

១. គុណភាពទឹកបឹងទន្លេសាប និងទឹកស្ទឹងសែនក្នុងខែកញ្ញាគឺមានគុណភាពល្អ ដោយទឹកមានភាពថ្លាប្រមាណ ១៥ ស.ម ទៅ ២៥ ស.ម ស៊ីតុណ្ហភាពទឹកមានចន្លោះពី ២៩ អង្សារសេ- ៣១ អង្សារសេ ចំណែកអុកស៊ីសែនរលាយក្នុងទឹកមានគ្រប់គ្រាន់លើសពី ៥.២ mgO2/L ។

២. ក្រុមការងារបានយកសំណាកទឹកដើម្បីពិនិត្យមើលសារធាតុប្លង់តុងចំនួន ០២ ទីតាំង គឺ (i) យកសំណាកទឹកនៅក្នុងតំបន់វាំមសារស្ទឹងសែនក្នុងដងស្ទឹងសែន និង(ii) យកសំណាកទឹកនៅចំណុចមាត់បឹងទន្លេសាប(បឹងតូច)។

៣. យកសំណាកត្រីស្ថិតក្នុងលំដាប់ Cypriniformes ចំនួន ៥ ប្រភេទមានដូចជា ត្រីប្រកែង_Puntioplites procto-zysron, ត្រីឆ្កោក_Cyclocheilichthys enoplos ត្រីឆ្ពិនមាស_Hyps_ibarbus sp, ត្រីខ្នងវែង_ Dangila lineata និងត្រីក្រុសអុចកន្ទុយ_ Osteochilus hasselti ត្រូវបានយកមកវះពោះដើម្បីធ្វើវិភាគពី Stomach_contents របស់ត្រីនីមួយៗ និងបានពិនិត្យវាយតម្លៃលើស្ថានភាពលំនៅដ្ឋានត្រីក្នុងតំបន់សិក្សាផងដែរ។

សូមជម្រាបជូនថា : សកម្មភាពចុះសិក្សាស្រាវជ្រាវអំពីជីវៈចម្រុះ និងបរិមាណប្លង់តុង (Plankton) នៅតំបន់បឹងទន្លេសាប ដែលមានទំនាក់ទំនងទៅនឹងការលូតលាស់របស់ប្រភេទត្រីស នៅភូមិសាស្ត្រតំបន់បឹងទន្លេសាប គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តដាក់ឲ្យអនុវត្តនៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ២០២៣ របស់អាជ្ញាធរទន្លេសាប ។

សកម្មភាពខាងលើនេះ មានគោលបំណង ៖

-វាយតម្លៃពីប្រភេទប្លង់តុងសត្វ និងរុក្ខជាតិដែលមាននៅក្នុងទឹកបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ។

- តាមដានការលូតលាស់ប្រភេទត្រីស(Cyprinidea) ចាប់ពីទើបបង្កកំណើតរហូតដល់ក្លាយជាត្រីមេបា។

- ធ្វើការវាយតម្លៃ និងផលប៉ះពាល់សម្រាប់ពពួកជីវៈចម្រុះក្នុងតំបន់សិក្សា។

- ប្រមូល ចងក្រងព័ត៌មាន ទិន្នន័យបឋមលើប្រភេទប្លង់តុងនៅតាមទីតាំងចុះសិក្សា សម្រាប់ចងក្រងជាឯកសារមូលដ្ឋាន លើការសិក្សាតាមដានជីវៈចម្រុះក្នុងតំបន់ទន្លេសាប។



# សិក្សាស្រាវជ្រាវ តាមដានការវិវត្តន៍គុណភាពដី លើដំណាំស្រូវ នៅតំបន់ប្រព័ន្ធធារាសាស្ត្រ អង្គគោក្នុងភ្លៀងអាងស្ទឹង-សែន



នៅថ្ងៃចន្ទ ៤កើត ខែភទ្របទ ដល់ ថ្ងៃសុក្រ ៨កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ដល់ ២២ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារនាយកដ្ឋានធនធានធម្មជាតិ ដឹកនាំដោយ លោកស្រី ប្រាក់ ចាន់វឌ្ឍនា អនុប្រធាននាយកដ្ឋាន បានចុះសិក្សាស្រាវជ្រាវ តាមដានការវិវត្តន៍ នៃ



គុណភាពដីលើដំណាំស្រូវនៅតំបន់ប្រព័ន្ធធារាសាស្ត្រអង្គគោក្នុងផ្ទៃរងទឹកភ្លៀងអាងស្ទឹងសែន ខេត្តកំពង់ធំ។

ការចុះសិក្សានេះ ក្រុមការងារបានធ្វើលើ ៖

ទី ១. ជួបពិភាក្សាជាមួយប្រធានសហគមន៍កសិករប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រអង្គគោ ស្តីពីស្ថានភាពការធ្វើស្រែនៅរដូវទី 2 (ស្រូវប្រថុយទឹក)ដែលចាប់ផ្តើមធ្វើពីពាក់កណ្តាលខែមេសា និងប្រមូលផលនៅចុងខែសីហា ឆ្នាំ 2023

ទី ២. ជួបពិភាក្សាជាមួយកសិករដែលបានសហការក្នុងការសិក្សានេះ ស្តីពីស្ថានភាពដីស្រែ និងស្ថានភាពការធ្វើស្រែរបស់ពួកគាត់

ទី ៣. ខួងយកសំណាកដីនៃដីស្រែដើម្បីយកទៅវិភាគគុណភាពដីនៅមន្ទីរពិសោធន៍គុណភាពដី។

ចុះសិក្សានៅតំបន់ពាក់ព័ន្ធខាងលើជាលទ្ធផលឃើញថា ៖

ទី ១. ស្ថានភាពការធ្វើស្រែនៅរដូវទី 2 ឆ្នាំ 2023 ការប្រូតកាត់ប្រមូលផលស្រូវ(ពូជស្រូវ OM ៥៤៥១)៖ ទាបបំផុត4តោន/ha មធ្យម 5តោន/ha និងខ្ពស់បំផុត 6តោន/ha

ទី ២. តម្លៃស្រូវសើម៖ ពូជ OM៥៤៥១ (ពូជនាំចូលពីប្រទេសវៀតណាម) នៅដើមរដូវប្រមូលផលលក់បាន 1020 រៀល/Kg និងចុងរដូវប្រមូលផល តម្លៃពី 1250 រៀល-1300 រៀល/Kនិងពូជសែនក្រអូប(ពូជក្នុងស្រុក)៖ តម្លៃ 1200-1300 រៀល/Kg ។

សូមជម្រាបជូនថា៖ សកម្មភាពចុះសិក្សាស្រាវជ្រាវ តាមដានការវិវត្តន៍ នៃគុណភាពដីលើដំណាំស្រូវនៅតំបន់ប្រព័ន្ធធារាសាស្ត្រអង្គគោក្នុងផ្ទៃរងទឹកភ្លៀងអាងស្ទឹងសែន គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តដាក់ឱ្យអនុវត្ត នៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ២០២៣ របស់អាជ្ញាធរទន្លេសាប។

សកម្មភាពខាងលើនេះ មានគោលបំណង៖

- ចងក្រងជាប្រព័ន្ធទិន្នន័យមូលដ្ឋាន លើស្ថានភាពគុណភាពដីដំណាំស្រូវសម្រាប់ជាទិន្នន័យក្នុងការស្រាវជ្រាវ តាមដាន អំពីការវិវត្តន៍ នៃស្ថានភាពគុណភាពដីដែលទាក់ទងនឹងការអនុវត្តលើការដាំដុះ
- ចងក្រងជាប្រព័ន្ធទិន្នន័យមូលដ្ឋានលើបច្ចេកទេសក្នុងការដាំដុះដំណាំស្រូវ សម្រាប់ជាទិន្នន័យក្នុងការស្រាវជ្រាវ តាមដានអំពីបម្រែបម្រួលលើការដាំដុះ។

# សកម្មភាពសិក្សាការប្រើប្រាស់ដីកសិកម្ម ជីគីមី និងថ្នាំកសិកម្មទីជម្រាលអាងទន្លេសាប



នៅថ្ងៃសុក្រ ១៥កើត ដល់ថ្ងៃសៅរ៍ ០១រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ២៩ ដល់ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីបច្ចេកទេស នៃនាយកដ្ឋានធនធានធម្មជាតិ ដឹកនាំដោយ លោក វិន ប៊ុនពៅ បានបន្តចុះសិក្សាស្រាវជ្រាវ និងវាយតម្លៃដែនព្រៃលិចទឹកតំបន់ ៣ ជុំវិញតំបន់បឹងទន្លេសាប នៅក្នុងស្រុកក្រគរ ខេត្តពោធិ៍សាត់ ។

ការចុះសិក្សានេះ ក្រុមការងារបាន៖

១. ជួបពិភាក្សាជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋ ។

២. ចុះដល់ទីតាំង ដើម្បីពិនិត្យស្ថានភាពបង្គោលព្រំតំបន់៣ ផ្ទៃដីទន្ទ្រានក្នុងតំបន់ ៣ និងស្ថានភាពទូទៅ ។

ជាមួយនឹងសកម្មភាពនេះ ការចុះសិក្សាស្រាវជ្រាវខាងលើទទួលបានលទ្ធផលដូចខាងក្រោម ៖



១. បង្គោលព្រំដែនព្រៃលិចទឹកតំបន់ ៣ ចំនួន ២២បង្គោលដែលបានពិនិត្យឃើញថានៅឈរត្រង់បានល្អច្រើន(២០/២២នៃបង្គោលសរុប នៅស្រុកក្រគរ) និងមានទ្រេតតិចតួច (០២/២២បង្គោល) ។

២. ការកាត់ឆ្វៀលដីតំបន់៣ ចេញមកតំបន់ ២ នៅក្នុងស្រុកក្រគរ គឺមានទំហំ ១,១២២ ហិកតា ៤៥អា ។

៣. ចំពោះផ្ទៃដីក្នុងដែនព្រៃលិចទឹកតំបន់ ៣ នៅតែមានប្រជាពលរដ្ឋមួយចំនួនបន្តចូលទៅធ្វើស្រែលើដីទន្ទ្រាន និងតំបន់ខ្លះក៏មិនហ៊ានចូលទៅធ្វើស្រែទេ ដោយការហាមឃាត់តឹងរឹងពីអាជ្ញាធរឃុំ ។

៤.ដីស្រែដែលទុកចោលក្នុងតំបន់ ៣ឃើញមានដុះព្រៃលិចទឹកឡើងវិញ ដូចជាពពួកស្មៅ និងវល្លិ៍ដុះលឿនជាងគេ ។

សូមជម្រាបជូនថា ៖ សកម្មភាពចុះសិក្សាស្រាវជ្រាវ និងវាយតម្លៃដែនព្រៃលិចទឹកតំបន់ ៣ ជុំវិញបឹងទន្លេសាប គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តដាក់ឲ្យអនុវត្តនៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ២០២៣ របស់នាយកដ្ឋានធនធានធម្មជាតិ នៃអាជ្ញាធរទន្លេសាប ។

សកម្មភាពខាងលើនេះ មានគោលបំណង ដើម្បី៖

- បន្តតាមដាន និងវាយតម្លៃបង្គោលព្រំ សរុប ៨០២បង្គោល និងផ្ទៃដីព្រៃកំណត់ដែនព្រៃលិចទឹកតំបន់ ៣ ។
- តាមដាន និងវាយតម្លៃផ្ទៃដីកាត់ឆ្វៀល(ថ្មី)ក្នុងតំបន់ ២ និងតំបន់ ៣ ។
- ពិនិត្យ និងវាយតម្លៃបឋមលើស្ថានភាពរបស់ប្រជាពលរដ្ឋក្រោយពីកាត់ដីឆ្វៀលក្នុងតំបន់ ២ និងតំបន់៣ ។
- តាមដានលើការលូតលាស់ប្រភេទព្រៃលិចទឹក(ថ្មី)នៅតាមទីតាំងដែលបានដកហូតមកវិញក្រោយពីការទន្ទ្រាន និងដីទុកចោល ព្រមទាំងដីព្រៃដែលបានភ្លើងឆេះកន្លងមក។



កំពង់ឆ្នាំង៖ កាលពីថ្ងៃសុក្រ ៧ កើត ដល់ថ្ងៃសៅរ៍ ៨ កើត ខែជេស្ឋ ឆ្នាំថោះ ចត្វាស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី ២៦-២៧ ខែឧសភា ឆ្នាំ២០២៣ លោក វិន ប៊ុនពៅ ប្រធាននាយកដ្ឋាន បានដឹកនាំក្រុមការងារមន្ត្រីបច្ចេកទេស នាយកដ្ឋានធនធានធម្មជាតិ នៃ អាជ្ញាធរទន្លេសាប បន្តចុះសិក្សាស្រាវជ្រាវ និងវាយតម្លៃដែនព្រៃលិចទឹកតំបន់ ៣ ជុំវិញបឹងទន្លេសាប នៅក្នុងស្រុកកំពង់លែង និងស្រុកជលគិរី ខេត្តកំពង់ឆ្នាំង ។

ការសិក្សាមានគោលបំណង ៖

១. សិក្សាតាមដាន និងវាយតំលៃបង្គោលកំណត់ព្រំ និងផ្ទៃដីព្រៃកំណត់ដែនព្រៃលិចទឹកតំបន់ ៣ សរុប ៨០២បង្គោល ។

២. សិក្សាតាមដាន និងវាយតម្លៃផ្ទៃដីកាត់ឆ្វៀល(ថ្មី)ក្នុងតំបន់ ២ និងតំបន់ ៣ ។

៣. ពិនិត្យ និងវាយតម្លៃបឋមលើស្ថានភាពសេដ្ឋកិច្ច-សង្គម ក្រោយពីកាត់ដីឆ្វៀលក្នុងតំបន់១ តំបន់ ២ និងតំបន់៣ និង

៤. សិក្សាតាមដានលើការលូតលាស់ប្រភេទព្រៃលិចទឹកនៅតាមទីតាំងចុះសិក្សា និងដីដែលបានដកហូតមកវិញក្រោយពីការទន្ទ្រាន ។





កំពង់ធំ ៖ កាលពីថ្ងៃចន្ទ ០៤ រោច ដល់ថ្ងៃពុធ ០៦ រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី០៤-០៦ ខែកញ្ញា ឆ្នាំ២០២៣ លោក វិន ប៊ុនពៅ ប្រធាននាយកដ្ឋានធនធានធម្មជាតិ បានដឹកនាំក្រុមការងារមន្ត្រីនាយកដ្ឋានធនធានធម្មជាតិ នៃអាជ្ញាធរទន្លេសាប បន្តចុះសិក្សាស្រាវជ្រាវ និងវាយតម្លៃដែនព្រៃលិចទឹកតំបន់ ៣ ជុំវិញបឹងទន្លេសាប នៅក្នុងស្រុកកំពង់ស្វាយ និងក្រុងស្ទឹងសែន ខេត្តកំពង់ធំ ។

គោលបំណងនៃការសិក្សារួមមាន ៖

១. បន្តសិក្សាតាមដាន និងវាយតំលៃបង្គោលព្រំ និងផ្ទៃដីព្រៃកំណត់ដែនព្រៃលិចទឹកតំបន់ ៣ សរុប ៨០២បង្គោល (បន្ត)

២. សិក្សាតាមដាន និងវាយតម្លៃផ្ទៃដីកាត់ឆ្វៀល(ថ្មី)ក្នុងតំបន់ ២ និងតំបន់ ៣

៣. ពិនិត្យ និងវាយតម្លៃបឋមលើស្ថានភាពសេដ្ឋកិច្ច-សង្គម ក្រោយពីកាត់ដីឆ្វៀលក្នុងតំបន់ ២ និងតំបន់៣ និង

៤. សិក្សាតាមដានលើការលូតលាស់ប្រភេទព្រៃលិចទឹក(ថ្មី) នៅតាមទីតាំងដែលបានដកហូតមកវិញក្រោយពីការទន្ទ្រាន ។

លទ្ធផលសង្ខេបការចុះសិក្សារួមមាន៖

• ពិនិត្យឃើញបង្គោលព្រំដែលព្រៃលិចទឹកបន្តការដួរ និងខុសទីតាំង

• ស្ថានភាពស្រែក្នុងដែនព្រៃលិចទឹកនៅតែបន្តធ្វើជារបៀបស្បែកខ្លា

• ដីស្រែទុកចោលត្រូវបានដំណុះព្រៃលិចទឹក ស្មៅ និងវល្លិ៍ឡើងវិញ

• ស្ថានភាពបង្គោលព្រំកំណត់ដីស្រែឆ្វៀលត្រូវបានដួល និងមិនទាន់បានដាំគ្រប់ទីតាំងនៅឡើយ

• ផ្ទៃដីស្រែមួយចំនួនត្រូវបានភ្ជួរទុកចោល ដើម្បីពន្លិចទឹកក្នុងរដូវវស្សា (ដីទន្ទ្រាន និងដីឆ្វៀលថ្មី) ។





ពោធិ៍សាត់: ថ្ងៃចន្ទ ១៥កើត ដល់ថ្ងៃសុក្រ ៤ រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី០៦ ដល់ថ្ងៃទី ១០ ខែមីនា ឆ្នាំ២០២៣ លោក វិន ប៊ុនពៅ ប្រធាននាយកដ្ឋាន បានដឹកនាំក្រុមការងារមន្ត្រីនាយកដ្ឋានធនធានធម្មជាតិ នៃ អាជ្ញាធរទន្លេសាប បន្តចុះសិក្សាស្រាវជ្រាវ និងវាយតម្លៃដែន ព្រៃលិចទឹកតំបន់ ៣ ជុំវិញបឹងទន្លេសាប នៅក្នុងស្រុកកណ្តៀង ខេត្តពោធិ៍សាត់ ។

គោលបំណងនៃការសិក្សារួមមាន ៖

១. បន្តតាមដាន និងវាយតំលៃបង្គោលព្រំ និងផ្ទៃដីព្រៃកំណត់ ដែនព្រៃលិចទឹកតំបន់ ៣ សរុប ៨០២បង្គោល

២. តាមដាន និងវាយតម្លៃផ្ទៃដីកាត់ឆ្វៀល(ថ្មី)ក្នុងតំបន់ ២ និង តំបន់ ៣

៣. ពិនិត្យ និងវាយតម្លៃបឋមលើស្ថានភាពសេដ្ឋកិច្ច-សង្គម ក្រោយពីកាត់ដីឆ្វៀលក្នុងតំបន់ ២ និងតំបន់៣ និង

៤. តាមដានលើការលូតលាស់ប្រភេទព្រៃលិចទឹក(ថ្មី)នៅតាម ទីតាំងដែលបានដកហូតមកវិញក្រោយពីការទន្ទ្រាន ។



ថ្ងៃសៅរ៍ ៧កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០២៣ ឯកឧត្តមសាស្ត្រាចារ្យ លឹម ពុយ អនុប្រធានអាជ្ញាធរទន្លេសាប ព្រមទាំងថ្នាក់ដឹកនាំ និងក្រុមការងារមន្ត្រីបច្ចេកទេសនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប បានចុះសិក្សាស្រាវជ្រាវនៅគន្លងដាយលេខ ១៣ តាមដងទន្លេសាប ដើម្បីកំណត់អត្តសញ្ញាណ E-DNA លើប្រភេទត្រីនីមួយៗ ។

ជាលទ្ធផលក្រុមការងារបានរកឃើញប្រភេទត្រីមានចំនួន ៣២ ប្រភេទ ក្នុងចំណោមត្រីប្រមាណ ១៧១ ប្រភេទ ដែលមានក្នុងបញ្ជីសារពើភ័ណ្ឌរបស់អាជ្ញាធរទន្លេសាប និងបានស្រង់យកជាសំណាកដើម្បីទៅធ្វើការវិភាគនៅមន្ទីរពិសោធន៍នាប្រទេសបារាំង ។

សូមបញ្ជាក់ថា គម្រោងសិក្សា E-DNA លើប្រភេទត្រីនៃបឹងទន្លេសាប នឹងត្រូវសិក្សាស្រាវជ្រាវបន្តដើម្បីសម្រេចបានលើអត្តសញ្ញាណត្រីដែលមានក្នុងបញ្ជីសារពើភ័ណ្ឌអាជ្ញាធរទន្លេសាប ។











## សកម្មភាពសិក្សាវាយតម្លៃផលចាប់ធនធានត្រី នៅខេត្តកំពង់ឆ្នាំង




ចុះសិក្សាស្រាវជ្រាវសម្រេចបាននៅខេត្តកំពង់ឆ្នាំង ស្រុកបរិបូរណ៍ ស្រុកកំពង់លែង ក្រុងកំពង់ឆ្នាំង ស្រុកកំពង់ត្រឡាច ស្រុករលាប្អៀ និងស្រុកជលគិរីជាលទ្ធផល៖

-ចំនួនគ្រួសារចេញនេសាទចាប់ពី៖ ខែមករា ដល់ខែធ្នូ ២០២៣ មានចំនួន ៣៥,៤០១ គ្រួសារ

-ចំនួនឧបករណ៍ចេញនេសាទកមាន៖ ៣៦ ប្រភេទ

-បរិមាណផលចាប់សរុប៖ ១២,០៩៤.៤៦ តោន ក្នុងនឹងមានត្រីចំនួន ១៣១ ប្រភេទត្រី

-តម្លៃផលនេសាទសរុប៖ ៦៦,៥១៩.៥៣ លានរៀល ស្មើនឹង ១៦១,៨៤៨,០០៤.៨៧ ដុល្លាអាមេរិក (៤១០០៛/១$)

ចំណាំ៖ ដើម្បីមានទិន្នន័យពេញមួយឆ្នាំ បានធ្វើការប៉ាន់ប្រាណផលចាប់បន្ថែម ដោយមិនបានចុះសិក្សាមានខែតុលា០៣ ស្រុក (បរិបូរណ៍ កំពង់លែង ក្រុងកំពង់ឆ្នាំង) ខែវិច្ឆិកា០៣ស្រុក(កំពង់ត្រឡាច ជលគិរី រលាប្អៀ) និងខែធ្នូ ០៦ស្រុក (កំពង់ត្រឡាច ជលគីរី រលាប្អៀរ ក្រុងកំពង់ឆ្នាំង កំពង់លែង បរិបូរណ៍)។ ការប៉ាន់ប្រមាណនេះ មិនបានចុះសិក្សាផ្ទាល់ អាចបានជាលទ្ធផល ប្រហែល ៣០ ឬ ៤០% ប៉ុណ្ណោះដើម្បីបំពេញបន្ថែមឲ្យបានគ្រប់មួយឆ្នាំ។

## សកម្មភាពសិក្សាវាយតម្លៃធនធានជលផលលើអាជីវកម្មវារីវប្បកម្ម និងចរន្តទីផ្សារតាមច្រកចេញ-ចូលត្រី



នៅថ្ងៃចន្ទ ៤កើត ខែភទ្របទ ដល់ ថ្ងៃសុក្រ ៨កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី១៨ ដល់ ២២ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីនាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ដឹកនាំ ដោយ លោក លឹម វុទ្ធី អនុប្រធាននាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស បានចុះធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌឧបករណ៍ នេសាទនៅក្នុងតំបន់បឹងទន្លេសាបក្នុងភូមិសាស្ត្រខេត្តសៀមរាប។

ការចុះសិក្សានេះ ក្រុមការងារបានធ្វើលើ ៖

១. ជួបជាមួយអាជ្ញាធរដែនដី និងជំនាញ ជលផលដើម្បីពិភាក្សាស្វែងយល់អំពីឧបករណ៍នេសាទ

២. សម្ភាសន៍អ្នកនេសាទនៅតាមតំបន់សិក្សា ដើម្បីយកព័ត៌មានពីឧបករណ៍នេសាទ។

ជាមួយនឹងសកម្មភាពក្រុមការងារចុះសិក្សានៅតំបន់ពាក់ព័ន្ធខាងលើជាលទ្ធផលឃើញថា ៖

១. រកឃើញឧបករណ៍នេសាទសរុបចំនួន ១៦ ប្រភេទ ក្នុងនោះ៖ ឧបករណ៍នេសាទលក្ខណៈគ្រួសារមានចំនួន ០៩ ប្រភេទ និងឧបករណ៍នេសាទខុសច្បាប់មានចំនួន ០៧ ប្រភេទ

២. ឧបករណ៍នេសាទដែលបើប្រាស់ច្រើនជាងគេក្នុងខែកញ្ញានេះមានដូចជាសៃយឺន មងរាយ សំណាញ់ កន្ស៊ំ សន្ទូចរនង និងឧបករណ៍បរណរ៉ាវ

សូមជម្រាបជូនថា: សកម្មភាពចុះធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌឧបករណ៍នេសាទបឹងទន្លេសាបនៅក្នុងភូមិសាស្ត្រតំបន់បឹងទន្លេសាបក្នុងខេត្តសៀមរាប គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តដាក់ឱ្យអនុវត្ត នៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ២០២៣ របស់អាជ្ញាធរទន្លេសាប។

សកម្មភាពខាងលើនេះ មានគោលបំណង៖

-ពិពណ៌នា ស្វែងយល់ និងធ្វើបច្ចុប្បន្នភាពបញ្ជីសារពើភ័ណ្ឌឧបករណ៍ នេសាទក្នុងតំបន់ទន្លេសាប

-ធ្វើជាសៀវភៅរូបភាព (Catalogue) ឧបករណ៍នេសាទ ។

# សិក្សាកែច្នៃធនធានជលផល និងចរន្តអាជីវកម្មនៅខេត្តជុំវិញបឹងទន្លេសាប និងតំបន់ពាក់ព័ន្ធ



ខេត្តសៀមរាប ៖ កាលពីថ្ងៃចន្ទ ០៤ រោច ដល់ថ្ងៃពុធ ០៦ រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី០៤-០៦ ខែកញ្ញា ឆ្នាំ២០២៣ លោក អ៊ូ ទូច ប្រធានការិយាល័យត្រួតពិនិត្យការធ្វើអាជីវកម្មលើធនធានធម្មជាតិ និងក្រុមការងារបានបន្តចុះសិក្សាការធ្វើអាជីវកម្មកែច្នៃផលនេសាទនៅខេត្តសៀមរាប ។

គោលបំណងនៃការសិក្សា ៖ តាមដានបរិមាណត្រីស្រស់ ប្រភេទនៃការកែច្នៃ បច្ចេកទេសនៃការកែច្នៃតាមប្រភេទនីមួយៗ និងសិក្សាការវិវត្តន៍នៃទីផ្សារតាមតំបន់នីមួយៗ។

ជាលទ្ធផលសង្ខេបបឋមនៃការចុះសិក្សារួមមាន៖

- បានចុះសិក្សាចំនួន ០៤ ទីតាំង: ឃុំកំពង់ឃ្លាំង ឃុំកំពង់ភ្លុក សង្កាត់ចុងឃ្នៀស និងឃុំកែវពណ៌
- ស្ថិតិអ្នកកែច្នៃត្រី បរិមាណត្រីស្រស់ និងត្រីកែច្នៃរួច នៅរដូវបិទនេសាទមានចំនួនតិចជាងរដូវបើកនេសាទ
- ប្រភេទនៃការកែច្នៃមានចំនួន ០៦ ប្រភេទ គឺ ត្រីងៀត ប្រហុក ត្រីឆ្អើរ ត្រីហើម ផ្អក និងកំពិសក្រៀម
- បច្ចេកទេសនៃការកែច្នៃត្រីលក្ខណៈគ្រួសារនៅតែធ្វើតាមទម្លាប់ចាស់ដដែល ចំពោះការកែច្នៃត្រីជាលក្ខណៈសិប្បកម្មមានបច្ចេកទេសត្រឹមត្រូវតាមស្តង់ដារ
- ប្រភពត្រី: មកពីបឹងទន្លេសាប វារីវប្បកម្មក្នុងតំបន់ ប្រទេសថៃ និងប្រទេសវៀតណាម ។ ប្រភេទត្រីសំខាន់ៗមានដូចជា: ត្រីឆ្ដោរ ត្រីរ៉ស់ ត្រីកញ្ចុះ ត្រីច្រកែង ត្រីឆ្ពិន កំពិស ត្រីប្រា ត្រីពោ ត្រីរៀល ត្រីក្រុស ត្រីខ្នងវែង និងត្រីកំភ្លាញ
- ទីផ្សារក្នុងការបែងចែកផលិតផលកែច្នៃរួចនៅក្នុងខេត្តសៀមរាប គឺមានការបញ្ជាទិញពីម៉ូយ ដោយនាំចេញយកទៅលក់បន្តនៅទីក្រុងភ្នំពេញ ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងប្រទេសថៃ
- តម្លៃត្រីស្រស់ និងត្រីកែច្នៃរួចនៅរដូវបិទនេសាទមានតម្លៃថ្លៃជាងនៅរដូវបើកនេសាទ ។







នៅថ្ងៃអង្គារ ៤រោច ដល់ថ្ងៃសៅរ៍ ៨រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ៣ ដល់ថ្ងៃទី ៧ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីនាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ដឹកនាំដោយលោក អ៊ូ ទូច ប្រធានការិយាល័យត្រួតពិនិត្យការធ្វើអាជីវកម្មលើធនធានធម្មជាតិ បានបន្តចុះសិក្សាការកែច្នៃធនធានជលផល និងចរន្តអាជីវកម្ម ស្ថិតនៅក្នុងភូមិកំពង់ចិន ភូមិកំពង់ក្ដី ភូមិឈើទាល ភូមិលាបទង ឃុំកំពង់ចិនត្បូង, ភូមិត្រាច ឃុំកំពង់ចិនជើង ស្រុកស្ទោង និងភូមិកំពង់ក្របៅ សង្កាត់កំពង់ក្របៅ ក្រុងស្ទឹងសែន ខេត្តកំពង់ធំ។ ការចុះសិក្សានេះក្រុមការងារស្រាវជ្រាវបានធ្វើការជាមួយ៖

១. ជួបសម្ភាសន៍ជាមួយឈ្មួញកណ្ដាល (អ្នកទិញ-លក់ផលជលផលស្រស់)

២. ជួបសម្ភាសន៍ជាមួយអាជីវករ (លក់ដុំ និងលក់រាយ) និងអ្នកកែច្នៃត្រី (លក្ខណៈគ្រួសារ និងលក្ខណៈមធ្យម)

ជាមួយនឹងសកម្មភាពនេះផងដែរក្រុមការងារចុះសិក្សានៅតំបន់ពាក់ព័ន្ធខាងលើ ជាលទ្ធផលបឋមរកឃើញថា ៖

ទី១. ដឹងពីបរិមាណត្រីស្រស់ ប្រភេទនៃការកែច្នៃ បច្ចេកទេសនៃការកែច្នៃតាមប្រភេទនីមួយៗ ដឹងពីចរន្តអាជីវកម្ម និងការវិវត្តន៍នៃទីផ្សារ។ ស្ថិតិអ្នកកែច្នៃត្រីនៅតំបន់សិក្សាខាងលើ មានចំនួនប្រមាណ ៥៧ គ្រួសារ។

ទី២. ត្រីបានកែច្នៃជា ៦មុខ ដូចជា ត្រីងៀត ប្រហុក ត្រីឆ្អើរ ផ្អក ត្រីប្រម៉ា និងត្រីហើម ដោយបានប្រើប្រាស់បរិមាណត្រីស្រស់អស់ប្រមាណ ១៩.៩៥ គ.ក្រ/៥ថ្ងៃ។

ទី៣. ប្រភពត្រីសម្រាប់ផ្គត់ផ្គង់ការកែច្នៃត្រីគឺមានប្រភពមកពីប្រទេសវៀតណាម ប្រទេសថៃ ការធ្វើវារីវប្បកម្មក្នុងស្រុក និងត្រីបឹងទន្លេសាប។

ទី៤. ចំពោះការកែច្នៃត្រី មិនទាន់មានលក្ខណៈបច្ចេកទេសនៅឡើយទេ។

ទី៥. ផលប៉ះពាល់ដែលកើតមានលើកែច្នៃត្រី៖ ពឹងផ្អែកលើត្រីនាំចូលពីក្រៅប្រទេស តម្លៃត្រីស្រស់កើនថ្លៃ ត្រីបឹងទន្លេសាបមិនអាចបំពេញតម្រូវការកែច្នៃ ពិបាកទុកដាក់ផលិតផលសម្រេច និងពិបាកលក់ផលិតផលកែច្នៃសម្រេច។

សូមជម្រាបជូនថា៖ សកម្មភាពការកែច្នៃធនធានជលផល និងចរន្តអាជីវកម្មនៅខេត្តកំពង់ធំ គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តដាក់ឲ្យអនុវត្តនៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ២០២៣ របស់អាជ្ញាធរទន្លេសាប ។

សកម្មភាពសិក្សាខាងលើ គឺមានគោលបំណង៖

- តាមដានបរិមាណត្រីស្រស់ ប្រភេទនៃការកែច្នៃ និងបច្ចេកទេសនៃការកែច្នៃតាមប្រភេទនីមួយៗ
- សិក្សាការវិវត្តន៍នៃទីផ្សារតាមតំបន់នីមួយៗ។







នៅថ្ងៃចន្ទ ៤កើត ដល់ថ្ងៃសុក្រ ៨កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ១៨ ដល់ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីនាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ដឹកនាំដោយលោក អ៊ូ ទូច ប្រធានការិយាល័យត្រួតពិនិត្យការធ្វើអាជីវកម្មលើធនធានធម្មជាតិ បានបន្តចុះសិក្សាការកែច្នៃធនធានជលផល និងចរន្តអាជីវកម្ម នៅខេត្តបន្ទាយមានជ័យ។

ការចុះសិក្សានេះក្រុមការងារស្រាវជ្រាវបានជួបសម្ភាសន៍ជាមួយពាណិជ្ជករ អាជីវករ និងអ្នកកែច្នៃត្រី។

ជាមួយនឹងសកម្មភាពនេះផងដែរក្រុមការងារចុះសិក្សានៅតំបន់ពាក់ព័ន្ធខាងលើ ជាលទ្ធផលបឋមរកឃើញថា ៖

ទី១. នៅរដូវបិទនេសាទនេះខេត្តបន្ទាយមានជ័យមានការច្នៃត្រីងៀត និងត្រីហើម ដោយបានប្រើប្រាស់បរិមាណត្រីស្រស់អស់ប្រមាណ ១០២,៦០០ គ.ក្រ។ ចំពោះការច្នៃដទៃទៀតដូចជា ប្រហុក ផ្អក និងត្រីឆ្អើរ... ប្រជាជនតែងតែធ្វើការច្នៃចាប់ពីខែតុលា ដល់ខែកុម្ភៈ។

ទី២. ប្រភពត្រីសម្រាប់ផ្គត់ផ្គង់ការកែច្នៃ គឺមានប្រភពមកពីប្រទេសថៃ និងប្រទេសវៀតណាម ការធ្វើវារីវប្បកម្មក្នុងស្រុក (ត្រីរ៉ស់ ត្រីប្រា ត្រីពោរ ត្រីកន្ធរ) និងត្រីបឹងទន្លេសាប។

ទី៣. ចំពោះការកែច្នៃត្រីជាលក្ខណៈគ្រួសារមិនមានបច្ចេកទេសកែច្នៃត្រឹមត្រូវតាមស្រង់ដានោះទេ (លើផ្នែកអនាម័យ ដូចជាទីតាំងកែច្នៃ ទឹកប្រើប្រាស់ កន្លែងទុកដាក់ផលិតផលសម្រេច)។

ទី៤. ត្រីធម្មជាតិនៅបឹងទន្លេសាបមិនអាចបំពេញតម្រូវការបានទេ ពោលគឺពឹងផ្អែកលើត្រីនាំចូលពីក្រៅប្រទេស។

សូមជម្រាបជូនថា ៖ សកម្មភាពការកែច្នៃធនធានជលផល និងចរន្តអាជីវកម្មនៅខេត្តបន្ទាយមានជ័យ គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តដាក់ឲ្យអនុវត្តនៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ២០២៣ របស់អាជ្ញាធរទន្លេសាប ។

សកម្មភាពខាងលើនេះ មានគោលបំណង៖

- តាមដានបរិមាណត្រីស្រស់ ប្រភេទនៃការកែច្នៃ និងបច្ចេកទេសនៃការកែច្នៃតាមប្រភេទនីមួយៗ
- សិក្សាការវិវត្តន៍នៃទីផ្សារតាមតំបន់នីមួយៗ។







នៅថ្ងៃសុក្រ ៦កើត ដល់ថ្ងៃសៅរ៍ ៧កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី២០ ដល់ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីនាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ដឹកនាំដោយលោក អ៊ូ ទូច ប្រធានការិយាល័យត្រួតពិនិត្យការធ្វើអាជីវកម្មលើធនធានធម្មជាតិ បានបន្តចុះសិក្សាការកែច្នៃធនធានជលផល និងចរន្តអាជីវកម្ម នៅឃុំផ្លុកទ្រ, ឃុំកំពង់ហៅ, ឃុំពាមឆ្កោក និងសង្កាត់ផ្សារឆ្នាំង ខេត្តកំពង់ឆ្នាំង ។

ការចុះសិក្សានេះក្រុមការងារស្រាវជ្រាវបានធ្វើការជាមួយ៖

១. ជួបសម្ភាសន៍ជាមួយឈ្មួញកណ្តាល (អ្នកទិញ-លក់ផលជលផលស្រស់)

២. ជួបសម្ភាសជាមួយអាជីវករ (លក់ដុំ និងលក់រាយ) និងអ្នកកែច្នៃត្រី (លក្ខណៈគ្រួសារ និងលក្ខណៈមធ្យម)

៣. ដឹងពីបរិមាណត្រីស្រស់ ប្រភេទនៃការកែច្នៃ បច្ចេកទេសនៃការកែច្នៃតាមប្រភេទនីមួយៗ ដឹងពីចរន្តអាជីវកម្ម ការវិវត្តន៍ នៃទីផ្សារ និងស្ថានភាពទូទៅរបស់អ្នកកែច្នៃត្រី។

ជាមួយនឹងសកម្មភាពនេះផងដែរក្រុមការងារចុះសិក្សា និងទទួលបានជាលទ្ធផលបឋមដូចខាងក្រោម ៖

- ស្ថិតិអ្នកកែច្នៃត្រីនៅក្នុងខេត្តកំពង់ឆ្នាំង មានចំនួនប្រមាណ ៤០ គ្រួសារ

- មានការច្នៃត្រីចំនួន ៤ ប្រភេទ ដូចជា ត្រីឆ្អើរ ប្រហុក ត្រីងៀត និងត្រីប្រម៉ា ប្រើបរិមាណត្រីស្រស់អស់ប្រមាណ ៣៩.៥០០ គ.ក្រ និងបានបរិមាណត្រីកែច្នៃរួច ១៨.៨០១ គ.ក្រ។

- សម្រាប់បច្ចេកទេសក្នុងការកែច្នៃត្រីគឺមានលក្ខណៈបច្ចេកទេសបុរាណធ្វើតាមទំលាប់។

- ប្រភពត្រីមកពីបឹងទន្លេសាប ទន្លេសាប ដៃទន្លេ ស្ទឹង ព្រែក ការធ្វើវារីវប្បកម្ម ខេត្តពោធិ៍សាត់ ខេត្តកំពង់ចាម និងមួយផ្នែកទៀតនាំចូលពីប្រទេសវៀតណាម។

- គិតលើការចំណាយទិញត្រីស្រស់ ឈ្នួលកម្មករ ចង្កាក់ និងអុស អ្នកកែច្នៃត្រីឆ្អើរលេខ ១ អាចចំណេញបានចន្លោះពី ២០.០០០ ទៅ ៣៥.០០០ រៀល/គ.ក្រ (ប្រភេទត្រីកេស ក្លាំងហាយ និងត្រីក្រម៉ម) ត្រីឆ្អើរលេខ២ ចន្លោះពី ១៥.០០០ ទៅ ២០.០០០ រៀល/គ.ក្រ (ប្រភេទត្រីកេស ក្លាំងហាយ និងត្រីក្រម៉ម) និងត្រីឆ្អើរលេខ៣ ចន្លោះពី ១០.០០០ ទៅ ១៥.០០០ រៀល/គ.ក្រ (ត្រីរៀល)។ អ្នកកែច្នៃប្រហុក អាចចំណេញបានចន្លោះពី ៥០០ ទៅ ៧០០ រៀល/គ.ក្រ។ អ្នកកែច្នៃត្រីងៀតលេខ ១ អាចចំណេញបានចន្លោះពី ១០.០០០ ទៅ ១២.០០០ រៀល/គ.ក្រ ត្រីងៀតលេខ២ ចន្លោះពី ៥.០០០ ទៅ ៧.០០០ រៀល/គ.ក្រ។ អ្នកកែច្នៃត្រីប្រម៉ា អាចចំណេញបានចន្លោះពី ១០.០០០ ទៅ ១២.០០០ រៀល/គ.ក្រ ត្រីងៀតលេខ២ ចន្លោះពី ៦.០០០ ទៅ ១០.០០០ រៀល/គ.ក្រ។

- ស្ថានភាពនៃការកែច្នៃប្រហុក នៅដើមរដូវបើកនេសាទនេះ មានសកម្មភាពកែច្នៃដែលមានបរិមាណត្រីច្រើនជាងគេគឺឃុំផ្លុកទ្រ (ទីតាំងឡើងត្រី)។

- ទំហំត្រីយកមកធ្វើការកែច្នៃប្រហុកនៅមានទំហំតូចនៅឡើយ ប៉ុន្តែមានតម្លៃថ្លៃ ២.០០០រៀល/គ.ក្រ។

- ចំពោះទីផ្សារលក់ផលិតផលកែច្នៃរបស់អ្នកកែច្នៃ គ្មានការជួយជ្រោមជ្រែងពីស្ថាប័នជំនាញពាក់ព័ន្ធនោះទេ។

សូមជម្រាបជូនថា៖ សកម្មភាពការកែច្នៃធនធានជលផល និងចរន្តអាជីវកម្មនៅខេត្តកំពង់ឆ្នាំង គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តដាក់ឲ្យអនុវត្តនៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ២០២៣ របស់អាជ្ញាធរទន្លេសាប ។

សកម្មភាពខាងលើនេះ មានគោលបំណង៖

- តាមដានបរិមាណត្រីស្រស់ ប្រភេទនៃការកែច្នៃ និងបច្ចេកទេសនៃការកែច្នៃតាមប្រភេទនីមួយៗ

- សិក្សាការវិវត្តន៍នៃទីផ្សារតាមតំបន់នីមួយៗ។



# សិក្សាវាយតម្លៃធនធានជលផលលើអាជីវកម្មធនធានធម្មជាតិ វារីវប្បកម្ម និងចរន្តទីផ្សារតាមច្រកចេញចូលត្រីនៅខេត្ត-ទាំង ៦ ជុំវិញបឹងទន្លេសាប



នៅថ្ងៃសៅរ៍ ៨រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ០៧ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីបច្ចេកទេស នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ដឹកនាំដោយលោក ព្រហ្ម សុគំនិត អនុប្រធានការិយាល័យត្រួតពិនិត្យការធ្វើអាជីវកម្មលើធនធានធម្មជាតិ បានបន្តចុះសិក្សាការ អំពីការវាយតម្លៃលើការធ្វើអាជីវកម្មត្រី ត្រីនុយ វារីវប្បកម្ម និងចរន្តទីផ្សារច្រកចេញ-ចូល ស្ថិតនៅនៅភូមិកំពង់ចិន ឃុំកំពង់ចិនត្បូង ស្រុកស្ទោង និងភូមិកំពង់ក្របៅ សង្កាត់កំពង់ក្របៅ ខេត្តកំពង់ធំ។

ការចុះសិក្សានេះ ក្រុមការងារស្រាវជ្រាវ បានធ្វើការជាមួយ ៖

១. ជួបសម្ភាសន៍ជាមួយអាជ្ញាធរដែនដី និងវារីវប្បករ។

២. ជួបសម្ភាសន៍ជាមួយប្រជានេសាទ និងអាជីវករទិញ-លក់ត្រី។

៣. ដឹងពីបរិមាណ នៃការធ្វើអាជីវកម្ម និងតម្លៃត្រី។

ជាមួយនឹងសកម្មភាពនេះផងដែរក្រុមការងារចុះសិក្សានៅតំបន់ពាក់ព័ន្ធខាងលើ ជាលទ្ធផលឃើញថា ៖

ទី១. ការធ្វើអាជីវកម្មត្រីមានចំនួន ២ ទីតាំង បរិមាណត្រី ក្នុងមួយទីតាំងជាមធ្យម ៣០០ Kg/ថ្ងៃ និងត្រីនុយជាមធ្យម ២០០ Kg/ថ្ងៃ ។



ទី២. ការធ្វើអាជីវកម្មត្រី និងត្រីនុយ ប្រជានេសាទប្រើប្រាស់ឧបករណ៍នេសាទ មងរាយ បរ សម្រាស់ ទ្បើរ របាំងស្បៃមុង....។

ទី៣. តម្លៃត្រីសម្រាប់ហូបមានតម្លៃចន្លោះ ១៥.០០០-៥០.០០០ រៀល/គីឡូក្រោម និងតម្លៃត្រីនុយ ចន្លោះ ៨០០-១.៥០០ រៀល/គីឡូក្រាម ។ ត្រីសម្រាប់បរិភោគអាជីវករលក់ក្នុងតំបន់ និងមួយចំនួនទៀតលក់នៅផ្សារទីរួមខេត្ត ចំណែកត្រីនុយលក់អោយវារីវប្បករនៅក្នុងតំបន់។

ទី៤. ការធ្វើវារីវប្បកម្ម ភាគច្រើនចិញ្ចឹមត្រីក្នុង ស្រះ និងមានបន្តិចបន្តួចចិញ្ចឹមក្នុងបែរតាមស្ទឹង ។ ចំពោះប្រភេទត្រីចិញ្ចឹមភាគច្រើនគេនិយមចិញ្ចឹមត្រីឆ្ពោរ ត្រីរ៉ស់ ត្រីប្រា និងត្រីអណ្ដែង។

សូមជម្រាបជូនថា៖ សកម្មភាពចុះសិក្សាវាយតម្លៃលើការធ្វើអាជីវកម្មត្រី ត្រីនុយ វារីវប្បកម្ម និងចរន្តទីផ្សារច្រកចេញ-ចូល គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តដាក់ឲ្យអនុវត្តនៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ២០២៣ របស់អាជ្ញាធរទន្លេសាប។

សកម្មភាពខាងលើនេះ មានគោលបំណង៖

- សិក្សាតាមដានបរិមាណ នៃការធ្វើអាជីវកម្មធនធានធម្មជាតិ ត្រី និងត្រីនុយ។
- ប្រភព និងប្រភេទត្រីនុយដែលធ្វើអាជីវកម្មលើវារីវប្បកម្ម។
- ចរន្តទីផ្សារនៃការធ្វើអាជីវកម្មធនធានធម្មជាតិ។





នៅថ្ងៃអង្គារ ៩រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ២០២៣ក្រុមការងារមន្ត្រីនាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ដឹកនាំដោយលោក ព្រហ្ម សុគំនិត អនុប្រធានការិយាល័យត្រួតពិនិត្យការធ្វើអាជីវកម្មលើធនធានធម្មជាតិ បានបន្តចុះសិក្សាការ អំពី ការវាយតម្លៃលើការធ្វើអាជីវកម្មត្រី ត្រីនុយ វារីវប្បកម្ម និងចរន្តទីផ្សារច្រកចេញ-ចូល សស្ថិតនៅឃុំផ្លុកទ្រូ ស្រុកបរិបូរណ៍ និងសង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ។

ការចុះសិក្សានេះ ក្រុមការងារស្រាវជ្រាវ បានធ្វើការជាមួយ ៖

១. ជួបសម្ភាសជាមួយអាជ្ញាធរដែនដី និងវារីវប្បករ

២. ជួបសម្ភាសជាមួយប្រជានេសាទ និងអាជីវករទិញ-លក់ត្រី

៣. ដឹងពីបរិមាណនៃការធ្វើអាជីវកម្មត្រី ត្រីនុយ និងតម្លៃ។

ជាមួយនឹងសកម្មភាពនេះផងដែរក្រុមការងារចុះសិក្សានៅតំបន់ពាក់ព័ន្ធខាងលើ ជាលទ្ធផលឃើញថា ៖

ទី១. ការធ្វើអាជីវកម្មត្រីមានចំនួន ២ ច្រក (ច្រកផ្សារឆ្នាំង និង ផ្លុកទ្រូ) បរិមាណត្រីនៅច្រកផ្សារឆ្នាំងមានជាមធ្យមប្រមាណ



២តោន/ថ្ងៃ និងត្រីនុយជាមធ្យម ៣តោន/ថ្ងៃ និងច្រកផ្លុកទ្រូ ត្រីមានជាមធ្យមប្រមាណ ៤តោន/ថ្ងៃ និងត្រីនុយជាមធ្យម ៧តោន/ថ្ងៃ ។

ទី២. ការធ្វើអាជីវកម្មត្រី និងត្រីនុយ ប្រជានេសាទប្រើប្រាស់ឧបករណ៍នេសាទ មងរាយ បរ សម្រាស់ ឡើរ ផ្លុកអំពូល លប ម៉ាឡេ....។

ទី៣. តម្លៃត្រីសម្រាប់បរិភោគមានតម្លៃ

- ត្រីលេខ១ចន្លោះពី : ១២.០០០-៤០.០០០ រៀល/គីឡូក្រាម
- ត្រីលេខ២ : ៦.០០០-១០.០០០ រៀល/គីឡូក្រាម
- ត្រីលេខ៣ : ៣.០០០-៥.០០០ រៀល/គីឡូក្រាម
- តម្លៃត្រីនុយ ចន្លោះពី: ១.០០០-១.២០០ រៀល/គីឡូក្រាម ។

ទី៤. ត្រីសម្រាប់បរិភោគអាជីវករលក់ក្នុងតំបន់ និងមួយចំនួនទៀតលក់នៅផ្សារទីរួមខេត្ត និងតាមយៀវត្រីនៅរាជធានីភ្នំពេញ ចំណែកត្រីនុយលក់អោយវារីវប្បករនៅក្នុងតំបន់។

ទី៥. ការធ្វើវារីវប្បកម្ម មានពីរប្រភេទ ចិញ្ចឹមក្នុងស្រះ និងចិញ្ចឹមក្នុងបែរ។ ត្រីនុយត្រូវបានយកធ្វើជាចំណីសម្រាប់ការចិញ្ចឹម។

សូមជម្រាបជូនថា ៖ សកម្មភាពចុះសិក្សាវាយតម្លៃលើការធ្វើអាជីវកម្មត្រី ត្រីនុយ វារីវប្បកម្ម និងចរន្តទីផ្សារច្រកចេញ-ចូល គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តដាក់ឲ្យអនុវត្តនៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ២០២៣ របស់អាជ្ញាធរទន្លេសាប។

សកម្មភាពខាងលើនេះ មានគោលបំណង៖

- សិក្សាតាមដានបរិមាណនៃការធ្វើអាជីវកម្មត្រី និងត្រីនុយ
- ប្រភព និងប្រភេទត្រីនុយដែលធ្វើអាជីវកម្មលើវារីវប្បកម្ម
- ចរន្តទីផ្សារនៃការធ្វើអាជីវកម្មធនធានធម្មជាតិ។



នៅថ្ងៃពុធ ១៣រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមន្រ្តីនាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ដឹកនាំដោយ លោក ព្រហ្ម សុគំនិត អនុប្រធានការិយាល័យត្រួតពិនិត្យការធ្វើអាជីវកម្មលើធនធានធម្មជាតិ បានបន្តចុះសិក្សាវាយតម្លៃលើការធ្វើអាជីវកម្មត្រី ត្រីនុយ វារីវប្បកម្ម និងចរន្តទីផ្សារច្រកចេញ-ចូល ស្ថិតនៅក្នុងឃុំកំពង់ស្វាយ ក្រុងសេរីសោភ័ណ្ឌ ឃុំភ្នំលាប ស្រុកព្រះនេត្រព្រះ និងឃុំសំបួរ ស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ។



ការចុះសិក្សានេះ ក្រុមការងារស្រាវជ្រាវបានធ្វើការជាមួយ ៖

១. ជួបសម្ភាសន៍ជាមួយអាជ្ញាធរដែនដី និងវារីវប្បករ។

២. ជួបសម្ភាសន៍ជាមួយប្រជានេសាទ និងអាជីវករទិញ-លក់ត្រី។

៣. ដឹងពីបរិមាណនៃការធ្វើអាជីវកម្ម និងតម្លៃត្រី

ជាមួយនឹងសកម្មភាពនេះផងដែរក្រុមការងារចុះសិក្សានៅតំបន់



ពាក់ព័ន្ធខាងលើ ជាលទ្ធផលឃើញថា ៖

ទី១. ការធ្វើអាជីវកម្មត្រីមានចំនួន ៣ ច្រក (ច្រករបៀង) បរិមាណត្រីមានការថយចុះជាងរដូវបើកនេសាទ។

ទី២. ការធ្វើអាជីវកម្មត្រី និងត្រីនុយ ប្រជានេសាទប្រើប្រាស់ឧបករណ៍នេសាទ មងរាយ បរ សម្រាស់ ឡើរ របាំងស្បៃមុង....។

ទី៣. តម្លៃត្រី និងត្រីនុយ មានតម្លៃថ្លៃជាងមុន ព្រោះបរិមាណផលចាប់មានការថយចុះ។

ទី៤. ការធ្វើវារីវប្បកម្មនៅខេត្តបន្ទាយមានជ័យភាគច្រើនចិញ្ចឹមត្រីក្នុង ស្រះ និងមានបន្តិចបន្តួចចិញ្ចឹមក្នុងបែរតាមបណ្ដោយស្ទឹង។

ទី៥. ការធ្វើអាជីវកម្មលើប្រភេទត្រីនុយមានមានផលវិជ្ជមាន (បំពេញតម្រូវការវារីវប្បកម្មក្នុងស្រុក) ផលអវិជ្ជមាន (ធ្វើឱ្យធនធានត្រីថយចុះ និងបាត់បង់ប្រភេទត្រីសាច់សម្រាប់បរិភោគ)។

សូមជម្រាបជូនថា ៖ សកម្មភាពចុះសិក្សាវាយតម្លៃលើការធ្វើអាជីវកម្មត្រី ត្រីនុយ វារីវប្បកម្ម និងចរន្តទីផ្សារច្រកចេញ-ចូល គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តដាក់ឲ្យអនុវត្តនៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ២០២៣ របស់អាជ្ញាធរទន្លេសាប ។

សកម្មភាពខាងលើនេះ មានគោលបំណង៖

- សិក្សាតាមដានបរិមាណនៃការធ្វើអាជីវកម្មធនធានធម្មជាតិ ត្រី និងត្រីនុយ។
- ប្រភព និងប្រភេទត្រីនុយដែលធ្វើអាជីវកម្មលើវារីវប្បកម្ម។
- ចរន្តទីផ្សារនៃការធ្វើអាជីវកម្មធនធានធម្មជាតិ។



នៅថ្ងៃអង្គារ ៣កើត ដល់ថ្ងៃសៅរ៍ ៧កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ១៧ ដល់ថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីនាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ដឹកនាំដោយលោក ព្រហ្ម សុគំនិត អនុប្រធានការិយាល័យ បានបន្តចុះសិក្សាការ អំពី ការវាយតម្លៃលើការធ្វើអាជីវកម្មត្រី ត្រីនុយ វារីវប្បកម្ម និងចរន្តទីផ្សារច្រកចេញ-ចូល ស្ថិតនៅឃុំកំពង់លួង ស្រុកក្រគរ និងឃុំកញ្ជរ ស្រុកកណ្ដៀង ខេត្តពោធិ៍សាត់។



ការចុះសិក្សានេះ ក្រុមការងារស្រាវជ្រាវបានធ្វើការជាមួយ ៖

១. ជួបសម្ភាសជាមួយអាជ្ញាធរដែនដី និងវារីវប្បករ។

២. ជួបសម្ភាសជាមួយប្រជានេសាទ និងអាជីវករទិញ-លក់ត្រី។

៣. ដឹងពីបរិមាណនៃការធ្វើអាជីវកម្ម និងតម្លៃត្រី។

ជាមួយនឹងសកម្មភាពនេះផងដែរក្រុមការងារចុះសិក្សានៅតំបន់ពាក់ព័ន្ធខាងលើ ជាលទ្ធផលឃើញថា ៖

ទី១. ការធ្វើអាជីវកម្មត្រីមានចំនួន ២ ទីតាំង បរិមាណត្រី ក្នុងមួយទីតាំងជាមធ្យមប្រមាណ ២.៥តោន/ថ្ងៃ និងត្រីនុយជាមធ្យម ៣.៥តោន/ថ្ងៃ ។



ទី២. ការធ្វើអាជីវកម្មត្រី និងត្រីនុយ ប្រជានេសាទប្រើប្រាស់ឧបករណ៍នេសាទ មងរាយ បរ សម្រាស់ ទ្បើរ របាំងស្បៃមុង....។

ទី៣. តម្លៃត្រីសម្រាប់បរិភោគមានតម្លៃចន្លោះពី ១០.០០០-៥០.០០០រៀល/គីឡូក្រាម និងតម្លៃត្រីនុយ ចន្លោះពី ១.៣០០-២.០០០ រៀល/គីឡូក្រាម។ ត្រីសម្រាប់បរិភោគអាជីវករលក់ក្នុងតំបន់ និងមួយចំនួនទៀតលក់នៅផ្សារទីរួមខេត្ត និងតាមយឿត្រីនៅរាជធានីភ្នំពេញ ចំណែកត្រីនុយលក់អោយវារីវប្បករនៅក្នុងតំបន់។

ទី៤. ការធ្វើវារីវប្បកម្ម មានពីរប្រភេទ ចិញ្ចឹមក្នុងស្រះ និងចិញ្ចឹមក្នុងបែរ។ ប្រភេទត្រីចិញ្ចឹមក្នុងស្រះ មានប្រភេទត្រីឆ្ដោរ ត្រីប្រាត្រីពោ បរិមាណចិញ្ចឹមចាប់ពី ១០.០០០ ទៅ ៣០.០០០ ក្បាល/ស្រះ និងចិញ្ចឹមតាមបែរ មានប្រភេទ ត្រីរ៉ស់ និងត្រីអណ្ដែង បរិមាណចិញ្ចឹមចាប់ពី ១.០០០ ទៅ ៥.០០០ ក្បាល/បែរ។

សូមជម្រាបជូនថា៖ សកម្មភាពចុះសិក្សាវាយតម្លៃលើការធ្វើអាជីវកម្មត្រី ត្រីនុយ វារីវប្បកម្ម និងចរន្តទីផ្សារច្រកចេញ-ចូល គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើនដែលត្រូវបានអនុម័តដាក់ឲ្យអនុវត្តនៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ២០២៣ របស់អាជ្ញាធរទន្លេសាប ។

សកម្មភាពខាងលើនេះ មានគោលបំណង៖

- សិក្សាតាមដានបរិមាណ នៃការធ្វើអាជីវកម្មធនធានធម្មជាតិត្រី និងត្រីនុយ។
- ប្រភព និងប្រភេទត្រីនុយដែលធ្វើអាជីវកម្មលើវារីវប្បកម្ម។
- ចរន្តទីផ្សារ នៃការធ្វើអាជីវកម្មធនធានធម្មជាតិ។





នៅថ្ងៃព្រហស្បតិ៍ ១៤កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីនាយកដ្ឋានត្រួត ពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ដឹកនាំដោយលោក ព្រហ្ម សុគំនិត អនុប្រធានការិយាល័យត្រួតពិនិត្យការធ្វើអាជីវកម្មលើធនធានធម្មជាតិ បានបន្តចុះសិក្សាការអំពីការវាយតម្លៃលើការធ្វើអាជីវកម្មត្រី ត្រីនុយ វារីវប្បកម្ម និងចរន្តទីផ្សារច្រកចេញ-ចូល ស្ថិតនៅភូមិសាស្ត្រឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគមន ឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង សង្កាត់ចុងឃ្នៀស ក្រុងសៀមរាប និងឃុំកែវពណ៌ ស្រុកពួក ខេត្តសៀមរាប។

ការចុះសិក្សានេះ ក្រុមការងារស្រាវជ្រាវ បានធ្វើការជាមួយ ៖

១. ជួបសម្ភាសន៍ជាមួយអាជ្ញាធរដែនដី និងវារីវប្បករ។

២. ជួបសម្ភាសន៍ជាមួយប្រជានេសាទ និងអាជីវករទិញ-លក់ត្រី ដើម្បីដឹងពីបរិមាណនៃការធ្វើអាជីវកម្ម និងតម្លៃត្រី។

ជាមួយនឹងសកម្មភាពនេះផងដែរក្រុមការងារចុះសិក្សានៅតំបន់ពាក់ព័ន្ធខាងលើ ជាលទ្ធផលឃើញថា ៖

ទី១. ការធ្វើអាជីវកម្មត្រីមានចំនួន ៤ ច្រក បរិមាណត្រីក្នុងមួយ



ច្រកជាមធ្យម ១.០០០ គីឡូក្រាម/ថ្ងៃ និងត្រីនុយជាមធ្យម ៥០០ គីឡូក្រាម/ថ្ងៃ បរិមាណនេះមានការថយចុះជាងរដូវបើកនេសាទ។

ទី២. ការធ្វើអាជីវកម្មត្រី និងត្រីនុយប្រជានេសាទប្រើប្រាស់ឧបករណ៍នេសាទ មងរាយ បរ សម្រាស់ ឡើររបាំងស្បៃមុង...។

ទី៣. តម្លៃត្រីសម្រាប់ហូបមានតម្លៃចន្លោះ ៥.០០០- ៤.៥០០ រៀល/គីឡូក្រាម តម្លៃនេះថ្លៃជាងឆ្នាំមុនៗ និងតម្លៃត្រីនុយចន្លោះ ១.០០០-២.៥០០ រៀល/គីឡូក្រាម ។ ត្រីសម្រាប់ហូបអាជីវករលក់ក្នុងតំបន់ និងមួយចំនួនទៀតលក់នៅផ្សារទីរួមខេត្ត ចំណែកត្រីនុយលក់អោយវារីវប្បករនៅក្នុងតំបន់។

ទី៤. ការធ្វើវារីវប្បកម្មនៅខេត្តសៀមរាប ភាគច្រើនចិញ្ចឹមត្រីក្នុងស្រះ និងមានបន្តិចបន្តួចចិញ្ចឹមក្នុងបែរ បច្ចុប្បន្នរដូវទឹកឡើងស្រះមួយចំនួនត្រូវបានលិច តែវារីវប្បករបាំងរបាំងព្រួលបន្ថែមការពារកុំអោយត្រីចេញ។

ទី៥. ការធ្វើអាជីវកម្មលើប្រភេទត្រីនុយមានមានផលវិជ្ជមាន (បំពេញតម្រូវការវារីវប្បកម្មក្នុងស្រុក) ផលអវិជ្ជមាន(ធ្វើឱ្យធនធានត្រីថយចុះ និងបាត់បង់ប្រភេទត្រីសាច់សម្រាប់ហូប)។

សូមជម្រាបជូនថា៖ សកម្មភាពចុះសិក្សាវាយតម្លៃលើការធ្វើអាជីវកម្មត្រី ត្រីនុយ វារីវប្បកម្ម និងចរន្តទីផ្សារច្រកចេញ-ចូល គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តដាក់ឲ្យអនុវត្តនៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ២០២៣ របស់អាជ្ញាធរទន្លេសាប ។

សកម្មភាពខាងលើនេះ មានគោលបំណង៖

- សិក្សាតាមដានបរិមាណនៃការធ្វើអាជីវកម្មធនធានធម្មជាតិ ត្រី និងត្រីនុយ។
- ប្រភព និងប្រភេទត្រីនុយដែលធ្វើអាជីវកម្មលើវារីវប្បកម្ម។
- ចរន្តទីផ្សារនៃការធ្វើអាជីវកម្មធនធានធម្មជាតិ។



នៅថ្ងៃអង្គារ ៩ រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងាររបស់នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ដឹកនាំដោយលោក អ៊ូ ទូច បានបន្តចុះសិក្សាស្រាវជ្រាវការធ្វើអាជីវកម្ម សិប្បីសត្វ និងឧរង្គសត្វ នៅឃុំកំពង់ឃ្លាំង ស្រុកសូទ្រនិគម, ឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង, ឃុំកែវពណ៌ ស្រុកពួក និងសង្កាត់ចុងឃ្នៀស ក្រុងសៀមរាប ។





ការចុះសិក្សានេះ ក្រុមការងារស្រាវជ្រាវបាន៖

១. បានជួបសម្ភាសជាមួយអាជ្ញាធរដែនដី ដើម្បីស្វែងយល់ពីស្ថានភាពលើការធ្វើអាជីវកម្មលៀស ខ្ចៅ ខ្យង និងពស់ អណ្ដើក។

២. ជួបសម្ភាសជាមួយអ្នកនេសាទ និងអាជីវករលើការធ្វើអាជីវកម្ម លើប្រភេទ លៀស ខ្ចៅ ខ្យង ពស់ និងអណ្ដើក។

៣. ការចុះពិនិត្យ កត់ត្រាទម្ងន់ តម្លៃ នៅតាមទីតាំងអាជីវកម្មនីមួយៗ។

ជាមួយនឹងសកម្មភាពនេះផងដែរក្រុមការងារបានចុះសិក្សាលើការធ្វើអាជីវកម្ម សិប្បីសត្វ និងឧរង្គសត្វ ជាលទ្ធផលឃើញថា ៖

១. ការធ្វើអាជីវកម្មមានចំនួន ៤ ទីតាំង



-លៀស ខ្ចៅ ខ្យង មានប្រមាណ ១-២តោន/ថ្ងៃ

-ពស់ និងអណ្ដើក មានប្រមាណ ៦០-៨០ គីឡូក្រាម/ថ្ងៃ។

២. អាជីវកម្ម លៀស ខ្ចៅ ខ្យង ពស់ និងអណ្ដើកមានបរិមាណថយចុះនៅក្នុងរដូវបើកនេសាទ

-តម្លៃលៀសសម្រាប់ហូប ១.០០០-១.៥០០រៀល/គីឡូក្រាម លៀសចំណីសត្វ ៥០០-៨០០រៀល/គីឡូក្រាម

-តម្លៃខ្ចៅដូង ២.៥០០-៣.០០០រៀល/គីឡូក្រាម

-តម្លៃខ្យង ៤.៥០០-៥.០០០រៀល/គីឡូក្រាម

-តម្លៃពស់ ១.២០០០-៤០.០០០ រៀល/គីឡូក្រាម

-តម្លៃអណ្ដើក ៤.០០០០-៥០.០០០ រៀល/គីឡូក្រាម។

៣. ការធ្វើអាជីវកម្មលៀស ខ្ចៅ ខ្យង ពស់ និងអណ្ដើក គឺឈ្មួញលក់ក្នុងខេត្តផ្ទាល់ និងមួយ និងនាំចេញទៅប្រទេសថៃ និងប្រទេសវៀតណាម។

សូមជម្រាបជូនថា៖ សកម្មភាពចុះសិក្សាស្រាវជ្រាវការធ្វើអាជីវកម្មសិប្បីសត្វ និងឧរង្គសត្វ គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តដាក់ឲ្យអនុវត្តនៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ២០២៣ របស់អាជ្ញាធរទន្លេសាប ។

សកម្មភាពខាងលើនេះ មានគោលបំណង៖

- សិក្សាតាមដានបរិមាណនៃការធ្វើអាជីវកម្ម លៀស ខ្ចៅ ខ្យង ពស់ និងអណ្ដើក

- សិក្សាចរន្តទីផ្សារនៃការធ្វើអាជីវកម្មលៀស ខ្ចៅ ខ្យង ពស់ និងអណ្ដើក

- សិក្សាពីផលប៉ះពាល់នៃការធ្វើអាជីវកម្ម លៀស ខ្ចៅ ខ្យង និងពស់ អណ្ដើក។





នៅថ្ងៃព្រហស្បតិ៍ ១៤រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ១៤ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីនាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ដឹកនាំដោយលោក ហេង សុវណ្ណារ៉ា ប្រធាននាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស បានបន្តចុះសិក្សាស្រាវជ្រាវការធ្វើអាជីវកម្ម សិប្បីសត្វ និងឧរង្គសត្វ ក្នុងខេត្តពោធិ៍សាត់៖ ឃុំកំពង់លួង ស្រុកក្រគរ ឃុំអន្លង់ត្នោត ស្រុកក្រគរ និងឃុំរាំងទិល ស្រុកកណ្ដៀង។ ១/. បានជួបសម្ភាសន៍ជាមួយអាជ្ញាធរដែនដីដើម្បីស្វែងយល់ពីស្ថានភាពលើការធ្វើអាជីវកម្មលៀស ខ្ចៅ ខ្យង និងពស់ អណ្ដើក។ ២/. ជួបសម្ភាសន៍ជាមួយអ្នកនេសាទ និងអាជីវករធ្វើអាជីវកម្មលើប្រភេទ លៀស ខ្ចៅ ខ្យង និងពស់ អណ្ដើក។ ៣/. ចុះពិនិត្យ និងកត់ត្រាទម្ងន់ តម្លៃ នៅតាមស្តង់អាជីវកម្មនីមួយៗ។

ជាមួយនឹងសកម្មភាពនេះផងដែរក្រុមការងារមន្ត្រីចុះសិក្សាលើការធ្វើអាជីវកម្ម សិប្បីសត្វ និងឧរង្គសត្វ ជាលទ្ធផលឃើញថា៖

ទី១/. ការធ្វើអាជីវកម្មលៀស ខ្ចៅ ខ្យង និងពស់ អណ្ដើក មានចំនួន ៣ទីតាំងគឺឃុំ កំពង់លួង ឃុំរាំងទិល និងឃុំអន្លង់ត្នោត



ទី២/.អាជីវកម្ម លៀស ខ្ចៅ ខ្យង និងពស់ អណ្ដើកមានបរិមាណថយចុះ និងតម្លៃថ្លៃ ធៀបទៅនឹងឆ្នាំមុន ក្នុងរដូវបិទនេសាទ។

ទី៣/.អាជីវកម្មប្រភេទលៀសចំណីសត្វមានការថយចុះច្រើន ដោយសារមានការទប់ស្កាត់ និងហាមឃាត់ពីអាជ្ញាធរ និងសមត្ថកិច្ចជំនាញ

ទី៤/. ការធ្វើអាជីវកម្មលៀស ខ្ចៅ ខ្យងនិងពស់ អណ្ដើក គឺឈ្មួញលក់ក្នុងខេត្តផ្ទាល់ និងមួយផ្នែកធំត្រូវបានប្រមូលទិញនាំចេញទៅប្រទេសវៀតណាម។

ទី៥/.ការធ្វើអាជីវកម្មលៀស ខ្ចៅ ខ្យង និងពស់ អណ្ដើក មានផលវិជ្ជមាន(ជួយបំពេញតម្រូវការបរិភោគខ្ពស់ និងតម្រូវការខាងផ្នែកកែច្នៃចំណីសត្វ) ផលអវិជ្ជមាន(ការរកនេសាទហួសកំរិតធ្វើអោយប្រភេទសិប្បីសត្វខ្នាតធំមិនសូវសំបូរ និងបាត់បង់ប្រភេទឧរង្គសត្វដែលកម្រ និងងាយរងគ្រោះក្នុងបឹងទន្លេសាប។

សូមជម្រាបជូនថា៖ សកម្មភាពចុះសិក្សាស្រាវជ្រាវការធ្វើអាជីវកម្ម សិប្បីសត្វ និងឧរង្គសត្វ នៅខេត្តពោធិ៍សាត់ គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តដាក់ឲ្យអនុវត្តនៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ ២០២៣ របស់អាជ្ញាធរទន្លេសាប ។ សកម្មភាពខាងលើនេះ មានគោលបំណង៖ ១/.សិក្សាតាមដានបរិមាណនៃការធ្វើអាជីវកម្ម លៀស ខ្ចៅ ខ្យង និងពស់ អណ្ដើក ២/.សិក្សាចរន្តទីផ្សារនៃការធ្វើអាជីវកម្ម លៀស ខ្ចៅ ខ្យង និងពស់ អណ្ដើក ៣/. សិក្សាពីផលប៉ះពាល់នៃការធ្វើអាជីវកម្ម លៀស ខ្ចៅ ខ្យង និងពស់ អណ្ដើក។



នៅថ្ងៃសុក្រ ៦កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ២០ខែតុលា ឆ្នាំ២០២៣ ក្រុមការងាររបស់នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ដឹកនាំដោយលោក ជួង សុវណ្ណគីរី អនុប្រធានការិយាល័យ បានបន្តចុះសិក្សាស្រាវជ្រាវការធ្វើអាជីវកម្ម សិប្បីសត្វ និងឧរង្គសត្វ នៅឃុំព្រែកនរិន្ទ និងឃុំកោះជីវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។



ការសិក្សានេះ ក្រុមការងារបាន ៖

១. ជួបសម្ភាសន៍ជាមួយអាជ្ញាធរដែនដី

២. ជួបសម្ភាសន៍ជាមួយអ្នកនេសាទ និងអាជីវករលើការធ្វើអាជីវកម្មលើសិប្បីសត្វ និងឧរង្គសត្វ លើប្រភេទ លៀស ខ្ចៅ ខ្យង ពស់ និងអណ្ដើក

៣. ការតាមដាន ពិនិត្យ វាស់ប្រវែង កត់ត្រាទម្ងន់ តម្លៃ នៅតាមទីតាំងអាជីវកម្មនីមួយៗ។

ជាមួយនឹងសកម្មភាពនេះផងដែរក្រុមការងារ បានបន្តចុះសិក្សាលើការធ្វើអាជីវកម្ម សិប្បីសត្វ និងឧរង្គសត្វ ជាលទ្ធផលឃើញថា ៖

ទី១. ការធ្វើអាជីវកម្មលៀស ខ្ចៅ ខ្យង ពស់ និងអណ្ដើក មានចំនួន ៤ទីតាំង ស្ថិតក្នុងឃុំកោះជីវាំង ឈ្មួញប្រមូលទិញ និងនាំយកទៅលក់បន្តនៅច្រកមេជ្រៃ និងច្រកចុងឃ្នៀស ខេត្តសៀមរាប ។

ទី២. បរិមាណការធ្វើអាជីវកម្ម លៀស ខ្ចៅ ខ្យង ពស់ និង



អណ្ដើក បានថយចុះ តែតម្លៃថ្លៃ បើធៀបទៅនឹងឆ្នាំមុន នៅក្នុងរដូវបើកនេសាទដូចគ្នា។

ទី៣. គ្មានសកម្មភាពធ្វើអាជីវកម្មលៀសសម្រាប់ចំណីសត្វ នៅក្នុងតំបន់ឃុំព្រែកនរិន្ទ និងឃុំកោះជីវាំង។

ទី៤. ការធ្វើអាជីវកម្មលៀស ខ្ចៅ ខ្យង ពស់ និងអណ្ដើក គឺឈ្មួញនាំចេញទៅលក់ក្នុងខេត្តបាត់ដំបង និងមួយផ្នែកធំនាំចេញទៅខេត្តសៀមរាប និងនាំចេញតាមច្រកប៉ោយប៉ែតទៅប្រទេសថៃ។

ទី៥. ការធ្វើអាជីវកម្មលៀស ខ្ចៅ ខ្យង ពស់ និងអណ្ដើក មានផលវិជ្ជមាន(ជួយបំពេញតម្រូវការបរិភោគ និងតម្រូវការខាងផ្នែកកែច្នៃចំណីសត្វ) តែផលអវិជ្ជមាន(ការនេសាទហួសកម្រិតធ្វើអោយប្រភេទសិប្បីសត្វខ្នាតធំមិនសូវសំបូរ និងបាត់បង់ប្រភេទឧរង្គសត្វដែលកម្រ និងងាយរងគ្រោះ ក្នុងបឹងទន្លេសាប។

សូមជម្រាបជូនថា៖ សកម្មភាពសិក្សាស្រាវជ្រាវការធ្វើអាជីវកម្មសិប្បីសត្វ និងឧរង្គសត្វ នៅខេត្តបាត់ដំបង គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តដាក់ឲ្យអនុវត្តនៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ២០២៣ របស់អាជ្ញាធរទន្លេសាប ។

សកម្មភាពសិក្សាខាងលើនេះ ក្នុងគោលបំណង ៖

- តាមដានបរិមាណការធ្វើអាជីវកម្ម លៀស ខ្ចៅ ខ្យង ពស់ និងអណ្ដើក ។
- ចរន្តទីផ្សារនៃការធ្វើអាជីវកម្មលៀស ខ្ចៅ ខ្យង ពស់ និងអណ្ដើក
- ផលប៉ះពាល់នៃការធ្វើអាជីវកម្ម លៀស ខ្ចៅ ខ្យង និងពស់ អណ្ដើក។





នៅថ្ងៃអង្គារ ៥រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីនាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ដឹកនាំដោយ លោក សោម សំបូរ អនុប្រធានការិយាល័យអភិរក្ស បានបន្តចុះសិក្សាស្រាវជ្រាវអំពីសក្ដានុពលនិងប្រសិទ្ធភាពក្នុងការគ្រប់គ្រងតំបន់អភិរក្សជលផលអតីតឡូត៍នេសាទលេខ៤ ខេត្តសៀមរាប ស្ថិតនៅក្នុងសង្កាត់ចុងឃ្នៀស ក្រុងសៀមរាប។

ការចុះសិក្សានេះ ក្រុមការងារបាន ៖ ទី ១/. ជួបជាមួយអាជ្ញាធរដែនដី និងមន្ត្រីជំនាញជលផល ដោយធ្វើការពិភាក្សាស្វែងយល់អំពីបញ្ហាប្រឈមក្នុងការគ្រប់គ្រង ការសហការ ការចូលរួមរបស់អ្នកពាក់ព័ន្ធទៅលើកិច្ចការងារអភិរក្ស។ ទី ២/. ជួបសម្ភាសន៍ជាមួយប្រជានេសាទ អំពីព័ត៌មានទូទៅពាក់ព័ន្ធនឹងការធ្វើនេសាទ ស្ថានភាពគ្រួសារ និងស្ថានភាពទូទៅធនធានជលផលក្នុងតំបន់។

ជាមួយនឹងសកម្មភាពក្រុមការងារចុះសិក្សានៅតំបន់ពាក់ព័ន្ធខាងលើ ជាលទ្ធផលឃើញថា ៖

ទី១/. ស្ថានភាពទូទៅនៃតំបន់អភិរក្សនេះ មានផ្ទៃដីទំហំ ៩៨៦ហិកតា បានបោះបង្គោលព្រំប្រទល់ទីតាំងកន្លែងអភិរក្ស



ចំនួន ១៤ បង្គោល។ នៅរដូវប្រាំងកម្ពស់ទឹកជាមធ្យម ១ម៉ែត្រ ទៅ ១,៥ម៉ែត្រ កម្ពស់ទឹកនៅរដូវវស្សាគិតត្រឹមថ្ងៃ៥ ខែកញ្ញា ឆ្នាំ២០២៣ មានកម្ពស់ ៤,៨៥ម៉ែត្រ។

ទី២/. នៅក្នុងរដូវទឹកតម្លើងនេះ ប្រជានេសាទជាទូទៅភាគច្រើនប្រើឧបករណ៍នេសាទដូចជា៖ មងរាយ កន្សុំកំពឹស ឬសៃយឺន និងលបទ្បុក ដោយទទួលបានទិន្នផលនេសាទជាមធ្យម ១០គីឡូក្រាម/ថ្ងៃ។

ទី៣/.អាជ្ញាធរដែនដី និងមន្ត្រីជំនាញជលផលៈ ការផ្សព្វផ្សាយច្បាប់ លក្ខន្តិកៈ អំពីការប្រើប្រាស់ធនធានធម្មជាតិឱ្យមាននិរន្តរភាព មានសកម្មភាពតិចតួច ទន្ទឹមនេះ ផែនការក្នុងការគ្រប់គ្រង កែលំអរតំបន់អភិរក្ស ដូចជាដាំព្រៃលិចទឹក លែងកូនត្រី រៀបចំស្ថានីយ៍បណ្ដុះកូនឈើ ស្តារបឹង ស្តារលូ ដាក់គល់ឈើ បោះបង្គោលព្រំ និងស្លាកសញ្ញាណែនាំផ្សេងៗ មានតិចតួចប៉ុណ្ណោះ ជាមួយគ្នានេះ ការផ្សព្វផ្សាយច្បាប់ លក្ខន្តិកៈ អំពីការប្រើប្រាស់ធនធានជលផលឱ្យមាននិរន្តរភាព មានសកម្មភាពតិចតួច។

បញ្ហាប្រឈមៈ កត្តាអាកាសធាតុ ព្រុះ ភ្លៀង ខ្យល់ បណ្ដាលឱ្យបាត់ឧបករណ៍នេសាទ និងមានការលំបាកក្នុងការចេញទៅធ្វើនេសាទ ជាមួយគ្នានេះ តម្លៃត្រីមានតម្លៃទាប ទន្ទឹមនេះ ប្រជានេសាទប្រើប្រាស់ឧបករណ៍នេសាទលបទ្បុក សំណូមពរសុំដាក់ឧបករណ៍ទាំងនោះប្រវែង ២៥០ម៉ែត្រ ដោយឡែកច្បាប់ជលផលបានអនុញ្ញាតត្រឹមប្រវែង ៧០ម៉ែត្រ ប៉ុណ្ណោះ។

សូមជម្រាបជូនថាៈ សកម្មភាពចុះសិក្សាស្រាវជ្រាវអំពីសក្ដានុពលនិងប្រសិទ្ធភាពក្នុងការគ្រប់គ្រងតំបន់អភិរក្សជលផលអតីតឡូត៍នេសាទលេខ៤ ខេត្តសៀមរាប ជាសកម្មភាពមួយ ក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តដាក់ឱ្យអនុវត្តនៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ២០២៣ របស់អាជ្ញាធរទន្លេសាប។ សកម្មភាពខាងលើនេះ មានគោលបំណង ១/. សិក្សាអំពីស្ថានភាពទូទៅ របស់តំបន់អភិរក្សជលផលអតីតឡូត៍នេសាទលេខ៤ ២/. ស្វែងយល់អំពីបញ្ហាប្រឈម ក្នុងការគ្រប់គ្រងតំបន់អភិរក្សជលផលអតីតឡូត៍នេសាទលេខ៤ ៣/. វិភាគស៊ីជម្រៅលើបញ្ហាប្រឈម ដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងតំបន់អភិរក្សជលផលអតីតឡូត៍នេសាទលេខ៤ ដើម្បីផ្ដល់ជម្រើសដំណោះស្រាយសមស្រប។



នៅថ្ងៃព្រហស្បតិ៍ ១៤កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីបច្ចេកទេស ការិយាល័យអភិរក្ស របស់នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស បានបន្តចុះសិក្សាស្រាវជ្រាវអំពីសក្ដានុពល និងប្រសិទ្ធភាពក្នុងការគ្រប់គ្រងតំបន់អភិរក្សជលផល អតីតឡូត៍នេសាទលេខ៤ ដោយមួយផ្នែកធំស្ថិតនៅសង្កាត់ចុងឃ្នៀស និងមួយផ្នែកតូចស្ថិតនៅឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។

ការចុះសិក្សានេះ ក្រុមការងារស្រាវជ្រាវបាន៖

១- ចុះជួបសម្ភាសន៍ជាមួយក្រុមប្រឹក្សាឃុំ សហគមន៍នេសាទ មន្ត្រីជំនាញជលផល និងប្រជានេសាទ រួមជាមួយការធ្វើអង្កេតផ្ទាល់ ដើម្បីស្វែងយល់អំពីស្ថានភាពទូទៅមាន៖ ប្រភេទមុខរបរការធ្វើនេសាទ ការប្រើប្រាស់ឧបករណ៍នេសាទ ទិន្នផលនេសាទ ការចូលរួម ឧបត្ថម្ភ គាំទ្រ សហការ ពីអង្គការ-ស្ថាប័នពាក់ព័ន្ធក្នុងកិច្ចការងារអភិរក្ស និងបញ្ហាប្រឈមនានាក្នុងការគ្រប់គ្រង។ ជាមួយនឹងសកម្មភាពនេះផងដែរក្រុមការងារមន្ត្រីបច្ចេកទេសបានចុះសិក្សានៅតំបន់ពាក់ព័ន្ធខាងលើ ជាលទ្ធផលឃើញថា៖

១. អាជ្ញាធរមូលដ្ឋាន មន្ត្រីជំនាញ និងប្រជានេសាទ មានការសាទរចំពោះចំណាត់ការ របស់រាជរដ្ឋាភិបាលកន្លងមក ដែលបានចុះដកហូតកាណូតប្រព្រឹត្តបទល្មើសជលផលតាមខ្នងផ្ទះ មានដូចជា អួនអូសគូ ស៊ីប...។ល។ ព្រោះការប្រើប្រាស់ឧបករណ៍នេសាទទាំងនេះ មិនត្រឹមតែបំផ្លាញធនធានជលផលប៉ុណ្ណោះទេ ថែមទាំងបំផ្លាញឧបករណ៍នេសាទរបស់ប្រជានេសាទផងដែរ។

២. ប្រជានេសាទជាទូទៅភាគច្រើននៅរដូវវស្សានេះ ប្រើឧបករណ៍នេសាទដូចជា មងរាយ មងបណ្ដែត កន្ទ្រុំកំពឹស លបឡុក ដោយទទួលបានទិន្នផលជាមធ្យម ១០គីឡូក្រាម/ថ្ងៃ ចំណែកឯ កម្ពស់ទឹកគិតត្រឹមថ្ងៃ២៨ ខែកញ្ញា ឆ្នាំ២០២៣ មានកម្ពស់ ៦.២៧ ម៉ែត្រ (វាស់ពីបាតតំបន់អភិរក្ស)។

៣. ប្រភេទឧបករណ៍នេសាទដែលលួចចូលនេសាទក្នុងតំបន់អភិរក្សមាន សន្ទូច (ទំហំផ្លែ លេខ ៩ លេខ ១៥) និងមង (ទំហំក្រឡា ៩ហ៊ុន ទៅ ១.៤ តឹក) ហើយភាគច្រើនធ្វើសកម្មភាពនៅពេលយប់។

៤. មន្ត្រីជំនាញជលផលផ្នែក សង្កាត់ និងសហគមន៍នេសាទបានសហការគ្នាចុះល្បាតរួមគ្នា មានចំនួន ១៤នាក់ ចែកចេញជាពីរក្រុម ប្ដូរវេនគ្នា ៣ថ្ងៃ ម្ដង ដោយទទួលបានការជួយឧបត្ថម្ភពីអង្គការ KFW តាំងពីឆ្នាំ ២០១៩ និងបញ្ចប់គម្រោងនៅខែធ្នូ ឆ្នាំ២០២៣ នេះ។ ទន្ទឹមនេះ មន្ត្រីជំនាញជលផលបានទទួលយកសំណើរបស់ ប្រជានេសាទដែលបានស្នើសុំដាក់ឧបករណ៍លបឡុកនៅរដូវបិទនេសាទប្រវែង ១០០ម៉ែត្រ និងរដូវបើកនេសាទប្រវែង ២៥០ម៉ែត្រ ក្រឡា ៣ហ៊ុន សំណើនេះមន្ត្រីជំនាញជលផលបានស្នើសុំទៅក្រសួងកសិកម្មរួចរាល់ហើយ។

សូមជម្រាបជូនថា: សកម្មភាពចុះសិក្សាស្រាវជ្រាវអំពីសក្ដានុពល និងប្រសិទ្ធភាពក្នុងការគ្រប់គ្រងតំបន់អភិរក្សជលផលអតីតឡូត៍នេសាទលេខ៤ ខេត្តសៀមរាប។ គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តដាក់ឱ្យអនុវត្ត នៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ២០២៣ របស់អាជ្ញាធរទន្លេសាប។

សកម្មភាពខាងលើនេះ មានគោលបំណង៖

- សិក្សាអំពីស្ថានភាពទូទៅ របស់តំបន់អភិរក្សជលផលអតីតឡូត៍នេសាទលេខ៤
- ស្វែងយល់អំពីបញ្ហាប្រឈម ក្នុងការគ្រប់គ្រងតំបន់អភិរក្ស



ជលផលអតីតឡូត៍នេសាទលេខ៤

- វិភាគស៊ីជម្រៅលើបញ្ហាប្រឈម ដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងតំបន់អភិរក្សជលផលអតីតឡូត៍នេសាទលេខ៤ ដើម្បីផ្ដល់ជម្រើសដំណោះស្រាយសមស្រប។



នៅថ្ងៃព្រហស្បតិ៍ ១៤កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីបច្ចេកទេស ការិយាល័យអភិរក្ស របស់នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស បានបន្តចុះសិក្សាស្រាវជ្រាវអំពីសក្តានុពល និងប្រសិទ្ធភាពក្នុងការគ្រប់គ្រងតំបន់អភិរក្សជលផល អតីតឡូត៍នេសាទលេខ៤ ដោយមួយផ្នែកធំស្ថិតនៅសង្កាត់ចុងឃ្នៀស និងមួយផ្នែកតូចស្ថិតនៅឃុំកំពង់ភ្លុក ស្រុកប្រាសាទបាគង ខេត្តសៀមរាប។

ការចុះសិក្សានេះ ក្រុមការងារស្រាវជ្រាវបាន៖

១- ចុះជួបសម្ភាសន៍ជាមួយក្រុមប្រឹក្សាឃុំ សហគមន៍នេសាទ មន្ត្រីជំនាញជលផល និងប្រជានេសាទ រួមជាមួយការធ្វើអង្កេតផ្ទាល់ ដើម្បីស្វែងយល់អំពីស្ថានភាពទូទៅមាន៖ ប្រភេទមុខរបរការធ្វើនេសាទ ការប្រើប្រាស់ឧបករណ៍នេសាទ ទិន្នផលនេសាទ ការចូលរួម ឧបត្ថម្ភ គាំទ្រ សហការ ពីអង្គការ-ស្ថាប័នពាក់ព័ន្ធក្នុងកិច្ចការងារអភិរក្ស និងបញ្ហាប្រឈមនានាក្នុងការគ្រប់គ្រង។ ជាមួយនឹងសកម្មភាពនេះផងដែរក្រុមការងារមន្ត្រីបច្ចេកទេសបានចុះសិក្សានៅតំបន់ពាក់ព័ន្ធខាងលើ ជាលទ្ធផលឃើញថា៖

១. អាជ្ញាធរមូលដ្ឋាន មន្ត្រីជំនាញ និងប្រជានេសាទ មានការសាទរចំពោះចំណាត់ការ របស់រាជរដ្ឋាភិបាលកន្លងមក ដែលបានចុះដកហូតកាណូតប្រព្រឹត្តបទល្មើសជលផលតាមខ្នងផ្ទះ មានដូចជា អួនអូសគូ ស៊ីប...។ល។ ព្រោះការប្រើប្រាស់ឧបករណ៍នេសាទទាំងនេះ មិនត្រឹមតែបំផ្លាញធនធានជលផលប៉ុណ្ណោះទេ ថែមទាំងបំផ្លាញឧបករណ៍នេសាទរបស់ប្រជានេសាទផងដែរ។

២. ប្រជានេសាទជាទូទៅភាគច្រើននៅរដូវវស្សានេះ ប្រើឧបករណ៍នេសាទដូចជា មងរាយ មងបណ្តែត កន្ទ្រុំកំពឹស លបឡូក ដោយទទួលបានទិន្នផលជាមធ្យម ១០គីឡូក្រាម/ថ្ងៃ ចំណែកឯ កម្ពស់ទឹកគិតត្រឹមថ្ងៃ២៨ ខែកញ្ញា ឆ្នាំ២០២៣ មានកម្ពស់ ៦.២៧ ម៉ែត្រ (វាស់ពីបាតតំបន់អភិរក្ស)។

៣. ប្រភេទឧបករណ៍នេសាទដែលលួចចូលនេសាទក្នុងតំបន់អភិរក្សមាន សន្ទូច (ទំហំផ្លែ លេខ ៩ លេខ ១៥) និងមង (ទំហំក្រឡា ៩ហ៊ុន ទៅ ១.៤ តឹក) ហើយភាគច្រើនធ្វើសកម្មភាពនៅពេលយប់។

៤. មន្ត្រីជំនាញជលផលផ្នែក សង្កាត់ និងសហគមន៍នេសាទបានសហការគ្នាចុះល្បាតរួមគ្នា មានចំនួន ១៤នាក់ ចែកចេញជាពីរក្រុម ប្តូរវេនគ្នា ៣ថ្ងៃ ម្តង ដោយទទួលបានការជួយឧបត្ថម្ភពីអង្គការ KFW តាំងពីឆ្នាំ ២០១៩ និងបញ្ចប់គម្រោងនៅខែធ្នូ ឆ្នាំ២០២៣ នេះ។ ទន្ទឹមនេះ មន្ត្រីជំនាញជលផលបានទទួលយកសំណើរបស់ ប្រជានេសាទដែលបានស្នើសុំដាក់ឧបករណ៍លបឡូកនៅរដូវបិទនេសាទប្រវែង ១០០ម៉ែត្រ និងរដូវបើកនេសាទប្រវែង ២៥០ម៉ែត្រ ក្រឡា ៣ហ៊ុន សំណើនេះមន្ត្រីជំនាញជលផលបានស្នើសុំទៅក្រសួងកសិកម្មរួចរាល់ហើយ។

សូមជម្រាបជូនថាៈ សកម្មភាពចុះសិក្សាស្រាវជ្រាវអំពីសក្តានុពល និងប្រសិទ្ធភាពក្នុងការគ្រប់គ្រងតំបន់អភិរក្សជលផលអតីតឡូត៍នេសាទលេខ៤ ខេត្តសៀមរាប។ គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តដាក់ឱ្យអនុវត្ត នៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ២០២៣ របស់អាជ្ញាធរទន្លេសាប។

សកម្មភាពខាងលើនេះ មានគោលបំណង៖

- សិក្សាអំពីស្ថានភាពទូទៅ របស់តំបន់អភិរក្សជលផលអតីតឡូត៍នេសាទលេខ៤
- ស្វែងយល់អំពីបញ្ហាប្រឈម ក្នុងការគ្រប់គ្រងតំបន់អភិរក្សជលផលអតីតឡូត៍នេសាទលេខ៤



-វិភាគស៊ីជម្រៅលើបញ្ហាប្រឈម ដែលពាក់ព័ន្ធក្នុងការគ្រប់គ្រងតំបន់អភិរក្សជលផលអតីតឡូត៍នេសាទលេខ៤ ដើម្បីផ្តល់ជម្រើសដំណោះស្រាយសមស្រប។

# សិក្សាវាយតម្លៃ និងផលចំណេញសេដ្ឋកិច្ចក្នុងផលិតកម្មស្រូវប្រាំងនៅវាលទំនាបបឹងទន្លេសាប ខេត្តកំពង់ធំ

នាថ្ងៃព្រហស្បតិ៍ ៤កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០២៣ មន្ត្រីបច្ចេកទេស នៃនាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ នៃអាជ្ញាធរទន្លេសាប បានបន្តធ្វើការសិក្សាការវិភាគតម្លៃ និងផលចំណេញក្នុងផលិតកម្មស្រូវ នៅវាលទំនាបបឹងទន្លេសាប នៅឃុំពង្រ, ទ្រៀល, ជ្រលង, សូយោង និងឃុំស្រឡៅ ស្រុកតាំងគោក ខេត្តកំពង់ធំ។



ការសិក្សានេះ ទទួលបានលទ្ធផលបឋម ដូចខាងក្រោម៖

- ផ្ទៃដីស្រែប្រាំងក្នុងស្រុកតាំងគោកមានចំនួន ២៣.០០០ ហិកតា ក្នុងតំបន់២
- ធ្វើស្រែប្រាំងបាន ២ដង ក្នុងមួយឆ្នាំ
- ទិន្នផលបាន ៣ ទៅ ៤ តោន ក្នុងមួយហិកតា ដោយប្រើប្រាស់ពូជស្រូវ OM5154 សែនក្រអូប និងរំដួល
- តម្លៃស្រូវក្នុងឆ្នាំ២០២៣ គឺ ១២០០រៀល/គក្រ
- ការធ្វើស្រែប្រាំង របស់កសិករក្នុងតំបន់នេះ ចំណាយអស់ប្រមាណ ២,៨ លានរៀល/ហត ដូចជា ថ្លៃពូជស្រូវ ថ្លៃជួលភ្ជួររាស់ ជួលច្រូត ជួលដឹកជញ្ជូន ថ្លៃថ្នាំ-ជីគីមី និងប្រេង/សាំង។
- ចំណេញចន្លោះពី ១,០០,០០០ ទៅ ១,៥០០,០០០ រៀល ក្នុងមួយហិកតា ក្នុងមួយដង
- បច្ចេកទេសធ្វើស្រែ និងការប្រើប្រាស់ថ្នាំគីមី ជីគីមី គឺធ្វើតាមតៗគ្នា។



- ប្រជាជនស្រុកតាំងគោក មានសមាជិកគ្រួសារចន្លោះពី ៤ ទៅ ៦នាក់/គ្រួសារ ប៉ុន្តែកម្លាំងពលកម្មធ្វើស្រែមានតែ ១ ទៅ ២នាក់ ប៉ុណ្ណោះ គឺការធ្វើស្រែដោយជួលគេធ្វើឲ្យ ដែលធ្វើឲ្យចំណាយច្រើន។
- ការធ្វើស្រែក្នុងស្រុកតាំងគោក គឺអនុវត្តន៍កសិកម្មជាលក្ខណៈគ្រួសារ ដែលមានផ្ទៃដី ២ទៅ ២០ ហិកតា/គ្រួសារ។

សូមជម្រាបជូនថា៖ សកម្មភាពសិក្សាវាយតម្លៃ និងផលចំណេញសេដ្ឋកិច្ចក្នុងផលិតកម្មស្រូវប្រាំងនៅវាលទំនាបបឹងទន្លេសាប ខេត្តកំពង់ធំ គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាព ដែលត្រូវបានអនុម័តឱ្យអនុវត្តន៍នៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ២០២៣ របស់នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ នៃអាជ្ញាធរទន្លេសាប ។

សកម្មភាពខាងលើនេះ មានគោលបំណងដើម្បី៖

- វិភាគចរន្តសេដ្ឋកិច្ចពីរបរស្រែប្រាំងក្នុងតំបន់សិក្សា
- វិភាគថ្លៃដើមផលិតកម្ម និងផលិតផលផលិតកម្មស្រែប្រាំង
- ស្វែងយល់ និងវិភាគចំណូលចំណាយពីការធ្វើរបរស្រែប្រាំង
- បញ្ហាប្រឈមក្នុងការងារធ្វើស្រែរបស់ប្រជាពលរដ្ឋ
- ចងក្រងជាឯកសារពីតម្លៃស្រូវ ទីផ្សារ ទិន្នផល ពូជស្រូវតាមឆ្នាំ/តំបន់។



នាថ្ងៃសុក្រ៦កើតខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី ២០ ខែតុលា ឆ្នាំ២០២៣ មន្ត្រីបច្ចេកទេសនៃនាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ នៃអាជ្ញាធរទន្លេសាប ដឹកនាំដោយលោកស្រ៊ន ស៊ីលីន អនុប្រធាននាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយនៃអាជ្ញាធរទន្លេសាប បានបន្តធ្វើការសិក្សាការវិភាគតម្លៃ និងផលចំណេញក្នុងផលិតកម្មស្រូវនៅវាលទំនាបបឹងទន្លេសាប នៅឃុំបារាយណ៍ ឃុំបឹង និងឃុំត្នោតជុំ ស្រុកបារាយណ៍ ខេត្តកំពង់ធំ។



ការសិក្សានេះ ទទួលបានលទ្ធផលបឋម ដូចខាងក្រោម៖
- ផ្ទៃដីស្រែប្រាំងក្នុងស្រុកបារាយណ៍មានចំនួន ១៩,៨៣៧ ហិកតា ក្នុងតំបន់២
- ធ្វើស្រែប្រាំងបាន ២ដង ក្នុងមួយឆ្នាំ
- ទិន្នផលបាន ៥ ទៅ ៦ តោន ក្នុងមួយហិកតា
- ការធ្វើស្រែប្រាំងរបស់កសិករក្នុងតំបន់នេះ ចំណាយអស់



ប្រមាណ ៤ លានរៀល/ហត ដូចជា ថ្លៃពូជស្រូវ ថ្លៃជួលភ្ជួររាស់ ជួលបាចជី ជួលព្រួស ជួលបាញ់ថ្នាំ ជួលច្រូត ជួលដឹកជញ្ជូន ថ្លៃថ្នាំ-ជីគីមី និងប្រេង/សាំង។
- ចំណេញបានប្រមាណ ២,០០០,០០០ ទៅ ២,៥០០,០០០ រៀល ក្នុងមួយហិកតា
- ប្រជាកសិករមួយចំនួនធំក្នុងឃុំបារាយណ៍ ជួលដីស្រែប្រាំងពីក្រុមហ៊ុនចិន ចន្លោះ ពី ០៥ ទៅ១០ហិកតាក្នុង មួយគ្រួសារ មានតម្លៃ ១៥០$/ហត និង ទិញទឹកតម្លៃ ៧០$/ហត។

សូមជម្រាបជូនថា៖ សកម្មភាពសិក្សាវាយតម្លៃ និងផលចំណេញសេដ្ឋកិច្ចក្នុងផលិតកម្មស្រូវប្រាំងនៅវាលទំនាបបឹងទន្លេសាប ខេត្តកំពង់ធំ គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាព ដែលត្រូវបានអនុម័តឱ្យអនុវត្តន៍នៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ២០២៣ របស់នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ នៃអាជ្ញាធរទន្លេសាប ។

សកម្មភាពខាងលើនេះ មានគោលបំណងដើម្បី៖
- វិភាគចរន្តសេដ្ឋកិច្ចពី របរស្រែប្រាំងក្នុងតំបន់សិក្សា
- វិភាគថ្លៃដើមផលិតកម្ម និងផលិតផលផលិតកម្មស្រែប្រាំង
- ស្វែងយល់ និងវិភាគចំណូលចំណាយពីការធ្វើរបរស្រែប្រាំង
- បញ្ហាប្រឈមក្នុងការងារធ្វើស្រែរបស់ប្រជាពលរដ្ឋ
- ចងក្រងជាឯកសារពីតម្លៃស្រូវ ទីផ្សារ ទិន្នផល ពូជស្រូវតាមឆ្នាំ/តំបន់។



# សិក្សាប្រជាសាស្ត្រនិងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាសហគមន៍នេសាទ នៅជុំវិញបឹងទន្លេសាប ជំហាន ១-បច្ចុប្បន្នភាពគម្រោងថ្នាក់ក្រោមជាតិនៅតំបន់ទន្លេសាប



នាថ្ងៃអង្គារ ៩រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ០៧ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារមន្រ្តីនាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ អាជ្ញាធរទន្លេសាប ដឹកនាំដោយ លោក យ៉ាន់ សំរិទ្ធ ប្រធាននាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ បានបន្តចុះអនុវត្តសកម្មភាពសិក្សា បច្ចុប្បន្នភាពប្រជាសាស្ត្រ និងស្ថានភាពសេដ្ឋកិច្ចសង្គម របស់ប្រជាសហគមន៍នេសាទ ជំហាន១ នៅខេត្តបាត់ដំបង ។

ក្រុមការងារបានជួបជាមួយមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដូចជា មន្ទីរផែនការខេត្តបាត់ដំបង អាជ្ញាធរឃុំព្រែកហ្លួង ស្រុកឯកភ្នំ និងឃុំជ្រៃ ស្រុកមោងឫស្សី ។

ជាមួយនឹងការសិក្សាខាងលើ ជាលទ្ធផលបឋម បានបង្ហាញឃើញថា ៖

ក. ប្រជាសាស្ត្រ៖ មានគ្រួសារសរុបចំនួន ៦,០៨៤គ្រួសារ ស្មើ ២៦,៤៦៧នាក់ (ស្រី ១២,៨២០នាក់) ប្រជាពលរដ្ឋ ១៨ឆ្នាំឡើង ១៦,៩១៥នាក់ (ស្រី ៧,៦៧០នាក់)។ អត្រាភាពក្រីក្រប្រមាណ ២៣% ធៀបទៅនឹងគ្រួសារសរុប និងពលរដ្ឋចំណាកស្រុកក្នុង-ក្រៅប្រទេសមានប្រមាណជា ១៦.៩% ។

ខ. ស្ថានភាពសេដ្ឋកិច្ចសង្គម៖

- ប្រជាសហគមន៍ឃុំទាំងពីរ ពឹងផ្អែកលើវិស័យកសិកម្មជាចម្បង មានប្រមាណ ៧៤.៩% ដែលភាគច្រើនធ្វើស្រូវវស្សា ស្រូវប្រាំង និងដំណាំរួមផ្សំ។ មុខរបរចម្បងផ្អែកវិស័យសិប្បកម្ម ០.២៥% និងសេវាកម្ម មានប្រមាណជា ២៤.៨៥% (លក់ដូរនិងជំនួញ ជាងជួសជុល ដឹកជញ្ជូន ស៊ីឈ្នួលក្នុងវិស័យកសិកម្ម កម្មករសំណង់ កម្មកររោងចក្រ បុគ្គលិកអង្គការ និងមន្ត្រីរាជការ) ។
- ប្រជាពលរដ្ឋទទួលបានសេវាសុខភាពល្អប្រសើរមានប្រមាណជា ៩៥% បានទទួលសេវានៅ មណ្ឌលសុខភាព និងក្រៅពីនេះពួកគេទៅទទួលសេវាសុខភាពឯកជន និងមន្ទីរពេទ្យខេត្ត។
- ប្រជាសហគមន៍ឃុំទាំងពីរ មានទឹកស្អាតប្រើប្រាស់១០០% ក្នុងនោះមានប្រព័ន្ធទឹកស្អាតមានប្រមាណ ៥៩.២% និងមានតែ ៤០.៨% ប្រើប្រាស់ទឹកស្រះ ទន្លេ អណ្ដូង។ ប្រជាពលរដ្ឋគ្រប់គ្រួសារមានការយល់ដឹងបរិភោគទឹកស្អាត និងដាំចម្អិនដាំឆ្អិន ដែលមានគ្រួសារទទួលទានទឹកឆ្លងកាត់ប្រព័ន្ធទឹកស្អាត មានប្រមាណ ៧៥.៧៩% ក្រៅពីនេះ ប្រើប្រាស់ទឹកដាំពុះ និងទឹកសុទ្ធ។ ការប្រើប្រាស់បង្គន់អនាម័យ មានចំនួន ៧៦.៨៥% ប៉ុន្តែមានតែ ៧២.៧% មានបង្គន់អនាម័យស្តង់ដារ ។

គ. បរិស្ថានធនធានធម្មជាតិ៖ បម្រែបម្រួលអាកាសធាតុពីមួយឆ្នាំទៅឆ្នាំ បានបង្កទៅជាគ្រោះមហន្តរាយផ្សេងៗ (គ្រោះរាំងស្ងួត គ្រោះទឹកជំនន់...) ការប្រើប្រាស់ជី/ថ្នាំគីមីក្នុងវិស័យកសិកម្ម បានបង្កឲ្យមានផលប៉ះពាល់ដល់បរិស្ថានធម្មជាតិ ជាមួយគ្នានេះសកម្មភាពលបលួចទន្រ្ទានព្រៃលិចទឹកនៅតែមាន និងកត្តាភ្លើងឆេះព្រៃលិចទឹកដែលជាជម្រកត្រីពងកូនតាមរូបភាពដុតរកសត្វ(ឃ្មុំ និងអណ្ដើក) ជាដើម។ សកម្មភាពប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់នៅតែមានក្នុងភូមិសាស្ត្រឃុំទាំងពីរ ។



សូមជម្រាបជូនថា: សកម្មភាពចុះសិក្សាបច្ចុប្បន្នភាពប្រជាសាស្ត្រ និងស្ថានភាពសេដ្ឋកិច្ចសង្គមរបស់ប្រជាសហគមន៍នេសាទនៅតំបន់ជុំវិញបឹងទន្លេសាប មានគោលបំណង ដើម្បីស្វែងយល់៖

១. ស្ថានភាពសេដ្ឋកិច្ចសង្គមពីជីវភាពរស់នៅរបស់ប្រជាសហគមន៍នេសាទលើការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់បឹងទន្លេសាប

២. ការប្រមូលចងក្រងបច្ចុប្បន្នភាពទិន្នន័យ-ព័ត៌មាន សម្រាប់ជាធាតុចូលក្នុងការរៀបចំឯកសារគោលនយោបាយក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិសម្រាប់ចូលរួមដល់ការគ្រប់គ្រងបឹងទន្លេសាប ប្រកបដោយនិរន្តរភាព ។



នាថ្ងៃពុធ ៥រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ០៤ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីនាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប ដឹកនាំដោយ លោក អុល សុជាតិ ប្រធានការិយាល័យសម្របសម្រួលវិវាទ បានបន្តចុះអនុវត្តសកម្មភាពសិក្សាបច្ចុប្បន្នភាពប្រជាសាស្ត្រ និងស្ថានភាពសេដ្ឋកិច្ចសង្គម របស់ប្រជាសហគមន៍នេសាទ ស្ថិតនៅក្នុង ឃុំបឹងបត់កណ្ដាល ស្រុកបាកាន និងឃុំក្បាលត្រាច ស្រុកក្រគរ ខេត្តពោធិ៍សាត់ ។

សកម្មភាពការសិក្សាជំហាន១ នេះ ក្រុមការងារបានជួបជាមួយមន្ទីរ អង្គភាពជំនាញពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដូចជា ៖

១. ជួបពិភាក្សាស្វែងយល់ និងប្រមូលទិន្នន័យ-ព័ត៌មាន ជាមួយនឹងមន្ទីរផែនការខេត្តពោធិ៍សាត់

២. ជួបពិភាក្សា និងប្រមូលទិន្នន័យ-ព័ត៌មានជាមួយអាជ្ញាធរឃុំបឹងបត់កណ្ដាល ស្រុកបាកាន និងឃុំក្បាលត្រាច នៃស្រុកក្រគរ ។

ជាមួយនឹងការអនុវត្តន៍សកម្មភាពក្នុងតំបន់សិក្សាខាងលើ ជាលទ្ធផលបឋម ទទួលបាន ៖

ក. ប្រជាសាស្ត្រ : មានគ្រួសារសរុបចំនួន ៥,៤៣១គ្រួសារ ស្មើនឹងប្រជាពលរដ្ឋសរុប ២៤,៤១៨នាក់ (ស្រី១២,២៩០នាក់) អត្រាភាពក្រីក្រប្រមាណ ១៧% ធៀបទៅនឹងគ្រួសារសរុប និងពលរដ្ឋចំណាកស្រុកក្នុង-ក្រៅប្រទេសមានប្រមាណជា ៣០.៣%។

ខ. ស្ថានភាពសេដ្ឋកិច្ច : ប្រជាពលរដ្ឋឃុំទាំងពីរ ពឹងផ្អែកលើវិស័យកសិកម្មជាចម្បង មានប្រមាណ ៨៧.៥% ដែលភាគច្រើនធ្វើស្រូវវស្សា និងស្រូវប្រាំង។ និងមុខរបរចម្បងផ្នែកវិស័យសិប្បកម្ម និងសេវាកម្ម មានប្រមាណជា១២.៥%។ ទន្ទឹមនឹងមុខរបរចម្បង ពួកគាត់ប្រកបរបរបន្ទាប់បន្សំ មានដូចជា នេសាទ ដាំដំណាំរួមផ្សំ ចិញ្ចឹមសត្វ វារីវប្បកម្ម ជាកម្មកររោងចក្រ-សំណង់ លក់ដូរគ្រឿងទេស ផ្នែកដឹកជញ្ជូន ជាដើម។

គ. សង្គមកិច្ច

- វិស័យសុខាភិបាល : ប្រជាពលរដ្ឋទទួលបានសេវាសុខភាពល្អប្រសើរ

មានប្រមាណ ៩០% បានទទួលសេវានៅ មណ្ឌលសុខភាព និងមានបណ្ដាញក្រុមទ្រទ្រង់សុខភាពតាមភូមិនីមួយៗ ។

- សុខភាពអនាម័យ : ប្រជាពលរដ្ឋប្រមាណ ៦៨.៤៨% មានទឹកស្អាតប្រើប្រាស់ និង ៣១.៥២%បន្តប្រើប្រាស់ទឹកអៅស្រះ ទន្លេ អណ្ដូង និង ៦៩.៨% មានបង្គន់អនាម័យស្តង់ដារ ។

- សេវាសាធារណៈ : អាជ្ញាធរឃុំបានប្រើប្រាស់ថវិកាមូលនិធិឃុំប្រកបដោយមានតម្លាភាព គណនេយ្យ ទាំងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការផ្ដល់ប័ណ្ណសមធម៌ និងផ្ដល់សេវារដ្ឋបាលល្អជូនប្រជាពលរដ្ឋ ។

+ ការសិក្សាស្វែងយល់ខាងលើ បានឃើញបញ្ហាប្រឈមមួយចំនួន ក្នុងនោះរួមមាន ៖

- ផលិតកម្មដំណាំស្រូវ បានចំណាយថ្លៃដើមខ្ពស់ (កម្លាំងពលកម្ម ការភ្ជួររាស់ ច្រូតកាត់ និងជី/ថ្នាំកំចាត់សត្វល្អិត)

- សិស្សមួយចំនួន បានបោះបង់ការសិក្សាដើម្បីជីវភាពគ្រួសារ និងចំណាកស្រុកជាមួយឪពុកម្ដាយ

- ប្រជាពលរដ្ឋរស់នៅភូមិដាច់ស្រយាល និងជាប់តំបន់ទន្លេសាប ជួបលំបាកការទទួលបានសេវាសុខភាព និងអនាម័យ

- ការអនុវត្តផែនការអភិវឌ្ឍន៍ឃុំនីមួយៗ នៅមានកម្រិត ផ្ដោតសំខាន់តែផ្នែកហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់

- បរិស្ថានធនធានធម្មជាតិបម្រែបម្រួលអាកាសធាតុពីមួយឆ្នាំទៅឆ្នាំ បានបង្កទៅជាគ្រោះមហន្តរាយផ្សេងៗ ដែលបណ្ដាលអោយប៉ះពាល់ដល់បរិស្ថានធម្មជាតិ ជាមួយគ្នានេះកត្តាភ្លើងឆេះព្រៃលិចទឹកដែលជាជម្រកត្រីពងកូនតាមរូបភាព ដុតរកសត្វ(ឃុំ និងអណ្ដើក) ការធ្វេសប្រហេសរបស់ប្រជាជនចម្អិនអាហារមិនពន្លត់ភ្លើងអោយបានត្រឹមត្រូវ និងការចោលកន្ទុយបារី...។ល។ យ៉ាងណាមិញ សកម្មភាពនេសាទដោយប្រើឧបករណ៍ខុសច្បាប់នៅតែមានក្នុងភូមិសាស្ត្រឃុំទាំងពីរ ។

សូមជម្រាបជូនថាៈ សកម្មភាពចុះសិក្សាបច្ចុប្បន្នភាពប្រជាសាស្ត្រ និងស្ថានភាពសេដ្ឋកិច្ចសង្គម របស់ប្រជាសហគមន៍នេសាទនៅតំបន់ជុំវិញបឹងទន្លេសាប។

មានគោលបំណង ដើម្បីស្វែងយល់ ៖

- ស្ថានភាពសេដ្ឋកិច្ចសង្គមពីជីវភាពរស់នៅរបស់ប្រជាសហគមន៍នេសាទលើការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់បឹងទន្លេសាប

- ការប្រមូលចងក្រងបច្ចុប្បន្នភាពទិន្នន័យ-ព័ត៌មាន សម្រាប់ជាធាតុចូលក្នុងការរៀបចំឯកសារគោលនយោបាយក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិសម្រាប់ចូលរួមដល់ការគ្រប់គ្រងបឹងទន្លេសាប ប្រកបដោយនិរន្តរភាព ។

## បច្ចុប្បន្នភាពគម្រោងថ្នាក់ក្រោមជាតិនៅតំបន់ទន្លេសាប



នៅថ្ងៃសុក្រ ៨កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារនៃនាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ បានបន្តចុះសិក្សាស្វែងយល់ និងបច្ចុប្បន្នភាពគម្រោងថ្នាក់ឃុំ និងថ្នាក់ស្រុកនៅបឹងទន្លេសាប ស្រុកបារាយណ៍ ខេត្តកំពង់ធំ ។

ការចុះសិក្សានេះក្រុមការងារ បានជួបជាមួយអាជ្ញាធរដែនដីនៃឃុំបឹង ស្រុកបារាយណ៍ ។

ជាមួយនឹងសកម្មភាពនេះដែរក្រុមការងារចុះសិក្សានៅតំបន់ពាក់ព័ន្ធខាងលើ ជាលទ្ធផលសង្ខេប រកឃើញថា :

១. ទទួលបានស្ថិតិគម្រោងអាទិភាពថ្នាក់ឃុំ និងស្រុក ចំនួន ៣៦ គម្រោងសម្រាប់អនុវត្តក្នុងឆ្នាំ ២០២៤ ហើយនឹងគ្រោងសមាហរណកម្មជាមួយដៃគូនាត្រីមាសទី ៤ ឆ្នាំ២០២៣ ខាងមុខ។

២. ទទួលបានជាការផ្លាស់ប្តូរបទពិសោធន៍ និងទស្សនទានទៅលើការពង្រឹងកិច្ចការងារកៀរគរគម្រោង និងការធ្វើសមាហរណកម្មគម្រោង សម្រាប់ចរចាជាមួយដៃគូម្ចាស់ជំនួយ។

៣. គម្រោងដែលគាំទ្រដោយដៃគូ និងគម្រោងកំពុងអនុវត្តមានការគាំទ្រពីដៃគូម្ចាស់ជំនួយតិចតួចពី ១ឆ្នាំទៅ ១ឆ្នាំ។

សូមជម្រាបជូនថា ៖ សកម្មភាពចុះសិក្សា និងបច្ចុប្បន្នភាពគម្រោងថ្នាក់ឃុំ និងថ្នាក់ស្រុកដែលអនុវត្តនៅតំបន់បឹងទន្លេសាប មានគោលបំណង សិក្សាស្វែងយល់ និងធ្វើបច្ចុប្បន្នភាពគម្រោងថ្នាក់ឃុំ និងស្រុកដែលមាននៅស្រុកបារាយណ៍ ខេត្តកំពង់ធំ សម្រាប់ចងក្រងជាស្ថិតិទៅតាមប្រភេទគម្រោង /វិស័យគម្រោង ជាធាតុចូលដើម្បីរៀបចំផែនការ កម្មវិធី/យុទ្ធសាស្ត្រ និងគោលនយោបាយ ។

## ពង្រឹងបណ្តាញទំនាក់ទំនងការងារជាមួយស្ថាប័ន និងសហគមន៍មូលដ្ឋានក្នុងការតាមដានផលប៉ះពាល់ទៅលើធនធាន-ធម្មជាតិ និង បរិស្ថានក្នុងតំបន់ជុំវិញបឹងទន្លេសាប



នាថ្ងៃព្រហស្បតិ៍ ១១កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីនាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប ដឹកនាំដោយ លោក អុល សុជាតិ ប្រធានការិយាល័យសម្របសម្រួលវិវាទ បានបន្តចុះអនុវត្តសកម្មភាពពង្រឹងបណ្តាញទំនាក់ទំនងការងារជាមួយអង្គភាពជំនាញពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន នៅខេត្តកំពង់ធំ ។

សកម្មភាពខាងលើ ក្រុមការងារបានជួបជាមួយមន្ទីរអង្គភាពជំនាញពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដើម្បី៖

១. ពិភាក្សាស្វែងយល់ និងប្រមូលទិន្នន័យ-ព័ត៌មានជាមួយនឹងខណ្ឌជលផលខេត្តកំពង់ធំ

២. ពិភាក្សា និងប្រមូលទិន្នន័យ-ព័ត៌មានជាមួយអាជ្ញាធរឃុំប្រាសាទ ស្រុកសន្ទុក ខេត្តកំពង់ធំ និងសហគមន៍នេសាទតាគង់អន្លង់ត្រីបឹងទក់បឹងគួយ។

ជាមួយនឹងការអនុវត្តន៍សកម្មភាពក្នុងតំបន់សិក្សាខាងលើ ជាលទ្ធផលបឋម បានបង្ហាញឃើញថា៖

១. សហគមន៍នេសាទតាគង់អន្លង់ត្រីបឹងទក់បឹងគួយ បានបង្កើតឡើងក្នុងឆ្នាំ២០០៧ មានសមាជិកគណៈកម្មការសហគមន៍ ចំនួន ១១នាក់ ស្រី ១នាក់ហើយមិនទាន់បោះឆ្នោតជ្រើសរើសគណៈកម្មការថ្មីនៅឡើយ។ សហគមន៍នេសាទនេះមានបឹង



អភិរក្សចំនួន ២កន្លែង គឺ បឹងទក់ មានទំហំ ១៥០ម×៣០០ម និង បឹងគួយ ទំហំ ១៥០ម×៣០០ម ដែលព័ទ្ធជុំវិញទៅដោយស្រែប្រាំង ។

២. គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០២៣ នេះ ស្ថាប័នជំនាញពាក់ព័ន្ធ បានបំពេញការងារ និងបានសហការធ្វើការបង្ក្រាបបទល្មើសនេសាទ ក៏ដូចជាការចូលរួមការពារ អភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិ សម្រេចបានការដកហូត និងបំផ្លាញចោលឧបករណ៍នេសាទខុសច្បាប់ រួមមាន៖

- ឧបករណ៍ឡក ចំនួន ៤,៣៣១គ្រឿង
- ឧបករណ៍របាំងស្បៃម៉ុងប្រវែង ៦៤,០៤៣ម៉ែត្រ
- ឧបករណ៍របាំងសាច់មងប្រវែង៦៧,៧៧៥ម៉ែត្រ
- ឧបករណ៍សម្រាស់ទំហំ ១,៣៤៦ម៉ែត្រការ៉េ
- ខ្សែរចងប្រវែង ៤៨៥ម៉ែត្រ
- លបប្រើស១០០ ចំនួន ២,៩៨៩គ្រឿង
- អួន ចំនួន ៣វង់
- ដុំភ្លើងឆក់ ចំនួន ១៦គ្រឿង
- ដងឆក់ ចំនួន ១៤គូរ
- ខ្សែរភ្លើងប្រវែង ៨៤គ្រឿង
- អាគុយ ចំនួន ១៦គ្រឿង
- បង្គោល ចំនួន ៧៤,៦២០ដើម
- បានប្រលែងត្រីចូលបឹងធម្មជាតិ

ចំនួន ២,៧១០គីឡូក្រាម។

សូមជម្រាបជូនថា៖ សកម្មភាពចុះសិក្សាសកម្មភាពពង្រឹងបណ្តាញទំនាក់ទំនងការងារជាមួយអង្គភាពជំនាញពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន មានគោលបំណង ដើម្បីបង្កើតបណ្តាញទំនាក់ទំនងកិច្ចសហប្រតិបត្តិការ ជាមួយមន្ត្រីស្ថាប័នជំនាញពាក់ព័ន្ធ និងថ្នាក់ក្រោមជាតិ ក្នុងការចែករំលែកចំណេះដឹងទិន្នន័យ ព័ត៌មានពីការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិប្រកបដោយចីរភាពនៅតំបន់ជុំវិញបឹងទន្លេសាប។



នាថ្ងៃពុធ ៤កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីនាយកដ្ឋាននីតិកម្ម និង ផ្សព្វផ្សាយ នៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប ដឹកនាំដោយ លោក អុល សុជាតិ ប្រធានការិយាល័យ សម្របសម្រួលវិវាទ បានបន្តចុះអនុវត្តសកម្មភាពពង្រឹង បណ្តាញទំនាក់ទំនងការងារជាមួយអង្គភាពជំនាញ ពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន នៅខេត្តបាត់ដំបង ។ ក្នុងពេលបំពេញការងារអនុវត្តសកម្មភាពខាងលើ ក្រុមការងារបានជួបជាមួយមន្ទីរ អង្គភាពជំនាញ ពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន ដូចជា ៖

១. ជួបពិភាក្សាស្វែងយល់ និងប្រមូលទិន្នន័យ-ព័ត៌មាន ជាមួយនឹង ខណ្ឌជលផល ខេត្តបាត់ដំបង

២. ជួបពិភាក្សា និងប្រមូលទិន្នន័យ-ព័ត៌មានជាមួយអាជ្ញាធរឃុំ ពាមឯក ស្រុកឯកភ្នំ ខេត្តបាត់ដំបង ។

៣. ជួបពិភាក្សា និងប្រមូលទិន្នន័យ-ព័ត៌មានជាមួយសហគមន៍ នេសាទព្រែកឆ្មោរ។

ជាមួយនឹងការអនុវត្តន៍សកម្មភាពក្នុងតំបន់សិក្សាខាងលើ ជា លទ្ធផលបឋម ទទួលបានដូចខាងក្រោម៖

១. ស្ថានភាពទូទៅនៃសហគមន៍នេសាទព្រែកឆ្មោរ មានសមាជិក សរុប ៨៣០នាក់ ស្រី៣០០នាក់ ដែលបានបោះឆ្នោតចុងក្រោយ ក្នុងឆ្នាំ ២០២២និងមានសមាជិកគណៈកម្មការសហគមន៍ ចំនួន៧នាក់ ស្រី ១នាក់។ សមាជិកគណៈកម្មការសកម្ម



មានចំនួន ៥នាក់។ សហគមន៍មានបឹងអភិរក្សចំនួន ១កន្លែង គឺ បឹងឆ្កែកូន មានទំហំ ១៥០ម x ៧០០ម។ សហគមន៍មួយ នេះ បាន និងកំពុងអនុវត្តន៍កាងារនៅមានចន្លោះប្រហោង ជាច្រើន ដែលបណ្តាលអោយប្រសិទ្ធភាពការងារមានការចុះ ខ្សោយ។ ព្រៃលិចទឹកនៅដែនសហគមន៍រងការបំផ្លិចបំផ្លាញ អស់ប្រមាណជាង ៦០% ដោយសារកត្តាភ្លើងឆេះព្រៃ និងការ រានដីព្រៃលិចទឹកធ្វើកសិកម្ម។

២. បញ្ហាប្រឈម ៖ ចំណេះដឹង និងសមត្ថភាពគណៈកម្មការ នៅមានកម្រិត។ ភាពខ្វែងគំនិតគ្នាក្នុងការអនុវត្តការងាររួម ទាំង កង្វះសម្ភារៈ មធ្យោបាយ ថវិកាក្នុងការចុះល្បាត។ កត្តា ប្រជាពលរដ្ឋក្នុងសហគមន៍មិនត្រឹមតែការចូលរួមថែរក្សាធនធាន ធម្មជាតិប៉ុណ្ណោះទេ ថែមទាំងបានចូលនេសាទក្នុងតំបន់អភិរក្ស ជារឿយៗ។ ការប្រើប្រាស់ជី ថ្នាំគីមីលើដីកសិកម្មជុំវិញតំបន់ អភិរក្សនៅតែបន្តកើតមាន ដែលបណ្តាលអោយមានត្រីពុលជា រៀងរាល់ឆ្នាំផងដែរ។

ដោយឡែក គិតត្រឹមខែតុលា ឆ្នាំ២០២៣ នេះ ស្ថាប័នជំនាញ ពាក់ព័ន្ធ បានបំពេញការងារ និងបានសហការធ្វើការបង្ក្រាប បទល្មើសនេសាទ ក៏ដូចជាការចូលរួមការពារ អភិរក្ស និង អភិវឌ្ឍន៍ធនធានធម្មជាតិ ទទួលបានលទ្ធផលសម្រេចបានការ ដកហូត និងបំផ្លាញចោលឧបករណ៍នេសាទខុសច្បាប់ រួមមាន៖

-បញ្ជូនសំណុំរឿងបទល្មើសនេសាទទៅតុលាការចំនួន ៥ ករណី
- ឧបករណ៍ឡុក បានចំនួន ១៥៨គ្រឿង
- ឧបករណ៍លូស្បៃម៉ុងចំនួន ១៥មាត់
- ឧបករណ៍របាំងស្បៃម៉ុងប្រវែង ៣៩,០៥០ម៉ែត្រ
- ឧបករណ៍របាំងសាច់មងប្រវែង ៤៥០ម៉ែត្រ
- ឧបករណ៍ មងរាយប្រវែង ១៥០ម៉ែត្រ
- អាគុយចំនួន ៨គ្រឿង
- បង្គោលចំនួន ១៣,៦៥០ដើម
- បានប្រលែងត្រីចូលបឹងធម្មជាតិចំនួន ១,០៥៣គីឡូក្រាម។

សូមជម្រាបជូនថាៈ សកម្មភាពចុះសិក្សាសកម្មភាពពង្រឹង បណ្តាញទំនាក់ទំនងការងារជាមួយអង្គភាពជំនាញពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន មានគោលបំណង ដើម្បីបង្កើតបណ្តាញ ទំនាក់ទំនងកិច្ចសហប្រតិបត្តិការជាមួយមន្ត្រីស្ថាប័នជំនាញ ពាក់ព័ន្ធ និងថ្នាក់ក្រោមជាតិ ក្នុងការចែករំលែកចំណេះដឹង ទិន្នន័យ ព័ត៌មានពីការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធាន ធម្មជាតិប្រកបដោយចីរភាពនៅតំបន់ជុំវិញបឹងទន្លេសាប។

## ពិគ្រោះយោបល់ប្រាស្រ័យទាក់ទង និងចែករំលែកការយល់ដឹងជាមួយ Environmental Think Tanks និងសម្រប-សម្រួលទំនាក់ទំនងបណ្ដាញការងារ Think Tanks

នៅថ្ងៃអង្គារ ៥កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ២០២៣ មន្ត្រីនាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ដឹកនាំដោយ លោក លឹម ហេង អនុប្រធាននាយកដ្ឋាន បានបន្តចុះសិក្សាស្វែងយល់ពិគ្រោះយោបល់ប្រាស្រ័យទាក់ទង និងចែករំលែកការយល់ដឹងជាមួយ Environmental Think Tanks និងសម្រប សម្រួលទំនាក់ទំនងបណ្ដាញការងារ Think Tanks ស្ថិតនៅក្នុងឃុំស្រែស្ដុក ស្រុកកណ្ដៀង និងឃុំកំពង់ពោធិ៍ ស្រុកក្រគរ ខេត្តពោធិ៍សាត់ ។



ការសិក្សានេះ ក្រុមការងារស្រាវជ្រាវបាន៖

ទី ១. ជួបជាមួយអាជ្ញាធរដែនដី និងសហគមន៍នេសាទមាត់ព្រៃ និងសហគមន៍ផ្លូវអំពិល-ថ្មី

ទី ២. ជួបសម្ភាសន៍ជាមួយប្រជាពលរដ្ឋ ពីស្ថានភាពទូទៅពាក់ព័ន្ធនឹងជីវភាពរស់នៅ និងធនធាននៅក្នុងតំបន់។

ជាមួយនឹងសកម្មភាពនេះដែរ ការសិក្សានៅតំបន់ពាក់ព័ន្ធខាងលើ ទទួលបានលទ្ធផល ដូចខាងក្រោម៖

ទី១.ស្ថានភាពទូទៅ

- សហគមន៍នេសាទមាត់ព្រៃ មានទំហំផ្ទៃដីអភិរក្សព្រៃលិចទឹកប្រមាណ ៤៨៤ ហ.ត ។ ព្រៃលិចទឹកមានការបាត់បង់ប្រមាណជា ៤ទៅ ៥ ហ.ត ដោយសារភ្លើងឆេះ នៅឆ្នាំ២០១៦ ។
- សហគមន៍ផ្លូវអំពិល-ថ្មី សព្វថ្ងៃនេះមិនមានសកម្មភាពនោះទេ ដោយសារបឹងព្រះស្ដេច ដែលជាបឹងអភិរក្សរបស់ខ្លួនបានគោករាក់អស់ទៅហើយ ។ សហគមន៍កំពុងពិចារណា ស្នើសុំបឹងបាក់ក្រជីង ទំហំ ៧ហ.ត ដើម្បីធ្វើជាបឹងអភិរក្សជំនួសវិញ ។



ទី២. មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងតំបន់សិក្សារួមមាន ៖ ធ្វើស្រែវស្សា- ស្រែប្រាំងប្រមាណ ៨០%, ក្រៅពីនេះជាអ្នកលក់ដូរ, នេសាទនៅរដូវទឹកដំឡើង, ចំណាកស្រុក ធ្វើសំណង់, រោងចក្រកាត់ដេរ និងចិញ្ចឹមសត្វគោ ក្របី មាន់ ទា ជាដើម ។

ទី៣. សហគមន៍បានទទួលការចូលរួមពីដៃគូមួយចំនួន ក្នុងកិច្ចការការពារ អភិរក្សធនធានធម្មជាតិរួមមាន ៖ រដ្ឋបាលជលផល ធនាគារអភិវឌ្ឍន៍អាស៊ី ADB, អង្គការអភិវឌ្ឍន៍នារីខ្មែរ និងអង្គការ មិត្តជនបទ, អង្គការស្ដារកម្ពុជា ដោយផ្ដោតសំខាន់លើសកម្មភាពចុះល្បាតប្រចាំខែ ការបោះបង្គោលព្រំដែនការពារ ដាំកូនព្រៃលិចទឹក ។

ទី៤. ធនធានត្រីថយចុះ បើប្រៀបធៀបនឹង ៤-៥ឆ្នាំចុងក្រោយនេះ ដោយសារ ការប្រើជី ថ្នាំកសិកម្ម ការបាត់បង់ព្រៃលិចទឹក, បទល្មើសប្រើប្រាស់ឧបករណ៍ខុសច្បាប់ និងការបូមទឹកច្រើនធ្វើស្រែប្រាំងហួសកម្រិត ។

សូមជម្រាបជូនថា : សកម្មភាពសិក្សាស្វែងយល់ពិគ្រោះយោបល់ ប្រាស្រ័យទាក់ទង និងចែករំលែកការយល់ដឹងជាមួយ Environmental Think Tanks និងសម្របសម្រួលទំនាក់ ទំនងបណ្ដាញការងារ Think Tanks ។

មានគោលបំណងដើម្បី :

- ពិគ្រោះយោបល់ និងសិក្សាស្វែងយល់ ដើម្បីប្រមូលចងក្រងរាល់ព័ត៌មានទិន្នន័យ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានកម្របឹងទន្លេសាប ។
- ចែករំលែកការយល់ដឹងពីហេតុផលប៉ះពាល់ និងការផ្ដួចផ្ដើមគំនិតក្នុងការការពារធនធានកម្រនៃបឹងទន្លេសាប ។
- ចងក្រងបណ្ដាញទំនាក់ទំនងជាមួយ Environmental Think Tanks ក្នុងកិច្ចសហប្រតិបត្តិ ការចែករំលែកព័ត៌មានទិន្នន័យក្នុងការចូលរួមដល់ការគ្រប់គ្រង អភិរក្ស និងអភិ វឌ្ឍន៍ធនធានកម្របឹងទន្លេសាប ។

# និរន្តរភាពសហគមន៍ជុំវិញបឹងទន្លេសាប ជាមួយ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

ខេត្តកំពង់ធំ : នៅថ្ងៃពុធ ១៣រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០២៣ មន្ត្រីនាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ដឹកនាំដោយ លោក លឹម ហេង អនុប្រធាននាយកដ្ឋាន បានបន្តចុះសិក្សាស្វែងយល់ពីនិរន្តរភាពសហគមន៍ជុំវិញបឹងទន្លេសាបជាមួយគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ស្ថិតនៅក្នុងឃុំត្រពាំងឫស្សី និងឃុំសាន់គ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។



ការសិក្សានេះ ក្រុមការងារស្រាវជ្រាវបាន៖

ទី ១/. ជួបជាមួយអាជ្ញាធរដែនដី និងសហគមន៍នេសាទ

ទី ២/. ជួបសម្ភាសន៍ជាមួយប្រជាពលរដ្ឋ ពីស្ថានភាពទូទៅពាក់ព័ន្ធនឹងជីវភាពរស់នៅ និងធនធាននៅក្នុងតំបន់។

ជាមួយនឹងសកម្មភាពនេះដែរ ការសិក្សានៅតំបន់ពាក់ព័ន្ធខាងលើ ទទួលបានលទ្ធផល ដូចខាងក្រោម៖

ទី១/.ស្ថានភាពទូទៅក្នុងដែនអភិរក្សរបស់សហគមន៍នេសាទសាមគ្គីអភិវឌ្ឍន៍បឹងស្លង់ សហគមន៍មានផ្ទៃដីអភិរក្សសរុប ៥៧៥ហ.ត ដែលមានទំហំអន្លង់អភិរក្សត្រីមេពូជ ទំហំ ៧០ x ៦០០ម៉ែត្រ ។ ផ្ទៃដីព្រៃលិចទឹកក្នុងដែនរបស់សហគមន៍រងការកាប់ទន្ទ្រានពីសំណាក់ក្រុមហ៊ុន និងប្រជាជនប្រមាណជា ៧០ហ.ត ដើម្បីយកដីធ្វើស្រែប្រាំង ។



ទី២/.មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងតំបន់សិក្សារួមមាន៖ ធ្វើស្រែប្រាំង ៨៥%(២ដង/ឆ្នាំ), មន្ត្រីរាជការ, លក់ដូរតាមផ្ទះ, នេសាទនៅរដូវទឹកដំឡើងបន្ទាប់ពីបញ្ចប់ការងារកសិកម្ម, ចំណាកស្រុកធ្វើសំណង់, រោងចក្រកាត់ដេរជាដើម ។

ទី៣/.សហគមន៍បានទទួលការចូលរួមពីសំណាក់ដៃគូមួយចំនួនដែលបានចូលរួមចំណែកក្នុងកិច្ចការការពារ អភិរក្សធនធានធម្មជាតិរួមមាន ៖ រដ្ឋបាលជលផល អង្គការអភិវឌ្ឍន៍នារីខ្មែរ និងអង្គការJICA ផ្តោតលើសកម្មភាពការបោះបង្គោលព្រំដែនការពារ ដាំកូនឈើ ស្តារអន្លង់អភិរក្ស និងការល្បាតតំបន់អភិរក្ស ។

ទី៤/.ធនធានត្រីថយចុះប្រមាណជា ៣០% បើប្រៀបធៀបនឹង៥ឆ្នាំមុន ដោយសារ ការប្រើជី ថ្នាំកសិកម្ម ការបាត់បង់ព្រៃលិចទឹក, បទល្មើសប្រើប្រាស់ឧបករណ៍ខុសច្បាប់ និងការបូមទឹកច្រើនធ្វើស្រែប្រាំងហួសកម្រិត ។

សូមជម្រាបជូនថា : សកម្មភាពសិក្សាស្វែងយល់ពីនិរន្តរភាពសហគមន៍ជុំវិញបឹងទន្លេសាបជាមួយគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដើម្បីស្វែងយល់អំពីកម្រិតវិសាលភាពក្នុងការអភិវឌ្ឍន៍គោលសម្រួលស្ថាប័នពាក់ព័ន្ធ និងដៃគូអភិវឌ្ឍន៍ក្នុងការចូលរួមគាំទ្រសកម្មភាពនៃការអភិវឌ្ឍន៍សហគមន៍គ្រប់គ្រង និងអភិវឌ្ឍន៍តំបន់បឹងទន្លេសាប ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ប្រកបដោយចីរភាព ។






នៅថ្ងៃអង្គារ ២រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០២៣ មន្ត្រីនាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ដឹកនាំដោយ លោក យ៉ាន់ សំរិទ្ធ ប្រធាននាយកដ្ឋាន បានបន្តចុះសិក្សាស្វែងយល់ពីនិរន្តរភាពសហគមន៍ជុំវិញបឹងទន្លេសាប ជាមួយគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងពិគ្រោះយោបល់ប្រាស្រ័យទាក់ទង និងចែករំលែកការយល់ដឹងជាមួយ environmental think tanks និងសម្រប សម្រួលទំនាក់ទំនងបណ្តាញការងារ think tanks ស្ថិតនៅក្នុងឃុំតាប៉ុន ស្រុកសង្កែ និងឃុំតាលាស់ ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។

ការសិក្សានេះ ក្រុមការងារស្រាវជ្រាវបាន៖

១. ជួបពិភាក្សាការងារជាមួយអាជ្ញាធរដែនដី និងសហគមន៍នេសាទស្វាយស សហគមន៍បឹងទឹម សហគមន៍បាសែត និងសហគមន៍ម៉ាណោក-សួស្តី

២. ជួបជាមួយប្រជាពលរដ្ឋ ពីស្ថានភាពទូទៅពាក់ព័ន្ធនឹងជីវភាពរស់នៅ និងធនធាននៅក្នុងតំបន់។

ជាមួយនឹងសកម្មភាពនេះដែរ ការសិក្សានៅតំបន់ពាក់ព័ន្ធខាងលើ ទទួលបានលទ្ធផល ដូចខាងក្រោម៖

ទី១. មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងតំបន់សិក្សារួមមាន



ធ្វើស្រែវស្សា- ស្រែប្រាំងប្រមាណ ៨០%, អ្នកលក់ដូរនៅតាមផ្ទះ, នេសាទត្រី, ចំណាកស្រុក ធ្វើសំណង់ និងស៊ីឈ្នួលវិស័យកសិកម្ម, រោងចក្រកាត់ដេរ និងចិញ្ចឹមសត្វគោ ក្របី មាន់ ទា ជាដើម ។

ទី២. សហគមន៍នេសាទទាំងនេះទទួលបានការគាំទ្រតិចតួច ប៉ុណ្ណោះពីអង្គការដៃគូតាមរយៈរដ្ឋបាលជលផលសម្រាប់ការងារចុះល្បាត និងបង្ក្រាបបទល្មើស ។រីឯអង្គការដៃគូមួយចំនួនទៀតដែលធ្លាប់បានគាំទ្រកន្លងមកបានបញ្ចប់គម្រោងរបស់ពួកគេ ។ ដូច្នេះ សហគមន៍នេសាទទាំងបីខាងលើ បាន និងកំពុងជួបនឹងបញ្ហាប្រឈមមួយចំនួនក្នុងការអនុវត្តការងាររបស់ខ្លួនក្នុងការអភិរក្សធនធានធម្មជាតិ ។

ទី៣. ធនធានត្រីថយចុះ បើប្រៀបធៀបនឹង ៤-៥ឆ្នាំមុន ដោយសារមានកត្តាមួយចំនួន ការប្រើជី ថ្នាំកសិកម្ម ការបាត់បង់ព្រៃលិចទឹក បទល្មើសប្រើប្រាស់ឧបករណ៍ខុសច្បាប់ និងការគោករាក់ព្រែក បឹងផ្សេងៗ ។

សូមជម្រាបជូនថា : សកម្មភាពសិក្សាស្វែងយល់ពីនិរន្តរភាពសហគមន៍ជុំវិញបឹងទន្លេសាប ជាមួយគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងពិគ្រោះយោបល់ ប្រាស្រ័យទាក់ទង និងចែករំលែកការយល់ដឹងជាមួយ environmental think tanks និង សម្របសម្រួលទំនាក់ ទំនងបណ្តាញការងារ think tanks មានគោលបំណងដើម្បី ៖

- ពិគ្រោះយោបល់ និងសិក្សាស្វែងយល់ ដើម្បីប្រមូលចងក្រងរាល់ព័ត៌មានទិន្នន័យ ដែលពាក់ព័ន្ធនឹងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានកម្រប៉ឹងទន្លេសាប ។
- ចែករំលែកការយល់ដឹងពីហេតុផលប៉ះពាល់ និងការផ្តួចផ្តើមគំនិតក្នុងការការពារធនធានកម្រនៃបឹងទន្លេសាប ។
- ចងក្រងបណ្តាញទំនាក់ទំនងជាមួយ environmental think tanks ក្នុងកិច្ចសហប្រតិបត្តិ ការចែករំលែកព័ត៌មានទិន្នន័យក្នុងការចូលរួមដល់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានកម្របឹងទន្លេសាប ។



# សិក្សាពីប្រសិទ្ធភាពលើការអនុវត្ត និងយន្តការគន្លឹះក្នុងការកសាងផែនការ គ្រប់គ្រងសហគមន៍ប្រកបដោយ និរន្តរភាព- នៅតំបន់បឹងទន្លេសាបជំហាន ២ ឆ្នាំ ២០២៣




ខេត្តពោធិ៍សាត់: ថ្ងៃអង្គារ ១២រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីនាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយនៃអគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប ដឹកនាំដោយ លោក យ៉ាន់ សំរិទ្ធ ប្រធាននាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ បានបន្តចុះអនុវត្តសកម្មភាពសិក្សាពីប្រសិទ្ធភាពលើការអនុវត្ត និងយន្តការគន្លឹះក្នុងការកសាងផែនការគ្រប់គ្រងសហគមន៍នេសាទប្រកបដោយនិរន្តរភាព។

ការចុះសិក្សានេះក្រុមការងារបានចុះ៖

ទី ១/. ជួបពិភាក្សាជាមួយអាជ្ញាធរដែនដី ឃុំរាំងទិល និងឃុំស្រែស្តុក

ទី ២/. ជួបពិភាក្សាជាមួយសហគមន៍នេសាទកោះព្រែករាំងទិល ក្នុងឃុំរាំងទិល និងសហគមន៍នេសាទចំរេះ ក្នុងឃុំស្រែស្តុក ។

# ជាមួយនឹងសកម្មភាពក្រុមការងារចុះសិក្សានៅតំបន់ពាក់ព័ន្ធខាងលើ ជាលទ្ធផលឃើញថា ៖

ទី១/. ស្ថានភាពទូទៅសហគមន៍នេសាទកោះព្រែករាំងទិល ដែលបង្កើតឆ្នាំ២០០១ មានសមាជិកគណៈកម្មការសរុបចំនួន



១១នាក់ (ស្រី ១នាក់) ។ សហគមន៍នេះ មានដំណើរការងារជាប្រចាំថ្ងៃ ដោយអនុវត្តទៅតាមផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍កោះព្រែករាំងទិល ក្រោមជំនួយគាំទ្រទាំងបច្ចេកទេស សម្ភារៈ និងថវិកា ពីអង្គការ (WCS, CI និង Rico) និងខណ្ឌជលផល។

ទី២/. ស្ថានភាពទូទៅសហគមន៍នេសាទចំរេះ ចាប់ផ្តើមដំណើរការនៅឆ្នាំ២០០៨ ដែលមានសមាជិកគណៈកម្មការសរុបចំនួន ១១នាក់ (ស្រី ១នាក់) ដោយមានការជួយគាំទ្រពីអង្គការហៅកាត់ថា អកអ (បានបណ្តុះបណ្តាលដល់គណៈកម្មការពីការងារគ្រប់គ្រងសហគមន៍) និងជំនួយពី ADB (ការងារចុះល្បាតសម្ភារៈ និងបោះបង្គោលព្រំតំបន់អភិរក្សចំរេះ ទំហំ ២១ហ.ត) រយៈពេល ០៣ឆ្នាំកន្លងមក។

ទី៣/បច្ចុប្បន្ន ពួកគេបានកំពុងជួបកង្វះនូវធនធានមនុស្ស ថវិកា សម្ភារៈ បច្ចេកទេស គាំទ្រដល់ដំណើរការងារប្រចាំថ្ងៃរបស់គណៈកម្មការសហគមន៍ និងថវិកា ក្នុងការអនុវត្តផែនការសកម្មភាពរបស់សហគមន៍នៅមានដែនកំម្រិត។

# សូមជម្រាបជូនថា: សកម្មភាពចុះសិក្សាពីប្រសិទ្ធភាពលើការអនុវត្ត និងយន្តការគន្លឹះក្នុងការកសាងផែនការគ្រប់គ្រងសហគមន៍នេសាទប្រកបដោយនិរន្តរភាព ខាងលើនេះ មានគោលបំណងស្វែងយល់ :

- ១/.យន្តការគន្លឹះក្នុងការរៀបចំផែនការគ្រប់គ្រងសហគមន៍
- ២/. ប្រសិទ្ធភាពនៃការអនុវត្តផែនការគ្រប់គ្រងសហគមន៍នេសាទនៅតាមបណ្តាសហគមន៍នេសាទ និង
- ៣/. កិច្ចសហការ សម្របសម្រួល ជាមួយនឹងស្ថាប័នជំនាញ និងអ្នកពាក់ព័ន្ធ ក្នុងការគ្រប់គ្រងធនធានធម្មជាតិនៅតំបន់បឹងទន្លេសាប ។

ផែនការយុទ្ធសាស្ត្រ គោលនយោបាយ និងសេដ្ឋកិច្ចជលផល



នាថ្ងៃពុធ ៣ កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រុមការងារមន្ត្រីនាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ នៃអាជ្ញាធរទន្លេសាប ដឹកនាំដោយ លោក អុល សុជាតិ ប្រធានការិយាល័យសម្របសម្រួលវិវាទ បានដឹកនាំក្រុមការងារ ចុះអនុវត្តបញ្ចប់សកម្មភាពសិក្សាពីប្រសិទ្ធភាពលើការអនុវត្ត និងយន្តការគន្លឹះក្នុងការកសាងផែនការគ្រប់គ្រងសហគមន៍នេសាទប្រកបដោយនិរន្តរភាព ប្រចាំឆ្នាំ២០២៣។

ការចុះសិក្សានេះ ក្រុមការងារបាន ៖

ទី ១. ជួបពិភាក្សាជាមួយអាជ្ញាធរដែនដី ឃុំរហាល និងឃុំប្រាសាទ។

ទី ២. ជួបពិភាក្សាជាមួយសហគមន៍នេសាទស្ទឹងកំបុតមានជ័យ ក្នុងឃុំរហាល និងសហគមន៍នេសាទដង្កៀបក្ដាមមានជ័យ ក្នុងឃុំប្រាសាទ ស្រុកព្រះនេត្រព្រះ ។

សម្រាប់ការអនុវត្តសកម្មភាពសិក្សានៅតំបន់ពាក់ព័ន្ធខាងលើ ជាលទ្ធផល បានបង្ហាញឲ្យឃើញថា ៖

១. ស្ថានភាពសហគមន៍ក្នុងការគ្រប់គ្រងធនធានធម្មជាតិ :

- ចំណេះដឹងរបស់គណៈកម្មការសហគមន៍នេសាទទាំង២ នៅមានកម្រិត ដែលជាផលវិបាក ក្នុងការដឹកនាំ អនុវត្តន៍ការងារ អោយមានប្រសិទ្ធភាព



- កង្វះការចូលរួមក្នុងការការពារ អភិរក្ស និងអភិវឌ្ឍន៍ធនធានធម្មជាតិ ជាពិសេស កម្លាំងស្នូលយុវជន នៅតាមសហគមន៍នេសាទនីមួយៗ

- កង្វះការបណ្ដុះបណ្ដាលសមត្ថភាពគណៈកម្មការសហគមន៍នេសាទ ជាពិសេស បច្ចេកទេសសំខាន់ៗ ដូចជា: ការរៀបចំកសាងផែនការគ្រប់គ្រងសហគមន៍ របៀបសរសេររបាយការណ៍ និងសំណើគម្រោងគាំទ្រសកម្មភាពជាដើម

- កង្វះការគាំទ្រនូវមធ្យោបាយ សម្ភារៈ ធនធានថវិកា សម្រាប់គាំទ្រដំណើរការការងារប្រចាំថ្ងៃ។

២. ប្រសិទ្ធភាពការអនុវត្ត ផែនការគ្រប់គ្រងសហគមន៍ :

- ការអនុវត្តផែនការគ្រប់គ្រងសហគមន៍មិនបានពេញលេញ និងមិនឆ្លើយតបទៅ នឹងទំហំការងារ និងការទទួលខុសត្រូវរបស់គណៈកម្មការសហគមន៍

- ប្រភពធនធានថវិកា សម្រាប់ការគាំទ្រដំណើរការអនុវត្តផែនការ គឺមានកម្រិត បើធៀបទៅនឹងផែនការគ្រប់គ្រងសហគមន៍ទាំងមូល

- កង្វះការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលក្ខណៈស៊ីជម្រៅទៅលើប្រសិទ្ធភាពនៃការអនុវត្តផែនការគ្រប់គ្រងសហគមន៍ពីសំណាក់អ្នកពាក់ព័ន្ធ។

សូមជម្រាបជូនថា : សកម្មភាពចុះសិក្សាពីប្រសិទ្ធភាពលើការអនុវត្ត និងយន្តការគន្លឹះក្នុងការកសាងផែនការគ្រប់គ្រងសហគមន៍នេសាទប្រកបដោយនិរន្តរភាព ខាងលើនេះ មានគោលបំណងស្វែងយល់ ៖

- យន្តការគន្លឹះក្នុងការរៀបចំផែនការគ្រប់គ្រងសហគមន៍

- ប្រសិទ្ធភាពនៃការអនុវត្តផែនការគ្រប់គ្រងសហគមន៍នេសាទនៅតាមបណ្ដាសហគមន៍នេសាទ

- កិច្ចសហការ សម្របសម្រួល ជាមួយនឹងស្ថាប័នជំនាញ និងអ្នកពាក់ព័ន្ធ ក្នុងការគ្រប់គ្រងធនធានធម្មជាតិនៅតំបន់បឹងទន្លេសាប ។




ផែនការយុទ្ធសាស្ត្រ គោលនយោបាយ និងសេដ្ឋកិច្ចសង្គម

# ពង្រឹងនិងពង្រីកការកសាងសមត្ថភាព

## វគ្គបណ្តុះបណ្តាលពីការសិក្សាពីប្លង់តុងរុក្ខជាតិ និងប្លង់តុងសត្វទឹកសាប សម្រាប់បឹងទន្លេសាប

រាជធានីភ្នំពេញ : ដើម្បីពង្រឹងសមត្ថភាព និងបង្កើនចំណេះដឹងបន្ថែមដល់មន្ត្រីបច្ចេកទេស នៅថ្ងៃទី ១៥-១៦ ខែឧសភា ឆ្នាំ ២០២៣ អាជ្ញាធរទន្លេសាប បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការសិក្សាពីប្លង់តុងរុក្ខជាតិ និងប្លង់តុងសត្វទឹកសាប សម្រាប់បឹងទន្លេសាប ក្រោមការដឹកនាំ និងសម្របសម្រួលដោយឯកឧត្តមសាស្ត្រាចារ្យ លឹម ពុយ អនុប្រធានអាជ្ញាធរទន្លេសាប ដោយមានការចូលរួមពីមន្ត្រីបច្ចេកទេសអាជ្ញាធរទន្លេសាប ចំនួន ១៥នាក់។







នៅក្នុងវគ្គបណ្តុះបណ្តាលជំហានទី១នេះ គឺផ្តោតសំខាន់លើការសិក្សាជាទ្រឹស្តី និងការអនុវត្តផ្ទាល់ នៃលក្ខណៈសំគាល់របស់ពពួកប្លង់តុង និងវដ្តជីវិតប្លង់តុងជាពិសេសប្លង់តុងដែលទាក់ទងនឹងការលូតលាស់របស់ពពួកត្រីស និងការអនុវត្តដោយផ្ទាល់ក្នុងការយកសំណាក ការរក្សាទុកសំណាក ការរៀបចំសំណាកពីនិត្យនៅមន្ទីរពិសោធន៍លើប្រភេទប្លង់តុងនីមួយៗ គុណវិបត្តិរបស់ប្លង់តុងលើគុណភាពទឹក និងការសរសេររបាយការណ៍លើ Primary production។

## សកម្មភាពវគ្គបណ្តុះបណ្តាល ស្តីពី Introduction to eSource Hydrological Modelling របស់គម្រោងកែលម្អវិស័យធារាសាស្ត្រកសិកម្ម



កាលពីថ្ងៃទី ២៦-២៧ ខែមិថុនា ឆ្នាំ ២០២៣ លោក វិន ប៊ុនពៅ ប្រធាននាយកដ្ឋាន និងមន្ត្រីក្រុមការងារបច្ចេកទេស នៃនាយកដ្ឋានធនធានធម្មជាតិ បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី Introduction to eSource Hydrological Modelling របស់គម្រោងកែលម្អវិស័យធារាសាស្ត្រកសិកម្ម (Irrigated Agriculture Improvement Project, IAIP) នៅសាលប្រជុំក្រសួងធនធានទឹក និងឧតុនិយម មានអញ្ជើញចូលរួមពីតំណាងក្រសួងធនធានទឹក និងឧតុនិយម អាជ្ញាធរទន្លេសាប គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា អគ្គិសនីកម្ពុជា និងមន្ត្រីដែលពាក់ព័ន្ធជាមួយគម្រោងមកពីក្រសួងស្ថាប័ន។

វគ្គបណ្តុះបណ្តាលនេះ មានគោលបំណង ៖

- គ្រប់គ្រងធនធានទឹកក្នុងព្រះរាជាណាចក្រកម្ពុជា តាមកម្មវិធី eWater Source
- ប្រើប្រាស់ម៉ូដែល និងធ្វើបច្ចុប្បន្នភាពវិស័យធនធានទឹកសម្រាប់ពេលអនាគតតាមកម្មវិធី eWater Source និង
- វិភាគ និងវាយតម្លៃពីការប្រែប្រួល នៃវិស័យធនធានទឹកក្នុងអាងទន្លេ និងអនុអាងទន្លេតាមរយៈម៉ូដែល eWater Source ។

## ការរៀបចំបណ្ដុះបណ្ដាលដល់សមាជិកក្រុមការងារពិនិត្យតាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក ជុំវិញតំបន់បឹងទន្លេសាប



ព្រឹកថ្ងៃព្រហស្បតិ៍ ១០រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី ០៧ ខែធ្នូ ឆ្នាំ ២០២៣ នៅអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប បានរៀបចំវគ្គបណ្ដុះបណ្ដាលការងារបច្ចេកទេសក្នុងការចុះពិនិត្យតាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹកជុំវិញតំបន់បឹងទន្លេសាបដោយប្រើប្រាស់ប្រព័ន្ធ KoboCllection ដឹកនាំដោយ ឯកឧត្ដម សរ គឹមសាន្ត អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ដើម្បីត្រៀមលក្ខណៈ ក្នុងការចុះអនុវត្តការងារតាមដានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់និយាមកាបង្គោលព្រំការពារដែនព្រៃលិចទឹក និងតំបន់កាត់ឆ្វៀល ក្នុងតំបន់ ១ តំបន់ ២ និងតំបន់ ៣ ដែលស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ ។ សូមបញ្ជាក់ថា : រាជរដ្ឋាភិបាលបានកាត់ឆ្វៀលដីមួយចំនួនចេញពីដែនព្រៃលិចទឹកពីតំបន់៣ មកតំបន់២ និង. ពីតំបន់២ មកតំបន់១ នៃអនុក្រឹត លេខ ១៩៧ អនក្រ.បក ចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១១ ជូនប្រជាពលរដ្ឋ អាស្រ័យផល និងតាំងទីលំនៅ ។ ហើយបច្ចុប្បន្នក្រុមការងារអាជ្ញាធរទន្លេសាប បាន និងកំពុងបន្តអនុវត្តន៍តួនាទីភារកិច្ច ក្នុងការប្រមូលផ្ទៀងផ្ទាត់ទិន្នន័យ ព័ត៌មានជាក់លាក់ ដើម្បីពិភាក្សាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងថ្នាក់ក្រោមជាតិនៃខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប និងឈានទៅរៀបចំរបាយការណ៍ជូនថ្នាក់ដឹកនាំ និងប្រមុខរាជរដ្ឋាភិបាល ។

## វគ្គបណ្ដុះបណ្ដាលថ្នាក់ជាតិ ស្ដីពីប្រព័ន្ធព័ត៌មាន ប្រព័ន្ធគ្រប់គ្រងឯកសារ និងផែនទីអាងទន្លេមេគង្គ នៅខេត្តកំពង់ចាម



នាថ្ងៃអង្គារ ២កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២៣ លោក សុខ មុនី ប្រធានការិយាល័យនីតិកម្ម នៃនាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ និងជាមន្ត្រីទុកដាក់ទិន្នន័យ នៃអាជ្ញាធរទន្លេសាប បានចូលរួមវគ្គបណ្ដុះបណ្ដាលថ្នាក់ជាតិ ស្ដីពីប្រព័ន្ធព័ត៌មាន ប្រព័ន្ធគ្រប់គ្រងឯកសារ និងផែនទីអាងទន្លេមេគង្គ ដែលរៀបចំដោយគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ក្រោមអធិបតីភាព ឯកឧត្ដម សូ សុភ័ទ្ធ អគ្គលេខាធិការគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (គជទមក) នៅខេត្តកំពង់ចាម។

វគ្គបណ្ដុះបណ្ដាលនេះ ក្នុងគោលបំណងដើម្បីៈ

១. បង្ហាញពីវឌ្ឍនភាពនៃប្រព័ន្ធគ្រប់គ្រងឯកសារ (DoMS) និងការអនុវត្តជាក់ស្ដែង ក្នុងការលើកកម្ពស់ការប្រើប្រាស់មុខងារ និងបង្ហាញពីឧបករណ៍ សេវាកម្មដែលបានធ្វើឲ្យប្រសើរឡើងនៃសេវាកម្មគេហទំព័រព័ត៌មាននៃប្រព័ន្ធព័ត៌មានរបស់ MRC ទៅកាន់អ្នកប្រើប្រាស់ទិន្នន័យ។

២. បង្ហាញពីវឌ្ឍនភាពនៃផែនទីអាងទន្លេមេគង្គ និងការកែប្រែថ្មីអ្នកប្រើប្រាស់ទិន្នន័យ ។

សូមជម្រាបជូនថា វគ្គបណ្ដុះបណ្ដាលនេះ បានអញ្ជើញចូលរួមពីមន្ត្រីតំណាងក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងបរិស្ថាន, ក្រសួងផែនការ, អាជ្ញាធរទន្លេសាប និងមន្ត្រីពី គ.ជ.ទ.ម.ក និងជំនាញការជាតិ អន្តរជាតិ សរុបចំនួន ២៨ រូប។

## សិក្សាស្រាវជ្រាវលើចក្ខុវិស័យរបស់អ្នកពាក់ព័ន្ធថ្នាក់ក្រោមជាតិចំពោះបឹងទន្លេសាប

កាលពីថ្ងៃទី០៤ ដល់ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៣ ឯកឧត្តម ជា សុខនី អគ្គលេខាធិការរង នៃអាជ្ញាធរទន្លេសាប បានដឹកនាំក្រុមការងារ ចុះសិក្សា ស្រាវជ្រាវ លើសកម្មភាពចក្ខុវិស័យរបស់អ្នកពាក់ព័ន្ធថ្នាក់ក្រោមជាតិចំពោះបឹងទន្លេសាប ស្ថិតនៅឃុំស្នាមព្រះ ស្រុកបាកាន ខេត្តពោធិ៍សាត់។



គោលបំណង៖សិក្សា ស្រាវជ្រាវ និងចងក្រងពីចក្ខុវិស័យថ្នាក់ក្រោមជាតិនាបច្ចុប្បន្ន និងពេលអនាគតដើម្បីបានជាធាតុចូលម្រាប់រៀបចំផែនការយុទ្ធសាស្ត្ររបស់បឹងទន្លេសាប។

លទ្ធផលសង្ខេប៖ ទទួលបានជាធាតុចូលចក្ខុវិស័យថ្នាក់ក្រោមជាតិអំពីចំនុចវិជ្ជមាន/អវិជ្ជមានក្នុងវិស័យសេដ្ឋកិច្ចសង្គម បរិស្ថាន ធនធានធម្មជាតិ ធនធានទឹក និង ធនធានជលផល ដែលជះឥទ្ធិពលដល់បឹងទន្លេសាប និងតំបន់ពាក់ព័ន្ធផ្សេងៗទៀត។

# សកម្មភាពសិក្សាការយល់ដឹងពីការចូលរួមយេនឌ័រលើកិច្ចការពារធនធានធម្មជាតិ

សកម្មភាពសិក្សាស្វែងយល់ពីការលើកកម្ពស់ការចូលរួម របស់យេនឌ័រលើកិច្ចការពារ គ្រប់គ្រង និងអភិរក្ស ធនធានធម្មជាតិនៅជុំវិញបឹងទន្លេសាប



ខេត្តកំពង់ធំ



ខេត្តបន្ទាយមានជ័យ



ខេត្តសៀមរាប



ខេត្តពោធិ៍សាត់



ខេត្តបាត់ដំបង

# II

# សកម្មភាពការងារកិច្ចសហប្រតិបត្តិការ

## គម្រោងការគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន ( Stung Sen IWRM )

### ឯកឧត្តមសាស្ត្រាចារ្យ លឹម ពុយ អញ្ជើញចូលរួមពិធីសម្ពោធដាក់ឱ្យដំណើរការប្រើប្រាស់ស្ថានីយផលិតទឹកស្អាត ខេត្តព្រះវិហារ

នាព្រឹកថ្ងៃទី 7 ខែធ្នូ ឆ្នាំ 2022 កន្លងទៅនេះ ឯកឧត្តមសាស្ត្រាចារ្យ លឹម ពុយ អនុប្រធានអាជ្ញាធរទន្លេសាប និងជាប្រធានក្រុមការងារគម្រោងគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន បានបន្តដឹកនាំគណៈប្រតិភូទីភ្នាក់ងារទឹកបារាំង ក្នុងពិធី ″សម្ពោធដាក់ឱ្យដំណើរការប្រើប្រាស់ស្ថានីយផលិតទឹកស្អាតឃុំទឹកក្រហម ស្រុកជាំក្សាន្ត ខេត្តព្រះវិហារ ″ ក្រោមអធិបតីភាពឯកឧត្តមសាស្ត្រាចារ្យ លឹម ពុយ តំណាងទីភ្នាក់ងារទឹកបារាំងរីនម៉ឺស (Rhin-Meuse) និងឯ.ឧ ព្រឹម រដ្ឋា ជាប្រធានក្រុមប្រឹក្សាភិបាល នៃគណៈកម្មការគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែនសម្រាប់ពាក់កណ្តាលអាណត្តិដំបូងឆ្នាំ 2023-2028 ។

ពិធីនេះ មានព្រះសង្ឃសូត្រជយន្តោ និងការរាំរបាំបាចផ្កាជូនពរដោយកុមារីដែលជាសិស្សនៅសាលាបឋម និងមានការចូលរួមពីមន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រះវិហារ និងកំពង់ធំ, លោកអភិបាលស្រុកជាំក្សាន្ត, សមាជិកក្រុមប្រឹក្សាភិបាលសមាគមទឹកស្អាតអាងស្ទឹងសែន, អង្គការ GESCOD, អង្គភាព SDEA, អាជ្ញាធរឃុំ/ភូមិ ព្រះសង្ឃ, ប្រជាពលរដ្ឋ, កងកម្លាំងនៃស្រុក និងលោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស សរុបប្រមាណ 150 នាក់ក្រោមការរៀបចំកម្មវិធីដោយអង្គការទឹកភ្លៀងកម្ពុជា ។

ស្ថានីយផលិតទឹកស្អាតឃុំទឹកក្រហមនេះ គឺជាស្ថានីយ៍ទី 7 ហើយ ដែលត្រូវបានសាងសង់ឡើងក្រោមជំនួយឥតសំណងរបស់ទីភ្នាក់ងារទឹកបារាំង (Rhin-Meuse ) ដោយចំណាយទឹកប្រាក់អស់ចំនួន 180000 ដុល្លារ ។ ការសាងសង់នេះអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាលបារាំងឈ្មោះ GESCOD



ដោយមានចុះកិច្ចព្រមព្រៀងជាមួយអង្គការទឹកភ្លៀងកម្ពុជា ដើម្បីសហការអនុវត្តគម្រោងគាំទ្រគណៈកម្មការគ្រប់គ្រងទឹកក្នុងប្រតិបត្តិការផ្គត់ផ្គង់ទឹកស្អាតនៅឃុំទឹកក្រហម ស្រុកជាំក្សាន្តរយៈពេល 1 ឆ្នាំ។

ស្ថានីយផលិតទឹកស្អាតឃុំទឹកក្រហមនេះ ចាប់ផ្តើមសាងសង់នៅថ្ងៃទី 16 ខែមីនា ឆ្នាំ 2022 និងបានបញ្ចប់ការសាងសង់នៅថ្ងៃទី 25 ខែវិច្ឆិកា ឆ្នាំ 2022 ដែលអាចផលិតទឹកស្អាត 45ម៉ែត្រគូប និងអាចផ្គត់ផ្គង់ទឹកស្អាត និងចែកចាយទុយោគ្របដណ្តប់ចំនួន 2 ឃុំនៅភូមិទឹកក្រហម អូរក្សាន្ត សង្គមថ្មីដែលស្ថិតនៅ



ឃុំទឹកក្រហម និងភូមិជាំក្សាន្ត ស្ថិតនៅក្នុងឃុំជាំក្សាន្ត។ កន្លែងចែកចាយទឹក ចែកជា 2 ផ្នែក គឺ 1) ទុយោចែកចាយសម្រាប់តបណ្តាញតាមខ្នងផ្ទះបានចាប់ពី 100 គ្រួសារទៅ 150 គ្រួសារចំនួនប្រជាពលរដ្ឋប្រមាណ 600 នាក់ និង 2) កន្លែងយកទឹកសាធារណៈចំនួន 4 កន្លែងមាននៅ (សាលារៀនបឋមអូរក្សាន្តចំនួន 1, សាលាបឋមសិក្សាជាំក្សាន្តចំនួន 1, វត្តទួលអណ្តែតចំនួន 1 និងមន្ទីរពេទ្យបង្អែកជាំក្សាន្តចំនួន 1 ។

---------------------------------------------------

គិតមកដល់ពេលនេះ មានស្ថានីយ៍ផលិតទឹកស្អាត ចំនួន 07 ហើយដែលបានដាក់ជូនប្រជាជនប្រើប្រាស់ដែលជាជំនួយឥតចំណងរបស់ទីភ្នាក់ងារទឹកបារាំងរីនម៉ឺស (Rhin-Meuse) ស្ថិតនៅក្នុងគម្រោងការគ្រប់គ្រងធនធានទឹកចម្រុះនៃអាងស្ទឹងសែន ដែលអនុវត្តដោយអាជ្ញាធរទន្លេសាប នៃក្រសួងធនធានទឹកនិងឧតុនិយម ក្នុងនោះ ខេត្តកំពង់ធំ មានចំនួន 3 ស្ថានីយគឺ នៅឃុំងន និងឃុំមានជ័យ ស្រុកសណ្ដាន់ និងស្រុកប្រាសាទបល្ល័ង្គ ឃុំសាលាវិស័យចំនួន 1 ស្ថានីយ៍ និងខេត្តព្រះវិហារចំនួន 4 ស្ថានីយគឺ ឃុំថ្មី ស្រុកគូលែន, ឃុំរក្សា ស្រុករវៀង, ឃុំពុទ្រា ស្រុកជ័យសែន និងឃុំទឹកក្រហម ស្រុកជាំក្សាន្ត។



## ការសិក្សាលើរបបជលសាស្ត្រ និងទឹកភ្លៀងនៅតំបន់បឹងទន្លេសាប

តាមរយៈការសិក្សា និងតាមដានរបស់អាជ្ញាធរទន្លេសាប ក្រោមការដឹកនាំដោយឯកឧត្តម លឹម ពុយ អនុប្រធានអាជ្ញាធរទន្លេសាប លើបរិមាណទឹកភ្លៀងប្រចាំថ្ងៃនៅតាមបណ្ដាស្ថានីយវាស់ទឹកភ្លៀងចំនួន 07ទីតាំង នៅតាមភូមិបណ្ដែតទឹកជុំវិញបឹងទន្លេសាប បង្ហាញឲ្យឃើញថា រវាងឆ្នាំ 2021 និងឆ្នាំ 2022 កម្រិតទឹកភ្លៀងមានភាពប្រែប្រួលច្រើននៅតាមបណ្ដាទីតាំងវាស់កម្រិតទឹកភ្លៀង ។ ឧទាហរណ៍៖ នៅតំបន់ពាមបាង-បឹងទន្លេឆ្មារ កម្រិតទឹកភ្លៀង នៅឆ្នាំ 2021 មានប្រមាណ 1.112 mm ចំណែកនៅឆ្នាំ 2022 មានប្រមាណ 2.659 mm ដូច្នេះនៅតំបន់នេះ កម្រិតទឹកភ្លៀងនៅឆ្នាំ 2022 កើនឡើងប្រមាណ 2 ដងកន្លះ លើសឆ្នាំ 2021 ដូចបានបង្ហាញជូនក្នុងផែនទីខាងក្រោម។ ចំពោះភាពខុសគ្នានៃកម្ពស់ទឹកបឹងទន្លេសាបនៅឆ្នាំ 2021 និងឆ្នាំ 2022 នៅស្ថានីយជលសាស្ត្រក្រគរ-កំពង់លួង ដូចមានបង្ហាញជូនក្នុងក្រាហ្វិកនៃរូបភាពភ្ជាប់មកជាមួយ ។




## វឌ្ឍនភាពនៃការសាងសង់ស្ថានីយផ្គត់ផ្គង់ទឹកស្អាត ឃុំតាំងក្រសៅ សម្រេចបាន ៧០ %



វឌ្ឍនភាពនៃការសាងសង់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតឃុំតាំងក្រសៅ បានចាប់ផ្ដើមដំណើរការសាងសង់បើកការដ្ឋានសាងសង់ នៅថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ 2023។ មកដល់បច្ចុប្បន្ននេះស្ថានីយទឹកស្អាតឃុំតាំងក្រសៅបានសម្រេច ៧០ % នៃការងារសាងសង់ ។ ស្ថានីយទឹកស្អាតមានកំពស់ ១៨ ម៉ែត្រ ដែលអាចស្តុកទឹកបានចំណុះទឹក ៤៥ ម៉ែត្រគូប។ ស្ថានីយទឹកស្អាតឃុំតាំងក្រសៅទទួលបាននូវការគាំទ្រថវិកាជំនួយឥតចំណងពីទីភ្នាក់ងារទឹកបារាំង RHIN- MEUSE Water Agency – Toulouse Metropole និង HAMAP for Humanitaire តាមរយៈគម្រោងគ្រប់គ្រងធនធានទឹកចម្រុះនៃអាងស្ទឹងសែនដែលអនុវត្តដោយក្រុមការងារគម្រោងរបស់អាជ្ញាធរទន្លេសាប នៃក្រសួងធនធានទឹក និងឧតុនិយម លើការសាងសង់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតសម្រាប់ចែកចាយដល់ប្រជាពលរដ្ឋនៅក្នុងឃុំតាំងក្រសៅ ក្នុងគោលបំណងលើកកម្ពស់សុខភាពប្រជាពលរដ្ឋឲ្យប្រសើរឡើង និងរួមចំណែកកាត់បន្ថយភាពក្រីក្រ។ ស្ថានីយទឹកស្អាតឃុំតាំងក្រសៅអាចផ្គត់ផ្គង់ទឹកដល់ប្រជាពលរដ្ឋប្រើប្រាស់ចាប់ពី២០០ ទៅ ៣០០ គ្រួសារនៅក្នុងភូមិ ភូមិតាំងក្រសៅ ភូមិព្រៃក្ដី និងភូមិថ្មី រួមទាំងសាលារៀន និង វត្តអារាម។



## អាងទឹករក្សាអាចចាត់ទុកជាលំនៅដ្ឋានដ៏សំខាន់សម្រាប់ធនធានត្រីក្នុងការលូតលាស់ និងការបន្តពូជ






អាងទឹករក្សា ដែលចាប់ផ្តើមដំណើរការពីខែធ្នូ ឆ្នាំ 2022 មានផ្ទៃក្រឡាលិចទឹកនៅតំបន់ផ្នែកខាងលើអាងប្រមាណ 2000ha ដែលអាចចាត់ទុកជាលំនៅដ្ឋានដ៏សំខាន់សម្រាប់ធនធានត្រីក្នុងការលូតលាស់ និងការបន្តពូជ។ ប្រជានេសាទដែលរកត្រីជាលក្ខណៈគ្រួសារក្នុងអាងទឹករក្សា ចាប់បានត្រីធំៗដែលពុំបានជួបប្រទះមុនពេលមានអាងទឹកដូចជា ត្រីសណ្តាយ ត្រីក្អែក ត្រីកេស ។ល។ បង្ហាញឲ្យឃើញថាពេលដែលលំនៅដ្ឋាន ព្រមទាំងចំណីអាហារមានជាអតិបរមា ធនធានត្រីមានការកើនឡើងយ៉ាងឆាប់រហ័ស។

ក្រុមការងារគម្រោងគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន នឹងបន្តការតាមដានលើការលូតលាស់របស់ធនធានត្រីនៅអាងទឹករក្សា ដោយសហការជាមួយហ្នឹងមន្ទីរធនធានទឹក និងឧតុនិយមខេត្តព្រះវិហារ។

## ឯកឧត្តមសាស្ត្រាចារ្យ លឹម ពុយ អញ្ជើញដឹកនាំនិងសម្របសម្រួលកិច្ចប្រជុំពិភាក្សាស្តីពីការរៀបចំបង្កើតក្រុមការងារទឹកស្អាត និងក្រុមការងារធនធានទឹក និងកសិកម្ម



នាព្រឹកកាលពីថ្ងៃទី 29 ខែសីហា ឆ្នាំ 2023 វេលាម៉ោង 7h30 នាទីព្រឹក នៅសាលប្រជុំសាលាខេត្តកំពង់ធំ ឯកឧត្តមសាស្ត្រាចារ្យ លឹម ពុយ អនុប្រធានអាជ្ញាធរទន្លេសាប និងជាប្រធានក្រុមការងារគម្រោងការគ្រប់គ្រងធនធានទឹកចម្រុះ នៃអាងស្ទឹងសែន និងអមដំណើរដោយអ្នកជំនាញការរបស់ការិយាល័យទឹកអន្តរជាតិបារាំង ព្រមទាំង ឯកឧត្តម ព្រឹម រដ្ឋា ប្រធានក្រុមប្រឹក្សាភិបាល និងឯកឧត្តម អ៊ុក គឹមសាន អនុប្រធានក្រុមប្រឹក្សា បានអញ្ជើញដឹកនាំ



និងសម្របសម្រួលក្នុងកម្មវិធីកិច្ចប្រជុំពិភាក្សាស្តីពីការរៀបចំបង្កើតក្រុមការងារទឹកស្អាត និងក្រុមការងារធនធានទឹក និងកសិកម្ម របស់គម្រោងគ្រប់គ្រងធនធានទឹកចម្រុះ នៃអាងស្ទឹងសែន។ កិច្ចប្រជុំនេះ មានគោលបំណង ពិភាក្សា និសម្រេចលើការរៀបចំផែនការសកម្មភាព ដែលត្រូវអនុវត្តរបស់ក្រុមការងារទាំង 2 សម្រាប់ត្រីមាសទី 4 ឆ្នាំ 2023។

## ឯកឧត្តម លឹម ពុយ បានដឹកនាំក្រុមការងារចុះធ្វើការតាមដានស្ថានភាពធនធានត្រីនៅមុនពេល និងក្រោយពីមានទំនប់អាងទឹករក្សា



ថ្ងៃសុក្រ១២រោច ខែអស្សុជ ឆ្នាំថោះបញ្ចស័កព.ស២៥៦៧ ត្រូវនឹងថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣ ឯកឧត្តម លឹម ពុយ ប្រធានក្រុមការងារអនុវត្តគម្រោងគ្រប់គ្រងធនធានទឹកចម្រុះនៃអាងស្ទឹងសែន និងជាប្រធានក្រុមការងារទី 3 ផ្នែកបរិស្ថាន និងសង្គមរបស់គម្រោង អមដំណើរ និងសហការដោយលោក ខាត់ កំសត់ អនុប្រធានមន្ទីរធនធានទឹកនិងឧតុនិយម ខេត្តព្រះវិហារ និងលោក សៀ សូលីន ប្រធានការិយាល័យធារាសាស្ត្រកសិកម្ម នៃមន្ទីរធនធានទឹកនិងឧតុនិយម បានដឹកនាំក្រុមការងារចុះធ្វើការតាមដានស្ថានភាពធនធានត្រីនៅមុនពេល និងក្រោយពីមានទំនប់អាងទឹករក្សាដែលធ្វើឲ្យលំនៅដ្ឋានត្រី និងចំណីមានជាអតិបរមា និងការតាមដានទៅលើប្លង់តុងតាមរយៈការចុះយកសំណាកទឹកដើម្បីវិភាគលើប្លង់តុងដែលជាចំណីសម្រាប់ប្រភេទធនធានត្រីក្នុងការរស់នៅប្រចាំថ្ងៃ និងជាចំណីកូនត្រីដែលទើបនឹងញាស់។





## ឯកឧត្តម លឹម ពុយ ចុះពិនិត្យមើលវឌ្ឍនភាពការងារគំរោងសាងសង់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតតាំងក្រសៅ ខេត្តកំពង់ធំ




កាលពីថ្ងៃទី 11 ខែវិច្ឆិកា ឆ្នាំ 2023 ឯកឧត្តម លឹម ពុយ អនុប្រធានអាជ្ញាធរទន្លេសាប និងជាប្រធានក្រុមការងារបច្ចេកទេសអនុវត្តគម្រោងគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន បានដឹកនាំសហការីជួបជាមួយប្រធានសមាគមទឹកស្អាតអាងស្ទឹងសែន បញ្ហាស្ថានីយផ្គត់ផ្គង់ទឹកស្អាតសាលាវិស័យមានបញ្ហាកករដីមួយចំនួនដែលបណ្ដាលមកពីទឹកជំនន់ទឹកភ្លៀងបានជ្រាបនៅកន្លែងអណ្ដូងទឹក និងចុះពិនិត្យមើលវឌ្ឍនភាពការងារគំរោងសាងសង់ស្ថានីយផ្គត់ផ្គង់ទឹកស្អាតតាំងក្រសៅ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ (ស្ថានីយនេះជាជំនួយឥតចំណងរបស់ទីភ្នាក់ងារទឹកបារាំង Rhin-Meuse និងអង្គការ HAMAP) ដែលមានអង្គការទឹកភ្លៀងកម្ពុជាជាអ្នកទទួលអនុវត្តគម្រោង។ កម្មវិធីខាងលើនេះរៀបចំដោយអង្គការទឹកភ្លៀងកម្ពុជា។



# គម្រោងសិក្សាគំរូបច្ចេកវិទ្យា សង្កេត និងបញ្ជូនទិន្នន័យជលសាស្ត្រសម្រាប់អាងទន្លេសាប

## សកម្មភាពបន្តចុះពិនិត្យផ្ទៀងផ្ទាត់ការបញ្ជូនទិន្នន័យ ព័ត៌មានជលសាស្ត្រ និងឧតុនិយមស្វ័យប្រវត្តិ មក Master Station ( Server ) និងថែទាំឧបករណ៍ស្ថានីយ ចំនួន ០៥ស្ថានីយ

នាថ្ងៃចន្ទ ១០រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារបច្ចេកទេស នៃគម្រោងសិក្សាគំរូបច្ចេកវិទ្យាសង្កេត និងបញ្ជូនទិន្នន័យជលសាស្ត្រសម្រាប់អាងទន្លេសាប ប្រទេសកម្ពុជា (Pilot Project of Hydrological Data Observation and Transmission Technology for Tonle Sap Basin in Cambodia) ដឹកនាំដោយលោក យ៉ាន់ សំរិទ្ធ ប្រធាននាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ និងជាអនុប្រធានគម្រោង បានបន្តចុះធ្វើការពិនិត្យ-ផ្ទៀងផ្ទាត់ទិន្នន័យកម្ពស់ទឹក និងកម្រិតទឹកភ្លៀង (Server) ស្ថានីយចំនួន ០៥ស្ថានីយ នៅ ខេត្តកំពង់ឆ្នាំង, ពោធិ៍សាត់ និងខេត្តបាត់ដំបង មក Master Stationអទស។ ដោយមានការជួយបច្ចេកទេសពីចម្ងាយរបស់ក្រុមជំនាញនៃវិទ្យាស្ថានស្រាវជ្រាវជលសាស្ត្រ និងស្វ័យប្រវត្តិកម្ម ការអភិរក្សទឹកណានជីង (NIHWA) នៃក្រសួងធនធានទឹកចិន ដើម្បីពិនិត្យ ផ្ទៀងផ្ទាត់ទិន្នន័យរួមគ្នា ដែលជាលទ្ធផលទទួលបានដូចខាងក្រោម៖

- ស្ថានីយឆ្នុកទ្រូ (AWS, HR): កម្រិតកំពស់ទឹក ៧.១៧ម និងកម្រិតទឹកភ្លៀងសរុប ៨៥៩មម គិតចាប់ពីស្ថានីយដាក់ដំណើរហូតដល់បច្ចុប្បន្ន។
- ស្ថានីយបាក់ត្រកួន (AWS and HQR): កំពស់ទឹកមាន ២.៣៨ម និងផលបូកកម្រិតទឹកភ្លៀងសរុប ៧២៩មម។
- ស្ថានីយប្រាំងចោត(H.R): កំពស់ទឹក ៣.៩០ម និងផលបូកកម្រិតទឹកភ្លៀងសរុប ៧៩៣មម។
- បានពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យ ព័ត៌មានឧតុនិយម និងកម្រិតទឹកភ្លៀង ពីស្ថានីយឧតុនិយម AWS ចំនួន ០២ស្ថានីយ គឺស្ថានីយស្ថិតនៅក្នុងឃុំឆ្នុកទ្រូ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង និងស្ថានីយស្ថិតស្ទឹងពោធិ៍សាត់ ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់។
- បានពិនិត្យ ផ្ទៀងផ្ទាត់ទិន្នន័យ ព័ត៌មានកម្ពស់ទឹក ពីស្ថានីយជលសាស្ត្រ H.R ចំនួន ០២ស្ថានីយ គឺស្ថិតនៅក្នុងឃុំឆ្នុកទ្រូ ស្រុកបរិបូរណ៍ ខេត្តកំពង់ឆ្នាំង និងស្ថានីយស្ទឹងសង្កែ (ស្ពានប្រាំងចោត), ស្រុកបាណន ខេត្តបាត់ដំបង។
- បានរៀបចំតេស្ដ៍សាកល្បងការភ្ជាប់បណ្ដាញ (Set up for Configuration) បញ្ជូនទិន្នន័យ ព័ត៌មានជលសាស្ត្រ ពីស្ថានីយ H. Q.R ស្ថិតស្ទឹងពោធិ៍សាត់ (ស្ពានបាក់ត្រកួន) ស្រុកភ្នំក្រវាញ ខេត្តពោធិ៍សាត់ ។
- ការធ្វើតេស្តសាកល្បង (System Test situation) ដូចជាការផ្ដល់ថាមពល អាគុយ-សូឡា(power supply)
- បានធ្វើការថែទាំស្ថានីយ ដូចជា លាងសម្អាតតម្រងទឹកភ្លៀង និងក្ដារម៉ែត្រ ផ្ទាំងសូឡា កាប់សម្អាតមែកឈើជុំវិញទីធ្លារ ស្ថានីយ។



សូមជម្រាបជូនថា៖ អាជ្ញាធរទន្លេសាប បានធ្វើកិច្ចសហការជាមួយវិទ្យាស្ថានស្រាវជ្រាវជលសាស្ត្រ និងស្វ័យប្រវត្តិកម្ម ការអភិរក្សទឹកណានជីង (NIHWA) នៃក្រសួងធនធានទឹកចិន ក្នុងការអនុវត្តគម្រោងសិក្សាគំរូបច្ចេកវិទ្យាសង្កេត និងបញ្ជូនទិន្នន័យជលសាស្ត្រសម្រាប់អាងទន្លេសាប ប្រទេសកម្ពុជា (Pilot Project of Hydrological Data Observation and Transmission Technology for Tonle Sap Basin in Cambodia) ដែលមានចំនួន ១១ ស្ថានីយ លើទីតាំង ៨ កន្លែង សម្រាប់ប្រមូលទិន្នន័យរបបជលសាស្ត្រ និងអាកាសធាតុ នៅតំបន់ជុំវិញអាងទន្លេសាប ដែលបានចាប់ផ្ដើមដំណើរសាងសង់នៅខែមករា ឆ្នាំ២០២៣ និងបានបញ្ចប់ការដំឡើងស្ថានីយនៅខែមីនា ឆ្នាំ២០២៣ ។ ស្ថានីយទាំង ១១ រួមមាន៖

- ស្ថានីយមជ្ឈមណ្ឌលរក្សាទិន្នន័យចំនួន ០១ (Master station-Sever) នៅអាជ្ញាធរទន្លេសាប និងស្ថានីយជលសាស្ត្រ និងឧតុនិយមស្វ័យប្រវត្តិទាំង ១១ ស្ថានីយ ជុំវិញតំបន់អាងទន្លេសាប មាន៖
- មាន ០៤ ស្ថានីយជលសាស្ត្រ ពួ (H.R):ដែលខេត្តកំពង់ធំ ចំនួន ០១ ស្ថានីយ (ស្ទឹងជីនិត), ខេត្តបាត់ដំបង ចំនួន ០២ ស្ថានីយ(តំបន់ព្រែកទាល់ និងស្ទឹងសង្កែ-ប្រាំងចោត) និងខេត្តកំពង់ឆ្នាំង ចំនួន០១ ស្ថានីយ (តំបន់ឆ្នុកទ្រូ)។
- មាន ០៣ស្ថានីយជលសាស្ត្រ និងឧតុនិយម (ADCP, H.Q.R) : ខេត្ត កំពង់ធំ ចំនួន ០១ ស្ថានីយ(ស្ទឹងសែន), ខេត្តសៀមរាប ចំនួន ០១ ស្ថានីយ (ស្ទឹងស្រែង) និងខេត្តពោធិ៍សាត់ចំនួន ០១ ស្ថានីយ (ស្ទឹងពោធិ៍សាត់-បាក់ត្រកួន)។
- មាន ០៤ ស្ថានីយឧតុនិយម (AWS): ខេត្តកំពង់ធំ ០២ ស្ថានីយ (តំបន់ពាមបាង និងស្ទឹងសែន(តាអោក) , ខេត្តកំពង់ឆ្នាំង ចំនួន ០១ ស្ថានីយ(តំបន់ឆ្នុកទ្រូ) និងខេត្តពោធិ៍សាត់ ចំនួន ០១ ស្ថានីយ (ស្ទឹងពោធិ៍សាត់- បាក់ត្រកួន)។

## សកម្មភាពដំឡើងស្ថានីយតាមដានអាកាសធាតុ និងរបបជលសាស្ត្រ





អាជ្ញាធរទន្លេសាប និងវិទ្យាស្ថានស្រាវជ្រាវ Nanjing Research Institute of Hydrology and Water Conservation Automation (NIHWA) នៃក្រសួងធនធានទឹក ប្រទេសចិន បានសហប្រតិបត្តិការអនុវត្តគម្រោងសិក្សាគំរូបច្ចេកវិទ្យាអង្កេត និងបញ្ជូនទិន្នន័យជលសាស្ត្រសម្រាប់អាងទន្លេសាបក្នុងប្រទេសកម្ពុជា ចំនួន ១១ ស្ថានីយ។

ក្រុមការងារបច្ចេកទេសអាជ្ញាធរទន្លេសាប បានបន្តកិច្ចសហការជាមួយមន្ទីរជំនាញ អាជ្ញាធរដែនដី ក្នុងការសិក្សាជ្រើសរើសទីតាំង និងដំឡើងស្ថានីយរបបជលសាស្ត្រ និងអាកាសធាតុ ចំនួន ០៨ ទីតាំង នៅជុំវិញអាងបឹងទន្លេសាប មាន:

១. ខេត្តកំពង់ធំ មាន ៣ទីតាំង ចំនួន ៤ ស្ថានីយ (AWS, HQR ,H.R)
២. ខេត្តសៀមរាប មាន ១ទីតាំង ចំនួន ១ ស្ថានីយ (HQR)
៣. ខេត្តបាត់ដំបង មាន ២ទីតាំង ចំនួន ២ ស្ថានីយ (AWS ,H.R)
៤. ខេត្តពោធិសាត់ មាន ១ទីតាំង ចំនួន ២ ស្ថានីយ (AWS, HQR)
៥. ខេត្តកំពង់ឆ្នាំង មាន ១ទីតាំង ចំនួន ២ ស្ថានីយ (AWS, H.R)។



## ឯកឧត្តម ម៉ៅ ហាក់ អនុប្រធានអាជ្ញាធរទន្លេសាប អញ្ជើញចុះពិនិត្យបច្ចេកទេសសាងសង់ និងដំឡើងស្ថានីយជលសាស្ត្រ និងឧតុនិយម ១១ ស្ថានីយ៍



នាថ្ងៃទី ១៩ ខែមេសា ឆ្នាំ២០២៣ ត្រូវនឹងថ្ងៃពុធ ១៤ រោច ខែចេត្រ ឆ្នាំថោះ បញ្ចស័ក ២៥៦៦ ឯកឧត្តម ម៉ៅ ហាក់ អនុប្រធានអាជ្ញាធរទន្លេសាប អញ្ជើញដឹកនាំក្រុមការងារអនុវត្តន៍គម្រោងចុះពិនិត្យបច្ចេកទេសបញ្ចប់ការសាងសង់ និងដំឡើងស្ថានីយជលសាស្ត្រ និង ឧតុនិយម ១១ ស្ថានីយ៍ នៅតំបន់អាងបឹងទន្លេសាប និងការតភ្ជាប់បណ្តាញទទួល-បញ្ជូនទិន្នន័យ ព័ត៌មានជលសាស្ត្រ និងអាកាសធាតុនៅស្ថានីយផ្នុកទ្រពៅរើយ និងត្នោតជុំ ។



## សកម្មភាពកិច្ចប្រជុំ និងសិក្ខាសាលា

# ប្រជុំពិនិត្យពិភាក្សា លើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រ សម្រាប់អាជ្ញាធរទន្លេសាប ២០២៤-២០២៨ និង ដំណើរការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ២០២៤ របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប



នាថ្ងៃសុក្រ ១២រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣ ឯកឧត្តម ហ៊ែល តូនី អនុប្រធានក្រុមប្រឹក្សាប្រឹក្សាស្រាវជ្រាវគោលនយោបាយ និងផែនការយុទ្ធ របស់អាជ្ញាធរទន្លេសាប តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ថោ ជេដ្ឋា រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជា ប្រធានអាជ្ញាធរទន្លេសាប បាន អញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំពិនិត្យ ពិភាក្សា លើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាប២០២៤-២០២៨ និងដំណើរការរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ២០២៤ របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ។

សូមជម្រាបថា កិច្ចប្រជុំពិនិត្យពិភាក្សា ខាងលើនេះ មានការអញ្ជើញចូលរួមពីឯកឧត្តមអនុប្រធាន ឯកឧត្តមអគ្គលេខាធិការ ឯកឧត្តមអគ្គលេខាធិការរង ប្រធាន-អនុប្រធាននាយកដ្ឋាន ប្រធាន-អនុប្រធានការិយាល័យ និង មន្ត្រីក្រោមឱវាទអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប សរុបចំនួន ៦៩ រូប ។

កិច្ចប្រជុំ បានពិនិត្យ និងពិភាក្សាលើ ៖

១. លទ្ធផល និងបទពិសោធន៍នៃការអនុវត្តរយៈពេល ៣ ឆ្នាំ នៃដំណើការផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាប២០២១-២០២៥ ដើម្បីធ្វើបច្ចុប្បន្នភាពផែនការឲ្យស្របនឹងគោលនយោបាយ យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី ១ របស់រាជរដ្ឋាភិបាល

២. សេចក្តីព្រាងផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប ២០២៤-២០២៨

៣. ទម្រង់តារាងម៉ាទ្រិចសកម្មភាពផែនការប្រចាំឆ្នាំ ២០២៤ របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដើម្បីចូលរួមអនុវត្តគាំទ្រដល់ដំណើរការផែនយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប ២០២៤-២០២៨ ឲ្យមានប្រសិទ្ធភាព ។

តាមរយៈនៃការពិនិត្យ និងពិភាក្សា អង្គប្រជុំ បានចូលរួមមតិយោបល់ ដែលជាធាតុចូលដ៏មានសារៈសំខាន់បន្ថែមទៀតក្នុងការធ្វើឲ្យផែនការយុទ្ធសាស្ត្រកាន់តែប្រសើរឡើង និងយកទៅអនុវត្តឲ្យស្របតាមបរិបទជាក់ស្តែង ។ ជារួម អង្គប្រជុំបានឯកភាព និងគាំទ្រ ៖ (១). ខ្លឹមសារ អត្ថន័យ (ចក្ខុវិស័យ, បេសកកម្ម, គោលដៅ, ទិសដៅ សកម្មភាពយុទ្ធសាស្ត្រ និងការតាមដានត្រួតពិនិត្យ វាយតម្លៃ) លើសេចក្តីព្រាងផែនការយុទ្ធសាស្ត្រ អ.ទ.ស ២០២៤-២០២៨ ដែលនឹងចូលរួមលើកកម្ពស់ដល់ការអនុវត្តគោលនយោបាយយុទ្ធសាស្ត្របញ្ចកោណ របស់រាជរដ្ឋាភិបាល, (២). បន្តពិនិត្យរៀបចំសកម្មភាពអនុវត្តប្រចាំឆ្នាំ ២០២៤ ចូលតារាងម៉ាទ្រិច ឲ្យបានត្រឹមត្រូវស្របនឹងតួនាទីភារកិច្ចរបស់នាយកដ្ឋាន និងការិយាល័យក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ដើម្បីរៀបចំផែនការសកម្មភាពប្រចាំឆ្នាំ ២០២៤ របស់អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ក្នុងស្មារតីយកចិត្តទុកដាក់ និងគាំទ្រផែនការយុទ្ធសាស្ត្រ ២០២៤-២០២៨ ឲ្យមានប្រសិទ្ធភាពខ្ពស់ ។





## កិច្ចប្រជុំពិភាក្សាការងារលើដំណើរការប្រើប្រាស់ថវិកាបេសកកម្មបន្តចុះអនុវត្តផែនការសកម្មភាព



រាជធានីភ្នំពេញ៖ នៅរសៀលថ្ងៃ សុក្រ ១ រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី ០១ ខែកញ្ញា ឆ្នាំ ២០២៣ ក្រោមការឯកភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជា ប្រធានអាជ្ញាធរទន្លេសាប បានអនុញ្ញាតឲ្យឯកឧត្តម ហៃល តូនី អនុប្រធានក្តាប់រួមអាជ្ញាធរទន្លេសាប ដឹកនាំកិច្ចប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តមអនុប្រធាន ឯកឧត្តមអគ្គលេខាធិការស្តីទី ឯកឧត្តមអគ្គលេខាធិការរង និងលោកប្រធាននាយកដ្ឋានទាំង ៤ លើដំណើរការប្រើប្រាស់ថវិកាបេសកកម្មបន្តចុះអនុវត្តផែនការសកម្មភាពរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការអាជ្ញាធរទន្លេសាប ស្របតាមការអនុវត្តដំណើរការថវិកាកម្មវិធី ផ្អែកតាមសារាចរណែនាំ គោលការណ៍ហិរញ្ញវត្ថុជាធរមាន និងបានដាក់ចេញទស្សនទានពង្រឹងការងារ រួមជាមួយផែនការសកម្មភាពចំពោះមុខក្នុងរយៈពេល ៤ ខែ ឆ្នាំ ២០២៣ ។

---

## ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាប ដឹកនាំប្រជុំតាម ZOOM ជាមួយក្រុមការងារចុះពិនិត្យតាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹកជុំវិញតំបន់បឹងទន្លេសាប

រសៀលថ្ងៃសុក្រ ១១រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០២៣ នៅអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប ឯកឧត្តម ហៃល តូនី អនុប្រធានក្តាប់រួម និងជាប្រធានក្រុមការងារតំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជា ប្រធានអាជ្ញាធរទន្លេសាប បានដឹកនាំសម្របសម្រួលកិច្ចប្រជុំពិភាក្សាតាម ZOOM ជាមួយក្រុមការងារចុះពិនិត្យតាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹកជុំវិញតំបន់បឹងទន្លេសាប មុននឹងក្រុមការងារទទួលខុសត្រូវតាមមុខព្រួញបណ្តាខេត្តអមផ្លូវជាតិលេខ ៥ និងលេខ ៦ ចុះអនុវត្តការងារអធិការកិច្ច និងស្រង់ព័ត៌មាន ទិន្នន័យពាក់ព័ន្ធបង្គោលកំណត់ព្រំតំបន់ ៣, ផ្ទាំងប៉ាណូ, តំបន់ផ្ទៃដីទន្ទ្រានព្រៃលិចទឹក (ចាស់-ថ្មី), តំបន់កាត់ឆ្កៀល ដែលស្ថិតនៅតាមទីតាំងជាក់ស្តែងក្នុងតំបន់ ១ តំបន់ ២ និងតំបន់ ៣ ក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប ។

សូមជម្រាបថា : កិច្ចប្រជុំពិភាក្សានេះ មានការចូលពី ឯកឧត្តមអគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាននាយដ្ឋាន អនុប្រធាននាយកដ្ឋាន និងមន្ត្រី ដែលជា ប្រធាន អនុប្រធាន និងសមាជិកនៃក្រុមការងារចុះពិនិត្យតាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹកជុំវិញតំបន់បឹងទន្លេសាប សរុបចំនួន : ២២នាក់ ។

កិច្ចប្រជុំ គឺបានពិភាក្សាផ្តោតលើ :

១. កិច្ចការបច្ចេកទេស (ផែនការការងារ, ការចាត់ចែងសមាជិកក្រុមការងារ, វិធីសាស្ត្រ, និងសម្ភារៈបច្ចេកទេស)

២. កិច្ចការហិរញ្ញវត្ថុក្នុងការចំណាយ




៣. បញ្ហាផ្សេងៗ

សូមបញ្ជាក់ថា : ក្រុមការងារចុះពិនិត្យតាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹកជុំវិញតំបន់បឹងទន្លេសាប របស់អាជ្ញាធរទន្លេសាប បាន និងកំពុងតែចុះជួបពិភាក្សាជាមួយអាជ្ញាធរដែនដី និងមន្ទីរជំនាញពាក់ព័ន្ធ នៅតាមបណ្តាខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប ដើម្បីធ្វើការផ្ទៀងផ្ទាត់ព័ត៌មាន ទិន្នន័យបឋម មុននឹងក្រុមការងារចុះដល់ទីតាំងជាក់ស្តែង ។ ដោយឡែក មន្ត្រីក្រុមការងារជំនាញបច្ចេកទេស នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ក៏បាននិងកំពុងយកចិត្តទុកដាក់កែសម្រួល និងរៀបចំរាល់ឯកសារបច្ចេកទេស និងផែនទីពាក់ព័ន្ធ (ទាំងផ្នែកទន់ និងផ្នែករឹង) ដើម្បីជួយគាំទ្រ និងសម្រួលដល់ក្រុមការងារចុះពិនិត្យតាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹកជុំវិញតំបន់បឹងទន្លេសាប និងបានផ្តល់ការបណ្តុះបណ្តាលពីការប្រើប្រាស់កម្មវិធីចុះប្រមូលទិន្នន័យ-ព័ត៌មាន ដោយប្រើប្រាស់កម្មវិធី (KOBO Collect) ។

# ឯកឧត្តម ហ៊ែល តូនី បានដឹកនាំកិច្ចប្រជុំពិភាក្សាពីវឌ្ឍនភាពការងារ និងគំនិតទស្សនទាន របស់នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស



រាជធានីភ្នំពេញ ៖ ដោយទទួលបានការឯកភាពដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមរដ្ឋមន្រ្តីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប ។

ព្រឹកថ្ងៃសុក្រ ១កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ ២០២៣ នៅអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ឯកឧត្តម ហ៊ែល តូនី អនុប្រធានទទួលបន្ទុកក្ដាប់រួម បានដឹកនាំកិច្ចប្រជុំពិភាក្សាការងារពាក់ព័ន្ធនឹងតួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ដើម្បីពិនិត្យមើលពីវឌ្ឍនភាពការងារ និងគំនិតទស្សនទានរបស់នាយកដ្ឋាន ក្នុងការគ្រប់គ្រង និងអនុវត្តតួនាទីភារកិច្ចប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ។

កិច្ចប្រជុំនេះ មានការចូលរួមពីឯកឧត្តម អនុប្រធាន អគ្គលេខាធិការ ប្រធាននាយកដ្ឋាននៃនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន អទស , ប្រធាន និងអនុប្រធានការិយាល័យ ក្រោមឱវាទនាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ។

បន្ទាប់ពីស្ដាប់បទបង្ហាញស្ដីពីវឌ្ឍនភាព និងគំនិតទស្សនទានរបស់ប្រធាននាយកដ្ឋាន

និងចំណាប់អារម្មណ៍របស់ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសរួចមក ឯកឧត្តម ប្រធានអង្គប្រជុំ បានឯកភាពអំពីគំនិតទស្សនទានដែលបានលើកឡើងរបស់នាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ព្រមទាំងបានចង្អុលបង្ហាញនូវគំនិតជាយុទ្ធសាស្ត្រគន្លឹះមួយចំនួន ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងអនុវត្តតួនាទីភារកិច្ចឲ្យបានកាន់តែល្អប្រសើរបន្ថែមទៀត ក្នុងការលើកស្ទួយស្ថាប័ន ក្នុងស្មារតីចូលរួមលើកកម្ពស់ប្រសិទ្ធភាពការអនុវត្តគោលនយោបាយយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ ដូចជា ៖

1- កែលម្អរក្នុងការគ្រប់គ្រង និងទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំនាយកដ្ឋាន តាមការិយាល័យជំនាញ ដើម្បីប្រសិទ្ធភាពការងារ និងសុខដុមក្នុងនាយកដ្ឋាន។

2- បន្តអនុវត្តបញ្ចប់គម្រោងសកម្មភាព 2023 និងរៀបចំពិនិត្យកែសម្រួលឲ្យបានច្បាស់លាស់ត្រឹមត្រូវ សម្រាប់ចងក្រងជារបាយការណ៍បច្ចេកទេសតាមសកម្មភាពនីមួយៗចុងឆ្នាំ២០២៣ និងត្រៀមលក្ខណៈបច្ចេកទេសឲ្យបានគ្រប់ជ្រុងជ្រោយចំពោះរបកគំហើញលទ្ធផលស្រាវជ្រាវ ក្នុងកិច្ចប្រជុំអន្តរក្រសួងជំនាញ

3- ពិនិត្យខ្លឹមសារបច្ចេកទេសគម្រោង ដែលត្រូវលើកឡើងសម្រាប់អនុវត្តន៍ឆ្នាំ 2024 អោយស្របនឹងតួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់នាយកដ្ឋាន

4-ដោយគម្រោងសកម្មភាពដែលមានលក្ខណៈអន្តរនាយកដ្ឋាន ត្រូវធ្វើការពិភាក្សាក្នុងលក្ខណៈកិច្ចសហប្រតិបត្តិការអន្តរនាយកដ្ឋាន ហើយត្រូវរៀបចំជា ក្រុមការងារបច្ចេកទេស សម្រាប់ដឹកនាំអនុវត្ត ករណីដូចជា ៖

(1). គម្រោងសិក្សាស្ទឹងទាំង១០ជុំវិញបឹងទន្លេសាប

(2). គម្រោងសកម្មភាពសិក្សាវាយតម្លៃបរិមាណផលចាប់ឡូត៍ដាយ និងការកែច្នៃត្រីតាមបណ្ដាឡូត៍ដាយ ។





## ឯកឧត្តម ហ៊ើល តូនី អនុប្រធានក្ដាប់រួម អាជ្ញាធរទន្លេសាប ទទួលជួបពិភាក្សាការងារជាមួយនាយកសាលាវិស្វករកសិកម្ម Toulous និងនាយកប្រតិបត្តិអង្គការ Loir Grands Migrateurs នៃប្រទេសបារាំង

រសៀលថ្ងៃអង្គារ ២កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី ១៤ ខែវិច្ឆិកា ឆ្នាំ ២០២៣ នៅអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប, ឯកឧត្តម ហ៊ើល តូនី អនុប្រធានក្ដាប់រួម, ឯកឧត្តម លឹម ពុយ អនុប្រធាន, ឯកឧត្តម សរ គឹមសាន្ត អគ្គលេខាធិការ, ឯកឧត្តម ជា សុខនី អគ្គលេខាធិការរង និងមន្ត្រីបច្ចេកទេសក្រោមឱវាទអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប បានទទួលជួបពិភាក្សាការងារកិច្ចសហប្រតិបត្តិការជាមួយ លោក Pascal LAFAILLE នាយកសាលាវិស្វករកសិកម្ម Toulouse និងលោកស្រី Aurore BAISEZ នាយកប្រតិបត្តិនៃអង្គការ Loire Grands Migrateurs (LOGRAMI) នៃប្រទេសបារាំង ។

ក្នុងជំនួបកិច្ចពិភាក្សានេះ ភាគីទាំងពីរ បានលើកបង្ហាញពីបេសកកម្មការងារ កិច្ចការចាំបាច់របស់អង្គភាព និងតម្រូវការនៃការចូលរួមពីភាគីពាក់ព័ន្ធ សំដៅពង្រឹងកិច្ចសហប្រតិបត្តិការដើម្បីដោះស្រាយ និងកាត់បន្ថយបញ្ហាប្រឈមនាពេលបច្ចុប្បន្ន និងទៅអនាគតនៅតំបន់បឹងទន្លេសាប ។

ជារួមកិច្ចពិភាក្សា បានប្រព្រឹត្តិទៅក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាល និងបានឯកភាពលើ ៣ ចំនុចដូចខាងក្រោម ៖

១. ពិនិត្យឡើងវិញលើខ្លឹមសារអនុស្សារណៈកិច្ចព្រមព្រៀង (MoU) រវាង សាលាវិស្វករកសិកម្ម Toulouse និង អាជ្ញាធរទន្លេសាប ដើម្បីស្នើសុំការអនុម័តជាថ្មីពី ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជា ប្រធានអាជ្ញាធរទន្លេសាប។



២. ការផ្លាស់ប្តូរចំណេះដឹង និងពង្រឹងសមត្ថភាពមន្ត្រីបច្ចេកទេសអាជ្ញាធរទន្លេសាប តាមរយៈវគ្គបណ្តុះបណ្តាល និងទស្សនៈកិច្ចសិក្សាស្វែងយល់នៅប្រទេសបារាំង។

៣. ពង្រឹងបច្ចេកទេសសិក្សាស្រាវជ្រាវ រៀបចំរបាយការណ៍បច្ចេកទេស និងការគ្រប់គ្រងព័ត៌មាន-ទិន្នន័យ ។

## ឯកឧត្តម ហ៊ើល តូនី អនុប្រធាន ទទួលបន្ទុកក្ដាប់រួម អាជ្ញាធរទន្លេសាប ដឹកនាំពិភាក្សា អំពីយន្តការ និងដំណើរការនៃការរៀបចំរបាយការណ៍បច្ចេកទេសលទ្ធផលសិក្សាស្រាវជ្រាវរបស់អាជ្ញាធរទន្លេសាប

ថ្ងៃព្រហស្បតិ៍ ៤ កើត ខែកត្តិក ឆ្នាំថោះ ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ ២០២៣ នៅអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប បានរៀបចំពិភាក្សា អំពីយន្តការ និងដំណើរការនៃការរៀបចំរបាយការណ៍បច្ចេកទេសលទ្ធផលសិក្សាស្រាវជ្រាវរបស់អាជ្ញាធរទន្លេសាប ក្រោមការដឹកនាំសម្របសម្រួលដោយ ឯកឧត្តម ហ៊ើល តូនី អនុប្រធានទទួលបន្ទុកក្ដាប់រួម និងមានការចូលរួមពី ឯកឧត្តមអនុប្រធាន អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាននាយកដ្ឋាន និងមន្ត្រីបច្ចេកទេសក្រោម។

ឯកឧត្តម លឹម ពុយ អនុប្រធាន អ.ទ.ស បានធ្វើការចែករំលែកនូវទស្សនៈវិស័យសម្រាប់សកម្មភាពស្រាវជ្រាវ នៅបឹងទន្លេសាបក្នុងឆ្នាំ ២០២៤ និងការធ្វើសំយោគឯកសារបច្ចេកទេសជា ៣ ផ្នែក ៖

* ផ្នែកទី១. ស្ថានភាពជីវវិទ្យា នៃបឹងទន្លេសាប ក្រោមផ្លូវជាតិលេខ ៥ និងលេខ ៦ (ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង សៀមរាប និងកំពង់ធំ)។

* ផ្នែកទី២. ស្ថានភាពធនធានជលផល នៅតំបន់ទន្លេសាប, ព្រៃលិចទឹក លំនៅដ្ឋានធនធានត្រី និងវិស័យកសិកម្មនៅតំបន់៣ ។

* ផ្នែកទី៣. ទស្សនៈវិស័យក្នុងការគ្រប់គ្រងនាពេលអនាគត។

បន្ទាប់ពីអង្គប្រជុំ បានស្តាប់បទបង្ហាញ និងពិភាក្សា ឯកឧត្តមប្រធានអង្គប្រជុំ បានកោតសរសើរចំពោះការចែករំលែកគំនិតទស្សនៈទានរបស់ ឯកឧត្តម លឹម ពុយ ក្នុងស្មារតីចូលរួមគាំទ្រដំណើរការនៃការរៀបចំឯកសារបច្ចេកទេសលទ្ធផលសិក្សាស្រាវជ្រាវរបស់ អាជ្ញាធរទន្លេសាប ឲ្យមានប្រសិទ្ធភាព ជាមួយគ្នានោះដែរ ឯកឧត្តមប្រធានអង្គប្រជុំ ក៏បានផ្តល់ការណែនាំទៅឯកឧត្តម សរ គឹមសាន្ត អគ្គលេខាធិការ ឲ្យពិនិត្យរៀបចំក្រុមការងារ ដើម្បីរៀបចំឯកសារបច្ចេកទេសដែលបានសិក្សាស្រាវជ្រាវកន្លងមករបស់អាជ្ញាធរទន្លេសាប ស្របតាមការណែនាំ និងឯកភាពដ៏ខ្ពង់ខ្ពស់ពី ឯកឧត្តមប្រធាន អាជ្ញាធរទន្លេសាប និងពិនិត្យមើលការពង្រឹងយន្តការការងារជាមួយនាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ក្នុងការជម្រុញការរៀបចំ Tonle Sap E-library ឲ្យស្របតាមការកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រ អាជ្ញាធរទន្លេសាប ២០២៤-២០២៨ ។



## ឯកឧត្តម ហៃល តូនី អនុប្រធានក្តាប់រួម អាជ្ញាធរទន្លេសាប ចូលរួមជាគណៈអធិបតីក្នុងសន្និសីទអន្តរជាតិ ស្តីពីការងារវិស័យធនធានទឹក ដើម្បីនិរន្តរភាពបរិស្ថាននៅតំបន់អាស៊ីអាគ្នេយ៍ ( Southeast Asian Water Jobs for Environmental Sustainability-SEAWAT )

ដោយទទួលបានការឯកភាពដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជា ប្រធានអាជ្ញាធរទន្លេសាប តបតាមការគោរពអញ្ជើញរបស់សាកលវិទ្យាល័យជាតិបាត់ដំបង ។ ឯកឧត្តម ហៃល តូនី អនុប្រធានក្តាប់រួម អាជ្ញាធរទន្លេសាប បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងសន្និសីទអន្តរជាតិ ស្តីពីការងារវិស័យធនធានទឹក ដើម្បីនិរន្តរភាពបរិស្ថាននៅតំបន់អាស៊ីអាគ្នេយ៍ (Southeast Asian Water Jobs for Environmental Sustainability-SEAWAT) ដែលបានប្រព្រឹត្តទៅរយៈពេល ៣ថ្ងៃ ចាប់ពីថ្ងៃទី១៨ ដល់ ២០ ខែវិច្ឆិកា ឆ្នាំ២០២៣ នៅសណ្ឋាគារអង្គរប៉ារ៉ាឌី ខេត្តសៀមរាប ។




កម្មវិធីនេះ រៀបចំដោយសាកលវិទ្យាល័យជាតិបាត់ដំបង ក្នុងគម្រោងកសាងសមត្ថភាពឧត្តមសិក្សា ERSMUS+ EBHE INOWASIA ដែលផ្តោតលើនវានុវត្តន៍ ការអភិវឌ្ឍកម្មវិធីអប់រំសម្រាប់បណ្តុះបណ្តាលអ្នកបច្ចេកទេសលើវិស័យធនធានទឹកឈានមុខនៅតំបន់អាស៊ីអាគ្នេយ៍។ សន្និសីទអន្តរជាតិនេះមានការចូលរួមពីអ្នកស្រាវជ្រាវថ្នាក់ជាតិ ប្រទេសក្នុងអនុតំបន់មេគង្គ និងអន្តរជាតិ រួមជាមួយក្រសួងស្ថាប័នជំនាញពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល ។

សន្និសីទនេះរៀបចំឡើងក្នុងគោលបំណងសំខាន់ចំនួន ៣ រួមមាន ៖

- ពិភាក្សាអំពីបញ្ហាប្រឈមទាក់ទងនឹងការបណ្តុះបណ្តាល ការស្រាវជ្រាវ និងកាលានុវត្តភាពលើវិស័យធនធានទឹកនិងបរិស្ថាននៅកម្ពុជា និងតំបន់អាស៊ីអាគ្នេយ៍
- ផ្តល់ឱកាសសម្រាប់អ្នកស្រាវជ្រាវក្នុងតំបន់ និងអន្តរជាតិ និងភាគីពាក់ព័ន្ធអាចផ្លាស់ប្តូរចំណេះដឹង ឧត្តមានុវត្ត និងដំណោះស្រាយបែបវិទ្យាសាស្ត្រដើម្បីដោះស្រាយបញ្ហាប្រឈមទឹក និងបរិស្ថានក្នុងតំបន់
- កំណត់ផែនទីចង្អុលផ្លូវសម្រាប់ដំណើរការអភិវឌ្ឍកម្មវិធីអប់រំ ស្រាវជ្រាវ និងនវានុវត្តន៍ពាក់ព័ន្ធនឹងទឹក និងបរិស្ថាននាពេលអនាគត ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) ឆ្នាំ២០៣០។




សន្និសីទបានរៀបចំជា ៤ផ្នែក សំខាន់ៗដូចជា ៖

ផ្នែកទី ១/. កម្មវិធីអប់រំការច្នៃប្រឌិតចម្រុះសម្រាប់លើវិស័យការងារទឹក

ផ្នែកទី ២/. សហប្រតិបត្តិការសាកលវិទ្យាល័យ-ឧស្សាហកម្ម ដើម្បីលើកកម្ពស់ការអប់រំ និងការស្រាវជ្រាវក្នុងវិស័យទឹក

ផ្នែកទី ៣/. និរន្តរភាពបរិស្ថាននៅតំបន់អាស៊ីអាគ្នេយ៍ និងបញ្ហាប្រឈមការគ្រប់គ្រងទឹក

ផ្នែកទី ៤/. មុខងារអេកូឡូស៊ី និងការអភិរក្សជីវៈចម្រុះដែលប្រឈមមុខនឹងការផ្លាស់ប្តូរសកល ។

ក្នុងអង្គពិធីសន្និសីទនេះដែរ ឯកឧត្តម ហៃល តូនី បានចូលរួមចែករំលែកបទពិសោធន៍ ចំណេះដឹង ទិសដៅ និងទស្សនៈវិស័យរបស់អាជ្ញាធរទន្លេសាប ស្តីអំពី បច្ចុប្បន្នភាព និងអនាគតបឹងទន្លេសាប ដើម្បីធានាការប្រើប្រាស់សេវាអេកូឡូស៊ីបឹងទន្លេសាប ដែលកំពុងប្រឈមនឹងការផ្លាស់ប្តូរជាសកល។ ឯកឧត្តមក៏បានចូលរួមជាវាគ្មិនកិត្តិយសសម្រាប់កិច្ចពិភាក្សាជាមួយភាគីពាក់ព័ន្ធ ជាតិ និងអន្តរជាតិលើប្រធានបទ ៖ (១). ការបណ្តុះបណ្តាលជំនាញទឹកនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDGs) នៃកម្មវិធីអប់រំការច្នៃប្រឌិតចម្រុះសម្រាប់ការងារលើវិស័យទឹក, (២). គម្លាតការស្រាវជ្រាវ នៅតំបន់បឹងទន្លេសាប និងទន្លេមេគង្គ សម្រាប់ទិសដៅសិក្សាស្រាវជ្រាវនាពេលអនាគត នៃមុខងារអេកូឡូស៊ីនិងការអភិរក្សជីវៈចម្រុះដែលប្រឈមមុខនឹងការផ្លាស់ប្តូរសកល, (៣). ការរៀបចំឯកសារសំណើស្តីពី ការរៀបចំមន្ទីរពិសោធន៍អន្តរជាតិរួមគ្នា ។

## ឯកឧត្ដម ហ៊ែល តូនី អនុប្រធានភ្ជាប់រួម អាជ្ញាធរទន្លេសាប ដឹកនាំកិច្ចប្រជុំពិភាក្សាក្រុមការងារចុះពិនិត្យតាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹក នៅតាមបណ្ដាខេត្តជុំវិញបឹងទន្លេសាប

នាព្រឹកថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០២៣ នៅអាជ្ញាធរទន្លេសាប មានកិច្ចប្រជុំពិភាក្សាក្រុមការងារចុះពិនិត្យតាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹក ស្ថិតក្នុងខេត្តទាំង៦ ជុំវិញបឹងទន្លេសាប (ខេត្តកំពង់ឆ្នាំង ពោធិ៍សាត់, បាត់ដំបង, បន្ទាយមានជ័យ, សៀមរាប និងខេត្តកំពង់ធំ) ដឹកនាំដោយ ឯកឧត្ដម ហ៊ែល តូនី អនុប្រធានភ្ជាប់រួម អាជ្ញាធរទន្លេសាប និងមានការចូលរួមពីថ្នាក់ដឹកនាំអគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាន-អនុប្រធាននាយកដ្ឋាន ប្រធាន-អនុប្រធានការិយាល័យ ដែលជាក្រុមការងារ សរុបចំនួន ២៧រូប ។

កិច្ចប្រជុំនេះ មានគោលបំណងពិនិត្យ និងពិភាក្សា ទៅលើ ៖

១. ផែនទីតំបន់៣ ទំហំផ្ទៃដីដែលបានកាត់ឆ្វៀលទៅជាតំបន់ ២ និងតំបន់ ១ ។

២.វិធីសាស្ត្រចុះសិក្សាតាមដានត្រួតពិនិត្យ និងស្រង់ទិន្នន័យ-ព័ត៌មានពាក់ព័ន្ធនឹងតំបន់ ៣ តំប៉ន់ ២ និងតំបន់ ១ បន្ទាប់ពីការកាត់ឆ្វៀល។

៣. ទម្រង់របាយការណ៍លទ្ធផលបន្ទាប់ពីចុះសិក្សាតាមដាន



ត្រួតពិនិត្យរបស់ក្រុមការងារតាមតំបន់នីមួយៗក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប ដើម្បីបូកសរុប និងរាយការណ៍ជូនថ្នាក់ដឹកនាំ និងរាជរដ្ឋាភិបាល ពិនិត្យ និងសម្រេច



៤. នីតិវិធីចុះផ្សព្វផ្សាយ ណែនាំ អំពីច្បាប់ បទដ្ឋានគតិយុត្ត ព័ត៌មាន គោលនយោបាយ និងចំណេះដឹងពាក់ព័ន្ធ ដល់ថ្នាក់ក្រោមជាតិ និងសហគមន៍មូលដ្ឋាន ស្ថិតក្នុងខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប ។

សូមបញ្ជាក់ជូនថា អាជ្ញាធរទន្លេសាប បានបង្កើតក្រុមការងារចុះពិនិត្យតាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹកស្ថិតក្នុងខេត្តទាំង៦ ជុំវិញបឹងទន្លេសាប (ខេត្តកំពង់ឆ្នាំង, ពោធិ៍សាត់, បាត់ដំបង, បន្ទាយមានជ័យ, សៀមរាប និងខេត្តកំពង់ធំ) ដែលរាជរដ្ឋាភិបាលបានឆ្វៀលចេញពីដែនព្រៃលិចតំបន់៣ មកតំបន់ ២ និងពីតំបន់២ មកតំបន់ ១ នៃអនុក្រឹត លេខ ១៩៧ អនក្រ.បកចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១១ ដែលមានដែនទំហំ ៦៤៧,៤០៦ហិកតា ជូនប្រជាពលរដ្ឋ អាស្រ័យផល និងតាំងទីលំនៅ ។ ក្រុមការងារ បាន និងកំពុងបន្តអនុវត្តន៍តួនាទីភារកិច្ច ក្នុងការប្រមូលផ្ទៀងផ្ទាត់ទិន្នន័យ ព័ត៌មានជាក់លាក់ ដើម្បីពិភាក្សាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងថ្នាក់ក្រោមជាតិនៃខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប និងធ្វើការផ្សព្វផ្សាយ បង្កើនការយល់ដឹងពីសារប្រយោជន៍ធនធានធម្មជាតិ និងចូលរួមកិច្ចការការពារ ធនធានធម្មជាតិបឹងទន្លេសាបប្រកបដោយចីរភាព ។





សកម្មភាពកិច្ចប្រជុំ និងសិក្ខាសាលា

## ឯកឧត្ដម ហ៊ើល តូនី អនុប្រធានភ្ជាប់រួម អាជ្ញាធរទន្លេសាប ដឹកនាំកិច្ចប្រជុំពិនិត្យពិភាក្សាលើផែនការសកម្មភាពអគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប ឆ្នាំ២០២៤



នៅព្រឹកថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃ៣០ ខែវិច្ឆិកា ឆ្នាំ២០២៣ នាសាលប្រជុំអាជ្ញាធរទន្លេសាប ឯកឧត្ដម ហ៊ើល តូនី អនុប្រធានភ្ជាប់រួម អាជ្ញាធរទន្លេសាប ដឹកនាំកិច្ចប្រជុំពិនិត្យផែនការសកម្មភាព អគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប ឆ្នាំ២០២៤ ។
សូមជម្រាបថា កិច្ចប្រជុំនេះមានការចូលរួមពីឯកឧត្ដមអគ្គលេខាធិការ ឯកឧត្ដមអគ្គលេខាធិការរង ប្រធាននាយកដ្ឋាន និងមន្ត្រីបច្ចេកទេស។ ឯកឧត្ដមអនុប្រធាន បានឱ្យដឹងថា គោលបំណងនៃកិច្ចប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាកែសម្រួល លើផែនការសកម្មភាពឆ្នាំ២០២៤ ដែលបានលើកឡើងដោយថ្នាក់ដឹកនាំ និងនាយកដ្ឋានទាំង៤ ចំណុះអគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប ស្របតាមផែនការយុទ្ធសាស្ត្រអាជ្ញាធរទន្លេសាប ២០២៤-២០២៨ និងយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល ដើម្បីអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពតាមតួនាទីភារកិច្ច របស់នាយកដ្ឋាននីមួយៗ ៕

---

## ឯកឧត្ដម ហ៊ើល តូនី អនុប្រធានភ្ជាប់រួម អាជ្ញាធរទន្លេសាប ដឹកនាំកិច្ចប្រជុំពិនិត្យពិភាក្សាលើផែនការសកម្មភាពអគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប ឆ្នាំ២០២៤



នាព្រឹកថ្ងៃសុក្រ ៤រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០២៣ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប ឯកឧត្ដម ហ៊ើល តូនី អនុប្រធានភ្ជាប់រួម អាជ្ញាធរទន្លេសាប តំណាងដ៏ខ្ពង់ខ្ពស់ឯកឧត្ដមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប បានទទួលជួបពិភាក្សាការងារជាមួយគណៈប្រតិភូមេគង្គ-ឡានឆាង ដែលដឹកនាំដោយ លោក Li Ge អគ្គនាយករងក្រសួងធនធានទឹក នៃសាធារណរដ្ឋប្រជាមានិតចិន និង Dr. Zhou Zhiwei, អគ្គលេខាធិការ មជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការធនធានទឹកឡានឆាង-មេគង្គ (LMC) ។
សូមជម្រាបថា កិច្ចប្រជុំនេះ មានការចូលរួមពីឯកឧត្ដមអគ្គលេខាធិការ ប្រធាននាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ អនុប្រធាននាយកដ្ឋានធនធានធម្មជាតិ មន្ត្រីបច្ចេកទេស នៃអាជ្ញាធរទន្លេសាប ព្រមទាំងមន្ត្រីបច្ចេកទេសនៃក្រសួងធនធានទឹកចិន និងមេគង្គ-ឡានឆាង។
ក្នុងឱកាសជំនួបនេះដែរ ឯកឧត្ដម អនុប្រធាន បានជម្រាបជូនគណៈប្រតិភូ អំពីតួនាទី ភារកិច្ច បេសកកម្មស្នូល និងសមិទ្ធផលស្នាដៃដែលអាជ្ញាធរទន្លេសាបសម្រេចបានកន្លងមក ព្រមទាំងបានបង្ហាញពីទស្សនទានការងារដែលកំណត់នៅក្នុងផែនការយុទ្ធសាស្ត្ររបស់អាជ្ញាធរទន្លេសាប ២០២៤-២០២៨ ផ្សាភ្ជាប់នឹងបញ្ហាប្រឈម និងវិធានការទប់ស្កាត់ផលប៉ះពាល់មកលើបឹងទន្លេសាបនាពេលបច្ចុប្បន្ន និងទៅអនាគត រួមជាមួយការលើកឡើងភាពទំនាក់ទំនងរវាងបឹងទន្លេសាប ជាមួយទន្លេមេគង្គ ។
ជាមួយនេះដែរ ប្រធានគណៈប្រតិភូ រួមជាមួយក្រុមប្រតិភូ ឡានឆាង-មេគង្គ បានចាប់អារម្មណ៍យ៉ាងខ្លាំង ជាមួយការលើកឡើងពាក់ព័ន្ធនឹងទស្សនទានការងាររបស់អាជ្ញាធរទន្លេសាបផ្សាភ្ជាប់នឹងបញ្ហាបឹងទន្លេសាប និងភាពទំនាក់ទំនងរវាងបឹងទន្លេសាប ជាមួយទន្លេមេគង្គ ។
ជាលទ្ធផលនៃកិច្ចពិភាក្សា គណៈប្រតិភូឡានឆាង-មេគង្គ លោក Li Ge និង Dr. Zhou Zhiwei, បានទទួលយកនូវសំណើរបស់ ឯកឧត្ដមអនុប្រធានអាជ្ញាធរទន្លេសាប ក្នុងការពង្រឹងចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការយូរអង្វែងរវាងអាជ្ញាធរទន្លេសាប និងឡានឆាង-មេគង្គ ហើយនឹងចាត់តាំងមន្ត្រីបច្ចេកទេស ០១រូប ដើម្បីសហការជួយរៀបចំសំណើគម្រោង Project Proposal កិច្ចសហប្រតិបត្តិការរវាង អាជ្ញាធរទន្លេសាប និង Lancang-Mekong Water Resources Cooperation-LMC នាពេលខាងមុខ ។

## ឯកឧត្តម ហ៊ែល តូនី បានដឹកនាំកិច្ចប្រជុំពិភាក្សាការងារពាក់ព័ន្ធនឹងតួនាទីភារកិច្ច និងការទទួលខុសត្រូវ របស់នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ

រាជធានីភ្នំពេញ ៖ ដោយទទួលបានការឯកភាពដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប ព្រឹកថ្ងៃសុក្រ ១៥កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ២០២៣ នៅអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ឯកឧត្តម ហ៊ែល តូនី អនុប្រធានទទួលបន្ទុកក្តាប់រួម បានដឹកនាំកិច្ចប្រជុំពិភាក្សាការងារពាក់ព័ន្ធនឹងតួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់នាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ ដើម្បីពិនិត្យមើលពីវឌ្ឍនភាពការងារ និងគំនិតទស្សនទានរបស់នាយកដ្ឋាន ក្នុងការគ្រប់គ្រង ដឹកនាំ និងអនុវត្តតួនាទីភារកិច្ចប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ។





+ កិច្ចប្រជុំនេះ មានការចូលរួមពីឯកឧត្តមអគ្គលេខាធិការ ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានការិយាល័យ និងមន្ត្រីរាជការក្រោមឱវាទនាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ ។

+ បន្ទាប់ពីស្តាប់បទបង្ហាញស្តីពីវឌ្ឍនភាព និងគំនិតទស្សនទានរយៈពេល ៩ខែដើមឆ្នាំ ២០២៣ របស់ប្រធាននាយកដ្ឋាន និងចំណាប់អារម្មណ៍របស់ថ្នាក់ដឹកនាំ និងមន្ត្រីរួចមក ។ ឯកឧត្តមប្រធានអង្គប្រជុំ បានឯកភាពអំពីគំនិតទស្សនទាន ដែលមានចក្ខុវិស័យច្បាស់លាស់ របស់ប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ ព្រមទាំងបានចង្អុលបង្ហាញនូវគំនិតជាយុទ្ធសាស្ត្រគន្លឹះមួយចំនួនបន្ថែមទៀត ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងអនុវត្តតួនាទីភារកិច្ចឲ្យបានកាន់តែល្អប្រសើរក្នុងការលើកស្ទួយស្ថាប័ន ដោយស្មារតីចូលរួមលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលការងារ ស្របតាមគោលនយោបាយយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលនីតិកាលទី៧ ៖

១-បន្តរួមសាមគ្គីភាពផ្ទៃក្នុងនាយកដ្ឋាន ក៏ដូចជាអង្គភាពទាំងមូល និងពង្រឹងការគ្រប់គ្រង ទទួលខុសត្រូវ តាមការិយាល័យជំនាញ ដើម្បីប្រសិទ្ធភាពការងារ និងសុខដុមផ្ទៃក្នុងរបស់នាយកដ្ឋាន

២- បន្តផ្តល់ការលើកទឹកចិត្ត និងផ្តល់ឱកាសស្មើគ្នាដល់មន្ត្រីក្នុងនាយកដ្ឋាន ដោយគិតគូអ្នកបន្តវេន តាមរយៈការពិនិត្យវាយតម្លៃលក្ខណៈសម្បត្តិ អត្តចរិក និងលទ្ធផលបំពេញការងារ ដោយផ្តោតលើភាព ក្លាហាន (សមត្ថភាព) វិន័យ និងគុណធម៌

៣- ត្រូវយកចិត្តទុកដាក់លើការអនុវត្តគម្រោងសកម្មភាព ឆ្នាំ២០២៣ និងរៀបចំគម្រោងសកម្មភាពការងារសម្រាប់អនុវត្តន៍ឆ្នាំ២០២៤ ស្របតាមតួនាទីភារកិច្ចរបស់នាយកដ្ឋាន និងស្ថាប័នក៏ដូចជាគាំទ្រគោលនយោបាយយុទ្ធបញ្ចកោណ ៖

-កំណែទម្រង់រដ្ឋបាលសាធារណៈ

-កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ

-ពង្រឹងសមត្ថភាពមន្ត្រីអោយស្របទៅនឹងសង្គមឌីជីថល។

៤- ពង្រឹងកិច្ចការតាមដានត្រួតពិនិត្យ និងវាយតម្លៃ នៃវឌ្ឍនភាពការងារអង្គភាព និងគម្រោងសកម្មភាពគាំទ្រដល់ការអនុវត្តផែនការយុទ្ធសាស្ត្រ របស់អាជ្ញាធរទន្លេសាប រួមជាមួយគម្រោង/កម្មវិធីនានា នៅតំបន់ទន្លេសាប

៥- បន្តជម្រុញការកសាងសមត្ថភាពធនធានមនុស្ស តាមរយៈការបណ្តុះបណ្តាល និងផ្លាស់ប្តូរបទពិសោធន៍ទាំងក្នុងស្រុក និងក្រៅស្រុកដល់មន្ត្រីជំនាញបន្ថែមទៀត ។



## ឯកឧត្តម ហ៊ើល តូនី បានដឹកនាំកិច្ចប្រជុំពិភាក្សាពីវឌ្ឍនភាពការងារ និងគំនិតទស្សនទាន របស់នាយកដ្ឋានធនធានធម្មជាតិ

រាជធានីភ្នំពេញ ៖ ដោយទទួលបានការឯកភាពដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប ។

ព្រឹកថ្ងៃព្រហស្បតិ៍ ១៤កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ ២០២៣ នៅអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ឯកឧត្តម ហ៊ើល តូនី អនុប្រធានទទួលបន្ទុកក្ដាប់រួម បានដឹកនាំកិច្ចប្រជុំពិភាក្សាការងារពាក់ព័ន្ធនឹងតួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់នាយកដ្ឋានធនធានធម្មជាតិ ដើម្បីពិនិត្យមើលពីវឌ្ឍនភាពការងារ និងគំនិតទស្សនទានរបស់នាយកដ្ឋាន ក្នុងការគ្រប់គ្រង និងអនុវត្តតួនាទីភារកិច្ចប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល ។





+កិច្ចប្រជុំនេះមានការចូលរួមពីឯកឧត្តមអនុប្រធាន អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាន-អនុប្រធាននាយកដ្ឋាននៃនាយកដ្ឋាន ចំណុះអគ្គលេខាធិការដ្ឋាន អទស , ប្រធាន-អនុប្រធានការិយាល័យ ក្រោមឱវាទនាយកដ្ឋានធនធានធម្មជាតិ ។

+បន្ទាប់ពីស្ដាប់បទបង្ហាញស្ដីពីវឌ្ឍនភាព និងគំនិតទស្សនទានរយៈពេល ៩ខែដើមឆ្នាំ ២០២៣ របស់ប្រធាននាយកដ្ឋាន និងចំណាប់អារម្មណ៍របស់ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេសរួចមក ឯកឧត្តម ប្រធានអង្គប្រជុំ បានឯកភាពអំពីគំនិតទស្សនទាន ដែលបានលើកឡើងរបស់នាយកដ្ឋានធនធានធម្មជាតិ ព្រមទាំងបានចង្អុលបង្ហាញនូវគំនិតជាយុទ្ធសាស្ត្រគន្លឹះមួយចំនួនបន្ថែមទៀត ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងអនុវត្តតួនាទីភារកិច្ចឲ្យបានកាន់តែល្អប្រសើរក្នុងការលើកស្ទួយស្ថាប័ន ដោយស្មារតីចូលរួមលើកកម្ពស់ប្រសិទ្ធភាពការអនុវត្តគោលនយោបាយយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល នីតិកាលទី៧ ដូចជា ៖

1- កែលម្អក្នុងការគ្រប់គ្រង និងទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំនាយកដ្ឋាន តាមការិយាល័យជំនាញ ដើម្បីប្រសិទ្ធភាពការងារ និងសុខដុមក្នុងនាយកដ្ឋាន

2- បន្តផ្ដល់ការលើកទឹកចិត្តដល់មន្ត្រីក្នុងនាយកដ្ឋាន និងគិតគូអ្នកបន្តវេន តាមរយៈការពិនិត្យវាយតម្លៃលក្ខណៈសម្បត្តិ អត្តចរិត និងលទ្ធផលបំពេញការងារ ដោយផ្ដោតលើភាពក្លាហាន សមត្ថភាព និងគុណធម៌

3- កែលម្អ និងអនុវត្តបញ្ចប់គម្រោងសកម្មភាព 2023 និងរៀបចំពិនិត្យកែសម្រួលឲ្យបានច្បាស់លាស់ត្រឹមត្រូវ សម្រាប់ចងក្រងជារបាយការណ៍បច្ចេកទេសតាមសកម្មភាពនីមួយៗចុងឆ្នាំ២០២៣ និងត្រៀមលក្ខណៈបច្ចេកទេសឲ្យបានគ្រប់ជ្រុងជ្រោយចំពោះរបកគំហើញលទ្ធផលស្រាវជ្រាវ ក្នុងកិច្ចប្រជុំអន្តរក្រសួងជំនាញ

4- ពិនិត្យខ្លឹមសារបច្ចេកទេសគម្រោង ដែលត្រូវលើកឡើងសម្រាប់អនុវត្តន៍ឆ្នាំ 2024 អោយស្របនឹងតួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់នាយកដ្ឋាន

5- តាមរយៈការលើកស្នើឡើងក្នុងអង្គប្រជុំចំពោះការសុំបន្តអនុវត្តគម្រោងសកម្មភាពសិក្សាផលចាប់ឡូត៍ដាយឆ្នាំ២០២៣-២០២៤ នៅឡូត៍លេខ ១៣ និង១៥ ក្នុងខេត្តកណ្ដាល។ ប្រធានអង្គប្រជុំ បានប្រគល់ជូនឯកឧត្តម លឹម ពុយ ដឹកនាំប្រជុំពិភាក្សាបែងចែកការទទួលខុសត្រូវឲ្យបានច្បាស់លាស់ជាមួយនាយកដ្ឋានធនធានធម្មជាតិ និងនាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស ដើម្បីសិក្សាបន្ត ។



# កិច្ចប្រជុំពិនិត្យវឌ្ឍនភាពនិងទស្សនទាន នៃការគ្រប់គ្រងពង្រឹងបណ្តាញផ្សព្វផ្សាយព័ត៌មាន សម្រាប់អាជ្ញាធរទន្លេសាប



ដោយទទួលបានការឯកភាពដ៏ខ្ពង់ខ្ពស់ពីឯកឧត្តម រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប ថ្ងៃសុក្រ ៨រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ០៨ ខែកញ្ញា ឆ្នាំ ២០២៣ នៅអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ឯកឧត្តម ហៃល តូនី អនុប្រធានទទួលបន្ទុកក្តាប់រួម បានដឹកនាំកិច្ចប្រជុំពិភាក្សាការងារពាក់ព័ន្ធនឹងតួនាទីភារកិច្ច និងការទទួលខុសត្រូវរបស់នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ដើម្បីពិនិត្យមើលពីវឌ្ឍនភាពការងារ និងគំនិតទស្សនទានរបស់នាយកដ្ឋាន ក្នុងការគ្រប់គ្រងពង្រឹងបណ្តាញប្រព័ន្ធផ្សព្វផ្សាយ និងចែករំលែកព័ត៌មាន ចំណេះដឹងរបស់អាជ្ញាធរទន្លេសាប ។

+ កិច្ចប្រជុំនេះ មានការចូលរួមពីឯកឧត្តម អគ្គលេខាធិការស្តីទី ប្រធាននាយកដ្ឋាននៃនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋាន អទស , ប្រធាន និងអនុប្រធានការិយាល័យ ក្រោមឱវាទនាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ។

+ បន្ទាប់ពីស្តាប់បទបង្ហាញស្តីពីវឌ្ឍនភាព និងគំនិតទស្សនទាន នៃការគ្រប់គ្រងពង្រឹងបណ្តាញប្រព័ន្ធផ្សព្វផ្សាយ និងការចែករំលែកព័ត៌មានចំណេះដឹង និងចំណាប់អារម្មណ៍របស់ថ្នាក់ដឹកនាំ និងមន្ត្រីបច្ចេកទេស ។ ឯកឧត្តម ប្រធានអង្គប្រជុំ បានឯកភាពអំពីគំនិតទស្សនទាន ដែលបានលើកឡើងរបស់នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ព្រមទាំងបានចង្អុលបង្ហាញនូវគំនិតជាយុទ្ធសាស្ត្រគន្លឹះមួយចំនួន ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្សព្វផ្សាយ និងការចែករំលែកឲ្យបានកាន់តែល្អប្រសើរបន្ថែមទៀតក្នុងការវិវត្តការងាររបស់ស្ថាប័ន ឲ្យស្របទៅសង្គមឌីជីថល ក្នុងស្មារតីចូលរួមលើកកម្ពស់ប្រសិទ្ធភាពការអនុវត្តគោលនយោបាយយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលនីតិកាលទី ៧ ដូចជា ៖

1- បន្តលើកកម្ពស់ និងពង្រឹងផ្នែកហេដ្ឋារចនាសម្ព័ន្ធព័ត៌មានវិទ្យា, ការប្រាស្រ័យទាក់ទង និងបច្ចេកវិទ្យា Information, Communication and Technology (ICT) ។

2- បន្តធ្វើបច្ចុប្បន្នភាព ដើម្បីឲ្យប្រព័ន្ធ Website និង Facebook របស់អាជ្ញាធរទន្លេសាបឲ្យកាន់តែប្រសើរឡើង

3- បន្តរៀបចំបង្កើតប្រព័ន្ធបណ្តាញផ្សព្វផ្សាយផ្សេងៗទៀត ដូចជា Telegram Channel ដើម្បីចែករំលែកព័ត៌មានបានរហ័សទាន់ពេល និងងាយស្រួលដល់មហាជនទទួលបានព័ត៌មាន

4- បន្តពិនិត្យសិក្សាលំអិត លើការរៀបចំបង្កើត TSA Map information

5- កំណត់ទម្រង់បែបទ សម្រាប់ការសរសេរអត្ថបទខ្លី (Breaking News) ដើម្បីផ្សព្វផ្សាយក្នុងបណ្តាញសង្គម (Facebook) និង វេបសាយ (Web site)

6- នាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ត្រូវបង្កើនប្រសិទ្ធភាពការងារក្នុងការធ្វើបច្ចុប្បន្នភាពលើការគ្រប់គ្រងបណ្តាញផ្សព្វផ្សាយ, មាន Facebook , Website និង Sever របស់អាជ្ញាធរទន្លេសាប ឲ្យបានល្អប្រសើរ ។






## ថ្នាក់ដឹកនាំអាជ្ញាធរទន្លេសាបជួបប្រជុំពិភាក្សាជាមួយនឹងតំណាងអង្គការ UNOPS



រាជធានីភ្នំពេញ : ថ្ងៃព្រហស្បតិ៍ ១រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី ០៦ ខែមីនា ឆ្នាំ ២០២៣ ឯកឧត្តម លឹម ពុយ អនុប្រធានអាជ្ញាធរទន្លេសាប ឯកឧត្តម ម៉ៅ ហាក់ អនុប្រធានអាជ្ញាធរទន្លេសាប និងមន្ត្រីបច្ចេកទេស បានជួបប្រជុំពិភាក្សាជាមួយនឹងតំណាងអង្គការ UNOPS ដែលមានលោកស្រី Samina Kadwani, Director of EAPMCO, លោក Akira Moretto, Head of Partnerships និងលោក Darapisour Rath, Partnerships Specialist នៅសាលប្រជុំអាជ្ញាធរទន្លេសាប។
កិច្ចប្រជុំពិភាក្សានេះមានគោលបំណង :

(១) ណែនាំខ្លួន និងការយល់គ្នាទៅវិញទៅមកអំពីសាវតាការងារ និងសកម្មភាពដែលបានធ្វើកន្លងមក

(២) ការយល់ដឹងអំពីបញ្ហាចំបងរបស់បឹងទន្លេសាប climate change, aquatic environment, water quality pollution, livelihood and social economy, biosphere reserve.

(៣) រៀបចំ Concept Note (គោលគំនិតបញ្ហា) ដើម្បីកសាងសំណើលើការស្រាវជ្រាវ គម្រោង ការកសាងធនធានមនុស្ស ។

## ឯកឧត្តម លឹម ពុយ បានអញ្ជើញចូលរួមប្រជុំ ក្រោមប្រធានបទ Mekong Research Symposium "Data into Action for Resilient Mekong"



ដោយបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប នាថ្ងៃអង្គារ ៨រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០២៣ ឯកឧត្តម លឹម ពុយ អនុប្រធានអាជ្ញាធរទន្លេសាប ទទួលជួយឯកឧត្តមប្រធានអាជ្ញាធរទន្លេសាបលើកិច្ចការបច្ចេកទេស និងសិក្សាស្រាវជ្រាវ បានអញ្ជើញចូលរួមប្រជុំ ក្រោមប្រធានបទ Mekong Research Symposium "Data into Action for Resilient Mekong" ដែលមានរយៈពេល ០៣ថ្ងៃ នៅទីក្រុងឈៀងរ៉ៃ ប្រទេសថៃ ដោយមានការអញ្ជើញចូលរួមពី បណ្តាប្រទេសតំបន់អាស៊ីដែលទន្លេមេគង្គហូរកាត់។ នៅក្នុងឱកាសនោះដែរ ឯកឧត្តមក៏បានអញ្ជើញធ្វើបទបង្ហាញស្តីពី Data on Tonle Sap Great Lake for Decision Making in Cambodia ជូនអង្គប្រជុំព្រមទាំងជាវាគ្មិនក្នុងកិច្ចពិភាក្សាប្តូរយោបល់លើការគ្រប់គ្រងទិន្នន័យ និងការផ្សព្វផ្សាយស្តីពីការប៉ះពាល់លើធនធានធម្មជាតិដែលទាក់ទងនឹងការផ្លាស់ប្តូរអាកាសធាតុលើអាងទន្លេមេគង្គ ជាពិសេសបឹងទន្លេសាប ។



# កិច្ចប្រជុំពិនិត្យលើវឌ្ឍនភាពអនុវត្តគម្រោងសហប្រតិបត្តិការចំនួន ៣ ដែលបាន និងកំពុងអនុវត្តដោយអាជ្ញាធរទន្លេសាប

រាជធានីភ្នំពេញ ៖ ដោយទទួលបានការឯកភាពដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប ។ ព្រឹកថ្ងៃច័ន្ទ ៤កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ១៨ ខែកញ្ញា ឆ្នាំ ២០២៣ អាជ្ញាធរទន្លេសាប បានរៀបចំកិច្ចប្រជុំពិនិត្យលើវឌ្ឍនភាពអនុវត្តគម្រោងចំនួន ៣ ដែលបាន និងកំពុងអនុវត្តដោយអាជ្ញាធរទន្លេសាបក្រោមកិច្ចសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ និងទស្សនៈទានការងារពង្រឹងអាជ្ញាធរទន្លេសាប ក្រោមអធិបតីភាពឯកឧត្តម ប៊ុន ហ៊ាន រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម ដែលទទួលជួយឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជា ប្រធានអាជ្ញាធរទន្លេសាប ក្នុងការសម្របសម្រួលកិច្ចការ អាជ្ញាធរទន្លេសាប ។

+ កិច្ចប្រជុំនេះមានការចូលរួមពីឯកឧត្តមអនុប្រធាន អគ្គលេខាធិការ អគ្គលេខាធិការរង ប្រធាន អនុប្រធាននាយកដ្ឋាន ប្រធាន អនុប្រធានការិយាល័យ មន្ត្រី និងមន្ត្រីកិច្ចសន្យាក្រោមឱវាទអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប សរុបចំនួន ៧០ នាក់ ។

+ ក្រោយពីស្តាប់សេចក្តីរាយការណ៍សង្ខេបការងាររួមកន្លងមករបស់ឯកឧត្តម សរ គឹមសាន្ត អគ្គលេខាធិការ អាជ្ញាធរទន្លេសាប អង្គប្រជុំក៏បានធ្វើបទបង្ហាញ ស្តីពីវឌ្ឍនភាព និងលទ្ធផលនៃការអនុវត្តគម្រោងសហប្រតិបត្តិការទាំង ៣ របស់ប្រធានគម្រោង រួមមាន ៖ (1). គម្រោងការតាមដានផលចាប់នៅខេត្តជុំវិញបឹងទន្លេសាប បង្ហាញដោយ លោក ហេង សុវណ្ណារ៉ា ប្រធាននាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស (2). គម្រោងការគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន បង្ហាញដោយ ឯកឧត្តម លឹម ពុយ អនុប្រធាន អាជ្ញាធរទន្លេសាប (3). គម្រោងសិក្សាគំរូបច្ចេកវិទ្យា សង្កេត និងបញ្ជូនទិន្នន័យជលសាស្ត្រសម្រាប់អាងទន្លេសាបកម្ពុជា បង្ហាញដោយ ឯកឧត្តម ម៉ៅ ហាក់ អនុប្រធានអាជ្ញាធរទន្លេសាប និងចុងក្រោយ (4). ទស្សនៈទានពង្រឹងការងារ អាជ្ញាធរទន្លេសាប បង្ហាញដោយ ឯកឧត្តម ហ៊ែល តូនី អនុប្រធានក្តាប់រួម នៃអាជ្ញាធរទន្លេសាប ។

+ បន្ទាប់ពីស្តាប់បទបង្ហាញខាងលើ អង្គប្រជុំបានពិនិត្យ និង



ពិភាក្សាការងារគ្នាយ៉ាងយកចិត្តទុកដាក់ក្នុងការចូលរួម លើកកម្ពស់ប្រសិទ្ធភាពការងារអង្គភាព និងបានឯកភាពគ្នាដូចខាងក្រោម ៖

1- ត្រូវពិនិត្យ និងកែសម្រួលសេចក្តីសម្រេចសមាសភាពក្រុមការងារអនុវត្តគម្រោងឡើងវិញ ដើម្បីស្នើសុំការសម្រេច និងអនុម័តដ៏ខ្ពង់ខ្ពស់បំផុតពីឯកឧត្តមប្រធាន អាជ្ញាធរទន្លេសាប ចំពោះគម្រោងកំពុងតែបន្តអនុវត្ត ករណីដូចជា ៖ គម្រោងគ្រប់គ្រងធនធានទឹកចម្រុះអាងស្ទឹងសែន និងគម្រោងការតាមដានផលចាប់នៅខេត្តជុំវិញបឹងទន្លេសាប (MRCs)

2- គម្រោងដែលបានបញ្ចប់ការគាំទ្រពីដៃគូ ត្រូវពិនិត្យរៀបចំយន្តការការងារជាថ្មីក្នុងការថែទាំ ដើម្បីឲ្យគម្រោងមាននិរន្តរភាព ដោយត្រៀមបញ្ចូលទៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំរបស់អង្គភាព ក្នុងការស្វែងរកថវិកាគាំទ្របន្ត

3- ត្រូវបន្តពិនិត្យ និងរៀបចំការងារបន្តលើការងារព្រំតំបន់ 2 និងតំបន់ 3 បន្ទាប់ពីការកាត់ឆ្វៀល

4- ត្រូវបន្តពង្រឹងការងារស្នូល និងលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលការងារអាជ្ញាធរទន្លេសាប ស្របតាមទស្សនៈទានការងារ ដែលបានកំណត់ ដោយឈរលើអភិបាលកិច្ច និងសុខដុមនីយកម្ម ។





## ឯកឧត្តម ម៉ៅ ហាក់ ដឹកនាំសម្របសម្រួលកិច្ចប្រជុំ ពិនិត្យវាយតម្លៃលទ្ធផលការអនុវត្តផែនការសកម្មភាពការងារឆ្នាំ ២០២២ និងលើកទិសដៅការងារបន្តឆ្នាំ ២០២៣



ដោយបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប នាព្រឹកថ្ងៃសុក្រ ១៣កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី ០៣ ខែកុម្ភៈ ឆ្នាំ ២០២៣ ឯកឧត្តម ម៉ៅ ហាក់ អនុប្រធានអាជ្ញាធរទន្លេសាបបានដឹកនាំសម្របសម្រួលកិច្ចប្រជុំ ពិនិត្យវាយតម្លៃលទ្ធផលការអនុវត្តផែនការសកម្មភាពការងារឆ្នាំ ២០២២ និងលើកទិសដៅការងារបន្តឆ្នាំ ២០២៣ ។ កិច្ចប្រជុំនេះបានពិនិត្យ និងពិភាក្សាលើគ្រប់សកម្មភាពអនុវត្តនៅឆ្នាំ២០២២ ដោយបានកំណត់ចំណុចវិជ្ជមាន និងចំណុចខ្វះខាត ព្រមទាំងបញ្ហាប្រឈមក្នុងការអនុវត្តសកម្មភាពការងារកន្លងមក ។ រីឯការរៀបចំផែនការសកម្មភាពសម្រាប់ឆ្នាំ២០២៣ អង្គប្រជុំបានពិនិត្យ និងពិភាក្សា ដោយយោងលើចំណុចខ្វះខាត បញ្ហាប្រឈមដែលបានជួបប្រទះ និងយោងលើស្ថានភាពវិវត្តជាក់ស្តែងនៅបឹងទន្លេសាប ។

## កិច្ចប្រជុំត្រួតពិនិត្យ តាមដានលទ្ធផលនៃការអនុវត្តផែនការសកម្មភាពការងារឆមាសទី ១ និងលើកទិសដៅការងារឆមាសទី ២ ឆ្នាំ ២០២៣

នៅព្រឹកថ្ងៃអង្គារ ១៤រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី ១៥ ខែសីហា ឆ្នាំ ២០២៣ ឯកឧត្តម ម៉ៅ ហាក់ អនុប្រធានអាជ្ញាធរទន្លេសាប តំណាងដ៏ខ្ពង់ខ្ពស់ពីឯកឧត្តម លឹម គានហោ រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប បានដឹកនាំសម្របសម្រួលកិច្ចប្រជុំត្រួតពិនិត្យ តាមដានលទ្ធផលនៃការអនុវត្តផែនការសកម្មភាពការងារឆមាសទី ១ និងលើកទិសដៅការងារឆមាសទី ២ ឆ្នាំ ២០២៣ របស់អាជ្ញាធរទន្លេសាប។ កិច្ចប្រជុំនេះ មានការចូលរួមពី ឯកឧត្តមអនុប្រធាន ឯកឧត្តមអគ្គលេខាធិការរង ប្រធាន-អនុប្រធាននាយកដ្ឋាន ប្រធាន-អនុប្រធានការិយាល័យ និងមន្ត្រីរាជការអាជ្ញាធរទន្លេសាបចំនួន ៦៥នាក់។
កិច្ចប្រជុំបានពិនិត្យ និងពិភាក្សាលើ ៖





១-ពិនិត្យមើលវឌ្ឍនភាពការងារ នៃការអនុវត្តសកម្មភាពនីមួយៗ ក្នុងឆមាសទី ១ ឆ្នាំ ២០២៣
២-ពិភាក្សាពីចំនុចខ្លាំង ចំនុចខ្សោយ ឧបសគ្គ/បញ្ហាប្រឈម និងដំណោះស្រាយ
៣-ផ្លាស់ប្តូរបទពិសោធន៍ និងចែករំលែកការយល់ដឹងតាមរយៈការអនុវត្តសកម្មភាពការងារនីមួយៗ
៤-លើកទិសដៅអនុវត្តបន្តការងារឆមាសទី ២ ឆ្នាំ ២០២៣។

## ឯកឧត្តម ម៉ៅ ហាក់ ដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយស្តីពី ការប្រើប្រាស់បណ្តាញផ្ទុកទិន្នន័យ (NAS) នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប

ថ្ងៃអង្គារ ២កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ ២០២៣ ឯកឧត្តម ម៉ៅ ហាក់ អនុប្រធានអាជ្ញាធរទន្លេសាប បានដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយស្តីពី ការប្រើប្រាស់បណ្តាញផ្ទុកទិន្នន័យ (NAS) ក្នុងការគ្រប់គ្រងព័ត៌មាន ទិន្នន័យរបស់អគ្គលេខាធិកាដ្ឋានអាជ្ញាធរទន្លេសាប ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីអគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប ។
កិច្ចប្រជុំនេះ មានគោលបំណង ៖
-ស្វែងយល់ អំពីរបៀបទុកដាក់ទិន្នន័យ នៅក្នុងបណ្តាញផ្ទុកទិន្នន័យ (NAS)
-ការរៀបចំ ទុកដាក់ទិន្នន័យ ប្រកបដោយសុវត្ថិភាព និងការទាញយកទិន្នន័យមកប្រើប្រាស់ ក្នុងអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ។



## ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរទន្លេសាប ដឹកនាំកិច្ចប្រជុំក្រុមការងារពិនិត្យតាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹកជុំវិញតំបន់បឹងទន្លេសាប



នៅអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរទន្លេសាប បានរៀបចំកិច្ចប្រជុំពិភាក្សាការងារបច្ចេកទេសជាមួយក្រុមការងារចុះពិនិត្យតាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹកជុំវិញតំបន់បឹងទន្លេសាប ក្រោមការដឹកនាំដោយប្រធានក្រុមការងារទទួលខុសត្រូវប្រចាំតាមមុខព្រួញ ដែលជាថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប ដើម្បីត្រៀមលក្ខណៈកិច្ចការបច្ចេកទេស ក្នុងការដាក់ផែនការចុះផ្សព្វផ្សាយ និងចុះអនុវត្តន៍តាមដានត្រួតពិនិត្យ និងផ្ទៀងផ្ទាត់និយាមកាបង្គោលព្រំការពារដែនព្រៃលិចទឹក និងតំបន់កាត់ឆ្វៀល ក្នុងតំបន់ ១ តំបន់ ២ និងតំបន់ ៣ ដែលស្ថិតក្នុងភូមិសាស្ត្រខេត្តកំពង់ឆ្នាំង ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងខេត្តកំពង់ធំ ។
សូមជម្រាបថា : (1). ប្រធានក្រុមការងារទទួលបន្ទុកផ្សព្វផ្សាយច្បាប់បទដ្ឋានគតិយុត្ត ព័ត៌មាន និងចំណេះដឹងពាក់ព័ន្ធ ដឹកនាំដោយ ឯកឧត្តម សរ គឹមសាន្ត អគ្គលេខាធិការ នៃអាជ្ញាធរទន្លេសាប, (2). ប្រធានក្រុមការងារទទួលបន្ទុកប្រចាំមុខព្រួញផ្លូវជាតិលេខ ៦ ដឹកនាំដោយ ឯកឧត្តម ខូវ មាស អគ្គលេខាធិការរង នៃអាជ្ញាធរទន្លេសាប និង (3). ប្រធានក្រុមការងារទទួលបន្ទុកប្រចាំមុខព្រួញផ្លូវជាតិលេខ ៥ ដឹកនាំដោយឯកឧត្តម ជា សុខនី អគ្គលេខាធិការរង នៃអាជ្ញាធរទន្លេសាប ។
សូមបញ្ជាក់ថា : អាជ្ញាធរទន្លេសាប បានបង្កើតក្រុមការងារចុះពិនិត្យតាមដាន និងអធិការកិច្ចដែនព្រៃលិចទឹក និងព្រៃលិចទឹកស្ថិតក្នុងខេត្តទាំង៦ ជុំវិញបឹងទន្លេសាប (ខេត្តកំពង់ឆ្នាំង, ពោធិ៍សាត់, បាត់ដំបង, បន្ទាយមានជ័យ, សៀមរាប និងខេត្តកំពង់ធំ) ដែលរាជរដ្ឋាភិបាលបានឆ្វៀលចេញពីដែនព្រៃលិចតំបន់៣ មកតំបន់២ និង. ពីតំបន់២ មកតំបន់១ នៃអនុក្រឹត លេខ ១៩៧ អនក្រ.បកចុះថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១១ ដែលមានដែនទំហំ ៦៤៧,៤០៦ហិកតា ជូនប្រជាពលរដ្ឋអាស្រ័យផល និងតាំងទីលំនៅ ។ ក្រុមការងារ បាន និងកំពុងបន្តអនុវត្តន៍តួនាទីភារកិច្ច ក្នុងការប្រមូលផ្ទៀងផ្ទាត់ទិន្នន័យព័ត៌មានជាក់លាក់ ដើម្បីពិភាក្សាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងថ្នាក់ក្រោមជាតិនៃខេត្តទាំង ៦ ជុំវិញបឹងទន្លេសាប និងធ្វើការផ្សព្វផ្សាយបង្កើនការយល់ដឹងពីសារប្រយោជន៍ធនធានធម្មជាតិ និងចូលរួមកិច្ចការការពារ ធនធានធម្មជាតិ បឹងទន្លេសាបប្រកបដោយចីរភាព ។

# ឯកឧត្តម សរ គឹមសាន្ត ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ របាយការណ៍សិក្សាស្រាវជ្រាវ ផលប៉ះពាល់នៃលំហូរទឹកទាបពីទន្លេមេគង្គទៅកាន់បឹងទន្លេសាបលើជីវភាពរបស់សហគមន៍បឹងទន្លេសាប និងបរិស្ថានធម្មជាតិ



នៅសណ្ឋាគារសាន់វេ រាជធានីភ្នំពេញ នាព្រឹកថ្ងៃចន្ទ ១កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ ឯកឧត្តម សរ គឹមសាន្ត អគ្គលេខាធិការ អាជ្ញាធរទន្លេសាប បានអញ្ជើញចូលរួមថ្លែងសុន្ទរកថា និងប្រកាសបើកកម្មវិធីស្តីពី សិក្ខាសាលាផ្សព្វផ្សាយរបាយការណ៍សិក្សាស្រាវជ្រាវផលប៉ះពាល់នៃលំហូរទឹកទាប ពីទន្លេមេគង្គទៅកាន់បឹងទន្លេសាបលើជីវភាពរបស់សហគមន៍បឹងទន្លេសាប និងបរិស្ថានធម្មជាតិ ដោយមានការចូលរួមពីសហគមន៍បឹងទន្លេសាប និងទន្លេមេគង្គគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា, តំណាងរដ្ឋបាលជលផល, អង្គការ World Fish, តំណាងអង្គការ Oxfam និងតំណាងរដ្ឋសភា ដែលមានមនុស្សសរុប ៤៤នាក់ (ស្រី ៩នាក់) ។

សុន្ទរកថាគន្លឹះរបស់ឯកឧត្តមបានផ្តោតថា បឹងទន្លេសាបជាបេះដូងកម្ពុជា បឹងទន្លេសាបជាជម្រក និងជម្រកជីវចម្រុះគ្រប់ប្រភេទ បឹងទន្លេសាបធំជាងគេនៅអាស៊ីអាគ្នេយ៍ ដែលអាចរីកក្រឡាផ្ទៃរហូតដល់ជាង 15,000 គីឡូម៉ែត្រការ៉េ ជាមួយជម្រៅទឹកបឹង 10 ម៉ែត្រ នៅរដូវវស្សា ឆ្នាំ២០០០ ដែលបង្កដោយលំហូរទឹកទន្លេមេគង្គទៅកាន់បឹងទន្លេសាប។ តែជាងពីរទសវត្សរ៍ចុងក្រោយនេះ ការអភិវឌ្ឍតាមដងទន្លេមេគង្គផ្នែកខាងលើ ការប្រែប្រួលអាកាសធាតុ កត្តាមនុស្ស និងកត្តាផ្សេងៗទៀត បានដាក់សម្ពាធលើទន្លេមេគង្គ ហើយបានបន្តជះឥទ្ធិពលយ៉ាងខ្លាំងលើការប្រែប្រួលរបបលំហូរជលសាស្ត្រទន្លេមេគង្គមកកាន់បឹងទន្លេសាប។ ជាក់ស្តែងឆ្នាំ២០២៣នេះ បឹងទន្លេសាបមានកម្ពស់អតិបរិមាត្រឹមតែ 6.95 ម៉ែត្រ (ហើយមានរយៈពេលខ្លី មិនដល់ត្រឹម១០ថ្ងៃផង កម្ពស់ទឹកចាប់ ផ្តើមស្រកទៅវិញ) បើប្រៀបធៀបនឹងកម្ពស់ទឹកឆ្នាំ២០០០ ខុសគ្នាប្រមាណជា 30% ។ កត្តានេះបានបង្កដល់ការប៉ះពាល់យ៉ាងខ្លាំង មិនត្រឹមតែជីវភាពរបស់ប្រជាសហគមន៍បឹងទន្លេសាបនោះទេ ថែមទាំងប៉ះពាល់ដល់ជីវចម្រុះផងដែរ។



ឯកឧត្តមបានមានប្រសាសន៍ផ្តាំផ្ញើដល់អ្នកចូលរួមទាំងអស់ឲ្យសស្រាក់សស្រាំផ្តល់គំនិតយោបល់ មតិត្រលប់ និងមតិកែលម្អលើលទ្ធផលសិក្សាស្រាវជ្រាវនេះឲ្យកាន់តែគ្រប់ជ្រុងជ្រោយសម្រាប់ថ្ងៃនេះ និងអនាគត ដើម្បីបឹងទន្លេសាបរបស់យើងទាំងអស់គ្នា។

សូមជម្រាបថា៖ ក្នុងសិក្ខាសាលាផ្សព្វផ្សាយនេះដែរ លោកខ្វាន់ ភត្រ្តា អនុប្រធាននាយកដ្ឋានធនធានធម្មជាតិ បានចូលរួមជាវាគ្មិនឆ្លើយសំណួរ និងពិភាក្សា "ដំណោះស្រាយបែបណាលើផលប៉ះពាល់សហគមន៍ និងបឹងទន្លេសាបដោយលំហូរទាបពីទន្លេមេគង្គទៅកាន់បឹងទន្លេសាប"

(១). អាជ្ញាធរទន្លេសាបមានផែនការយុទ្ធសាស្ត្ររបស់ខ្លួន 2024-2028 ដោយមានផ្នែកសេដ្ឋកិច្ចសង្គម ជាទិសដៅយុទ្ធសាស្ត្រសម្រាប់ការសិក្សាស្រាវជ្រាវ និងរៀបចំគោលនយោបាយការងារ និងមុខរបរ តំបន់បឹងទន្លេសាប

(២). បឹងទន្លេសាបមានប្រភពទឹកចំនួនបីធំៗ ទឹកពីទន្លេមេគង្គប្រមាណ ៥២% ទឹកពីដៃស្ទឹងធំៗទាំង១១ ប្រមាណ ៣៨% និងទឹកពីទឹកភ្លៀងប្រមាណ ១០% យើងពិតជាពិបាកណាស់ក្នុងការធ្វើឲ្យលំហូរទឹកទន្លេមេគង្គត្រលប់មកភាពប្រក្រតីមកវិញ តែយើងអាចឲ្យបឹងទន្លេសាបបន្សាំខ្លួន (resilience) បានទៅនឹងការប្រែប្រួលរបបជលសាស្ត្រ ទោះជម្រៅទឹក ៦ម៉ែត្រ ឬ ៧ម៉ែត្រក្តី ដោយមានការសិក្សាបែបវិទ្យាសាស្ត្រមួយថា តើបឹងទន្លេសាបយើងត្រូវការទឹកចំនួនប៉ុន្មានដើម្បីរស់ដោយផ្សារភ្ជាប់ជាមួយប្រព័ន្ធអេកូឡូស៊ីរួមមាន ទឹក ត្រី ព្រៃ មនុស្ស និងបរិស្ថានធម្មជាតិ។

## កិច្ចប្រជុំពិភាក្សាពីដំណើរការអនុវត្តការងាររបស់អគ្គលេខាធិការដ្ឋានអាជ្ញាធរទន្លេសាប

រាជធានីភ្នំពេញ ៖ ដោយទទួលបានការឯកភាពដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមរដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម និងជាប្រធានអាជ្ញាធរទន្លេសាប នៅព្រឹកថ្ងៃព្រហស្បតិ៍ ៥កើត ខែភទ្របទ ឆ្នាំថោះ ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី ១៩ ខែតុលា ឆ្នាំ ២០២៣ ឯកឧត្តម សរ គឹមសាន្ត អគ្គលេខាធិការ អាជ្ញាធរទន្លេសាប បានដឹកនាំកិច្ចប្រជុំពិភាក្សាពីដំណើរការអនុវត្តការងាររបស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប ដែលមានការចូលរួមពីថ្នាក់ដឹកនាំ អគ្គលេខាធិការរង ទីប្រឹក្សា ប្រធាន-អនុប្រធាននាយកដ្ឋាន និងប្រធានការិយាល័យ សរុបចំនួន ២៧នាក់។
កិច្ចប្រជុំនេះមានគោលបំណងពិភាក្សាពីចំណុចខ្លាំង ចំណុចខ្សោយ បញ្ហាប្រឈម និងផ្តោតសំខាន់អំពីលទ្ធផល នៃការចុះសិក្សាស្រាវជ្រាវ ក្នុងផែនការសកម្មភាពប្រចាំឆ្នាំរបស់អាជ្ញាធរទន្លេសាប។ នៅក្នុងកិច្ចប្រជុំមានការចូលរួមយ៉ាងផុលផុស ពិភាក្សា ផ្តល់គំនិតធាតុចូល និងបទពិសោធន៍ល្អៗ ដែលធ្លាប់បានឆ្លងកាត់កន្លងមក សំដៅលើកកម្ពស់ប្រសិទ្ធភាពបន្ថែមទៀតក្នុងការចុះសិក្សាស្រាវជ្រាវ រៀបចំរបាយការណ៍ពីលទ្ធផល ផ្តល់យោបល់ជូនថ្នាក់ដឹកនាំ ។
នៅក្នុងឱកាសនោះដែរ ឯកឧត្តមប្រធានអង្គប្រជុំបានណែនាំ



ដល់នាយកដ្ឋានក្រោមឱវាទអគ្គលេខាធិការដ្ឋានត្រូវខិតខំយកចិត្តទុកដាក់ បន្តអនុវត្តផែនការសកម្មភាពការងារឆ្នាំ2023 និងគិតគូរគ្រោងផែនការសកម្មភាពឆ្នាំ2024 របស់ខ្លួនអោយស្របតាមតួនាទីភារកិច្ច
លិខិតបទដ្ឋាននានា និងស្របតាមផែនការយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ។

## ឯកឧត្តម ខូច មាស បានអញ្ជើញចូលរួមទិវាជាតិអាហារូបត្ថម្ភលើកទី១០



រាជធានីភ្នំពេញ : ថ្ងៃចន្ទ ៨រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០២៣
ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ បានសហការជាមួយក្រសួង-ស្ថាប័ន ដៃគូរអភិវឌ្ឍ និងសង្គមស៊ីវិលនានា បានរៀបចំវេទិកាជាតិអាហារូបត្ថម្ភលើកទី១០ ក្រោមប្រធានបទ ស្តីពី "ការពង្រឹងប្រព័ន្ធស្បៀងក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ" ក្រោមអធិបតីភាពឯកឧត្តមបណ្ឌិតសភាចារ្យ អ៊ុក រ៉ាប៊ុន ទេសរដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ។ អង្គវេទិកាបានអានសារលិខិត សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងវេទិកាជាតិអាហារូបត្ថម្ភ លើកទី១០ ដែលក្នុងនោះរាជរដ្ឋាភិបាលបានផ្តល់នូវអនុសាសន៍សំខាន់ៗមួយចំនួនស្របតាមយុទ្ធសាស្ត្របញ្ចកោណ ដំណាក់ទី ១ ឱ្យទទួលបានជោគជ័យ ពិសេសមុំទី៤ " ការពង្រឹងប្រព័ន្ធគាំពារសង្គម និងប្រព័ន្ធស្បៀង "។
តំណាងដៃគូអភិវឌ្ឍ បានធ្វើបង្ហាញពីតម្រូវការនៃអាហារូបត្ថម្ភទូទៅសម្រាប់ប្រជាជនកម្ពុជា និងវិភាគអំពីបញ្ហានៃការបំពេញកង្វះសារធាតុចិញ្ចឹម ទាក់ទងទៅនឹងបម្រែបម្រួលអាកាសធាតុដែលយើងកំពុងជួបប្រទះ។
ឯកឧត្តមទេសរដ្ឋមន្ត្រី បានបញ្ជាក់បន្ថែមអំពី ការរៀបចំទិវាជាតិអាហារូបត្ថម្ភ គឺបានប្រារព្ធចំនួន ៩ លើករួចមកហើយ ចាប់តាំងពីឆ្នាំ២០១៤ មក ដោយជ្រើសយក ថ្ងៃទី ០៦ ខែវិច្ឆិកា ជារាងរាល់ឆ្នាំ និងសូមគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន អនុវត្តតាមអនុសាសន៍ សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ក្នុងការយកចិត្តទុកដាក់លើការពង្រឹងប្រព័ន្ធស្បៀងឱ្យបានរឹងមាំ សំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ឆ្ពោះទៅសម្រេចបានគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ ២០៣០ ពិសេសគោលដៅទី២ គឺ បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបាននូវសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងវិញអាហារូបត្ថម្ភ និងលើកកម្ពស់កសិកម្មប្រកបដោយចីរភាព។

## សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិពីលទ្ធផលនៃការវាយតម្លៃតម្រូវការសមត្ថភាព និងសេចក្តីព្រាងផែនការពង្រឹងសមត្ថភាព សម្រាប់ការគ្រប់គ្រងបណ្តាញតាមដានទន្លេ របស់គណៈកម្មការទន្លេមេគង្គ



រាជធានីភ្នំពេញ៖ នាថ្ងៃសុក្រ ៥រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០២៣ លោក ហេង សុវណ្ណារ៉ា ប្រធាននាយកដ្ឋានត្រួតពិនិត្យការ ធ្វើអាជីវកម្ម និងអភិរក្ស និងកញ្ញា ប្រាក់ ចាន់វឌ្ឍនា អនុប្រធាននាយកដ្ឋានធនធានធម្មជាតិ នៃអាជ្ញាធរទន្លេសាប បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ថ្នាក់ជាតិ ស្តីពីលទ្ធផលនៃការវាយតម្លៃតម្រូវការសមត្ថភាព និងសេចក្តីព្រាងផែនការពង្រឹង សមត្ថភាព សម្រាប់ការគ្រប់គ្រងបណ្តាញតាមដានទន្លេរបស់គណៈកម្មការទន្លេមេគង្គ ក្រោមអធិបតីភាព ឯកឧត្តម តែ ណាវុធ អនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (គជទមក)។ សមាសភាពចូលរួមសិក្ខាសាលា អញ្ជើញមកពីក្រសួង-ស្ថាប័នពាក់ព័ន្ធ រួមមាន ក្រសួងធនធានទឹក និងឧតុនិយម, រដ្ឋបាលជលផល, អាជ្ញាធរទន្លេសាប, គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (CNMC), គណៈកម្មការទន្លេមេគង្គ (MRC) និងក្រុម GIZ។

សិក្ខាសាលា បានពិភាក្សាពិគ្រោះយោបល់ បានផ្តោតសំខាន់លើ៖

១. តម្រូវការសមត្ថភាព និងអាទិភាពនៃអ្នកពាក់ព័ន្ធលើលទ្ធផលនៃការវាយតម្លៃ

២. ស្ថាប័នណាខ្លះគួរអនុវត្តន៍ និងចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោល និងគួរទទួលបានការបណ្តុះបណ្តាលអ្វី

៣. ពិភាក្សាលើបញ្ហាប៉ារ៉ាម៉ែត្រតាមផ្នែកនីមួយៗពាក់ព័ន្ធនឹងផ្នែកជលសាស្ត្រ, ផ្នែក Fisheries, ផ្នែក Sediments, Water Quality, Ecological Health និងយេនឌ័រ និងបរិយាបន្នលើវិធីសាស្ត្រសម្រាប់ផែនការសកម្មភាពអភិវឌ្ឍន៍សមត្ថភាព (CDAP) និងការដាក់ពិន្ទុក្នុងការធ្វើចំណាត់ថ្នាក់អាទិភាពសម្រាប់ការគ្រប់គ្រងបណ្តាញតាមដានទន្លេមេគង្គឆ្លងដែនរបស់ MRC ។

សូមបញ្ជាក់ថា សិក្ខាសាលានេះមានគោលបំណង ដើម្បី ៖

- ដើម្បីបង្ហាញលទ្ធផលនៃការវាយតម្លៃតម្រូវការសមត្ថភាព (CNA) និងដើម្បីបញ្ជាក់ឡើងវិញនូវតម្រូវការសមត្ថភាព និងចន្លោះខ្វះខាតដែលកំណត់ដោយថ្នាក់ជាតិ ។
- ដើម្បីបង្ហាញនិងពិភាក្សាលើសេចក្តីព្រាងផែនការសកម្មភាពអភិវឌ្ឍន៍សមត្ថភាព (CDAP) ។
- ដើម្បីទទួលបានមតិកែលម្អ និងអនុសាសន៍ពីប្រទេសសមាជិកចំពោះ (CDAP) ដែលបានធ្វើបច្ចុប្បន្នភាព។

## សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីឯកសារគោលនយោបាយសម្រាប់ជម្រើសការវិនិយោគ និងវិធានការពាក់ព័ន្ធដើម្បីបង្កើនប្រសិទ្ធភាពផលិតកម្មជលផលការផ្លាស់ប្តូរស្ថានភាពទន្លេ

នាថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២៣ លោក ហេង សុវណ្ណារា ប្រធាននាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស នៃអាជ្ញាធរទន្លេសាប បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពីឯកសារគោលនយោបាយសម្រាប់ជម្រើសការវិនិយោគ និងវិធានការពាក់ព័ន្ធ ដើម្បីបង្កើនប្រសិទ្ធភាពផលិតកម្មជលផលក្រោមការផ្លាស់ប្តូរស្ថានភាពទន្លេ ។ សិក្ខាសាលា បានដឹកនាំដោយឯកឧត្តម សូ សុភ័ទ្ធ អគ្គលេខាធិការនៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានដឹកនាំ និងមានការចូលរួមពី ក្រសួង-ស្ថាប័នពាក់ព័ន្ធ រួមមាន ក្រសួងធនធានទឹក និងឧតុនិយម រដ្ឋបាលជលផល អាជ្ញាធរទន្លេសាប គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងគណៈកម្មការទន្លេមេគង្គ។

#សិក្ខាសាលានេះមានគោលបំណង ៖

1. ជម្រាបជូនអំពីស្ថានភាព និន្នាការ និងបញ្ហាប្រឈមសម្រាប់ការគ្រប់គ្រងជលផលប្រកបនិរន្តរភាពក្នុងអាងទន្លេមេគង្គក្រោម
2. ពិនិត្យ និងពិភាក្សាទៅលើ ឯកសារគោលនយោបាយសម្រាប់ជម្រើស ការវិនិយោគ និងវិធានការពាក់ព័ន្ធដើម្បីបង្កើនប្រសិទ្ធភាពផលិតកម្មជលផល ក្រោមការផ្លាស់ប្តូរស្ថានភាពទន្លេ។
3. ពិភាក្សា និងប្រមូលធាតុចូល អំពីយុទ្ធសាស្ត្រអនុវត្ត ពីភាគីពាក់ព័ន្ធសម្រាប់ការអនុវត្តជំហានបន្ទាប់ ។



## កិច្ចប្រជុំជំនាញផ្នែកបរិស្ថានថ្នាក់តំបន់ ស្តីពីរបាយការណ៍តាមដានភាពសម្បូរបែប និងភាពផ្សេងគ្នានៃប្រភេទត្រីឆ្នាំ២០១៨-២០២២ នៅប្រទេសវៀតណាម



ថ្ងៃ ១១កើត ដល់ ១២កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី២៥ -២៦ ខែតុលា ឆ្នាំ២០២៣ ក្រុមការងារកម្ពុជាដែលមានការចូលរួមពីអាជ្ញាធរទន្លេសាប, រដ្ឋបាលជលផល និងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា បានចូលរួមកិច្ចប្រជុំជំនាញផ្នែកបរិស្ថានថ្នាក់តំបន់ ស្តីពីរបាយការណ៍តាមដានភាពសម្បូរបែប និងភាពផ្សេងគ្នា នៃប្រភេទត្រីឆ្នាំ ២០១៨-២០២២ និងឯកសារគោលនយោបាយជម្រើសការវិនិយោគ និងវិធានការពាក់ព័ន្ធ ដើម្បីបង្កើនប្រសិទ្ធភាពផលិតកម្មជលផល ក្រោមការផ្លាស់ប្តូរស្ថានភាពទន្លេថ្ងៃទី២៥-២៦ ដោយមានការចូលរួមពីប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ (កម្ពុជា ឡាវ ថៃ និងវៀតណាម) និងមន្ត្រីលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ។

កិច្ចប្រជុំនេះមានគោលបំណង ៖

១. ចែករំលែករបកគំហើញ ក៏ដូចជាស្ថានភាព និងនិន្នាការនៃរបាយការណ៍តាមដានសម្បូរបែប និងភាពផ្សេងគ្នានៃប្រភេទត្រីក្នុងអាងទន្លេមេគង្គក្រោម សម្រាប់ឆ្នាំ ២០១៨-២០២២។

២. ពិភាក្សាលើការរួមបញ្ចូលទិន្នន័យការតាមដានភាពសម្បូរបែប និងភាពផ្សេងគ្នានៃប្រភេទត្រី ជាមួយការវាយតម្លៃទិន្នផលជលផលទៅតាមប្រភេទទីជម្រក និងការរួមចំណែកដល់របាយការណ៍ស្ថានភាពអាងទន្លេមេគង្គឆ្នាំ២០២៣។

៣. ប្រមូលមតិយោបល់ និងអនុសាសន៍ពីប្រទេស ជាសមាជិកដើម្បីបង្កើនគុណភាពនៃរបាយការណ៍។

៤. ពិនិត្យ និងពិភាក្សាអំពី ឯកសារគោលនយោបាយជម្រើសការវិនិយោគ និងវិធានការពាក់ព័ន្ធដើម្បីបង្កើនប្រសិទ្ធភាពផលិតកម្មជលផល ក្រោមការផ្លាស់ប្តូរស្ថានភាពទន្លេ។

៥. ពិភាក្សាអំពីជំហ៊ានបន្តដើម្បីអនុវត្តឯកសារគោលនយោបាយនេះ។

## សន្និសីទអន្តរជាតិរបស់គណៈកម្មការទន្លេមេគង្គលើកទី ៤ ស្តីពី នវានុវត្តន៍ និងកិច្ចសហប្រតិបត្តិការសម្រាប់អាងទន្លេមេគង្គ

វៀងច័ន្ទ (ឡាវ)៖ ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីឯកឧត្តមប្រធានអាជ្ញាធរទន្លេសាប នាថ្ងៃអាទិត្យ ១២កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី ០២ ខែមេសា ឆ្នាំ ២០២៣ លោក វិន ប៊ុនពៅ ប្រធាននាយកដ្ឋានធនធានធម្មជាតិ បានចូលរួមសន្និសីទអន្តរជាតិរបស់គណៈកម្មការទន្លេមេគង្គ លើកទី ៤ ស្តីពី នវានុវត្តន៍ និងកិច្ចសហប្រតិបត្តិការសម្រាប់អាងទន្លេមេគង្គ ដែលមានសន្តិសុខទឹក និងប្រកបដោយចីរភាព នៅសាធារណៈរដ្ឋប្រជាមានិតឡាវ ដឹកនាំដោយ ឯកឧត្តម សូ សុភ័ទ្ទ អគ្គលេខាធិការគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងមន្ត្រីតំណាងក្រសួង ស្ថាប័នប្រទេសកម្ពុជា ចំនួន ១៧នាក់ និងសមាជិកប្រទេសទាំង ៣ ទៀត គឺថៃ ឡាវ និងវៀតណាម ព្រមទាំង វិទ្យាស្ថានស្រាវជ្រាវ និងអង្គការដៃគូមួយចំនួន សរុបប្រមាណ ៨០០ នាក់។សន្និសីទនេះរៀបចំឡើងក្នុងគោលបំណង៖

-បង្ហាញពីសាវតា និងការចែករំលែកបទពិសោធន៍ ស្តីពីផលប៉ះពាល់ និងការគ្រប់គ្រងធនធានទឹកចម្រុះ ទឹកជំនន់ រាំងស្ងួត ខ្យល់ព្យុះ និងការប្រែប្រួលអាកាសធាតុសកល

-ផ្តល់កិច្ចសហប្រតិបត្តិការ ដើម្បីជៀសវាង និងកាត់បន្ថយផលប៉ះពាល់ឆ្លងដែន (ទឹកជំនន់ រាំងស្ងួត និងការប្រែប្រួលអាកាសធាតុ...)




-បង្ហាញពីបច្ចេកវិទ្យាថ្មៃប្រឌិតសម្រាប់ការត្រួតពិនិត្យទន្លេតាមរយៈម៉ូដែល និងការព្យាករណ៍

-កិច្ចសហប្រតិបត្តិការក្នុងការចែករំលែកទិន្នន័យ ព័ត៌មាន និងការគ្រប់គ្រងទឹកឆ្លងដែនឱ្យកាន់តែប្រសើរ

-ប្រព័ន្ធគាំទ្រការសម្រេចចិត្តប្រកបដោយភាពច្នៃប្រឌិតសម្រាប់ការអភិវឌ្ឍធនធានទឹករួមគ្នា និង

-កិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈ និងឯកជន ដើម្បីផ្តល់ហិរញ្ញប្បទានប្រកបដោយការទទួលខុសត្រូវ និងការអភិវឌ្ឍប្រកបដោយចីរភាព។

## សន្និសីទថ្នាក់ជាតិ ស្ដីពីភាពជាដៃគូនៃឋបនីយជីវមណ្ឌលបឹងទន្លេសាប និងជាវាគ្មិនចែករំលែកបទពិសោធន៍លើរបបជលសាស្ត្រ និងការគ្រប់គ្រងធនធានទឹកនៅតំបន់ទន្លេសាប

ថ្ងៃពុធ ១៤កើត ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី ០៣ ខែឧសភា ឆ្នាំ ២០២៣ លោក វិន ប៊ុនពៅ ប្រធាននាយកដ្ឋានធនធានធម្មជាតិ និងលោក ណុំ សោភារិទ្ធ អនុប្រធាននាយកដ្ឋានត្រួតពិនិត្យការធ្វើអាជីវកម្ម និងអភិរក្ស នៃអាជ្ញាធរទន្លេសាប បានចូលរួមសន្និសីទថ្នាក់ជាតិ ស្ដីពីភាពជាដៃគូនៃឋបនីយជីវមណ្ឌលបឹងទន្លេសាប និងជាវាគ្មិនចែករំលែកបទពិសោធន៍លើរបបជលសាស្ត្រ និងការគ្រប់គ្រងធនធានទឹកនៅតំបន់ទន្លេសាប ជាពិសេសតំបន់ឋបនីយជីវមណ្ឌលបឹងទន្លេសាប ដែលមានតំណាងក្រសួង ស្ថាប័ន អាជ្ញាធរខេត្តជុំវិញបឹងទន្លេសាប និងអង្គការក្រៅរដ្ឋាភិបាលនានាចូលរួមសរុបប្រមាណ ១០០នាក់ ក្រោមការដឹកនាំ និងសម្របសម្រួលដោយលោកជំទាវ ម៉ុម ថាវី រដ្ឋលេខាធិការក្រសួងបរិស្ថាន។ សន្និសីទនេះរៀបចំឡើងក្នុងគោលបំណង ចែករំលែកបទពិសោធន៍ ចំណេះដឹង និងពិភាក្សាអំពីដំណោះស្រាយ



គោលនយោបាយ និងវិទ្យាសាស្ត្រ ដើម្បីគ្រប់គ្រងតំបន់ឋបនីយជីវមណ្ឌលបឹងទន្លេសាបប្រកបដោយប្រសិទ្ធភាព និងកសាងកិច្ចសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធនឹងប្រព័ន្ធអេកូឡូស៊ី និងគំនិតផ្ដួចផ្ដើមនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## កិច្ចប្រជុំវេទិកាកម្រិតខ្ពស់ថ្នាក់តំបន់អាស៊ី និងប៉ាស៊ីហ្វិកលើកទី ១១ ស្ដីពី 3R




នាថ្ងៃទី ០៨-១០ ខែកុម្ភៈ ឆ្នាំ ២០២៣ ត្រូវនឹងថ្ងៃពុធ ៣រោច ដល់ថ្ងៃសុក្រ ៥រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ លោកវិន ប៊ុនពៅ ប្រធាននាយកដ្ឋានធនធានធម្មជាតិ នៃអាជ្ញាធរទន្លេសាប បានចូលរួមកិច្ចប្រជុំវេទិកាកម្រិតខ្ពស់ថ្នាក់តំបន់អាស៊ី និងប៉ាស៊ីហ្វិកលើកទី ១១ ស្ដីពី 3R (ការប្រើប្រាស់ឡើងវិញ និងសេដ្ឋកិច្ចវិលជុំឆ្ពោះទៅរកនិរន្តរភាពប្រព័ន្ធអេកូឡូស៊ីទន្លេសាប ក្រោមប្រធានបទ "ការចូលរួមអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ចវិលជុំសំខាន់ៗឆ្ពោះទៅរកការសម្រេចបាននូវសង្គមគ្មានសំរាម (បរិស្ថានល្អ) និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព " (Integrating Circular Economy in Major Development Sectors toward Achieving Zero Waste Societies and the SDGs) នៅខេត្តសៀមរាប ក្រោមការដឹកនាំ និងសម្របសម្រួលដោយក្រសួងបរិស្ថាន និងមានសមាជិកចូលរួមសរុបចំនួន ៥០០នាក់ មកពីក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការដៃគូ សង្គមស៊ីវិល សហគ្រាសក្រុមហ៊ុនឯកជន វិទ្យាស្ថានស្រាវជ្រាវ អាជ្ញាធរថ្នាក់ក្រោមជាតិទាំង ២៥ ខេត្តក្រុង និងប្រទេសជាសមាជិកចូលរួមចំនួន ៥៨ ប្រទេសក្នុងពិភពលោក ព្រមទាំងដៃគូរម្ចាស់ជំនួយនានា ។ គោលបំណងនៃកិច្ចប្រជុំស្ដីពី 3R និងសេដ្ឋកិច្ចវិលជុំឆ្ពោះទៅរកនិរន្តភាពប្រព័ន្ធអេកូឡូស៊ីទន្លេសាបរួមមាន៖

១. ពិភាក្សាបញ្ហាគ្រប់គ្រងកាកសំណល់សំរាមប្លាស្ទិក និងប្រព័ន្ធអេកូឡូស៊ីទន្លេសាប និងតំបន់នានា ។

២. ការផ្ដល់ទស្សនៈទាន និងបទពិសោធន៍លើ 3R និងសេដ្ឋកិច្ចវិលជុំឆ្ពោះទៅរកនិរន្តភាពប្រព័ន្ធអេកូឡូស៊ីពីដៃគូ និងប្រទេសមួយចំនួន ប្រមាណ ៥៨ ប្រទេស រួមទាំងប្រទេសមួយចំនួនផ្សេងៗទៀត ។

៣. ពិភាក្សាលើការអភិវឌ្ឍន៍បរិស្ថានបៃតងរយៈពេលវែង និងចូលរួមប្ដេជ្ញាបញ្ចប់ការបំពុលបរិស្ថានប្លាស្ទិកតាមដងទន្លេដល់កម្រិតសូន្យពីឆ្នាំ ២០២២ ដល់ ២០៥០ ។

៤. ការពង្រឹងបន្ថែមបទដ្ឋានគតិយុត្តិស្ដីពីការគ្រងគ្រងសំរាមនៅតាមប្រទេសនីមួយៗ និងការពង្រឹងពង្រីកធនធានមនុស្សមូលនិធិ និងបរិស្ថាន ។



## ទស្សនៈកិច្ចនៅតំបន់ព្រែកទាល់ នៃគម្រោងគ្រប់គ្រងនិងអភិរក្សតំបន់ដីសើមអាងទន្លេមេគង្គក្រោមក្នុងប្រទេសកម្ពុជា នៅខេត្តសៀមរាប



នាថ្ងៃអង្គារ ១៥ រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០២៣ លោក វិន ប៊ុនពៅ ប្រធាននាយកដ្ឋានធនធានធម្មជាតិ នៃអាជ្ញាធរទន្លេសាប ត្រូវបានចាត់អោយទៅចូលរួមកម្មវិធីទស្សនៈកិច្ចនៅតំបន់ព្រែកទាល់ នៃគម្រោងគ្រប់គ្រង និងអភិរក្សតំបន់ដីសើមអាងទន្លេមេគង្គក្រោមក្នុងប្រទេសកម្ពុជា រៀបចំដោយក្រសួងបរិស្ថាន និងសម្របសម្រួលពីគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។

គោលបំណងសំខាន់នៃទស្សនៈកិច្ច ដើម្បី៖

១. ដំណើរទស្សនៈកិច្ចមជ្ឈមណ្ឌលគ្រប់គ្រង និងអភិរក្សតំបន់ដីសើមរ៉ាមសារព្រែកទាល់

២. ដំណើរទស្សនៈកិច្ចសំបុកសត្វស្លាបទឹកសាបក្នុងតំបន់អភិរក្សរ៉ាមសារសត្វស្លាបព្រែកទាល់

៣. ការចុះពិនិត្យ និងវាយតម្លៃសមិទ្ធផលបញ្ចប់គម្រោង (ការជួសជុលអាគារ បង្គោលព្រំអភិរក្សតំបន់រ៉ាមសារ ម៉ាស៊ីនបូបទឹកសម្រាប់ការងារអន្តរាគមន៍ពន្លត់អគ្គិភ័យចល័ត ការបំពាក់បរិក្ខារមួយចំនួន និងផែស្នាលបណ្ដុះកូនឈើព្រៃលិចទឹក) ។

សូមជម្រាបជូនថា ៖ ដំណើរទស្សនៈកិច្ចនេះ បានប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម តែ ណាវុធ អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (គជទមក) និងមន្ត្រីតំណាងក្រសួងបរិស្ថាន ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលជលផល), អាជ្ញាធរទន្លេសាប អង្គការក្រៅរដ្ឋាភិបាល និងដៃគូ និងមន្ត្រីពីគ.ជ.ទ.ម.ក និងជំនាញការជាតិ អ្នកចូលរួមចំនួន ១៨រូប។

លទ្ធផលទទួលបានពីដំណើរទស្សនៈកិច្ច បានផ្ដល់ការយល់ដឹងពី៖

១. សាវតានៃការគ្រប់គ្រង និងអភិរក្សតំបន់ដីសើមព្រែកទាល់ (រ៉ាមសារ)។

២. ការតាមដាន កត់ត្រា និង ចំណាត់ថ្នាក់ប្រភេទសត្វស្លាបជាប្រចាំថ្ងៃពីមន្ត្រីអនុរក្សប្រចាំការ។

៣. ការងារគ្រប់គ្រងធនធានធម្មជាតិ ជលផល និងការបង្ក្រាបបទល្មើសក្នុងតំបន់ដែនអភិរក្សរ៉ាមសារព្រែកទាល់។

៤. វិធីសាស្រ្ត ឬនិតិវិធីវិភាគទិន្នន័យសត្វស្លាបដោយប្រើប្រាស់វិធីសាស្រ្តស្ថិតិកត់ត្រាប្រចាំថ្ងៃ ខែ និងឆ្នាំលើការងារបន្លាស់ទីចំណី ការបន្តពូជ និងប្រភេទសត្វ ។

## សិក្ខាសាលាបណ្ដុះបណ្ដាល ស្ដីពីការវិភាគផ្នែកសេដ្ឋកិច្ច និងដំណោះស្រាយតាមធម្មជាតិ និងកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិ នៃគម្រោងគ្រប់គ្រងទឹកជំនន់ និងភាពរាំងស្ងួត

រាជធានីភ្នំពេញ៖ នីថ្ងៃទី ២៥-២៦ ខែឧសភា ឆ្នាំ ២០២៣ លោក វិន ប៊ុនពៅ ប្រធាននាយកដ្ឋានធនធានធម្មជាតិ នៃអាជ្ញាធរទន្លេសាប បានចូលរួមសិក្ខាសាលាបណ្ដុះបណ្ដាល ស្ដីពីការវិភាគផ្នែកសេដ្ឋកិច្ច និងដំណោះស្រាយតាមធម្មជាតិ និងកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិ នៃគម្រោងគ្រប់គ្រងទឹកជំនន់ និងភាពរាំងស្ងួត នៅតំបន់ព្រំដែនកម្ពុជា-ថៃ ដែលរៀបចំឡើងដោយគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដឹកនាំសម្របសម្រួលដោយឯកឧត្តម ពេជ ឌុន ទីប្រឹក្សា គ.ជ.ទ.ម.ក និងអញ្ជើញចូលរួមពីមន្ត្រីតំណាងក្រសួង ស្ថាប័ន មន្ទីរធនធានទឹក និងឧតុនិយមខេត្ត, ICEM, GIZ, លេខាធិការដ្ឋាន MRC ជំនាញការជាតិ អន្តរជាតិ សរុបចំនួន ២៦រូប។

គោលបំណងនៃសិក្ខាសាលាបណ្ដុះបណ្ដាលគឺ ៖

១-បង្ហាញពីការវិភាគផ្នែកសេដ្ឋកិច្ច និងដំណោះស្រាយតាមធម្មជាតិ នៅតំបន់ ៩C នៃស្ទឹងមង្គលបុរី

២-បង្ហាញពីសារៈសំខាន់នៃដំណោះស្រាយតាមធម្មជាតិសម្រាប់



ធ្វើសេចក្ដីសម្រេចចិត្ត និងការធ្វើផែនការ។

គោលបំណងនៃកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិគឺ ៖

១-ផ្សព្វផ្សាយនិងបកប្រែផែនទី ៩C-៩T

២-ពិនិត្យនិងធ្វើបច្ចុប្បន្នភាពនៃមូលនិធិ GEF-8 និង GCF

៣-ពិភាក្សាជំហានបន្ទាប់ សម្រាប់ឆ្នាំ២០២៣។

សកម្មភាពកិច្ចប្រជុំ និងសិក្ខាសាលា

## កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិលើកទី ១ ស្ដីពីសំណើគម្រោងការបន្ថែមសមត្ថភាពផលិត ថាមពលពីទួប៊ីនចំនួន០៤ ទៅទួប៊ីនចំនួន ០៥ នៃគម្រោងវារីអគ្គិសនី ដនសាហុង ( DSHPP Extension )



នាថ្ងៃចន្ទ ២ កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០២៣ លោក វិន ប៊ុនពៅ ប្រធាននាយកដ្ឋានធនធានធម្មជាតិ នៃអាជ្ញាធរទន្លេសាប ត្រូវបានចាត់អោយទៅចូលរួមប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ លើកទី ១ ស្ដីពីសំណើគម្រោងការបន្ថែមសមត្ថភាពផលិត ថាមពលពីទួប៊ីនចំនួន ០៤ ទៅទួប៊ីនចំនួន ០៥ នៃគម្រោង វារីអគ្គិសនី ដនសាហុង (DSHPP Extension) របស់ឡាវ ដែលបានដឹកនាំ និងសម្របសម្រួលដោយ ឯកឧត្ដម តែណា វុធ អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (គជទមក) ដែលមានសមាសភាពចូលរួមពីមន្ត្រីតំណាងពី ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសាធារណៈការ និង ដឹកជញ្ជូន, ក្រសួងបរិស្ថាន, ក្រសួងរ៉ែ និងថាមពល, អាជ្ញាធរ ទន្លេសាប, អគ្គិសនីកម្ពុជា, មន្ទីរធនធានទឹក និងឧតុនិយមខេត្ត និងសហគមន៍នេសាទ នៃខេត្តស្ទឹងត្រែង, ក្រចេះ, កំពង់ចាម, កំពង់ធំ, កំពង់ឆ្នាំង មន្ត្រី និងទីប្រឹក្សា គ.ជ.ទ.ម.ក វិទ្យាស្ថាន និងគ្រឹះស្ថានអប់រំ អង្គការក្រៅរដ្ឋាភិបាល និងជំនាញការជាតិ និងតំបន់ (MRS) សរុបអ្នកចូលរួមប្រមាណចំនួន ២៨ រូប ។

គោលបំណងសំខាន់នៃកិច្ចប្រជុំពិគ្រោះយោបល់ គឺដើម្បី៖

១. ខ្លឹមសារសង្ខេបកិច្ចព្រមព្រៀងមេគង្គឆ្នាំ ១៩៩៥ នីតិវិធី ស្ដីពីការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (PNPCA) ដំណើរការពិគ្រោះយោបល់ជាមុន សម្រាប់សំណើគម្រោងវារីអគ្គិសនី ដនសាហុង (DSHPP) និងស្ថានភាពបច្ចុប្បន្ន នៃសំណើគម្រោងការបន្ថែមសមត្ថភាពផលិតថាមពលពី ទួប៊ីនចំនួន ០៤ ទៅទួប៊ីនចំនួន ០៥ នៃ DSHPP ។

២. យល់ដឹងពីឯកសារសំណើគម្រោងការបន្ថែមសមត្ថភាពផលិតថាមពលពីទួប៊ីនចំនួន ០៤ ទៅទួប៊ីន ចំនួន ០៥ នៃគម្រោងវារីអគ្គិសនី ដនសាហុង (DSHPP) ដែលបានដាក់ជូនពិនិត្យជាផ្លូវការដោយភាគីឡាវ ។

៣. ជូនជ្រាបរបាយការណ៍សិក្សា ស្ដីពីការពិនិត្យបច្ចេកទេសឡើងវិញ លើសំណើគម្រោងការបន្ថែមសមត្ថភាពផលិតថាមពលពីទួប៊ីនចំនួន ០៤ ទៅទួប៊ីនចំនួន ០៥ នៃ DSHPP ដែលបានរៀបចំដោយលេខាធិការដ្ឋាន MRC ផ្អែកលើឯកសារដែលបានដាក់ជូនពិនិត្យជាផ្លូវការដោយភាគីឡាវ ។

៤. ការផ្ដល់យោបល់ និងទស្សនៈនានា ស្ដីពីសំណើគម្រោងការបន្ថែមសមត្ថភាពផលិតថាមពលពីទួប៊ីនចំនួន ០៤ ទៅទួប៊ីនចំនួន ០៥ នៃ DSHPP និងរបាយការណ៍សិក្សាពិនិត្យបច្ចេកទេសឡើងវិញនៃ DSHPP ដែលបានធ្វើបច្ចុប្បន្នភាព។

៥. ការបែងចែកក្រុមពិភាក្សាចំនួន ០៣ ដើម្បីពិភាក្សាលើ Updated TRR ទាក់ទងនឹង៖ ជលសាស្ត្រ, សុវត្ថិភាពទំនប់, នាវាចរណ៍, ជលផល, កំណកកករល្បាប់, គុណភាពទឹក, អេកូឡូស៊ី, បរិស្ថាន និងសង្គម-សេដ្ឋកិច្ច ។

ជាមួយនឹងអង្គប្រជុំពិគ្រោះយោបល់ខាងលើ ទទួលបានលទ្ធផលដូចខាងក្រោម ៖

- ស្នើសុំពិនិត្យ និងសិក្សាបន្ថែមលើផលប៉ះពាល់បរិស្ថានធម្មជាតិ និងសង្គម-សេដ្ឋកិច្ច។
- សិក្សាបន្ថែមលើផ្លូវនាវាចរណ៍, លំហូរទឹក, ជលផល (ចរាចរណ៍ត្រី), កំណកកករ និងគុណភាពទឹក។
- សិក្សាបន្ថែម និងបន្តសិក្សាលំអិតលើស្ថានភាពធនធានធម្មជាតិផ្នែកខាងក្រោម (ព្រៃលិចទឹក, តំបន់រ៉ាមសារ និងជីវចម្រុះ...)។
- ពិនិត្យ និងវាយតម្លៃលើការងារគ្រប់គ្រងទ្វារទឹក (បិទ-បើក) តើពិតក្នុងកម្រិតណា បើគម្រោងខាងលើគឺដំណើរការតែនៅរដូវវស្សា (មិនដំណើរការនៅរដូវប្រាំង)។
- កម្ពុជាត្រូវការឡាវផ្ដល់ទិន្នន័យ-ព័ត៌មានជាប្រចាំពាក់ព័ន្ធដំណើរការស្ថានីយវារីអគ្គិសនី ។
- ស្នើសុំពិនិត្យ និងពិភាក្សាលើផែនការឆ្លងដែន និងផលប៉ះពាល់ផ្សេងៗ ។
- ស្នើគម្រោងសិក្សាបន្ថែម និងយោងលើឯកសារសិក្សាពីភាគីនិងជំនាញការផ្សេងៗ ដើម្បីវាយតម្លៃលើផលប៉ះពាល់ទំនប់ដនសាហុង និងក្រៅពីគម្រោងក្នុងការវាយតម្លៃលម្អិត របស់គម្រោង និងផ្នែកខាងក្រោម ព្រមទាំងទន្លេសាប ។



## ពិធីប្រកាសផ្សព្វផ្សាយស្ដីពីរបាយការណ៍លទ្ធផលអង្កេតកសិកម្មកម្ពុជាឆ្នាំ ២០២១



នាថ្ងៃពុធ ៨កើត ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០២៣ លោក វិន ប៊ុនពៅ ប្រធាននាយកដ្ឋានធនធានធម្មជាតិ នៃអាជ្ញាធរទន្លេសាប ត្រូវបានចាត់អោយទៅ ចូលរួមពិធីប្រកាសផ្សព្វផ្សាយ ស្ដីពីរបាយការណ៍លទ្ធផលអង្កេតកសិកម្មកម្ពុជាឆ្នាំ ២០២១ នៅសណ្ឋាគារភ្នំពេញ។ គោលបំណងសំខាន់ នៃការផ្សព្វផ្សាយរួមមាន៖

១. សាវតានៃគម្រោងអង្កេតកសិកម្មកម្ពុជា ២០២១

២. ការប្រមូលចងក្រងព័ត៌មាន ទិន្នន័យ និងវិធីសាស្រ្តវាយតម្លៃ

៣. ការរៀបចំរបាយការណ៍ស្ថិតិអង្កេតកសិកម្មកម្ពុជា

៤. ការរៀបចំផែនទីស្ថិតិអង្កេតកសិកម្មកម្ពុជាឆ្នាំ ២០២១ ។

លទ្ធផលនៃពិធីប្រកាសផ្សព្វផ្សាយ ស្ដីពីរបាយការណ៍លទ្ធផលអង្កេតកសិកម្មបានផ្ដោតលើ៖

១. វិធីសាស្រ្ត និងទិដ្ឋភាពទូទៅពីសារៈសំខាន់នៃស្ថិតិអង្កេតកសិកម្មកម្ពុជាឆ្នាំ ២០២១ (ផលិតកម្មដំណាំ, ការចិញ្ចឹមបសុសត្វ និងបក្សី, វារីវប្បកម្ម និងនេសាទ, កម្លាំងពលកម្ម និងសេដ្ឋកិច្ច)។

២. ការផ្សព្វផ្សាយព័ត៌មាន និងបច្ចេកវិទ្យាកសិកម្ម ដើម្បីគាំទ្រដល់សន្តិសុខស្បៀង អាហារូបត្ថម្ភ និងលើកកម្ពស់វិស័យកសិកម្មប្រកបដោយចីរភាព ។

៣. សម្រេចអោយបានសមភាពយេនឌ័រ និងកុមារ។

៤. របាយការណ៍អង្កេតកសិកម្មឆ្លុះបញ្ចាំងពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០ ។

៥. ការដាក់អោយប្រើប្រាស់ជាផ្លូវការពីលទ្ធផលរបាយការណ៍អង្កេតកសិកម្ម ដើម្បីជួយការកាត់បន្ថយ និងបញ្ចប់ភាពក្រីក្រនៅកម្ពុជា និងសកល ។

សូមជម្រាបជូនថា ៖ ពិធីប្រកាសផ្សព្វផ្សាយស្ដីពីរបាយការណ៍លទ្ធផលអង្កេតកសិកម្មកម្ពុជាឆ្នាំ ២០២១ បានប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម ប៊ិន ត្រាឈៃ រដ្ឋមន្រ្តីក្រសួងផែនការ និងលោកស្រី Rebekah Bell តំណាងអង្គការស្បៀង និងកសិកម្មនៃអង្គការសហប្រជាជាតិប្រចាំកម្ពុជា ព្រមទាំងអញ្ជើញចូលរួមមកពីតំណាងក្រសួង-ស្ថាប័ន ក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, អាជ្ញាធរទន្លេសាប អង្គការក្រៅរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ វិទ្យាស្ថានស្រាវជ្រាវ និងដៃគូផ្សេងៗ និងជំនាញការជាតិ និងអន្តរជាតិ សរុបចំនួនប្រមាណ ១០០រូប ។

## សិក្ខាសាលាថ្នាក់តំបន់នៃគម្រោង ស្ដីពី " ការទូតក្នុងការគ្រប់គ្រងទឹកនៅអាងទន្លេមេគង្គ ដើម្បីអោយមានការប្រើប្រាស់អាងទន្លេជារួម និងសម្រេចបាននូវភាពរុងរឿង

សៀមរាប ៖ នៅថ្ងៃទី ៣០-៣១ ខែឧសភា ឆ្នាំ ២០២៣ លោក វិន ប៊ុនពៅ ប្រធាននាយកដ្ឋានធនធានធម្មជាតិ នៃអាជ្ញាធរទន្លេសាប បានចូលរួមសិក្ខាសាលាថ្នាក់តំបន់នៃគម្រោង ស្ដីពី " ការទូតក្នុងការគ្រប់គ្រងទឹកនៅអាងទន្លេមេគង្គ ដើម្បីអោយមានការប្រើប្រាស់អាងទន្លេជារួម និងសម្រេចបាននូវភាពរុងរឿង " ដែលរៀបចំដោយវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) នាទីរួមខេត្តសៀមរាប និងមានការអញ្ជើញចូលរួមពីមន្រ្តីតំណាងក្រសួង ស្ថាប័នវិទ្យាស្ថានស្រាវជ្រាវ អង្គការដៃគូ និងក្រុមការងារគម្រោងសរុបចំនួន ៣០ នាក់។ សិក្ខាសាលានេះ មានគោលបំណង ៖

១.ផ្សព្វផ្សាយលទ្ធផលសិក្សាស្រាវជ្រាវពីការទូតទឹក (ប្រទេសចិន កម្ពុជា ថៃ ឡាវ និងវៀតណាម) ។

២.ពិភាក្សា និងស្វែងរកវិធីសាស្រ្តរួមមួយ ដើម្បីដោះស្រាយបញ្ហាប្រឈមជុំវិញការគ្រប់គ្រងធនធានទឹកទន្លេមេគង្គ និង



៣.ការប្រើប្រាស់ក្របខណ្ឌការទូតទឹក ដើម្បីអោយមានការប្រើប្រាស់អាងទន្លេជារួម និងសម្រេចបាននូវភាពរុងរឿង (និរន្តភាពទឹក) ។

# សិក្ខាសាលាពិគ្រោះយោបល់លើរបាយការណ៍បឋម នៃការសិក្សាស្រាវជ្រាវ ស្តីពីផលប៉ះពាល់ នៃកម្ពស់ទឹកទាប របស់បឹងទន្លេសាបលើជីវចម្រុះ និងជីវភាព របស់សហគមន៍លើបឹងទន្លេសាប



រាជធានីភ្នំពេញ ៖ នាថ្ងៃចន្ទ ៩ កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី ២៣ ខែតុលា ឆ្នាំ២០២៣ លោក វិន ប៊ុនពៅ ប្រធាននាយកដ្ឋានធនធានធម្មជាតិ នៃអាជ្ញាធរទន្លេសាប ត្រូវបានចាត់អោយទៅចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើរបាយការណ៍បឋម នៃការសិក្សាស្រាវជ្រាវ ស្តីពីផលប៉ះពាល់ នៃកម្ពស់ទឹកទាប របស់បឹងទន្លេសាបលើជីវចម្រុះ និងជីវភាពរបស់សហគមន៍លើបឹងទន្លេសាប ដែលបានដឹកនាំ និងសម្របសម្រួលដោយ លោក ចាន់ វិចិត្រ ប្រធានវេទិកា នៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា និងលោកបណ្ឌិត ដោក ដុម៉ា ជំនាញការគម្រោង និងមានសមាសភាពចូលរួមពីមន្ត្រីតំណាងពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, អាជ្ញាធរទន្លេសាប, មេឃុំ, ប្រធានភូមិ អនុភូមិ, ប្រធានសហគមន៍នេសាទ (៣ឃុំ/៣ខេត្ត) វិទ្យាស្ថាន និងគ្រឹះស្ថានសិក្សាស្រាវជ្រាវ ព្រមទាំងអង្គការផ្សេងៗ (សិក្សាក្នុងតំបន់ទន្លេសាប ដូចជា OFARM, FAC..) សរុបអ្នកចូលរួមចំនួន ៣០ រូប ។

គោលបំណងសំខាន់នៃកិច្ចប្រជុំពិគ្រោះយោបល់ គឺដើម្បី៖

១. ដើម្បីពិនិត្យលើខ្លឹមសារសង្ខេបសិក្សាស្រាវជ្រាវ ពីផលប៉ះពាល់ នៃលំហូរទឹកទាបនៅបឹងទន្លេសាប និងជីវភាពរស់នៅរបស់សហគមន៍ក្នុងតំបន់កំពង់ឃ្លាំង ខេត្តសៀមរាប, តំបន់រហាលសួង ខេត្តបាត់ដំបង និងតំបន់កំពង់លួង ខេត្តពោធិ៍សាត់ ។

២. ដើម្បីពិនិត្យការប្រែក្លាយសង្គម សេដ្ឋកិច្ច និងយុទ្ធសាស្ត្រដោះស្រាយរបស់សហគមន៍នីមួយៗ (៣តំបន់) ។

៣. ពិនិត្យលើការសិក្សាពីបម្រែបម្រួលប្រព័ន្ធអេកូឡូស៊ីសំខាន់ៗ របស់បឹងនៃលក្ខខណ្ឌលំហូរទឹកទាប(២០១៩-២០២៣)។

៤. ពិនិត្យលើកម្រិតនៃផលប៉ះពាល់ដល់សហគមន៍ខាងលើ

៥. ស្វែងយល់បន្ថែមពីការប្រែប្រួលប្រព័ន្ធបរិស្ថាន និងជីវភាពប្រជាជននៅតំបន់សិក្សា ។

ទន្ទឹមនឹងនោះ អង្គសិក្ខាសាលាពិគ្រោះយោបល់ខាងលើ ទទួលបានលទ្ធផលដូចខាងក្រោម ៖

- ស្នើសុំពិនិត្យ និងសិក្សាបន្ថែមលើផលប៉ះពាល់ ប្រភពទិន្នន័យសម្រាប់រៀបចំរបាយការណ៍បឋមក្នុងការសិក្សា (ត្រូវយកទិន្នន័យផ្លូវការ និងមានការចូលរួមពិនិត្យ និងវាយតម្លៃបន្ថែមលើលទ្ធផលសិក្សា មុនរៀបចំជាផែនការ និងយុទ្ធសាស្ត្រផ្សព្វផ្សាយបន្ត ឬដាក់ជូនរាជរដ្ឋាភិបាល) ។
- ស្នើសុំ NGO-FORUM សិក្សាបន្ថែមលើផលប៉ះពាល់បរិស្ថានធនធានទឹក ជីវចម្រុះ និងសេដ្ឋកិច្ចសង្គម ។ល។
- ស្នើសុំពិនិត្យ និងកែសម្រួលទិន្នន័យបន្ថែមក្នុងរបាយការណ៍បឋម ដើម្បីរកធាតុចូលត្រឹមត្រូវពីក្រសួង ស្ថាប័នជំនាញ និងពាក់ព័ន្ធ (ថ្នាក់ជាតិ និងក្រោមជាតិ) ។
- ជាពិសេស អាជ្ញាធរទន្លេសាប ស្នើដល់ក្រុមការងាររៀបចំរបាយការណ៍ត្រូវសិក្សាបន្ថែមលើទិន្នន័យ និងអ្នកចូលរួម (ក្រសួង ស្ថាប័នជំនាញ) ដើម្បីវាយតម្លៃលើលទ្ធផលសិក្សានេះ ព្រោះការចងក្រងលទ្ធផលនេះមានរយៈពេលខ្លីណាស់ គឺប្រមាណជា ១ ទៅ ២ ខែ ។
- តំណាងក្រុមការងារគម្រោង NGO-FORUM ក៏បានទទួលយកនូវសំណូមពរ និងសំណើទាំងអស់ក្នុងពេលនេះ ដើម្បីធ្វើការពិនិត្យ និងរៀបចំកែសម្រួលបន្ថែមនូវអ្វីដែលអង្គសិក្ខាកាមបានលើកឡើង ។





## សិក្ខាសាលាស្តីពី កិច្ចប្រជុំប្រចាំឆ្នាំ និងវាគ្មិនពិភាក្សាជាមួយអ្នកពាក់ព័ន្ធតំណាងតាមប្រទេសក្នុងគម្រោង ស្តីពី ការឆ្លុះបញ្ចាំង និងផែនការសម្រាប់ឆ្នាំ ២០២៣




ថ្ងៃពុធ ៨រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី ១៤ ខែមីនា ឆ្នាំ ២០២៣ កញ្ញា ប្រាក់ ចាន់វឌ្ឍនា ប្រធានការិយាល័យកសិកម្មចម្រុះ នៃអាជ្ញាធរទន្លេសាប បានចូលរួមសិក្ខាសាលាស្តីពី កិច្ចប្រជុំប្រចាំឆ្នាំ និងវាគ្មិនពិភាក្សាជាមួយអ្នកពាក់ព័ន្ធតំណាងតាមប្រទេសក្នុងគម្រោងស្តីពី ការឆ្លុះបញ្ចាំង និងផែនការសម្រាប់ឆ្នាំ ២០២៣ ដែលមានរយៈពេល០២ថ្ងៃ នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ រៀបចំដោយវិទ្យាស្ថានស្រាវជ្រាវស្រូវអន្តរជាតិ (International Rice Research Institute សហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

សិក្ខាសាលានេះ ជាយន្តការតម្រង់ទិសនៃគំនិតផ្តួចផ្តើមតំបន់អាស៊ានដ៏មហិមានៃដីសណ្តរឌែលតា(Asian Mega-Delta) សម្រាប់ពង្រឹងផែនការយុទ្ធសាស្ត្រ សហប្រតិបត្តិការ និងការផ្តល់ឱកាសដល់អ្នកវិទ្យាសាស្ត្រ ដៃគូអភិវឌ្ឍន៍ក្នុងតំបន់ដឹងធាតុចូល និងវិភាគពីដំណើរការនៃការអភិវឌ្ឍកម្មវិធីជាមួយនឹងសមិទ្ធផលពីប្រទេសដែលបានជ្រើសរើសក្នុងការអនុវត្តដែលធានាដល់និរន្តរភាព និងលទ្ធផលពីបណ្តាលប្រទេសសាមី។



## សិក្ខាសាលាថ្នាក់ជាតិលើកទី២ ស្តីពីការចាត់អាទិភាពបាំងត្រី និងការតាមដានផ្លូវត្រី នៅខេត្តកំពង់ធំ

ថ្ងៃសុក្រ ១២រោច ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣ លោក ប៊ុន វុឌ្ឍី អនុប្រធាននាយកដ្ឋានធនធានធម្មជាតិ នៃអាជ្ញាធរទន្លេសាប ត្រូវបានចាត់អោយទៅចូលរួមសិក្ខាសាលាថ្នាក់ជាតិលើកទី២ ស្តីពីការចាត់អាទិភាពរបាំងត្រី និងការតាមដានផ្លូវត្រី ដែលរៀបចំដោយគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។

គោលបំណងសំខាន់នៃកិច្ចប្រជុំគឺដើម្បី៖

១. ពិភាក្សាសេចក្តីព្រាងឯកសាររបាយការណ៍ស្តីពីការចាត់អាទិភាពរបាំងត្រី និងការតាមដានផ្លូវត្រី។

២. ស្វែងរកមតិយោបល់ ដើម្បីកែសម្រួលសេចក្តីព្រាងឯកសាររបាយការណ៍ចុងក្រោយ ស្តីពីការចាត់អាទិភាពរបាំងត្រីសម្រាប់ការវិនិយោគក្នុងការសាងសង់សំណង់ជណ្តើរត្រីនៅក្នុងឆ្នាំ២០២៤ និងសកម្មភាពត្រួតពិនិត្យផ្លូវត្រី ។

សូមជម្រាបជូនថា ៖ សិក្ខាសាលាថ្នាក់ជាតិនេះ បានប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម តែ ណាវុធ អនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (គជទមក) ដោយមានការ



អញ្ជើញចូលរួមមកពីតំណាងក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលជលផល), ក្រសួងបរិស្ថាន, ក្រសួងរ៉ែ និងថាមពល, ក្រសួងអភិវឌ្ឍន៍ជនបទ, អាជ្ញាធរទន្លេសាប និងមន្ត្រីពី គ.ជ.ទ.ម.ក និងជំនាញការជាតិ សរុបអ្នកចូលរួមចំនួន ២០ រូប។

# សិក្ខាសាលាពិគ្រោះយោបល់ស្ដីពី ការត្រួតពិនិត្យតាមដានសូចនាករកម្រិតនៃការអនុវត្តការគ្រប់គ្រងធនធានទឹកចម្រុះ លើកទី៣ នៅរាជធានីភ្នំពេញ



នាថ្ងៃសុក្រ ០៦កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី២០ ខែតុលា ឆ្នាំ២០២៣ លោក ខ្វាន់ ភត្រ្តា អនុប្រធាននាយកដ្ឋានធនធានធម្មជាតិ បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្ដីពី ការត្រួតពិនិត្យតាមដានសូចនាករកម្រិតនៃការអនុវត្តការគ្រប់គ្រងធនធានទឹកចម្រុះ លើកទី៣ ក្រោមអធិបតីភាព ឯកឧត្តម ឈា ប៊ុនរិទ្ធ រដ្ឋលេខាធិការប្រចាំការ ក្រសួងធនធានទឹក និងឧតុនិយម នៅសណ្ឋារគារហ៊ីម៉ារ៉ាវី រាជធានីភ្នំពេញ ។ សិក្ខាសាលាពិគ្រោះយោបល់ មានការអញ្ជើញចូលរួមពីតំណាងក្រសួងស្ថាប័នជំនាញពាក់ព័ន្ធ រួមទាំងមន្ទីរធនធានទឹក និងឧតុនិយម ខេត្តព្រៃវែង, ខេត្តកណ្ដាល, ខេត្តកំពង់ធំ, ខេត្តបាត់ដំបង, ខេត្តក្រចេះ, ខេត្តរតនគិរី និងតំណាងក្រសួង ស្ថាប័នជាតិ វិទ្យាស្ថានស្រាវជ្រាវ សាកលវិទ្យាល័យ សហគមន៍ អង្គការមិនមែនរាជរដ្ឋាភិបាល និងទីប្រឹក្សាជាតិ។

សិក្ខាសាលាពិគ្រោះយោបល់នេះ មានគោលបំណង ដើម្បីប្រមូលធាតុចូល និងវាយតម្លៃរួមគ្នា និងស្វែងយល់ពីការអនុវត្តគម្រោងសកម្មភាពនានាក្នុងវិស័យធនធានទឹក ក្នុងការឆ្លុះបញ្ចាំងពីចំណុចខ្វះខាត បញ្ហាប្រឈមនានា និងកំណត់នូវសកម្មភាពមធ្យោបាយ ដែលជាធាតុចូលដ៏មានប្រសិទ្ធភាព លើការគ្រប់គ្រងធនធានចម្រុះនៅកម្ពុជាឱ្យកាន់តែមានសុក្រឹតភាព និងល្អគ្រប់ជ្រុងជ្រោយបន្ថែមទៀត។

អង្គសិក្ខាសាលាបានពិភាក្សា និងត្រួតពិនិត្យសូចនាករ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (Sustainable Development Goals-SDG 6.5.1) ដែលមានសមាសភាព៤ រួមមាន៖

១. បរិយាកាសអំណោយផល (នយោបាយ ច្បាប់ ផែនការនានា)
២. ស្ថាប័ន និងការចូលរួម (ប្រភេទ និងតួនាទីនៃស្ថាប័ននយោបាយ សង្គម សេដ្ឋកិច្ច និងរដ្ឋបាល និងក្រុមអ្នកពាក់ផ្សេងៗ )
៣. ឧបករណ៍គ្រប់គ្រង (ឧបករណ៍ និងសកម្មភាពដែលជួយដល់អ្នកធ្វើការសម្រេចចិត្ត)
៤. ហិរញ្ញប្បទាន (ការរៀបចំថវិកា និងហិរញ្ញវត្ថុសម្រាប់ការអភិវឌ្ឍ និងការគ្រប់គ្រងធនធានទឹក)។

អង្គសិក្ខាសាលាបានពិគ្រោះយោបល់ និងការផ្ដល់ពិន្ទុតាមសមាសភាព ៤ ខាងលើ ផ្អែកតាមស្ថាប័នពាក់ព័ន្ធនានា បានផ្ដល់តម្លៃពិន្ទុជាមធ្យម នៃសមាភាពទាំង៤ សម្រាប់ឆ្នាំ២០២៣ ស្មើនឹង ៦៦ពិន្ទុ ឃើញថាកើន ៧ពិន្ទុ បើប្រៀបធៀបនឹងឆ្នាំ២០២០ មានត្រឹមតែ៥៩ ពិន្ទុ ក្នុងនោះផ្ដោតលើ៖

១. បរិយាកាសអំណោយផល មានពិន្ទុ ៧៤
២. ស្ថាប័ន និងការចូលរួម មានពិន្ទុ ៧៥
៣. ឧបករណ៍គ្រប់គ្រង មានពិន្ទុ ៦៣
៤. ហិរញ្ញប្បទាន មានពិន្ទុ ៥២ ។

សូមជម្រាបជូនថា៖ ការតាមដាន និងត្រួតពិនិត្យសកល នៃសូចនាករ SDG 6.5.1 ស្ដីពី "កម្រិតនៃការអនុវត្តការគ្រប់គ្រងធនធានទឹកចម្រុះ" ដែលស្ថិតក្រោមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៦ (SDG 6) ស្ដីពី "ធានាឱ្យមានទឹក និងអនាម័យ និងការគ្រប់គ្រងទឹក និងអនាម័យប្រកបដោយចីរភាពសម្រាប់ប្រជាជនគ្រប់រូប" ស្របតាមទម្រង់ ( Format) និងលក្ខណៈវិនិច្ឆ័យ (Criteria) ធ្វើឡើងជាទៀងទាត់រៀងរាល់ ៣ឆ្នាំម្ដង៕





## កិច្ចប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិ ពីទិន្នន័យសេដ្ឋកិច្ច-សង្គម យេនឌ័រនិងភាពងាយរងគ្រោះ ខេត្តកំពង់ធំ



នៅថ្ងៃចន្ទ ១១កើត ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣ លោក អ៊ុក បញ្ញារិទ្ធ អនុប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និងសហប្រតិបត្តិការ បានចូលរួមប្រជុំពិគ្រោះយោបល់ថ្នាក់ជាតិស្ដីពីទិន្នន័យសេដ្ឋកិច្ច-សង្គម យេនឌ័រ និងភាពងាយរងគ្រោះ ក្រោមអធិបតីភាព ឯកឧត្តម តែ ណាវុធ អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា នៅសណ្ឋាគារកំពង់ធំផាលេស ទីរួមខេត្តកំពង់ធំ ។ កិច្ចប្រជុំនេះមានការចូលរួមពីមន្ត្រីពាក់ព័ន្ធចំនួន ១៥រូប (ស្រី ០១រូប) ។

កិច្ចប្រជុំខាងលើនេះមានគោលបំណងសំខាន់ចំនួន ៣ គឺ៖

១. ពិភាក្សាបញ្ជាក់ និងណែនាំអំពីទិន្នន័យ Socio-Economic (SE) និង Gender and Vulnerability (G&V) ដែលអាចមាន។ ឱ្យនិយមន័យអំពីទិន្នន័យ និងចន្លោះខ្វះខាតអំពីទិន្នន័យដែលត្រូវបានប្រមូលដោយ MCs ជាមួយនឹងដំណើរការនៃការរៀបចំ និងធ្វើ Quality Assurance (QA)/ Quality Check (QC) ដើម្បីធ្វើ Dataset និងរបាយការណ៍ចុងក្រោយដែលបានទិន្នន័យពី Socio-Economic (SE) និង Gender and Vulnerability (G&V) ។

២. ស្វែងរកមតិយោបល់ និងការឯកភាពគ្នាលើការធ្វើ Validation និងការឯកភាពលើទិន្នន័យ Socio-Economic (SE) និង Gender and Vulnerability (G&V) ដែលបានបញ្ជូន និងប្រើប្រាស់។ វិធីសាស្ត្រ/ដំណោះស្រាយនៃការប្រមូលផ្តុំទិន្នន័យ/ការវិភាគ លទ្ធផល និងសារសំខាន់ៗនៃវិមតិសង្គម និងសេដ្ឋកិច្ច នៃសេចក្ដីព្រាងទី 1 និងទី 2 នៃសេចក្ដីព្រាង SOBR ឆ្នាំ 2023 និងសេចក្ដីព្រាង Mekong Atlas ដែលបានធ្វើបច្ចុប្បន្នភាព ផែនទី ។

៣. ពិភាក្សាអំពីជំហានបន្ទាប់ និងអនុសាសន៍សម្រាប់ការបំពេញចន្លោះអំពីទិន្នន័យ Socio-Economic (SE) និង Gender and Vulnerability (G&V) ដែលបានកំណត់ជាពិសេស ហើយទិន្នន័យដែលត្រូវការសម្រាប់ធ្វើការវាយតម្លៃយេនឌ័រ និងសង្គម នៅឆ្នាំ 2024 នឹងអនុសាសន៍សម្រាប់កែលម្អការស្ទង់មតិជាតិ ការប្រមូលទិន្នន័យ និងយន្តការដំណើរការសម្រាប់ការរៀបចំផែនការ និងការសម្រេចចិត្តដែលមានស្រាប់នៅក្នុងប្រទេស ។

## សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី ការដាក់បញ្ចូលតំបន់រាំមសារព្រែកទាល់ ជាឧទ្យានបេតិកភណ្ឌអាស៊ាន




បាត់ដំបង: ថ្ងៃសុក្រ ១៥រោច ខែពិសាខ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី ១៩ ខែឧសភា ឆ្នាំ ២០២៣ លោក ខូវ វេងសុង ប្រធានការិយាល័យធនធានរ៉ែ នៃនាយកដ្ឋានធនធានធម្មជាតិ, អាជ្ញាធរទន្លេសាប បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ស្តីពី ការដាក់បញ្ចូលតំបន់រាំមសារព្រែកទាល់ ជាឧទ្យានបេតិកភណ្ឌអាស៊ាន នៅទីរួមខេត្តបាត់ដំបង ក្រោមអធិបតីភាព ឯកឧត្តម ស្រ៊ន ដារិទ្ធ រដ្ឋលេខាធិការក្រសួងបរិស្ថាន និងឯកឧត្តម ផេង សិទ្ធី អភិបាលរងខេត្តបាត់ដំបង ព្រមទាំងមន្ត្រីតំណាងមកពីក្រសួង ស្ថាប័ន មន្ទីរ អាជ្ញាធរខេត្ត សហគមន៍ និងអង្គការក្រៅរដ្ឋាភិបាលចូលរួម សរុបប្រមាណ ៤០នាក់ ។ អង្គសិក្ខាសាលានេះរៀបចំឡើងក្នុងគោលបំណង ចែករំលែកបទពិសោធន៍ ចំណេះដឹងអំពីគោលការណ៍នៃការដាក់លិខិតស្នើសុំ និងកិច្ចពិភាក្សាបន្ថែម ដើម្បីបំពេញចន្លោះខ្វះខាត និងទទួលបានផ្លែផ្កាប្រកបដោយប្រសិទ្ធភាព និងជោគជ័យ ។

## សិក្ខាសាលាស្តីពី ការដាក់លេខកូដនាមភូមិសាស្ត្រ និងការប្រើប្រាស់នៅកម្ពុជា នៅទីស្តីការក្រសួងដែនដី នគរូបនីយកម្ម និងសំណង់



នាថ្ងៃពុធ ១១កើត ខែអស្សុជ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០២៣ លោក ខូវ វេងសុង ប្រធានការិយាល័យធនធានរ៉ែ និងលោក យាន ច័ន្ទតារា អនុប្រធានការិយាល័យព័ត៌មានភូមិសាស្ត្រ និងផែនទី បានចូលរួមសិក្ខាសាលាស្តីពី ការដាក់លេខកូដនាមភូមិសាស្ត្រ និងការប្រើប្រាស់នៅកម្ពុជា នៅទីស្តីការក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ក្រោមអធិបតីភាព ឯកឧត្តម សរ សុវណ្ណ រដ្ឋលេខាធិការក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ ហើយមានការសម្របសម្រួលដោយអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ដែលមានសិក្ខាកាមចូលរួមមកពីតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ តំណាងរាជធានី-ខេត្តទាំង២៥ ក្រុមហ៊ុនឯកជន សរុបអ្នកចូលរួមចំនួន ១៨០រូប ។ សិក្ខាសាលានេះមានគោលបំណង ៖

១. ជម្រាបជូនដល់គ្រប់ក្រសួងស្ថាប័នបានយល់ពីការដាក់លេខកូដនាមភូមិសាស្ត្រត្រឹមត្រូវឲ្យមានការឯកភាពគ្នា។
២. ផ្សព្វផ្សាយពីអត្ថប្រយោជន៍ការប្រើប្រាស់លេខកូដនាមភូមិសាស្ត្រទូទាំងប្រទេស ។

ទន្ទឹមនឹងនេះក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ស្នើសុំគ្រប់ក្រសួងស្ថាប័ន បន្តផ្តល់កិច្ចសហការ និងការប្រើប្រាស់លេខកូដនាមភូមិសាស្ត្រ ដែលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានកំណត់ និងប្រើប្រាស់ដូចមាននៅក្នុងបញ្ជីរាយនាមភូមិសាស្ត្រ ក្នុងគោលដៅធានាបាននូវការឯកភាព និងស្តង់ដាសម្រាប់បម្រើអោយការប្រើប្រាស់ ក៏ដូចជាការផ្លាស់ប្តូរទិន្នន័យភូមិសាស្ត្រនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។



## កិច្ចប្រជុំនៃការបញ្ចប់គម្រោងសមាសភាគរបស់ប្រទេសឡាវ ស្តីពីការគ្រប់គ្រង និងអភិរក្សតំបន់ដីសើម ប្រទេសឡាវ



ខេត្តចាំប៉ាសាក់ ប្រទេសឡាវ , នាថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០២៣ ក្រុមការងារកម្ពុជាចំនួន ០៣រូប ដែលក្នុងនោះមាន លោក ខូវ វេងសុង ប្រធានការិយាល័យធនធានរ៉ែ នៃនាយកដ្ឋានធនធានធម្មជាតិ នៃអាជ្ញាធរទន្លេសាប (អទស) និងមន្ត្រីមកពីគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា(គជទមក) បានចូលរួមក្នុងកិច្ចប្រជុំនៃការបញ្ចប់គម្រោងសមាសភាគរបស់ប្រទេសឡាវ ស្តីពីការគ្រប់គ្រង និងអភិរក្សតំបន់ដីសើម នៅខេត្តចាំប៉ាសាក់ ប្រទេសឡាវ ដែលមានការរៀបចំ និងដឹកនាំប្រជុំដោយក្រសួងធនធានធម្មជាតិ និងបរិស្ថាន នៃប្រទេសឡាវ និងរដ្ឋបាលខេត្តចាំប៉ាសាក់ សម្រាប់កិច្ចប្រជុំបញ្ចប់គម្រោងនេះ ។ សម្រាប់សមាសភាគឡាវ ការអនុវត្តគម្រោងនេះត្រូវបានបញ្ចប់កាលពីខែធ្នូ ឆ្នាំ២០២២ មកម្លេះ ។

## សិក្ខាសាលាបណ្តុះបណ្តាលអំពីគោលការណ៍ណែនាំ ស្តីពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម



ថ្ងៃពុធ ១០កើត ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី ០១ ខែមីនា ឆ្នាំ ២០២៣ លោក ហឿង ឆេងហ៊ាង ប្រធានការិយាល័យគណនេយ្យ និងហិរញ្ញវត្ថុ និងលោក សាំង វ៉ូឡា ប្រធានការិយាល័យផែនការ និងសហប្រតិបត្តិការ នៃអាជ្ញាធរទន្លេសាប បានចូលរួមវគ្គបណ្តុះបណ្តាលអំពីគោលការណ៍ណែនាំ ស្តីពីការតាមដាន និងវាយតម្លៃថវិកាសមិទ្ធកម្ម ដែលរៀបចំឡើងដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោមអធិបតីភាព ឯកឧត្តម វង្សី វិស្សុត រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការប្រចាំការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយមានសិក្ខាកាមចូលរួមមកពីតំណាងក្រសួងស្ថាប័នចំនួន១០០នាក់។ វគ្គបណ្តុះបណ្តាលនេះ មានគោលបំណងបណ្តុះបណ្តាលដល់គ្រូបង្គោល នៃក្រសួងស្ថាប័ននីមួយៗ ដើម្បីបណ្តុះបណ្តាលបន្តដល់មន្ត្រីជំនាញថវិកាតាមក្រសួងស្ថាប័នរបស់ខ្លួន។

---

## សិក្ខាសាលាផ្សព្វផ្សាយ ស្តីពីរបាយការណ៍គុណភាពទឹកឆ្នាំ២០២២ ខេត្តកំពង់ធំ



នៅថ្ងៃចន្ទ ១កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧ ត្រូវនឹងថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២៣ លោក អ៉ី ពុទ្ធាលី អនុប្រធានការិយាល័យធនធានទឹក នៃនាយកដ្ឋានធនធានធម្មជាតិ របស់អាជ្ញាធរទន្លេសាប ត្រូវបានចាត់អោយទៅចូលរួមសិក្ខាសាលាផ្សព្វផ្សាយ ស្តីពីរបាយការណ៍គុណភាពទឹកឆ្នាំ២០២២ ដែលរៀបចំដោយគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ។

គោលបំណងសំខាន់នៃកិច្ចប្រជុំ ដើម្បី៖

១. ជម្រាបជូនអំពីរបាយការណ៍ស្ថានភាពតាមដានគុណភាពទឹកឆ្នាំ២០២២ ក្នុងអាងទន្លេមេគង្គក្រោម។

២. ពង្រីកការយល់ដឹងដល់ក្រសួង ស្ថាប័នពាក់ព័ន្ធអំពីការតាមដានគុណភាពទឹករបស់ MRC។

៣. ជម្រុញការយល់ដឹងអំពីសមិទ្ធផលដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងការប្រើប្រាស់ផលិតផលរបស់ MRC។

សូមជម្រាបជូនថា ៖ សិក្ខាសាលាថ្នាក់ជាតិនេះ បានប្រព្រឹត្តទៅក្រោមអធិបតីភាព ឯកឧត្តម តែ ណាវុធ អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា (គជទមក) ដោយមានការអញ្ជើញចូលរួមមកពីតំណាងក្រសួងធនធានទឹក និងឧតុនិយម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រដ្ឋបាលជលផល), ក្រសួងបរិស្ថាន, អាជ្ញាធរទន្លេសាប និងមន្ត្រីពី គ.ជ.ទ.ម.ក និងជំនាញការជាតិ សរុបអ្នកចូលរួមចំនួន ១៥ រូប។

លទ្ធផលទទួលបាន ពីសិក្ខាសាលាផ្សព្វផ្សាយ បានផ្តល់ការយល់ដឹងពី៖

- ស្ថានភាពគុណភាពទឹកទៅតាមស្ថានីយ៍តាមដានសរុបចំនួន ៤៨ ក្នុងនោះរួមមាន ១៩ ស្ថានីយ៍របស់ប្រទេសកម្ពុជា។
- ការកំណត់ស្តង់ដាគុណភាពទឹកលើប៉ារ៉ាម៉ែត្រសំខាន់និងវិធីសាស្ត្រប្រមូលសំណាកគុណភាពទឹក ។
- ការវិភាគទិន្នន័យគុណភាពទឹកដោយប្រើប្រាស់វិធីសាស្ត្រស្ថិតិវិភាគ ។



## សិក្ខាសាលាផ្សព្វផ្សាយស្ដីអំពី ការចែករំលែកលទ្ធផលស្រាវជ្រាវ និងការពិគ្រោះយោបល់លើការកែលម្អកម្មវិធីសិក្សាបរិញ្ញាបត្រជាន់ខ្ពស់ នៃជំនាញវិស្វកម្មទឹក និងអនាម័យទីក្រុង



រាជធានីភ្នំពេញ៖ ថ្ងៃពុធ ១២កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០២៣ លោក អ៊ី ពុទ្ធាលី អនុប្រធានការិយាល័យធនធានទឹក នៃអាជ្ញាធរទន្លេសាប បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយស្ដីអំពី ការចែករំលែកលទ្ធផលស្រាវជ្រាវ និងការពិគ្រោះយោបល់លើការកែលម្អកម្មវិធីសិក្សាបរិញ្ញាបត្រជាន់ខ្ពស់ នៃជំនាញវិស្វកម្មទឹក និងអនាម័យទីក្រុង នៃគម្រោង Provincial Water Supply and Sanitation Project (PWSSP) ក្រោមជំនួយហិរញ្ញវត្ថុពីសហភាពអឺរ៉ុប និងទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ ដែលដឹកនាំដោយក្រុមអ្នកអនុវត្តគម្រោង និងអ្នកស្រាវជ្រាវរបស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ដោយមានការអញ្ជើញចូលរួមពីតំណាងក្រសួងស្ថាប័នពាក់ព័ន្ធសរុបចំនួន៧៤នាក់។

គោលបំណងសិក្ខាសាលានេះគឺ ៖

១. ចែករំលែកលទ្ធផលស្រាវជ្រាវថ្មីៗបំផុត ដែលផលិតដោយក្រុមស្រាវជ្រាវពហុជំនាញលើវិស័យទឹកស្អាត និងអនាម័យទីក្រុង

២. កែលម្អកម្មវិធីសិក្សាបរិញ្ញាបត្រជាន់ខ្ពស់ នៃជំនាញវិស្វកម្មទឹក និងអនាម័យទីក្រុងឲ្យមានសង្គតិភាពជាមួយតម្រូវការទីផ្សារបច្ចុប្បន្ន នៅប្រទេសកម្ពុជា តាមរយៈការទទួលបាននូវធាតុចូលជាចាំបាច់ពីបណ្ដាអ្នកជំនាញ និងស្ថាប័នពាក់ព័ន្ធនានាដែលធ្វើការលើវិស័យនេះ។



## សិក្ខាសាលាផ្សព្វផ្សាយបច្ចេកវិទ្យាផែនទី ស្ដីពីវឌ្ឍនភាព នៃការរៀបចំហេដ្ឋារចនាសម្ព័ន្ធភូមិសាស្ត្រ តាមបណ្ដាក្រសួង និងស្ថាប័ន



ថ្ងៃអង្គារ ៤កើតខែជេស្ឋឆ្នាំថោះបញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី ២៣ ខែឧសភា ឆ្នាំ ២០២៣ លោក ឡញ់ ណារិន្ទ ប្រធានការិយាល័យកសិកម្ម នៃនាយកដ្ឋានធនធានធម្មជាតិ បានចូលរួមសិក្ខាសាលាផ្សព្វផ្សាយបច្ចេកវិទ្យាផែនទី ស្ដីពីវឌ្ឍនភាព នៃការរៀបចំហេដ្ឋារចនាសម្ព័ន្ធភូមិសាស្ត្រ តាមបណ្ដាក្រសួង និងស្ថាប័ន ដោយប្រើប្រាស់កម្មវិធី អាក ជី អាយ អេស (Advancing Geospatial infrastructure of Organization with ArcGIS Technology) ដែលរៀបចំដោយ ក្រុមហ៊ុន អារុណា ថិចណូឡូហ្ស៊ី (Aruna Technology) និងក្រុមហ៊ុន ESRI THAILAND និងអញ្ជើញចូលរួមពីមន្ត្រីតំណាងមកពីក្រសួង ស្ថាប័ន មន្ទីរ អាជ្ញាធរខេត្ត-ក្រុង សហគមន៍ និងអង្គការក្រៅរដ្ឋាភិបាល សរុបចំនួនប្រមាណ ៥០នាក់។ សិក្ខាសាលានេះ រៀបចំឡើងក្នុងគោលបំណងចែករំលែកចំណេះដឹង បទពិសោធន៍ និងបង្ហាញពីបច្ចេកវិទ្យាដែលថ្មីៗ ជូនដល់មន្ត្រីជំនាញដែលពាក់ព័ន្ធនឹងការងារ ជី អាយ អេស (GIS)។

## សកម្មភាពរៀបចំបច្ចុប្បន្នភាពប្រព័ន្ធអេឡិចត្រូនិច (ដំឡើងទំហំ Size) អាជ្ញាធរទន្លេសាប

សកម្មភាពរៀបចំដំឡើងប្រព័ន្ធម៉ាស៊ីន Server សម្រាប់រក្សាទុកឯកសាររបស់អាជ្ញាធរទន្លេសាប NAS









ការផ្សព្វផ្សាយ

## សកម្មភាពផលិតវីដេអូផ្សព្វផ្សាយពីសក្តានុពល ផលប៉ះពាល់បឹងទន្លេសាប

### សកម្មភាពចុះប្រមូលចងក្រង រូបភាព វីដេអូ ពីទិដ្ឋភាពទីតាំងភូមិសាស្ត្រតំបន់បឹងទន្លេសាប រវាងភាពខុសគ្នារដូវប្រាំង និងរដូវវស្សា ខេត្តពោធិ៍សាត់



ខេត្តពោធិ៍សាត់ នៅថ្ងៃព្រហស្បតិ៍ ៦រោច ខែភទ្របទ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ០៥ ខែតុលា ឆ្នាំ២០២៣ មន្ត្រីជំនាញនាយកដ្ឋាននីតិកម្ម និងផ្សព្វផ្សាយ ដឹកនាំដោយ លោក នូប សំណាង ប្រធានការិយាល័យផ្សព្វផ្សាយព័ត៌មាន បានបន្តចុះប្រមូលចងក្រង រូបភាព វីដេអូ ទុកជាឯកសារស្តីពីទិដ្ឋភាពទីតាំងភូមិសាស្ត្រតំបន់បឹងទន្លេសាប រវាងភាពខុសគ្នារដូវប្រាំង និងរដូវវស្សា ស្ថិតនៅក្នុងឃុំកំពង់លួង ស្រុកក្រគរ ខេត្តពោធិ៍សាត់ ។

សកម្មភាពនេះ ក្រុមការងារបាន៖
១. ជួបសម្ភាសន៍ជាមួយអាជ្ញាធរដែនដី
២. ជួបសម្ភាសន៍ជាមួយប្រជាពលរដ្ឋដឹកភ្ញៀវទេសចរណ៍
៣. ជួបសម្ភាសន៍ជាមួយប្រជាពលរដ្ឋមានមុខរបបអ្នកលក់ដូរ និងប្រជានេសាទ
៤. ថតទិដ្ឋភាពទីតាំងភូមិសាស្ត្រឃុំ នៅរដូវវស្សា

ជាមួយនឹងសកម្មភាពនេះ ទទួលបានលទ្ធផលបឋម ដូចខាងក្រោម៖
១. នៅរដូវវស្សាភូមិបណ្តែតបានផ្លាស់ទីតាំងមកទីទួលចំងាយប្រហែល ៣ គីឡូម៉ែត្រ ពីទីតាំងចាស់នារដូវប្រាំង និងមានកម្ពស់ទឹកចន្លោះពី ៦ម៉ែត្រ ទៅ ៧ ម៉ែត្រ
២. ប្រជាពលរដ្ឋនៅរដូវវស្សាប្រកបរបបចម្បងមាន : នេសាទ ៥០ ភាគរយ, លក់ដូរ ២៥ភាគរយ, អ្នកដឹកភ្ញៀវ ៣ភាគរយ ចិញ្ចឹមត្រី ១០ភាគរយ, ធ្វើស្រែចំការ ៧ភាគរយ និងសប្បកម្ម 5ភាគរយ
៣.មធ្យោបាយធ្វើដំណើរទៅកាន់ភូមិទី១ ភូមីទី២ ភូមិទី៣ និងភូមិ៥ តាមរយៈទូក កាណូត ចំណែកភូមិទី ៤ អាចធ្វើដំណើតាម ម៉ូតូ ឡាន បាន
៤. បន្ទាប់ពីបានប្រមូលព័ត៌មាន ក្រុមការងារនឹងផលិតជាវីដេអូខ្លីពីទិដ្ឋភាពទីតាំងភូមិសាស្ត្រនៅរដូវវស្សា

សូមជម្រាបជូនថា: សកម្មភាពចុះប្រមូលចងក្រង រូបភាព វីដេអូទុកជាឯកសារ ស្តីពីទិដ្ឋភាពទីតាំងភូមិសាស្ត្រតំបន់បឹងទន្លេសាប រវាងភាពខុសគ្នារដូវប្រាំង និងរដូវវស្សា គឺជាសកម្មភាពមួយក្នុងចំណោមសកម្មភាពសំខាន់ៗជាច្រើន ដែលត្រូវបានអនុម័តដាក់ឱ្យអនុវត្ត នៅក្នុងផែនការសកម្មភាពប្រចាំឆ្នាំ២០២៣ របស់អាជ្ញាធរទន្លេសាប។
សកម្មភាពខាងលើ មានគោលបំណង៖
- បង្ហាញពីទិដ្ឋភាពស្ថានភាពលើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខុសគ្នារវាងរដូវប្រាំង និងរដូវវស្សា
- បង្ហាញពីទិដ្ឋភាពការធ្វើដំណើររបស់ប្រជាពលរដ្ឋខុសគ្នារវាងរដូវប្រាំង និងរដូវវស្សា
- បង្ហាញពីទិដ្ឋភាពភូមិសាស្ត្រក្នុងឃុំភាពខុសគ្នារវាងរដូវប្រាំង និងរដូវវស្សា។





## បណ្ដាញប្រព័ន្ធផ្សព្វផ្សាយរបស់អាជ្ញាធរទន្លេសាប

| WEBSITE | Facebook | Telegram | Twitter | Youtube |
| --- | --- | --- | --- | --- |
| https://tonlesap.gov.kh | @TSA.MOWRAM | @t.me/TonleSap_Authority | @twitter.com/tonle_sap | @youtube.com/tonle_sap |




Server




សារព័ត៌មាន



ទស្សនាវដ្ដី



ប័ណ្ណជូនពរ




សៀវភៅកត់ត្រាប្រចាំថ្ងៃ

**អគ្គលេខាធិការដ្ឋាន អាជ្ញាធរទន្លេសាប**
អគារលេខ ៣៦៤ មហាវិថី ព្រះមុនីវង្ស សង្កាត់ ផ្សារដើមថ្កូវ ខណ្ឌ ចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥)២៣ ៧២៧ ៤៥៤ / ២៣ ៧២៧ ៤៥៨, ទូរសារលេខ: (៨៥៥)២៣ ៧២៧ ៤៥៤
Email: info[@]tonlesap.gov.kh website : www.tonlesap.gov.kh.